សិស្សពូកែគណិតវិទ្យា

កម្រិតវិទ្យាល័យ

# ន្ប ច័ន្តណាវិទ្ធិ

# ប្រធានលំហាត់

## លំហាត់ទី ៤២៤

គេមានទំនាក់ទំនង $(3-2i)Z+(3+2i)\overline{Z}-12=0\ (I)$ ។

ក- បង្ហាញថាសំណុំចំណុច $M$ ក្នុងប្លង់កុំផ្លិច ដែលមានអាភិក $Z$ ផ្ទៀងផ្ទាត់ទំនាក់ទំនង $(I)$ គឺជាបន្ទាត់ $L$ មួយដែលគេត្រូវកំណត់ ។

ខ- $A$ និង $B$ គឺជាពីរចំណុចដែលមានអាភិករៀងគ្នា $3+5i$ និង $-3+i$ ។
បង្ហាញថា បន្ទាត់ $L$ ជាមេដ្យាទ័រនៃអង្កត់ $[AB]$ ។

## លំហាត់ទី ៤២៥

ពហុធា $f(z)=az^{2018}+bz^{2017}+cz^{2016}$ មានមេគុណជាចំនួនពិតមិនធំជាង $2019$ និង $f\left(\frac{1+\sqrt{3}i}{2}\right)=2015+2019\sqrt{3}i$ ។ ចូររកសំណល់ពេលដែលគេចែក $f(1)$ និង $1000$ ។

## លំហាត់ទី ៤២៦

កំពូល $M$ និង $N$ របស់ត្រីកោណសម័ង្ស $MNP$ ឋិតនៅលើរង្វង់ $C$ ។ ចំណុច $Q$ មួយផ្សេងពី $N$ នៅលើរង្វង់ $C$ ដែល $MQ=MN$ ។ បន្ទាត់ $QP$ ប្រសព្វរង្វង់ $C$ ជាលើកទីពីរត្រង់ $R$ ។ ចូរគណនារង្វាស់ $PR$ ។

## លំហាត់ទី ៤២៧

តាង $m*n=\dfrac{m+n}{mn+4}$ ។
គណនា $A=((\cdots(2009*2008)*2007)*\cdots*1)*0)$ ។

## លំហាត់ទី ៤២៨

តើមានចំនួនគត់ $n$ ប៉ុន្មានចាប់ពី $1$ ដល់ $2008$ ដែល:
$2.6.10...(4n-2)$ ចែកដាច់នឹង $n!$ ។

## លំហាត់ទី ៤២៩

មានចំនួនពិត 3គូគឺ $(a_1;b_1)$ ; $(a_2;b_2)$ និង $(a_3;b_3)$ ដែលបំពេញទំនាក់ទំនង :
$\begin{cases} a^3-3ab^2=2009 \\ b^3-3a^2b=2008 \end{cases}$ ។ គណនា $P=\left(1-\dfrac{a_1}{b_1}\right)\left(1-\dfrac{a_2}{b_2}\right)\left(1-\dfrac{a_3}{b_3}\right)$ ។

## លំហាត់ទី ៤៣០

ចំពោះចំនួនគត់ $n$ នីមួយៗមិនអវិជ្ជមាន គេបង្កើតចំនួនថ្មី $f(n)$ ។
ឧបមថា $f(0)=0$ ; $f(1)=1$ និង ចំពោះ $n\geq 2;\ f(n)-2f(n-1)+f(n-2)=(-1)^n(2n-4)$ ។ គណនា $f(2008)$ និង $f(2009)$ ។

## លំហាត់ទី ៤៣១

គេឱ្យចំនួនពិត $x=k+\sqrt{k^2-1}$ ដែល $k$ ជាចំនួនគត់វិជ្ជមានធំជាង $1$ ។
ចំពោះ $n=1;2;3;...$ គេតាង $A_n$ ជាផ្នែកគត់នៃ $x^n$ ។
ចូរគណនា $A_{2n}$ ជាអនុគមន៍នៃ $A_n$ ។

**លំហាត់ទី ៤៣២**

ក្នុងចតុកោណព្នាយ $ABCD$ $(AD \parallel CB)$ មានផ្ទៃក្រឡា $S$ ថេរ $E$ ជាចំនុចប្រសព្វនៃអង្កត់ទ្រូងទាំងពីរ ។ តើចតុកោណព្នាយណាដែលមានផ្ទៃក្រឡាត្រីកោណ $ABE$ ធំបំផុត ?

**លំហាត់ទី ៤៣៣**

តាង $I_n=\int_0^{\frac{\pi}{2}} sin^n x dx$ ។ ចូរស្រាយបំភ្លឺថា $\frac{\pi}{2(n+1)} \le I_n^2 \le \frac{\pi}{2n}$ ។

**លំហាត់ទី ៤៣៤**

ចូរប្រៀបធៀបពីរចំនួន $A=\sqrt[3]{2008}+\sqrt[3]{2006}$ និង $B=2\sqrt[3]{2007}$ ។

**លំហាត់ទី ៤៣៥**

គេឱ្យបីចំនួនពិតវិជ្ជមាន $a;b;c$ ដែលមានផលគុណស្មើ $1$ ។
រកតម្លៃធំបំផុតនៃផលគុណ $P=\left(a-1+\frac{1}{b}\right)\left(b-1+\frac{1}{c}\right)\left(c-1+\frac{1}{a}\right)$ ។

**លំហាត់ទី ៤៣៦**

រកចំនួនគត់ធម្មជាតិ $n$ ដែល $n+S(n)=2009$ ។
$S(n)$ ជាផលបូកបណ្តាខ្ទង់ ទាំងអស់នៃចំនួនគត់ធម្មជាតិ $n$ ។

**លំហាត់ទី ៤៣៧**

គេឱ្យស្វ៊ីត $\{a_n\}$ ជាចំនួនពិតដែលកំណត់ដោយ :

$$\begin{cases} a_1=1 \\ a_{n+1}=1+a_1\cdot a_2\cdot a_3\cdots a_n \ , \ (n\ge 1) \end{cases}$$ ។

គណនាផលបូក $S=\sum_{i=1}^{+\infty}\frac{1}{a_n}$ ។

**លំហាត់ទី ៤៣៨**

រកគ្រប់អនុគមន៍ $f:\Re\to\Re$ ផ្ទៀងផ្ទាត់លក្ខខណ្ឌខាងក្រោម :
$f[x(1+f(y))+f(y)]=x(1+y)+y$ គ្រប់ $x,y\in\Re$ ។

**លំហាត់ទី ៤៣៩**

ប្រមាណវិធី $*$ ត្រូវកំណត់នៅលើសំណុំចំនួនគត់វិជ្ជមានដែល បើ $x$ និង $y$ ជាពីរចំនួនគត់វិជ្ជមាន នោះ $x*y$ ក៏ជាចំនួនគត់វិជ្ជមានដែរ ។ ដោយសន្មត់ថា $*$ បំពេញលក្ខខណ្ឌខាងក្រោម ចំពោះគ្រប់ ចំនួនគត់វិជ្ជមាន $x;y$ និង $z$ ចូរគណនា $5*6$ ។

$$\begin{cases} x*(y+z)=(x*y)(x*z) & (1) \\ (x+y)*1=(x*1)+(y*1) & (2) \\ (x+y)*2=(x*2)+4(xy*1)+(y*2) & (3) \end{cases}$$ ។

## លំហាត់ទី ៤៤០

ចំពោះ $P; R$ រៀងគ្នាជាកន្លះបរិមាត្រ និងកាំរង្វង់ចារឹកក្រៅត្រីកោណមួយ ចូរកំណត់ប្រភេទត្រីកោណនោះ ដើម្បីឱ្យផលធៀប $\frac{P}{R}$ មានតម្លៃធំបំផុត ។

## លំហាត់ទី ៤៤១

គណនាតម្លៃនៃកន្សោម

១) $S_n = lncos\frac{a}{2} + lncos\frac{a}{2^2} + \cdots + lncos\frac{a}{2^n}$

២) $P_n = \left(1+\frac{1}{cosa}\right)\left(1+\frac{1}{cos2a}\right)\cdots\left(1+\frac{1}{cos2^n a}\right)$ ។

## លំហាត់ទី ៤៤២

គេឱ្យចំនួនគត់ $n$ ដែល $n \geq 2$ និងចំនួនមិនអវិជ្ជមាន $a_1, a_2, a_3, ..., a_n$ ។

ចូរស្រាយបំភ្លឺថា $\frac{a_1+a_2+a_3+\cdots+a_n}{n} \geq \sqrt[n]{a_1 \cdot a_2 \cdot a_3 \cdots a_n}$ ។

## លំហាត់ទី ៤៤៣

គេឱ្យ $a, b, c$ ជាចំនួនពិត ខុសពី $-1$ និង $1$ ដែល $a+b+c=abc$ ។

ចូរបង្ហាញថា $\frac{a}{1-a^2}+\frac{b}{1-b^2}+\frac{c}{1-c^2}=\frac{4abc}{(1-a^2)(1-b^2)(1-c^2)}$ ។

## លំហាត់ទី ៤៤៤

១. គេឱ្យ $x > -1$ និង $0 \leq n \leq 1$ ស្រាយថា $(1+x)^n \leq 1+nx$ ។

២. អនុវត្តវិសមភាពខាងលើ ចូរស្រាយថា

$\left[(sinx)^{2012}\right]^{(cosx)^{2012}} + \left[(cosx)^{2012}\right]^{(sinx)^{2012}} \geq 1,\ \forall x \in \mathbb{R}$ ។

## លំហាត់ទី ៤៤៥

ដោះស្រាយសមីការ

១) $\sqrt{3}cos^2x + 2sinxcosx - \sqrt{3}sin^2x - 1 = 0$

២) $\frac{16}{\sqrt{x-2010}} + \frac{1}{\sqrt{y-2012}} = 10 - \left(\sqrt{x-2010}+\sqrt{y-2012}\right)$ ។

## លំហាត់ទី ៤៤៦

១. ចូរស្រាយបំភ្លឺទ្រឹស្តីបទស៊ីនុស $\frac{a}{sinA}=\frac{b}{sinB}=\frac{c}{sinC}=2R$ ។

២. បង្ហាញថា បើ $a^2, b^2, c^2$ ជាតួបន្តគ្នានៃស្វ៊ីតនព្វន្ត នោះ $cotA, cotB, cotC$ ក៏ជា

តួបន្តគ្នានៃស្វ៊ីតនពន្តដែរ ។

## លំហាត់ទី ៤៤៧

$ABCD$ ជាការេ ជ្រុងមានរង្វាស់ស្មើ $a$ ។ ចំណុច $M$ នៃអង្កត់ទ្រូងមានចំណោលកែង $P$ និង $Q$ លើជ្រុង $[AB]$ និង $[AD]$ រៀងគ្នា ។ គេពិនិត្យសូលីត $\sum$ កកើតដោយពហុកោណ $PBCDQM$ ក្នុងរង្វិលជុំវិញអង្កត់ $[AB]$ ហើយសន្មត់យក $AP = x$ ដែល $0 \le x \le a$ ។

១) គណនាផ្ទៃក្រឡាសរុប $S$ និងមាឌ $V$ នៃសូលីត $\sum$ ជាអនុគមន៍នៃ $x$ ។

២) កំណត់ទិសដៅអថេរភាពនៃ $S$ និង $V$ កាលណា $x$ ប្រែប្រួលពី $0$ ទៅ $a$ ។

## លំហាត់ទី ៤៤៨

គេអោយ $a, b$ ជាពីរចំនួនពិតខុសគ្នា និង $c$ ជាចំនួនពិតវិជ្ជមានផ្ទៀងផ្ទាត់ $a^4 - 2019a = b^4 - 2019b = c$ ។ ស្រាយបញ្ជាក់ថា $-\sqrt{c} < ab < 0$ ។

## លំហាត់ទី ៤៤៩

រកគ្រប់ចំនួនបឋម $p$ ដោយដឹងថាមានចំនួនគត់វិជ្ជមាន $x, y, z$ ដែលធ្វើអោយ $x^p + y^p + z^p - x - y - z$ ជាផលគុណនៃបីចំនួនបឋមផ្សេងគ្នា ។

## លំហាត់ទី ៤៥០

ត្រីកោណ $ABC$ មាន $AB < AC$ ។ មេដ្យាទ័រនៃជ្រុង $BC$ ជួបបន្ទាត់ $AB$ និង $AC$ ត្រង់ចំណុច $P$ និង $Q$ រៀងគ្នា ។ តាង $H$ ជាអរតូសង់នៃត្រីកោណ $ABC$ ។ $M$ និង $N$ ជាចំណុចកណ្ដាលនៃជ្រុង $BC$ និង $PQ$ រៀងគ្នា ។ ស្រាយបញ្ជាក់ថា បន្ទាត់ $HM$ និង $AN$ ប្រសព្វគ្នាត្រង់ចំណុចមួយនៅលើរង្វង់ ។

## លំហាត់ទី ៤៥១

រកដែនកំណត់នៃអនុគមន៍ខាងក្រោម :

ក. $y = \sqrt{log_x\left(x^3+1\right) log_{x+1} x - 2}$

ខ. $y = log_{x^2+1} \dfrac{1-\sqrt{1-4x^2}}{x}$ ។

## លំហាត់ទី ៤៥២

ស្រាយបញ្ជាក់ថា អង្កត់ទ្រូងនៃចតុកោណមួយកែងគ្នាលុះត្រាតែជ្រុងឈមនៃចតុកោណនោះ មានផលបូកការេស្មើគ្នា ។

## លំហាត់ទី ៤៥៣

គេឱ្យស្វ៊ីតចំនួនពិត $(u_n)$ ដែលផ្ទៀងផ្ទាត់ចំពោះគ្រប់ចំនួនគត់ $n$, $u_{n+2} = 2u_{n+1} - 2u_n$, $u_0 = -2$ និង $u_1 = 2$ ។ គណនា $u_n$ ។

## លំហាត់ទី ៤៥៤

រកតួទី $n$ នៃស្វ៊ីត $(u_n)$ ដែលកំណត់ដោយ $u_1 = 1$ និង $u_{n+1} = u_n(u_n + 2)$, $\forall n \in \mathbb{N}$

។

លំហាត់ទី ៤៥៥

ដោះស្រាយសមីការ

ក ) $\left(\frac{12}{5}\right)^x+\left(\frac{15}{4}\right)^x+\left(\frac{20}{3}\right)^x=3^x+4^x+5^x$ ។

លំហាត់ទី ៤៥៦

ដោយមិនចាំបាច់ធ្វើប្រមាណវិធីគុណចូរស្រាយថា $2011\times2013<2012^2$ រួចទាញថា $log_{2011}2012>log_{2012}2013$ ។

លំហាត់ទី ៤៥៧

ដោះស្រាយសមីការ

ខ ) $\frac{\left(1+2cosx+3cos^2x+4cos^3x+\cdots+ncos^{n-1}x\right)-(1+2+3+\cdots+n)cos^nx}{2\times1+3\times2cosx+4\times3cos^2x+\cdots+n(n-1)cos^{n-2}x+(n+1)ncos^{n-1}x}=\frac{1}{4}$ ។

លំហាត់ទី ៤៥៨

រកបណ្តាអនុគមន៍ $f(x)$ ដែលកំណត់លើ $\mathbb{R}$ ហើយផ្ទៀងផ្ទាត់

$f(x+y)+f(x-y)=2f(x)cosy,\ \forall x,y\in\mathbb{R}$ និង $f(0)=2013$, $f\left(\frac{\pi}{2}\right)=2013$ ។

លំហាត់ទី ៤៦០

ក្នុងសំណុំចំនួនកុំផ្លិច $C$ គេមានសមីការ $(E):\ z^3-(6+4i)z^2+(8+14i)z-12i=0$ ។

ក. ដោះស្រាយសមីការ $(E)$ យក $z_1$ ជាឫសពិត និង $z_2,z_3$ ជាឫសពីរផ្សេងទៀតដែល $|z_2|<|z_3|$ ។

ខ. ក្នុងប្លង់ប្រដាប់ដោយតម្រុយអរតូណរម៉ាល់ $(o;\vec{i};\vec{j})$ គេឱ្យបីចំណុច $M_1(z_1)$, $M_2(z_2)$ និង $M_3(z_3)$ ។ ស្រាយថា $M_1M_2M_3$ ជាត្រីកោណកែង ។ សរសេរចំនួនកុំផ្លិច $z_1=1-i\left(\sqrt{3}+2\right)$ និង $z_2=\sqrt{2+\sqrt{2}}+i\sqrt{2-\sqrt{2}}$ ជាទម្រង់ត្រីកោណមាត្រ ។

លំហាត់ទី ៤៦១

គណនាលីមីតខាងក្រោម

ក. $A=\lim_{n\to+\infty}\left(1-\frac{1}{2^2}\right)\left(1-\frac{1}{3^2}\right)\cdots\left(1-\frac{1}{n^2}\right)$

ខ. $B=\lim_{n\to+\infty}\left(\frac{n}{\sqrt{n^4+1}}+\frac{n}{\sqrt{n^4+2}}+\cdots+\frac{n}{\sqrt{n^4+n}}\right)$ ។

លំហាត់ទី ៤៦២

គេអោយចតុកោណប៉ោង $ABCD$ ដែលមាន $O$ ជាចំណុចប្រសព្វរវាងអង្កត់ទ្រូងទាំងពីរ ។ ស្រាយបញ្ជាក់ថា $S_{OAB}\cdot S_{OCD}=S_{OBC}\cdot S_{OAD}$ ។

## លំហាត់ទី ៤៦៣

ក. ស្រាយថា $a+b\geq 2\sqrt{ab}$ ចំពោះគ្រប់ចំនួនគត់វិជ្ជមាន $a$ និង $b$ ។

គណនា $A=\lim\limits_{x\to 0}(e^x+x)^{\frac{1}{x}}$ រួចទាញថា $A^{a+b}\geq A^{2\sqrt{ab}}$ ។

ខ. ស្រាយថា $\dfrac{2}{e^2}\leq \displaystyle\int_0^2 e^{x-x^2}dx\leq 2\sqrt[4]{e}$ ។

## លំហាត់ទី ៤៦៤

តាង $u_0,u_1,u_2,...,u_n$ ជាស្វ៊ីតនៃចំនួនពិតដែលបំពេញទំនាក់ទំនង

$(3-u_{n+1})(6+u_n)=18$ និង $u_0=3$ ។ គណនា $\displaystyle\sum_{k=0}^{2011}\frac{1}{u_k}$ ។

## លំហាត់ទី ៤៦៥

គេឱ្យ $sinx+siny+sinz=0$ ។ កំណត់តម្លៃអតិបរមា និង អប្បបរមានៃកន្សោម $M=sin^2x+sin^4y+sin^6z$ ។

## លំហាត់ទី ៤៦៦

គណនា $I=\displaystyle\int_0^{\pi} e^{|cosx|}\left(2sin\left(\frac{1}{2}cosx\right)+3cosx\left(\frac{1}{2}cosx\right)sinx\right)dx$ ។

## លំហាត់ទី ៤៦៧

ពីរចំនួន $a$ និង $b$ ត្រូវបានជ្រើសរើសដោយចៃដន្យចេញពីសំណុំនៃចំនួនគត់ធម្មជាតិ $N=\{1,2,3,...,30\}$ ។ ប្រូបាបដែល $a^2-b^2$ ចែកដាច់នឹង 3 ស្មើនឹង :

ក. $\dfrac{9}{87}$ ខ. $\dfrac{12}{87}$ គ. $\dfrac{15}{87}$ ឃ. $\dfrac{47}{87}$

## លំហាត់ទី ៤៦៨

ចូរកំណត់ចំនួនគត់វិជ្ជមាន $k$ តូចជាងគេ ដោយដឹងថាមានចំនួនគត់ $x_1,x_2,x_3,...,x_k$ ដែល $x_1^3+x_2^3+x_3^3+\cdots+x_k^3=2002^{2002}$ ។

## លំហាត់ទី ៤៦៩

គេឱ្យស្វ៊ីតចំនួនពិត $(u_n)_{n\in\mathbb{N}}$ ដោយ $u_n=\dfrac{1}{2!}+\dfrac{1}{3!}+\cdots+\dfrac{k}{(k+1)!},\ k\in\mathbb{N}$ ។

គណនា $\lim\limits_{n\to+\infty}\sqrt[n]{u_1^n+u_2^n+\cdots+u_{2013}^n}$ ។

## លំហាត់ទី ៤៧០

គេឱ្យ $a,b$ និង $c$ ជាចំនួនពិតវិជ្ជមានដែល $a+b+c=1$ ។

បង្ហាញថា $\left(\dfrac{1}{a}+\dfrac{1}{bc}\right)\left(\dfrac{1}{b}+\dfrac{1}{ca}\right)\left(\dfrac{1}{c}+\dfrac{1}{ab}\right)\geq 1728$ ។

## លំហាត់ទី ៤៧១

គណនាដេរីវេទី $n$ នៃអនុគមន៍ $y = cosx + sinx$ ជាអនុគមន៍នៃ $n$ ។ រកតម្លៃ $x$ ជាអនុគមន៍នៃ $n$ ដើម្បីអោយ $y^{(n)} = 0$ និងអនុវត្តចំពោះ $n = 2013$ ។

## លំហាត់ទី ៤៧២

ក. ស្រាយបញ្ជាក់ថា ចំពោះគ្រប់ចំនួនពិតវិជ្ជមាន $a, b, c$ គេបាន

$$\sqrt[3]{(x+a)(y+b)(z+c)} \geq \sqrt[3]{xyz} + \sqrt[3]{abc}$$ ។

ខ. ស្រាយថា $\frac{(2a+b+c)^2}{2a^2+(b+c)^2} + \frac{(2b+c+a)^2}{2b^2+(c+a)^2} + \frac{2c+a+b}{2c^2+(a+b)^2} \leq 8$ ចំពោះគ្រប់ចំនួនពិតវិជ្ជមាន $a, b, c$ ។

## លំហាត់ទី ៤៧៣

ដោះស្រាយសមីការឌីផេរ៉ង់ស្យែល $y'' - 4y' + 8y = e^{2x} + cos2x$ ។

## លំហាត់ទី ៤៧៤

ក្នុងចតុមុខ $OABC$ យក $E$ ជាចំណុចកណ្តាលនៃទ្រនុង $AB$ ហើយ $F$ និង $P$ ចែកក្នុង $OC$ និង $OA$ តាមផលធៀប $\frac{FO}{FC} = \frac{2}{1}$ និង $\frac{PO}{PA} = \frac{1}{2}$ ។ យក $Q$ នៅលើទ្រនុង $BC$ ដែល $\overrightarrow{BQ} = t\overrightarrow{BC}$ ។ បើ $PQ$ ប្រសព្វ $EF$ ត្រង់ចំណុច $M$ ។ បង្ហាញថា $\overrightarrow{OM} = k\overrightarrow{OE} + (1-k)\overrightarrow{OF}, (0 < k < 1)$ និង $\overrightarrow{OM} = m\overrightarrow{OP} + (1-m)\overrightarrow{OQ}, (0 < m < 1)$ រួចកំណត់តម្លៃ $t$ ។

## លំហាត់ទី ៤៧៥

គូប $ABCDEFGH$ មួយមានរង្វាស់ជ្រុង $a$ ។ $I$ ជាចំណុចកណ្តាលនៃ $AB$ ហើយ $J$ ជាចំណុចកណ្តាលនៃ $EH$ ។ រករង្វាស់ខ្លីបំផុតពី $I$ ទៅ $J$ តាមមុខខាងនៃគូប ។

## លំហាត់ទី ៤៧៦

ស្រាយបញ្ជាក់ថា លក្ខខណ្ឌចាំបាច់ និងគ្រប់គ្រាន់ដើម្បីអោយត្រីកោណ $ABC$ កែងត្រង់ $A$ គឺ $\frac{sinB + sinC}{cosB + cosC} = sinA$ ។

## លំហាត់ទី ៤៧៧

គេគ្រោងថាឈ្នួលប្រចាំឆ្នាំនៃផ្ទះមួយកើនឡើង $6\%$ រៀងរាល់ឆ្នាំ ។ គេសំគាល់ដោយ $f(n)$ ឈ្នួលប្រចាំឆ្នាំនៅឆ្នាំ $2002 + n$ $(n \in \mathbb{N})$ ។

១. សរសេរ $f(n+1)$ ជាអនុគមន៍នៃ $n$ រួចសរសេរ $f(n)$ ជាអនុគមន៍នៃ $f(0)$ និង $n$ ។

២. គេឧបមាថា $f(0) = 80000$៛ តើឈ្នួលប្រចាំឆ្នាំនៃផ្ទះមួយនៅឆ្នាំ 2008 ត្រូវជាប៉ុន្មាន ?

៣. តើចាប់ពីឆ្នាំណាទៅទើបឈ្នួលផ្ទះប្រចាំឆ្នាំ កើនលើសពីពីរដងនៃឈ្នួលផ្ទះប្រចាំឆ្នាំ

នៅឆ្នាំ 2002 ?

## លំហាត់ទី ៤៧៨

ស៊ីត $(x_n)$ កំណត់ដោយ $x_1=1,x_2=1$ និង $x_{n+1}=x_n+x_{n-1}$ ចំពោះ $n\geq 2$ ។

១- បង្ហាញថា $x_{k+1}\cdot x_{k+2}-x_k\cdot x_{k+3}=(-1)^k$ ចំពោះ $\forall k\in\mathbb{N}$ ។

២- គេតាង $arccot$ ជាអនុគមន៍ច្រាសនៃអនុគមន៍ $cot$ ។

បង្ហាញថា $arccotx_1-arccotx_3-arccotx_5-\cdots-arccotx_{2011}=arccotx_{2012}$ ។

## លំហាត់ទី ៤៧៩

អនុគមន៍ $f$ កំណត់ចំពោះគ្រប់ចំនួនពិត $x$ ដោយ $f(x)=cosx+cos\left(\sqrt{p}x\right)$ ដែល $p$ ជាចំនួនបឋម ។ បង្ហាញថា $f$ មិនមែនជាអនុគមន៍ខួបលើសំណុំចំនួនពិតទេ ។

## លំហាត់ទី ៤៨០

គេឱ្យចំនួនពិត $u_1;u_2;\ldots$ បំពេញទំនាក់ទំនង

$u_{n+1}=\dfrac{u_n^2-u_{n-1}+2u_n}{u_{n-1}+1}$ និង $u_1=1;u_2=7$ ។ គណនាតម្លៃនៃ $u_5$ ។

## លំហាត់ទី ៤៨១

រង្វង់ពីរកាត់គ្នាត្រង់ចំណុច $A$ និង $B$ ។ បន្ទាត់ចល័ត $(MN)$ កាត់តាម $A$ ហើយជួបរង្វង់ធំត្រង់ $M$ និងរង្វង់តូចត្រង់ $N$ ។ បង្ហាញថា $\dfrac{BM}{BN}$ មានតម្លៃថេរកាលណា $(MN)$ វិលជុំវិញចំណុច $A$ ។

## លំហាត់ទី ៤៨២

គណនា $S_{2008}=(1\times3+2\times4+3\times5+\cdots+2008\times2010)-\left(1^2+2^2+\cdots+2008^2\right)$ ។

## លំហាត់ទី ៤៨៣

ស៊ីតនៃចំនួនគត់រ៉ឺឡាទីប $(u_n)$ កំណត់ដោយ $u_1=1;u_2=1;u_3=-1$ និង $u_n=u_{n-1}\times u_{n-3}$ ចំពោះ $n\geq 4$ ។ រកម្លៃមួយតួដំបូង និងតួ 2008 នៃស៊ីត $(u_n)$ ។

## លំហាត់ទី ៤៨៤

គេមានសមភាព

$14^2=\left(6\times1^2+6\times1+2\right)^2$; $15^2=\left(6\times1^2+6\times1+3\right)^2$

$38^2=\left(6\times2^2+6\times2+2\right)^2$; $39^2=\left(6\times2^2+6\times2+3\right)^2$

$74^2=\left(6\times3^2+6\times3+2\right)^2$; $75^2=\left(6\times3^2+6\times3+3\right)^2$ ។

ដោយសង្កេតឧទាហរណ៍ខាងក្រោមនេះ ចូរទាញរករូបមន្តទូទៅ ហើយស្រាយបញ្ជាក់រូបមន្តទូទៅនោះផង :

$2^2+3^2+4^2+14^2=15^2$; $4^2+5^2+6^2+38^2=39^2$;

$6^2+7^2+8^2+74^2=75^2$ ។

## លំហាត់ទី ៤៨៥

គេអោយអាំងតេក្រាល $I_n=\int_0^{\frac{\pi}{4}} tan^n x dx,\ n\in\mathbb{N}$ ។

ក- បង្ហាញថា $(I_n)$ ជាស្វ៊ីតចុះ ។

ខ- គណនា $I_n+I_{n-2},\ (n\geq 2)$ រួចទាញថា $\frac{1}{2(n+1)}\leq I_n\leq\frac{1}{2(n-1)}$ ។

## លំហាត់ទី ៤៨៦

គេអោយ $a_i, i=1,\ldots,6$ ជាចំនួនវិជ្ជមាន ដែល $a_1+a_2+a_3-a_4-a_5-a_6=3$ និង $a_1^2+a_2^2+a_3^2+a_4^2+a_5^2+a_6^2=9$ ។

ស្រាយបញ្ជាក់ថា

$$a_1a_2a_3a_4a_5a_6\leq 1 \text{ ។}$$

## លំហាត់ទី ៤៨៧

១. បើ $x+iy=\sqrt[3]{a+ib}$ ស្រាយបញ្ជាក់ថា $\frac{a}{x}+\frac{b}{y}=4\left(x^2-y^2\right)$ ។

២. បើ $x_p=cos\left(\frac{\pi}{2^p}\right)+isin\left(\frac{\pi}{2^p}\right)$ ចូរបង្ហាញថា $\lim_{n\to+\infty} x_1\cdot x_2\cdot x_3\cdots x_n=-1$ ។

## លំហាត់ទី ៤៨៨

បង្ហាញថា $x^5-1=(x-1)\left[x^2+2xcos\frac{\pi}{5}+1\right]\left[x^2+2xcos\frac{3\pi}{5}+1\right]$ ។

## លំហាត់ទី ៤៨៩

អនុគមន៍ $f(x)=a_0+a_1x+a_2x^2+\cdots+a_nx^n$ មានលេខមេគុណ $a_i$ បំពេញលក្ខខណ្ឌ $0\leq a_i\leq a_0$ ដែល $i=1;2;3;\ldots;n$ ។ គេយក $(f(x))^2=b_0+b_1x+b_2x^2+\cdots+b_{n+1}x^{n+1}+\cdots+b_{2n}x^{2n}$ ។ បង្ហាញថា $b_{n+1}\leq\frac{1}{2}(f(1))^2$ ។

## លំហាត់ទី ៤៩០

គេមានស្វ៊ីតនៃចំនួន $x_1;x_2;x_3;\ldots$ ដែលកំណត់ដោយ $x_1=1;x_2=1$ និង $x_n=x_{n-1}+x_{n-2}$ ចំពោះ $n\geq 3$ ។

ក. រកដប់តួដំបូងនៃស្វ៊ីតនោះ ។

ខ. គេយក $A=\begin{bmatrix}1&1\\1&0\end{bmatrix}$ ជាម៉ាទ្រីសការេលំដាប់ 2 ។ បង្ហាញថា $A^n=\begin{bmatrix}x_{n+1}&x_n\\x_n&x_{n-1}\end{bmatrix}$ ចំពោះ $n=2;3;4;\ldots$ ។

## លំហាត់ទី ៤៩១

ត្រីកោណ $ABC$ មានមុំក្នុងទាំងបីជាមុំស្រួច ។ កន្លះបន្ទាត់ពុះក្នុងនៃមុំ $\angle BAC$ ជួបជ្រុង

$[BC]$ ត្រង់ $D$ ហើយជួបរង្វង់ចារិកក្រៅត្រីកោណ $ABC$ ត្រង់ $E$ ។ តាមចំណុច $D$ គេគូសបន្ទាត់កែងនឹងជ្រុង $[AB]$ និង $[AC$ រៀងគ្នាត្រង់ចំណុច $M$ និង $N$ ។ បង្ហាញថា ចតុកោណ $AMEN$ និង ត្រីកោណ $ABC$ មានផ្ទៃក្រឡាស្មើគ្នា ។

## លំហាត់ទី ៤៩២

បង្ហាញថា $\sqrt{7}+\sqrt[3]{7}+\sqrt[4]{7}<7$ ហើយ $\sqrt{4}+\sqrt[3]{4}+\sqrt[4]{4}>4$ ។

## លំហាត់ទី ៤៩៣

គេឱ្យពហុធា $g(n)=n^4+2n^3+2n^2+2n+1$ ចំពោះ $n=1;2;3;\ldots$ ។
បង្ហាញថា $g(n)$ មិនមែនជាការេនៃចំនួនគត់ វិជ្ជមានណាមួយឡើយ ។

## លំហាត់ទី ៤៩៤

ចំពោះគ្រប់ចំនួនគត់ វិជ្ជមាន $n$ គេមាន :
$f(n)=1-\frac{1}{2}+\frac{1}{3}-\cdots+\frac{1}{2n-1}-\frac{1}{2n}$ និង $g(n)=\frac{1}{n+1}+\frac{1}{n+2}+\cdots+\frac{1}{2n}$ ។
បង្ហាញថា $f(n)=g(n)$ ចំពោះគ្រប់ចំនួនគត់ វិជ្ជមាន $n$ ។

## លំហាត់ទី ៤៩៥

គេឱ្យចំនួនគត់វិជ្ជមានពីរ : $X=111\cdots11$ ដែលមានលេខ $1$ ចំនួន $m$ ដង
និង $Y=100\cdots05$ ដែលមានលេខ $0$ ចំនួន $m-1$ ដង ។
បង្ហាញថា $1+XY$ ជាការេនៃមួយចំនួនគត់វិជ្ជមាន ហើយទាញរកឫសការេវិជ្ជមាននៃ $1+XY$ ។

## លំហាត់ទី ៤៩៦

គេតាង $s(n)$ ជាផលបូក $n$ តួដំបូងនៃស្វ៊ីត $0;1;1;2;2;3;3;4;4;\cdots;k;k;k+1;k+1;\cdots$ ។
ក. គណនា $s(n)$ ជាអនុគមន៍នៃ $n$ ។
ខ. បង្ហាញថា $s(a+b)-s(a-b)=ab$ ចំពោះគ្រប់ចំនួនគត់វិជ្ជមាន $a$ និង $b$ ដែល $a>b$ ។

## លំហាត់ទី ៤៩៧

គេឱ្យត្រីកោណកែង $ABC$ មួយ ដែលមាន $AC=1$, $\widehat{ACB}=90^0$ និង $\widehat{BAC}=x$ ។ $D$ ជាចំណុចមួយនៃអ៊ីប៉ូតេនុស $[AB]$ ហើយដែល $AD=1$ ។ $E$ ជាចំណុចមួយនៃ $[BC]$ ហើយដែល $\widehat{EDC}=x$ ។ បន្ទាត់ $(EF)$ កែងនឹង $[BC]$ ត្រង់ $E$ ហើយជួប $[AB]$ ត្រង់ $F$ ។ គណនា $\lim\limits_{x\to 0}EF$ ។

## លំហាត់ទី ៤៩៨

គេឱ្យចំនួនបឋមបីផ្សេងគ្នា $p$ ; $q$ និង $r$ ។
បង្ហាញថា $\sqrt[3]{p}$ ; $\sqrt[3]{q}$ និង $\sqrt[3]{r}$ មិនមែនជា តួបី (មិនចាំបាច់បន្តបន្ទាប់គ្នា) នៃស្វ៊ីតនព្វន្តណាមួយឡើយ ។

## លំហាត់ទី ៤៩៩

គេឱ្យ $N = \underbrace{44...4}_{2010}\underbrace{88...8}_{2009}9$ ។ គណនា $\sqrt{N}$ ។

## លំហាត់ទី ៥០០

រកតម្លៃនៃ $M = \frac{1+2}{2} + \frac{1+2+3}{2^2} + \frac{1+2+3+4}{2^3} + \frac{1+2+3+4+5}{2^4} + \cdots$ ។

## លំហាត់ទី ៥០១

តាង $\mathbb{N}$ ជាសំណុំចំនួនគត់វិជ្ជមាន ។ $f : \mathbb{N} \to \mathbb{N}$ ជាអនុគមន៍ដែលផ្ទៀងផ្ទាត់លក្ខខណ្ឌ $f(x+1) = f(x) + x$ ចំពោះ $x \in \mathbb{N}$ និង $f(1) = 5$ ។ រកតម្លៃនៃ $f(2009)$ ។

## លំហាត់ទី ៥០២

ស្រាយបញ្ជាក់ថា សមីការ $x^5 + x = 2009$ មានឫសវិជ្ជមានតែមួយគត់ ហើយឫសនោះជាចំនួនអសនិទាន ។ គេឱ្យ $4,5^5 \approx 1845$ ; $4,6^5 \approx 2059$ ។

## លំហាត់ទី ៥០៣

ស្រាយបញ្ជាក់ថា ចំពោះគ្រប់ចំនួនពិតវិជ្ជមាន $a, b, c$

នោះ $\frac{a}{10b+11c} + \frac{b}{10c+11a} + \frac{c}{10a+11b} \geq \frac{1}{7}$ ។

## លំហាត់ទី ៥០៤

ចំណុច $M, K, L$ ត្រូវគេដៅរៀងគ្នាលើជ្រុង $AB$ , $BC$ , $CA$ នៃត្រីកោណ $ABC$ ។ ស្រាយបញ្ជាក់ថា យ៉ាងតិចក្រឡាផ្ទៃនៃត្រីកោណមួយ ក្នុងចំណោមក្រឡាផ្ទៃត្រីកោណ $MAL$, $KBM$ ឬ $LCK$ មិនតិចជាង $\frac{1}{4}$ នៃក្រឡាផ្ទៃត្រីកោណ $ABC$ ។

## លំហាត់ទី ៥០៥

គេឱ្យស្វ៊ីតនៃចំនួនពិត $\langle a_n \rangle_{n\geq 1}$ កំណត់ដោយ $a_1 = 2,\ a_{n+1} = \frac{a_n^2+1}{2}$ ចំពោះ $n \geq 1$ ។ ស្រាយបញ្ជាក់ថា $\sum_{j=1}^{N} \frac{1}{a_j+1} < 1$ ចំពោះគ្រប់ចំនួនគត់ធម្មជាតិ $N$ ។

## លំហាត់ទី ៥០៦

គេឱ្យចំនួនគត់រ៉ឺឡាទីប $\alpha, \beta, \lambda$ និង $\mu$ ដែលផ្ទៀងផ្ទាត់សមភាព $\alpha\mu = 1 + \beta\lambda$ ។ គេយក $x_0$ ជាតួចែករួមធំបំផុតនៃចំនួនគត់រ៉ឺឡាទីប $a$ និង $b$ ហើយយក $y_0$ ជាតួចែករួមធំបំផុតនៃ $\alpha a + \beta b$ និង $\lambda a + \mu b$ ។ ចូរប្រៀបធៀបចម្ងាយពីចំណុច $M_0(x_0, y_0)$ ទៅអ័ក្សទាំងពីរនៃតម្រុយអរតូណរម៉ាល់មួយ ។

## លំហាត់ទី ៥០៧

គេឱ្យអនុគមន៍ពហុធា $f(x) = a_n x^n + a_{n-1} x^{n-1} + \cdots + a_1 x + a_0$ ដែលមានលេខមេគុណជាចំនួនគត់រ៉ឺឡាទីប ។ គេដឹងថាមានចំនួនគត់រ៉ឺឡាទីប $x_0$ ដែល $f(x_0) = p$ ជា

ចំនួនបឋម ។ បង្ហាញថា មានចំនួនគត់រ៉ឺឡាទីប $\beta$ ច្រើនរាប់មិនអស់ដែល $f(\beta)$ មិនមែនជាចំនួនបឋម ។

## លំហាត់ទី ៥០៨

ស្វ៊ីត $(x_n)$ កំណត់ដោយ $x_1 = 1, x_2 = 1$ និង $x_{n+1} = x_n + x_{n-1}$ ចំពោះ $n \geq 2$ ។

ស្វ៊ីត $(y_n)$ កំណត់ដោយ $y_n = |x_{n+4}x_{n-2} - x_{n+2}x_n|$ ចំពោះ $n \geq 3$ ។

ស្វ៊ីត $(z_n)$ កំណត់ដោយ $z_n - 9 = 4x_{n-2}x_nx_{n+2}x_{n+4}$ ចំពោះ $n \geq 3$ ។

១-បង្ហាញថា $(y_n)$ ជាស្វ៊ីតថេរចំពោះ $n \geq 3$ ។ ទាញរកតម្លៃតួ $y_{3042011}$ ។

២- បង្ហាញថា តួនីមួយៗនៃស្វ៊ីត $(z_n)$ ជាការេប្រាកដ ។

## លំហាត់ទី ៥០៩

គេឱ្យ $a$ និង $X$ ជាចំនួនគត់រ៉ឺឡាទីបដែល $a > 1, X > 0$ ។ $k$ ជាចំនួនគត់ រ៉ឺឡាទីបមិនអវិជ្ជមាន និង $c_j$ ជាចំនួនគត់រ៉ឺឡាទីបដែល $0 \leq c_j < a$ ចំពោះ $j = 0, 1, ..., k$ ។

បង្ហាញថា $X$ អាចសរសេរបានតែមួយបែបគត់ជារាង $X = \sum_{j=0}^{k} c_j a^j$ ។

## លំហាត់ទី ៥១០

រង្វង់មួយមានផ្ចិត $O$ និងកាំ $R$ ចារឹកក្រៅត្រីកោណ $ABC$ មួយដែលមានបរិមាត្រ $2p$ ។ ត្រីកោណ $ABC$ នេះចារឹកក្រៅរង្វង់មួយទៀតដែលមានផ្ចិត $I$ និងកាំ $r$ ។

បង្ហាញថា $4R + r = p\left(tan\dfrac{A}{2} + tan\dfrac{B}{2} + tan\dfrac{C}{2}\right)$ ។

## លំហាត់ទី ៥១១

គេបានប្រើទ្រុងចំនួន 99 គ្រឿងសម្រាប់ដឹកជញ្ជូនកូនមាន់ចំនួន $7y38x5$ ក្បាល ទៅកាន់កសិដ្ឋាន មួយ ។ រកលេខ $x$ និង $y$ ក្នុងរបាប់គោលដប់ដោយដឹងថា ក្នុងទ្រុងនីមួយៗមានចំនួនកូនមាន់ស្មើៗគ្នា ។

## លំហាត់ទី ៥១២

សមីការ $ax^2 + 2010x + c = x$ គ្មានឫសទេនៅក្នុងសំណុំចំនួនពិត ។

បង្ហាញថា សមីការ $a\left(ax^2 + 2010x + c\right) + 2010\left(ax^2 + 2010x + c\right) + c = x$ គ្មានឫសនៅក្នុងសំណុំចំនួនពិតដែរ ។

## លំហាត់ទី ៥១៣

ពហុធា $P(x) = x^n + a_1x^{n-1} + a_2x^{n-2} + \cdots + a_{n-1}x + 1$ មានលេខមេគុណ $a_1, a_2, ...,$ $a_{n-1}$ ជាចំនួនមិនអវិជ្ជមាន ។គេដឹងថាពហុធា $P(x)$ មាន $n$ ឫសសុទ្ធតែជាចំនួនពិត ។

បង្ហាញថា $P(2010) \geq \left(2\sqrt{2010}\right)^n$ ។

## លំហាត់ទី ៥១៤

គេមានចំនួនគត់វិជ្ជមាន $r$ ដែលជាសំណល់ក្នុងវិធីចែកអឺគ្លីតនៃចំនួនគត់វិជ្ជមាន $a$ និង $b$ ។

១. បង្ហាញថា $2^r - 1$ ជាសំណល់ ក្នុងវិធីចែកអឺគ្លីតនៃចំនួនគត់វិជ្ជមាន $2^a - 1$ និង $2^b - 1$ ។

២. គេតាង $\mu$ ជាតួចែករួមធំបំផុតនៃ $a$ និង $b$ ។ បង្ហាញថា $2^\mu - 1$ ជាតួចែករួមធំបំផុតនៃ $2^a - 1$ និង $2^b - 1$ ។

## លំហាត់ទី ៥១៥

រកសំណល់នៃវិធីចែក $2010^{2009}$ នឹង $13$ ។

## លំហាត់ទី ៥១៦

បង្ហាញថា $A = 1^{2008} + 2^{2008} + 3^{2008} + 4^{2008} - 5^{2008} - 6^{2008} - 7^{2008} - 8^{2008} - 9^{2008}$ ចែកដាច់នឹង $5$ ។

## លំហាត់ទី ៥១៧

រកតម្លៃធំបំផុតនៃ $A = sinx_1.sinx_2...sinx_{2010}$ ដោយដឹងថា $tanx_1.tanx_2...tanx_{2010} = 1$ ។

## លំហាត់ទី ៥១៨

រកគ្រប់គូ $(x, y)$ ជាឫសនៃសមីការ $2007^{sin^2 x} + 2007^{cos^2 x} = 2009 + cos2y$ ។

## លំហាត់ទី ៥១៩

រកពហុធា $P(x)$ ដឺក្រេទី៤ ផ្ទៀងផ្ទាត់លក្ខខណ្ឌពីរខាងក្រោម :

1) $P(0) = 0$

2) $P(x) - P(x-1) = x(x+1)(2x+1)$ គ្រប់ $x \in \Re$ ។

## លំហាត់ទី ៥២០

តាង $a_1; a_2; a_3...$ ជាស្វ៊ីតនៃចំនួនគត់ដែលបំពេញទំនាក់ទំនង $a_{n-1} + a_n = 2n$ ចំពោះគ្រប់ $n \ge 2$ ។ បើ $a_1 = 100$ គណនា $a_{2009}$ ។

## លំហាត់ទី ៥២១

កំណត់អនុគមន៍ $f : \Re \to \Re$ ដែលចំពោះគ្រប់ចំនួនពិត $x, y$

$f[x - f(y)] = 1 - x - y$ ។

## លំហាត់ទី ៥២២

គេឱ្យរង្វង់ផ្ចិត $O$ កាំ $r$ និងត្រីកោណ $ABC$ ប្រែប្រួល ចារឹកក្រៅរង្វង់ ។ បន្ទាត់កាត់តាម $O$ កាត់ $AB$, $AC$ រៀងគ្នាត្រង់ $M$ និង $N$ ។ កំណត់ទីតាំងចំណុច $A$ និង អង្កត់ $MN$ ដើម្បីឱ្យផ្ទៃក្រឡាត្រីកោណ $AMN$ មានតម្លៃ តូចបំផុត ។

## លំហាត់ទី ៥២៣

គេឱ្យរង្វង់បីកាត់គ្នាពីរៗដូចរូបខាងក្រោម ។ សង់រូបឡើងវិញហើយបង្ហាញថាចំណុច $E, D$

និង $F$ នៅលើបន្ទាត់តែមួយ ។




## លំហាត់ទី ៥២៤

បង្ហាញថា $1^{2009}+2^{2009}+3^{2009}+\cdots+(n-1)^{2009}+n^{2009}$ ចែកមិនដាច់នឹង $n+2$ ចំពោះគ្រប់ចំនួនគត់វិជ្ជមាន $n$ ។

## លំហាត់ទី ៥២៥

គេមាន $f(x)=x^2-3x+3$ ។

ក. បង្ហាញថា បើ $f(x)=x$ នោះ $f(f(x))=x$ ។

ខ. រកឫសនៃសមីការ $f(x)=x$ ។ ទាញរកឫសនៃសមីការ $\left(x^2-3x+3\right)^2-3\left(x^2-3x+3\right)+3=x$ ។

## លំហាត់ទី ៥២៦

គេតាង $n!=n(n-1)(n-2)\times\cdots\times 2\times 1$ ។ បង្ហាញថា ចំពោះគ្រប់ចំនួនគត់វិជ្ជមាន $n$ គេបាន :

$$1+\frac{2009}{1!}+\frac{(2009)(2010)}{2!}+\cdots+\frac{(2009)(2010)\cdots(2009+n-1)}{n!}=\frac{(2010)(2011)\cdots(2009+n)}{n!}$$ ។

## លំហាត់ទី ៥២៧

អនុគមន៍ $g$ កំណត់ចំពោះគ្រប់ចំនួនពិត $x$ ដោយ $g(x+1)+g(x-1)=\sqrt{2}g(x)$ ។

ក. គេតាង $g(x)=p$ និង $g(x-1)=q$ ចំពោះគ្រប់ចំនួនពិត $x$ ។

គណនា $g(x+1), g(x+2), g(x+3)$ និង $g(x+4)$ ជាអនុគមន៍នៃ $p$ និង $q$ ។

ខ. បង្ហាញថា $g$ ជាអនុគមន៍ខួប ។

## លំហាត់ទី ៥២៨

គេមានស្វ៊ីតនៃចំនួនពិត $(u_n)$ ដែលកំណត់ដោយ $u_1=\dfrac{1}{2}$ និង $u_n=\left(\dfrac{2n-3}{2n}\right)u_{n-1}$ ចំពោះ $n=2;3;\ldots$ ។

បង្ហាញថា $u_1+u_2+\cdots+u_n<1$ ចំពោះគ្រប់ចំនួនគត់វិជ្ជមាន $n$ ។

## លំហាត់ទី ៥២៩

ត្រីកោណកែង $ABC$ មួយមានអ៊ីប៉ូតេនុស $BC = a$ និងកម្ពស់ $AH = h$ ។ គេចែក $[BC]$ ជា $n$ ចំណែកស្មើគ្នា ដែល $n$ ជាចំនួនគត់សេស ។ គេយក $[PQ]$ ជាចំណែកដែលនៅកណ្ដាលគេ ហើយដែលរង្វាស់មុំ $P\widehat{A}Q = x$ ។

បង្ហាញថា $tanx = \dfrac{4nh}{a\left(n^2-1\right)}$ ។

## លំហាត់ទី ៥៣០




គេឱ្យចំណុច $M$ មួយនៃកន្លះរង្វង់ដែលមានអង្កត់ផ្ចិត $[AB]$ ។ រកសំណុំចំណុច $M$ កាលណា $A$ ចល័តលើជ្រុង $[Ox)$ និង $B$ ចល័តលើជ្រុង $[Oy)$ នៃមុំកែង $xOy$ មួយដោយរក្សាប្រវែង $AB$ ថេរ ។

## លំហាត់ទី ៥៣១

បង្ហាញថា $3^{2n} + 2^{6n-5}$ ចែកដាច់នឹង $11$ ចំពោះគ្រប់ចំនួនគត់វិជ្ជមាន $n$ ។

## លំហាត់ទី ៥៣២

គេឱ្យចំនួនគត់វិជ្ជមាន $a$ និង $b$ ដែល $2a^2 + a = 3b^2 + b$ ។

បង្ហាញថា $a-b$ ; $2a+2b+1$ ; និង $3a+3b+1$ សុទ្ធតែជាការេប្រាកដ ។

## លំហាត់ទី ៥៣៣

សំណុំ $E_n$ មួយមាន $n$ ធាតុដែល $n$ ជាចំនួនគត់វិជ្ជមាន ។ តាង $P(E_n)$ ជាសំណុំនៃសំណុំរងរបស់ $E_n$ ហើយ $Card\left(P(E_n)\right)$ ជាចំនួនធាតុនៃ $P(E_n)$ ។ តាមវិចារដោយកំណើន បង្ហាញថា $Card\left(P(E_n)\right) = 2^n$ ។

## លំហាត់ទី ៥៣៤

ត្រីកោណ $ABC$ មួយមានជ្រុង $BC = a$ ; $AC = b$ ដែល

$a + b = (atanA + btanB)tan\dfrac{C}{2}$ ។ បង្ហាញថា $ABC$ ជាត្រីកោណសមបាត ។

## លំហាត់ទី ៥៣៥

ស្វ៊ីត $(x_n)$ មួយកំណត់ដោយ $x_1 = 1$ និង $x_{n+1} = 1 + x_1x_2\cdots x_n$ ចំពោះ $n = 1,2,\ldots$ ។ គណនា $\lim\limits_{n\to+\infty} S_n$ ។

## លំហាត់ទី ៥៣៦

១. សិក្សាអថេរភាពនៃអនុគមន៍ $y = f(x) = \dfrac{x^2-1}{x^2+2}$ ( គេមិនអោយសង់ក្រាបតាង $f$ ទេ ) ។

២. $g$ ជាអនុគមន៍បង្រួមនៃអនុគមន៍ $f$ នៅលើ $[0;+\infty[$ ។ ពីអថេរភាពនៃអនុគមន៍ $f$

បញ្ជាក់អថេរភាពនៃអនុគមន៍ $g$ នៅលើ $[0;+\infty[$ ទាញរកអនុគមន៍ច្រាស $g^{-1}$ នៃអនុគមន៍ $g$ ។ សង់ខ្សែកោង $(C')$ និង $(C'')$ តាង $g$ និង $g^{-1}$ ។

**លំហាត់ទី ៥៣៧**

អនុគមន៍ $f(x;y)$ មួយផ្ទៀងផ្ទាត់លក្ខខណ្ឌទាំងបីដូចខាងក្រោមចំពោះគ្រប់ចំនួនគត់មិនអវិជ្ជមាន $x$ និង $y$ :

$(i)$ $f(0;y)=1+y$

$(ii)$ $f(x+1;0)=f(x;1)$

$(iii)$ $f(x+1;y+1)=f(x;f(x+1;y))$ ។

ក. គណនា $f(1;n)$, $f(2;n)$ និង $f(3;n)$ ជាអនុគមន៍នៃ $n$ ។

ខ. គណនា $f(4;2009)$ ។

**លំហាត់ទី ៥៣៨**

បើ $a+b+c=1$ ; $a^2+b^2+c^2=9$ និង $a^3+b^3+c^3=1$ ចូររក $\frac{1}{a}+\frac{1}{b}+\frac{1}{c}$ ។

**លំហាត់ទី ៥៣៩**

គេឱ្យចំណុច $O$ ជាគល់តម្រុយនៃប្រព័ន្ធកូអរដោនេមានបីវិមាត្រ ហើយតាង $A,B$ និង $C$ ជាចំណុចនៅលើអ័ក្សវិជ្ជមាន $x,y$ និង $z$ រៀងគ្នា ។ បើ $OA=\sqrt[4]{75}$ និង $\angle BAC=30^0$ ចូរគណនា $100S_{\triangle ABC}$ ( $S_{\triangle ABC}$ ជាផ្ទៃក្រឡានៃត្រីកោណ $ABC$ ) ។

**លំហាត់ទី ៥៤០**

ស្វ៊ីត $a_1,a_2,a_3,\ldots$ កំណត់ដោយ $a_1=1$ និង ចំពោះ $n\geq 2$,

$$a_n=(a_1+a_2+\cdots+a_{n-1})\times n \text{ ។}$$

ស្រាយបញ្ជាក់ថា $a_{2020}$ ចែកដាច់នឹង $2020^2$ ។

**លំហាត់ទី ៥៤១**

ស្រាយបញ្ជាក់ថា $cos\frac{\pi}{7}+cos\frac{3\pi}{7}+cos\frac{5\pi}{7}=\frac{1}{2}$ ។

**លំហាត់ទី ៥៤២**

ដាក់ជាផលគុណកត្តា $a^{10}+a^5+1$ ។

**លំហាត់ទី ៥៤៣**

ដោះស្រាយសមីការ $x+3\left(2-3x^2\right)^2=2$ ។

**លំហាត់ទី ៥៤៤**

គេឱ្យ $a,b,c,d$ ផ្ទៀងផ្ទាត់ $\begin{cases} a^2+b^2=a+b & (1) \\ c^2+d^2=-(c+d) & (2) \end{cases}$ ។

ស្រាយបញ្ជាក់ថា $(a-c)^2+(b-d)^2\leq 8$ ។

## លំហាត់ទី ៥៤៥

រកតម្លៃ $p\in\mathbb{N}$ ផ្ទៀងផ្ទាត់សមីការ $(x-p)(x-2011)+1=(x+m)(x+n)$ ចំពោះគ្រប់ $x\in\mathbb{R};\ m,n\in\mathbb{Z}$ ។

## លំហាត់ទី ៥៤៦

ផលគុណនៃ 7 នឹង ចំនួនដែលមាន 6 ខ្ទង់ $\overline{abcdef}$ ស្មើនឹងផលគុណនៃ 6 នឹង ចំនួនដែលមានលេខ 6 ខ្ទង់ $\overline{defabc}$ ។ រកចំនួនដែលមាន 6 ខ្ទង់ទាំងពីរ ។

## លំហាត់ទី ៥៤៧

គេឱ្យ $x_0=2010$ និង $x_{n+1}=\dfrac{1+x_n}{1-x_n}$ ចំពោះ $n\geq 0$ ។ គណនា $x_{2012}$ ។

## លំហាត់ទី ៥៤៨

ស្រាយបញ្ជាក់ថា ផលបូកនៃគ្រប់ចំនួនគត់មាន 2013 ខ្ទង់ ស្មើនឹង
$494\underbrace{99\ldots9}_{2010}55\underbrace{00\ldots0}_{2011}$ ។

## លំហាត់ទី ៥៤៩

គេឱ្យស្វ៊ីត Fibonacci ដែលកំណត់ដោយ $a_1=a_2=1$ និង $a_{n+2}=a_n+a_{n+1}$ ។
ស្រាយបញ្ជាក់ថា $\dfrac{1}{2}+\dfrac{1}{2^2}+\dfrac{2}{2^3}+\dfrac{3}{2^4}+\dfrac{5}{2^5}+\cdots+\dfrac{a_n}{2^n}<2$ ។

## លំហាត់ទី ៥៥០

គេឱ្យអនុគមន៍ $f$ ដោយ $f:\mathbb{N}\times\mathbb{N}\to\mathbb{N}$ ផ្ទៀងផ្ទាត់ទំនាក់ទំនងខាងក្រោម

$$\begin{cases} f(1,1)=2 \\ f(m+1,n)=f(m,n)+m \\ f(m,n+1)=f(m,n)-n \end{cases}$$

គ្រប់ $m,n\in\mathbb{N}$ ។ រកគ្រប់គូចំនួនគត់វិជ្ជមានដែល $f(a,b)=2013$ ។

## លំហាត់ទី ៥៥១

គេឱ្យទ្វាទេសកោណនិយ័ត $ABCDEFGHIJKL$ និង $R$ ជាកាំរង្វង់ចារឹកក្រៅទ្វាទេសកោណនិយ័ត ( ពហុកោណនិយ័តមាន 12 ជ្រុងប៉ុនគ្នា ) ។

ក ) ស្រាយបញ្ជាក់ថា $\dfrac{AB}{AF}+\dfrac{AF}{AB}=4$

ខ ) គណនាជាអនុគមន៍នៃ $R$ ផលបូក $S=AB^2+AC^2+AD^2+AE^2+AF^2$ ។

## លំហាត់ទី ៥៥២

គេឱ្យចំនួន $N=1+10^3+\dfrac{10^3\left(10^3-1\right)}{1\cdot 2}+\dfrac{10^3\left(10^3-1\right)\left(10^3-2\right)}{1\cdot 2\cdot 3}+\cdots+\dfrac{10^3\left(10^3-1\right)}{1\cdot 2}+10^3+1$ ។ តើ $N$ មានប៉ុន្មានខ្ទង់ បើគេដឹងថា $lg2=0.3010$ ?

## លំហាត់ទី ៥៥៣

គេឱ្យពហុធា $P(x)=\left(1+x+x^2+\cdots+x^{2010}\right)^2-x^{2010}$ ។
ចូរដាក់ $P(x)$ ជាផលគុណនៃពីរពហុធា ។

## លំហាត់ទី ៥៥៤

តាង $f:\mathbb{R}\to\mathbb{R}$ ជាអនុគមន៍ដែល $f(0)=1$ និងចំពោះ $x,y\in\mathbb{R}$
$f(xy+1)=f(x).f(y)-f(y)-x+2$ ។ រក $f(2010)$ ។

## លំហាត់ទី ៥៥៥

ចូរពិនិត្យមើលស្វ៊ីតខាងក្រោម

$u_1=1$

$u_2=3+5$

$u_3=7+9+11$

$u_4=13+15+17+19$

...

ស្រាយបញ្ជាក់ថា គ្រប់តួនៃស្វ៊ីត $\{u_n\}$ ជាគូបនៃចំនួនគត់ធម្មជាតិ ។

## លំហាត់ទី ៥៥៦

គេអោយអនុគមន៍ $f(x)=\left(x^3+12x-31\right)^{2020}$ ។
ចូរគណនា $f(a)$ បើ $a=\sqrt[3]{16+8\sqrt{5}}+\sqrt[3]{8-16\sqrt{5}}$ ។

## លំហាត់ទី ៥៥៧

ស្រាយបញ្ជាក់ថា វិសមភាព $\dfrac{cosA}{a^3}+\dfrac{cosB}{b^3}+\dfrac{cosC}{c^3}\ge\dfrac{3}{2abc}$ ពិតចំពោះគ្រប់ត្រីកោណ $ABC$ ដែលមាន រង្វាស់ជ្រុង $a,b,c$ និងមុំឈម $\angle A,\angle B,\angle C$ រៀងគ្នា ។

## លំហាត់ទី ៥៥៨

គេអោយ $a,b,c$ ជាបីចំនួនពិតវិជ្ជមាន ។
ស្រាយបញ្ជាក់ថា $\dfrac{a^2+1}{b+c}+\dfrac{b^2+1}{c+a}+\dfrac{c^2+1}{a+b}\ge 3$ ។

## លំហាត់ទី ៥៥៩

គេអោយ $f(x)=-x^2-2ax-b\ (a\ne 0)$ ។
គេដឹងថា $f(1)=3$ និង តម្លៃអតិបរមានៃ $f$ គឺ $4$ ។ កំណត់តម្លៃ $a$ និង $b$ ។

**(អាហារូបករណ៍ប្រទេសជប៉ុន)**

## លំហាត់ទី ៥៦០

តាង $f:\mathrm{R}\to\mathrm{R}$ ជាអនុគមន៍ដែល $f(0)=1$ និងចំពោះ $x,y\in\mathrm{R}$
$f(xy+1)=f(x).f(y)-f(y)-x+2$ ។ រក $f(2010)$ ។

## លំហាត់ទី ៥៦១

១. ត្រីកោណ $ABC$ មានមេដ្យាន $AM$ ។ បង្ហាញសមភាព $AB^2+AC^2=2AM^2+\frac{BC^2}{2}$ ។

២. ត្រីកោណ $ABC$ មាន $G$ ជាទីប្រជុំទម្ងន់ ។ តាង $a=BC, b=CA, c=AB$ ។ ស្រាយបញ្ជាក់ថា $GA^2+GB^2+GC^2=\frac{1}{3}\left(a^2+b^2+c^2\right)$ ។

## លំហាត់ទី ៥៦១

ត្រីកោណ $ABC$ កែងត្រង់ $A$ ។ ការេ $MNPQ$ ចារឹកក្នុងត្រីកោណកែង $ABC$ ដែល $M$ នៅលើ $AB$, $N$ និង $P$ នៅលើ $BC$ និង $Q$ នៅលើ $CA$ ។ ដូចគ្នាការេដែលមានជ្រុង $a_1,a_2,a_3$ ចារឹកក្នុងត្រីកោណកែង $QPC$ ,$MBN$ និង $AMQ$ រៀងគ្នា ដោយមានកំពូល 2 នៃការេនៅលើអ៊ីប៉ូតេនុស និង កំពូលមួយនៅលើជ្រុងមុំកែងនីមួយៗនៃត្រីកោណកែង ។ ស្រាយបញ្ជាក់ថា $\frac{1}{a_1^2}+\frac{1}{a_2^2}=\frac{1}{a_3^2}$ ។

## លំហាត់ទី ៥៦២

ស្រាយបញ្ជាក់ថា ចំនួនគត់តូចបំផុតដែលធំជាង $(\sqrt{3}+1)^{4020}$ ចែកដាច់នឹង $2^{2011}$ ។

## លំហាត់ទី ៥៦៣

១. សរសេរ $x^4+4y^4$ ជាផលគុណនៃពីរពហុធាដឺក្រេទីពីរនៃ $x$ និង $y$ :

២. បង្ហាញថា $n^4+4^n$ មិនមែនជាចំនួនបឋមទេ ចំពោះគ្រប់ចំនួនគត់រ៉ឺឡាទីប $n>1$ ។

## លំហាត់ទី ៥៦៤

រកអនុគមន៍ $g$ ដែលផ្ទៀងផ្ទាត់សមីការ $g(x)+g\left(\frac{1}{1-x}\right)=x$ ចំពោះគ្រប់ចំនួនពិត $x$ ដែល $x\neq 0, x\neq 1$ ។

## លំហាត់ទី ៥៦៥

រកគ្រប់ចំនួនគត់វិជ្ជមាន $n$ ដើម្បីឱ្យ $n^2-19n+99$ ជាការេប្រាកដ ។

## លំហាត់ទី ៥៦៦

គេឱ្យចំនួនពិត $x,y\in(-2,2)$ និង $xy=-1$ ។
ស្រាយបំភ្លឺថា $\frac{4}{4-x^2}+\frac{9}{9-y^2}\geq\frac{12}{5}$ ។

## លំហាត់ទី ៥៦៧

ឧបមា ពហុធា $p(x)=x^5+x^2+1$ មានឫសប្រាំ $r_1,r_2,r_3,r_4,r_5$ និង $q(x)=x^2-2$ ។ ចូរគណនា $q(r_1)q(r_2)q(r_3)q(r_4)q(r_5)$ ។

## លំហាត់ទី ៥៦៨

ក. រកចំនួនកុំផ្លិច $z$ ដែលផ្ទៀងផ្ទាត់ $z^7+1=0$ ។

ខ. ទាញបញ្ជាក់ថា $cos\frac{\pi}{7}-cos\frac{2\pi}{7}+cos\frac{3\pi}{7}=\frac{1}{2}$ ។

លំហាត់ទី ៥៦៩

គេឱ្យ $O$ ជាចំណុចប្រសព្វរវាងអង្កត់ទ្រូង $AC$ និង $BD$ នៃប្រលេឡូក្រាម $ABCD$ ដែលមាន $\angle CAB=\angle DBC=2\angle DBA$ ។ គណនាផលធៀបនៃមុំ $\angle ACB$ និង $\angle AOB$ ។

លំហាត់ទី ៥៧០

រកចំនួនគត់គូដែលមានលេខបួនខ្ទង់ខុសៗគ្នានៅចន្លោះ 2000 និង 5000 ។

លំហាត់ទី ៥៧១

គេឱ្យចំនួនគត់វិជ្ជមាន $a,b,a',b',d,d'$ ដែល $GCD(a,b)=d$ និង $GCD(a',b')=d'$ ។ ស្រាយបញ្ជាក់ថា $GCD(aa',bb',ab',a'b)=dd'$ ។

លំហាត់ទី ៥៧២

គេឱ្យស្វ៊ីត $(a_n)$ កំណត់ដោយ $a_n=\frac{n(n-1)}{2}cos\frac{n(n-1\pi)}{2}$ ។
គណនា $a_1+a_2+\cdots+a_{2020}$ ។

លំហាត់ទី ៥៧៣

គេឱ្យ $\triangle ABC$ កែងត្រង់ $C$ និងមានប្រវែងជ្រុងទាំងបីជាចំនួនវិជ្ជមាន ។ កម្ពស់គូសចេញពីកំពូល $C$ កាត់អ៊ីប៉ូតេនុស $AB$ ត្រង់ចំណុច $D$ ដែល $BD=24389$ ។ គណនា $sin\angle BAC$ ។

លំហាត់ទី ៥៧៤

គេឱ្យអនុគមន៍ $f$ កំណត់លើ $\mathbb{N}$ ដោយ $f(1)=11, f(2)=22, f(3)=33, f(4)=44$ និង $f(n)=f(n-1)-f(n-2)+f(n-3)-f(n-4)$ ចំពោះគ្រប់ $n\geq 5$ ។ គណនា $f(2020)$ ។

លំហាត់ទី ៥៧៥

គេឱ្យចតុកោណព្នាយ $ABCD$ មានបាត $AD\parallel BC$ ។ $E$ ជាចំណុចចល័តមួយនៅលើអង្កត់ $AB$ ។ $O_1$ និង $O_2$ ជាផ្ចិតរង្វង់ចារឹកក្រៅ $\triangle AED$ និង $\triangle BEC$ រៀងគ្នា ។ បង្ហាញថា $O_1O_2$ មានប្រវែងថេរ ។

លំហាត់ទី ៥៧៦

ក្នុងត្រីកោណកែង $XYZ$ មួយមាន $\widehat{X}=90^0, YZ=x, ZX=y$ និង $XY=z$ ។ បង្ហាញថា $x^n>y^n+z^n$ ចំពោះគ្រប់ចំនួនគត់រ៉ឺឡាទីប $n$ ដែល $n\geq 3$ ។

លំហាត់ទី ៥៧៧

គេបានបេះផ្លែស្វាយមករៀបគរជា 11 គំនរស្មើៗគ្នា ហើយនៅសល់ផ្លែស្វាយចំនួន 6 ផ្លែទៀត ។ តែបើគេយកផ្លែស្វាយទាំងនោះមករៀបជា 17 គំនរស្មើៗគ្នាវិញ នោះពុំមានផ្លែស្វាយនៅ

សល់ទេ ។ រកចំនួនផ្ទៃស្វាយតិចបំផុតដែលគេបានបេះ ។

លំហាត់ទី ៥៧៨

ចតុកោណប៉ោង $ABCD$ មួយមានជ្រុង $AB=a, BC=b, CD=c, DA=d$ វង្វាស់មុំ $A\hat{B}C=x$ និង $A\hat{D}C=y$ ។ រកលក្ខខណ្ឌដើម្បីឱ្យចតុកោណ $ABCD$ មានផ្ទៃក្រឡាអតិបរមា ។

លំហាត់ទី ៥៧៩

ស្វ៊ីតនៃចំនួន $(u_n)$ កំណត់ដោយ $u_1=1;\ u_2=1$ និង $u_n=u_{n-1}+u_{n-2}$ ចំពោះ $n=3;4;...$។

តាង $a=\dfrac{1+\sqrt{5}}{2}$ និង $b=\dfrac{1-\sqrt{5}}{2}$ ។

១. បង្ហាញថា $u_n>a^{n-2}$ ចំពោះគ្រប់ចំនួនគត់ $n\ge 3$ ។

២. បង្ហាញថា $u_n=\dfrac{1}{\sqrt{5}}(a^n-b^n)$ ចំពោះគ្រប់ចំនួនគត់រ៉ឺឡាទីបវិជ្ជមាន $n$ ។

លំហាត់ទី ៥៨០

គណនាផលបូក $S=\dfrac{1}{2^1}-\dfrac{2^1}{2^2}+\dfrac{3}{2^3}-\dfrac{4}{2^4}+\cdots-\dfrac{2010}{2^{2010}}+\dfrac{2011}{2^{2011}}$ ។

លំហាត់ទី ៥៨១

គេឱ្យចំនួនគត់វិជ្ជមាន $I_n=8^n+9^{3n+1}+25^{3n+1}$ ចំពោះ $n=0,1,2,...,2011$ ។

រក $gcd(I_0,I_1,I_2,...,I_{2011})$ ។

លំហាត់ទី ៥៨២

បង្ហាញថា ចំនួនគត់ $N=5^{5^{2011}}+5^{5^{2010}}+1$ មិនមែនជាចំនួនបឋម ។

លំហាត់ទី ៥៨៣

ដោះស្រាយសមីការខាងក្រោមក្នុងសំណុំចំនួនគត់រ៉ឺឡាទីប :

$x^2+x+503=y^2$ ។

លំហាត់ទី ៥៨៤

រកគ្រប់អនុគមន៍ $f:\mathbf{R}-\left\{\dfrac{2}{3}\right\}\to\mathbf{R}$ ដែលបំពេញសមីការអនុគមន៍ខាងក្រោម :

$\dfrac{1}{2}f\left(\dfrac{2x}{3x-2}\right)+f(x)=503x$ ។

លំហាត់ទី ៥៨៥

គេឱ្យពហុធា $P(x)=\displaystyle\sum_{k=0}^{2011}\frac{1}{(2011+k+1)}x^4$ ។

ស្រាយបញ្ជាក់ថា សមីការ $P(x^2)=P^2(x)$ គ្មានឫសជាចំនួនពិត ។

លំហាត់ទី ៥៨៦

គេឱ្យចតុកោណ $ABCD$ ចារឹកក្នុងរង្វង់ ហើយមានផ្ទៃក្រឡា $S$ ។
គេឱ្យ $AB=a, BC=b, CD=c, AD=d$ និង $p$ ជាកន្លះបរិមាត្រ ។
ក ) ស្រាយបញ្ជាក់ថា $S=\sqrt{(p-a)(p-b)(p-c)(p-d)}$ ។
ខ ) បើ $S=\left(\frac{p}{2}\right)^2$ បង្ហាញថា $ABCD$ ជាការេ ។

## លំហាត់ទី ៥៨៧

ក ) រកតម្លៃនៃ $A=2011^3-2010.2011^3-2010^2.2011+2010^3$ ។
ខ ) រកតម្លៃនៃ $B=403^5-402^2(403^3+2.403^2+3.403+4)$ ។

## លំហាត់ទី ៥៨៨

គណនាផលបូកតួមិនកំណត់នៃស្វ៊ីតខាងក្រោម :

$S=\frac{1^3}{3^1}+\frac{2^3}{3^2}+\frac{3^3}{3^3}+\frac{4^3}{3^4}+\frac{5^3}{3^5}+\cdots$ ។

## លំហាត់ទី ៥៨៩

គេឱ្យ $f(n)=\frac{1}{\sqrt[3]{n^2+2n+1}+\sqrt[3]{n^2-1}+\sqrt[3]{n^2-2n+1}}$ គ្រប់ $n\in\mathbf{N}$ ។
គណនាផលបូក $S=f(1)+f(3)+f(5)+\cdots+f(10^6-3)+f(10^6-1)$ ។

## លំហាត់ទី ៥៩០

បន្ទាត់៣ផ្សេងគ្នា ត្រូវបានគូសនៅក្នុងប្លង់ ។ ឧបមាថាមាន $n$ រង្វង់យ៉ាងពិតប្រាកដនៅក្នុងប្លង់ដែលប៉ះនឹងបន្ទាត់ទាំង៣ ។ រកតម្លៃដែលអាចមាននៃ $n$ ដោយគូសរូបបញ្ជាក់ ។

## លំហាត់ទី ៥៩១

តាង $u_0,u_1,u_2,...,u_n$ ជាស្វ៊ីតនៃចំនួនពិត ដែលបំពេញទំនាក់ទំនងខាងក្រោម :

$(3-u_{n+1})(6+u_n)=18$ និង $u_0=3$ ។ គណនា $\sum_{k=0}^{2011}\frac{1}{u_k}$ ។

## លំហាត់ទី ៥៩២

ស្វ៊ែរ $S_1$ មួយមានកាំ $r$ ចារឹកក្នុងកោនមួយមានមុំនៅត្រង់កំពូលនៃមុខកាត់តាមអ័ក្សស្មើ $\frac{\pi}{3}$ ។
ក ) រកផលធៀប $\frac{V_1}{V}$ រវាងមាឌ $V_1$ និង មាឌ $V$ នៃស្វ៊ែរ $S_1$ និង កោន ។
ខ ) ហៅ $S_2$ ជាស្វ៊ែរនៅក្នុងកោន ប៉ះនឹងជនេត្រនៃកោន ហើយប៉ះនឹងស្វ៊ែរ $S_1$

$S_3$ ជាស្វ៊ែរនៅក្នុងកោន ប៉ះនឹងជនេត្រនៃកោន ហើយប៉ះនឹងស្វ៊ែរ $S_2$

..............................................................................................

$S_{k+1}$ ជាស្វ៊ែរនៅក្នុងកោន ប៉ះនឹងជនេត្រនៃកោន ហើយប៉ះនឹងស្វ៊ែរ $S_k$

ស្រាយបញ្ជាក់ថាគ្រប់ $n \in \mathbf{N}$ ផលបូកមាឌនៃស្វ៊ែរ $S_1, S_2, ..., S_n$ តូចជាង $\frac{1}{2}V$ ។

លំហាត់ទី ៥៩៣

គេឱ្យ $c > 0$ និង $a, b \geq c$ ។ ស្រាយបញ្ជាក់ថា $\sqrt{c(a-c)} + \sqrt{c(b-c)} \leq \sqrt{ab}$ ។

លំហាត់ទី ៥៩៤

គណនាអាំងតេក្រាល $I(k) = \int_0^{\infty} \frac{sinkxcos^k x}{x} dx$ ដែល $k$ ជាចំនួនគត់វិជ្ជមាន ។

លំហាត់ទី ៥៩៥

គណនាអាំងតេក្រាល $I = \int_0^{\frac{\pi}{2}} ln(sinx)dx$ ។

លំហាត់ទី ៥៩៦

គណនាអាំងតេក្រាល $I = \int \frac{dx}{cosx}$ ។

លំហាត់ទី ៥៩៥

$i$ ជាចំនួនកុំផ្លិចដែល $i = \sqrt{-1}$ ។ បង្ហាញថា $i^i$ ជាចំនួនពិត ។

លំហាត់ទី ៥៩៦

គេអោយ $j$ និង $n$ ជាចំនួនគត់វិជ្ជមាន និងយក $S_j = 1^j + 2^j + 3^j + \cdots + n^j$ ។ បង្ហាញថា

$\binom{k+1}{1} S_1 + \binom{k+2}{2} S_2 + \cdots + \binom{k+1}{k} S_k = (n+1)^{k+1} - (n+1)$ ។

លំហាត់ទី ៥៩៧

ប្រើអនុមាណរួមគណិតវិទ្យា បង្ហាញថា $133|(11)^{n+2} + 12^{2n+1}$ ។

លំហាត់ទី ៥៩៨

គេអោយ $0 \leq x, y, z \leq 1$ ។ ស្រាយបញ្ជាក់ថា

$$(2^x + 2^y + 2^z)(2^{-x} + 2^{-y} + 2^{-z}) \leq \frac{81}{8} \text{ ។}$$

លំហាត់ទី ៥៩៩

បើ $\frac{a_0}{n+1} + \frac{a_1}{n} + \frac{a_2}{n-1} + \cdots + \frac{a_{n-1}}{2} + a_n = 0$ ស្រាយបញ្ជាក់ថា សមីការ $a_0 x^n + a_1 x^{n-1} + a_2 x^{n-2} + ... + a_{n-1} x + a_0 = 0$ មានឫសយ៉ាងតិចមួយចន្លោះ $(0,1)$ ។

លំហាត់ទី ៦០០

បើ $f(x) = 0$ ជាសមីការពហុធាដែលមាន $n$ ឫសចំនួនពិត ស្រាយបញ្ជាក់ថា សមីការ $f'(x) = 0$ មានយ៉ាងហោច $(n-1)$ ឫសចំនួនពិត ។

លំហាត់ទី ៦០១

$p$ ជាចំនួនគត់ធម្មជាតិ ។ ស្រាយបញ្ជាក់ថា $p^{n+1} + (p+1)^{2n-1}$ ចែកដាច់នឹង $p^2 + p + 1$

ចំពោះគ្រប់ចំនួនគត់ធម្មជាតិ $n$ ។

## លំហាត់ទី ៦០២

បើ $p$ ជាចំនួនបឋម ស្រាយតាមអនុមាណរួមគណិតវិទ្យាថា $p|(n^p - n)$ ចំពោះគ្រប់ $n \in \mathbb{N}$ ។

## លំហាត់ទី ៦០៣

ដោះស្រាយសមីការ $8\sqrt{sinx} + 27\sqrt{cosx} = 97^{\frac{3}{4}},\ x \in \left(0; \frac{\pi}{2}\right)$ ។

## លំហាត់ទី ៦០៤

ដោះស្រាយសមីការ $sinx + cosx = \sqrt{2 + sin^{2018}\left(x - \frac{\pi}{4}\right)}$ $(*)$ ។

## លំហាត់ទី ៦០៦

គេអោយ $p$ និង $q$ ជាចំនួនពិតដែល $p \neq 0$ ហើយ $a, b, c$ ជាឫសនៃពហុធា $px^3 - px^2 + qx + q$ ។ ស្រាយបញ្ជាក់ថា $(a+b+c)\left(\frac{1}{a} + \frac{1}{b} + \frac{1}{c}\right) = -1$ ។

## លំហាត់ទី ៦០៧

ដេរីវេនៃអនុគមន៍បណ្តាក់

ស្រាយថាបើ $\phi(x) = \psi[f(x)]$ នោះ $\phi'(x) = \psi'[f(x)].f'(x)$ ។

## លំហាត់ទី ៦០៨

ទ្រឹស្តីបទ Lebnitz

បើ $y = uv$ ដែល $u, v$ ជាអនុគមន៍នៃ $x$ ស្រាយបញ្ជាក់ថាដេរីវេទី $n$ កំណត់ដោយ $y_n = (uv)_n = u_n v + {}^nC_1 u_{n-1} v_1 + {}^nC_2 u_{n-2} v_2 + \cdots + {}^nC_n v_n$ ។

## លំហាត់ទី ៦០៩

ស្រាយបញ្ជាក់វិសមភាព :

$$\frac{4^n}{n+1} < \frac{(2n)!}{(n!)^2} \text{ ចំពោះ } n \geq 2 \text{ ។}$$

## លំហាត់ទី ៦១០

ដេរីវេនៃអនុគមន៍ច្រាស

ទ្រឹស្តីបទ :បើ $f$ ជាអនុគមន៍ជាប់មួយទល់មួយ កំណត់នៅលើចន្លោះ $I$ និង $f$ មានដេរីវេត្រង់ $x_0$ ដែល $f(x_0) \neq 0$ នោះអនុគមន៍ច្រាសនៃអនុគមន៍ $f$ មានដេរីវេត្រង់ $f(x_0)$ ដែលដេរីវេរបស់វាត្រង់ $f(x_0)$ នោះគឺ $\frac{1}{f'(x_0)}$ ។

## លំហាត់ទី ៦១១

ក) កំណត់ចំនួនពិត $x$ និង $y$ ដោយដឹងថា $3^x + 3^y = 30$ និង $log_3 x - log_3 y = 1$ ។

ខ ) ដោះស្រាយក្នុងសំណុំចំនួនពិតនូវសមីការ $\sqrt{1-x^2}=3\cdot x-4\cdot x^3$ ។

**លំហាត់ទី ៦១២**

ស្រាយបញ្ជាក់ថា ចំពោះគ្រប់ $a_1,a_2,b_1,b_2\in(1,\infty)$ វិសមភាពខាងក្រោមពិត :

$$\frac{1}{\sqrt{1+log_{a_1}\sqrt{b_1}}}+\frac{1}{\sqrt{1+log_{a_2}\sqrt{b_2}}}+\frac{1}{\sqrt{1+log_{b_1}a_1^2}}+\frac{1}{\sqrt{1+log_{b_2}a_2^2}}\le 2\cdot\sqrt{2}$$ ។

**លំហាត់ទី ៦១៣**

ដោះស្រាយវិសមីការ

$$log_{\sqrt{5}}\left(3^{x^2-x-1}+2\right)+log_5\left(3^{x^2-x-1}+2\right)+log_{25}\left(3^{x^2-x-1}+2\right)+log_{625}\left(3^{x^2-x-1}+2\right)+\ldots+log_{5^{2^k}}\left(3^{x^2-x-1}+2\right)+\ldots\le 4$$ ។

**លំហាត់ទី ៦១៤**

ក ) ស្រាយបញ្ជាក់ថា $ln(1+x)\ge x-\frac{x^2}{2},\ (\forall)x\in[0,\infty)$ ។

ខ ) គេអោយ $f:\mathbb{R}\to[0,\infty)$ ជាអនុគមន៍ជាប់ ។

ស្រាយបញ្ជាក់ថា $\lim\limits_{n\to\infty}\sum_{k=1}^{n}ln\left(1+\frac{1}{n}\cdot f\left(\frac{k}{n}\right)\right)=\int_0^1 f(x)dx$ ។

**លំហាត់ទី ៦១៥**

គណនា $\lim\limits_{x\to 2}\frac{\sqrt{4x+1}-\sqrt[3]{x+6}-\sqrt[4]{x-1}}{3^x+4^x-5^x}$ ។

**លំហាត់ទី ៦១៦**

ក ) ចំពោះ $a>0$ ស្រាយបញ្ជាក់ថា $\lim\limits_{n\to\infty}\frac{1+2^a+3^a+\ldots+n^a}{n^{a+1}}=\frac{1}{a+1}$ ។

ខ ) គណនា $\lim\limits_{n\to\infty}\frac{1+\sqrt[4]{2}+\sqrt[4]{3}+\ldots+\sqrt[4]{n}}{n\cdot\sqrt[4]{n^3}\left(\sqrt[4]{(n+1)^2+1}-\sqrt[4]{n^2+1}\right)}$ ។

**លំហាត់ទី ៦១៧**

រកគ្រប់ $b\in\mathbb{N}$ ដើម្បីអោយ $\sqrt[3]{2+\sqrt{b}}+\sqrt[3]{2-\sqrt{b}}$ ជាចំនួនគត់ ។

**លំហាត់ទី ៦១៨**

គណនា $\int_{-\pi}^{\pi}\frac{sin(2020x)}{(1+2^x)sinx}dx$ ។

**លំហាត់ទី ៦១៩**

គេអោយស្វ៊ីតចំនួនពិតវិជ្ជមាន $a_0,a_1,a_2,a_3,\ldots,a_n$ កំណត់ដោយ $a_0=1$ និង

$$a_{n+1}=\begin{cases}\frac{1}{2}a_n & \text{បើ } a_n \text{ គូ}\\ \frac{1}{2}(a_n+2017) & \text{បើ } a_n \text{ សេស}\end{cases} \text{ ។}$$

ក ) ស្រាយបញ្ជាក់ថា ស្វ៊ីត $\{a_n\}$ ជាស្វ៊ីតខួប ។

ខ ) ចូររក $a_{2017}$ ។

## លំហាត់ទី ៦២០

គេអោយ $\{a_n\}$ ជាស្វ៊ីតកំណត់ដោយ $a_0=0, a_1=1, a_2=2$ និង

$$a_n=a_{n-1}+a_{n-2}-a_{n-3}+1$$

ចំពោះ $n\geq 3$ ។ រក $a_{2023}$ ។

## លំហាត់ទី ៦២១

ស្រាយបញ្ជាក់ថា $\sqrt{3}$ ជាចំនួនអសនិទាន។

## លំហាត់ទី ៦២២

នៅដើមឆ្នាំ ២០១១ នេះ ចំនួនភ្ញៀវទេសចរដែលបានមកទស្សនាប្រាសាទអង្គរវត្តស្មើនឹង $pq\left(p^2-q^2\right)$ ដែល $p$ និង $q$ ជាចំនួនគត់ធម្មជាតិ ហើយ $p>q$ ។ គេស្រង់ឈ្មោះទេសចរទាំងនោះដាក់ក្នុងបញ្ជីមួយដែលមានចុះលេខរៀងត្រឹមត្រូវ ។ បង្ហាញថា លេខរៀងរបស់ទេសចរចុងក្រោយគេបង្អស់ជាពហុគុណនៃ 3 ។

## លំហាត់ទី ៦២៣

ចំណុច $M_i(x,y,z)$ មានកូអរដោនេជាចំនួនគត់រ៉ឺឡាទីបដែលផ្ទៀងផ្ទាត់ $x^2+y^2+z^2=x^3+y^3+z^3$ ។ បង្ហាញថា មានចំណុច $M_i(x,y,z)$ ច្រើនរាប់មិនអស់នៅក្នុងលំហ ។

## លំហាត់ទី ៦២៤

ស្វ៊ីត $(u_n)$ កំណត់ដោយ $u_1=1, u_2=1$ និង $u_{n+1}=u_n+u_{n-1}$ ចំពោះ $n\geq 2$ ។ បង្ហាញថា $u_{2011}u_{2012}-u_{2010}u_{2013}=1$ ហើយ $u_{1042012}u_{1042013}-u_{1042011}u_{1042014}=-1$ ។

## លំហាត់ទី ៦២៥

ស្វ៊ីត $(I_k)$ កំណត់ដោយ $I_k=\int_0^{\frac{\pi}{2}} sin^k x dx$ ចំពោះគ្រប់ចំនួនគត់ធម្មជាតិ $k$ ។

អនុគមន៍ $f$ កំណត់ដោយ $f(k)=(k+1)I_kI_{k+1}$ ។

ក. កំណត់ទំនាក់ទំនងរវាង $I_k$ និង $I_{k+2}$ ។

ខ. ប្រៀបធៀប $f(k)$ និង $f(k+1)$ ចំពោះគ្រប់ចំនួនគត់ធម្មជាតិ $k$ ។

គណនាតម្លៃ $f(2011)$ ។

## លំហាត់ទី ៦២៦

$P_n(x)$ ជាពហុធាដឺក្រេទី $n$ ដែលផ្ទៀងផ្ទាត់ $P_n(x) = -2xP_{n-1}(x) + P'_{n-1}(x)$ ។
១- បង្ហាញថាដេរីវេទី $n$ នៃអនុគមន៍ $y = e^{-x^2}$ កំណត់ដោយ $y^{(n)} = e^{-x^2}P_n(x)$ ។
២- ទាញបញ្ជាក់ថា $P_{n+1}(x) + 2xP_n(x) + 2nP_{n-1}(x) = 0$ ហើយ $P''_n(x) - 2xP'_n(x) + 2nP_n(x) = 0$ ។

## លំហាត់ទី ៦២៧

.គេឱ្យចំនួនពិតវិជ្ជមាន $a$ និង $b$។ កំណត់គ្រប់គូនៃចំនួនពិតវិជ្ជមាន $x, y$ ដែលផ្ទៀងផ្ទាត់សមីការ $\dfrac{27xy}{(1+2ax)(1+2by)} = \dfrac{1}{ab} + \dfrac{x}{a} + \dfrac{y}{b}$។

## លំហាត់ទី ៦២៨

រកគ្រប់ចំនួនពិត $x$ ផ្ទៀងផ្ទាត់វិសមីការ $2|x - |x + |x-1||| > |x + |x - |x+1|||$។

## លំហាត់ទី ៦២៩

ស្រាយបញ្ជាក់ថា ចំពោះគ្រប់ចំនួនធម្មជាតិ $k$ : $(k!)^{k^2+k+1}$ ជាតួចែកនៃចំនួន $(k^3)!$។

## លំហាត់ទី ៦៣០

ស្រាយបញ្ជាក់ថា បើត្រីកោណ $ABC$ មានជ្រុង និងមុំឈម $A, B$ ផ្ទៀងផ្ទាត់ទំនាក់ទំនង $(a^2+b^2)sin(A-B) = (a^2-b^2)sin(A+B)$ នោះវាជាត្រីកោណសមបាត ឬ ត្រីកោណកែង។

## លំហាត់ទី ៦៣១

គេមានត្រីកោណ $ABC$។ គេជ្រើសរើសចំណុចនៅលើជ្រុង $BC, CA, AB$ តាងដោយ $D, E, F$ រៀងគ្នាដែល $\dfrac{BD}{DC} = \dfrac{CE}{EA} = \dfrac{AF}{FB} = k$ ($k$ ជាចំនួនវិជ្ជមាន)។ តាង $S$ ជាផ្ទៃក្រឡា $\triangle ABC$។ គណនាផ្ទៃក្រឡា $\triangle DEF$។

## លំហាត់ទី ៦៣២

គេឱ្យ $a > 0, b > 0, C > 0$។
ស្រាយបញ្ជាក់ថា $ab(a+b) + bc(b+c) + ca(c+a) \geq 6abc$។

## លំហាត់ទី ៦៣៣

គេឱ្យចំនួនគត់វិជ្ជមាន $x, y, z$ ដែល $\dfrac{x+1}{y} + \dfrac{y+1}{z} + \dfrac{z+1}{x}$ ជាចំនួនគត់។ តាង $d$ ជាតួចែករួមធំបំផុតនៃចំនួន $x, y, z$។ ស្រាយបញ្ជាក់ថា $d \leq \sqrt[3]{xy+yz+zx}$។

## លំហាត់ទី ៦៣៤

គេឱ្យស្វ៊ីតមិនកំណត់ $\{a_n\}$។ ស្រាយថាបើ $a_n + a_{n+2} > 2a_{n+1}$ ចំពោះ $n = 1, 2, ..$ នោះ $\dfrac{a_1 + a_3 + \cdots + a_{2n+1}}{n+1} \geq \dfrac{a_2 + a_4 + \cdots + a_{2n}}{n}$ ចំពោះ $n = 1, 2, ..$។

## លំហាត់ទី ៦៣៥

ស្រាយបញ្ជាក់ថា $2sin\left(1+\frac{1}{2}+\cdots+\frac{1}{2^{n-1}}\right)\frac{\pi}{4}=\underbrace{\sqrt{2+\sqrt{2+\cdots+\sqrt{2}}}}_{n\text{រ៉ាឌីកាល់}}$។

## លំហាត់ទី ៦៣៦

គេឱ្យត្រីកោណមានមុំស្រួច $ABC$។ តាង $D,F$ ជាចំណុចកណ្ដាលរៀងគ្នានៃ $BC,AB$។ ចំណោលកែងពីចំណុច $C$ ទៅលើ $AC$ និង ចំណោលកែង ត្រង់ចំណុច $B$ ទៅលើ $BC$ ជួបគ្នាត្រង់ $N$។ ស្រាយបញ្ជាក់ថា $DN$ មានប្រវែងស្មើនឹងកាំរង្វង់
ចារឹកក្រៅត្រីកោណ $ABC$។

## លំហាត់ទី ៦៣៧

រកចំនួនគត់ធំបំផុត តូចជាង $A=\frac{2013!+2010!}{2012!+2011!}$។

## លំហាត់ទី ៦៣៨

រកគ្រប់តម្លៃនៃ $b$ ដែល $B=11...1-bb...b$ ជាការេប្រាកដ ដោយដឹងថា លេខ 1 មាន 4024 ខ្ទង់ និង $b$ មាន 2012 ខ្ទង់។

## លំហាត់ទី ៦៣៩

ដោះស្រាយសមីការ $\left(x^{2012}+1\right)\left(1+x^2+x^4+\cdots+x^{2010}\right)=2012x^{2011}$។

## លំហាត់ទី ៦៤០

គេឱ្យអនុគមន៍ $f(x,y)=1-\frac{x}{y}$ ដែល $x>0$ និង $y>0$។ គេតាង

$$F_n(x)=\begin{cases} f(x,x) & \text{បើ } n=1 \\ f\left(F_{n-1}(x),x\right) & \text{បើ } n>1 \end{cases}$$ ។ គណនា $F_{2022}(2)$។

## លំហាត់ទី ៦៤១

$\triangle ABC$ មានរង្វាស់ជ្រុង $AB=4$, $BC=7$ និង $AC=5$។ តាង $\alpha=\angle BAC$ ចូរគណនាតម្លៃនៃកន្សោម $sin^6\frac{\alpha}{2}+cos^6\frac{\alpha}{2}$។

## លំហាត់ទី ៦៤២

គណនាផលបូក $f\left(\frac{1}{2020}\right)+f\left(\frac{2}{2020}\right)+\cdots+f\left(\frac{2019}{2020}\right)$ ដោយដឹងថា
$f(x)=\frac{4^x}{4^x+2};\ x\in\mathbb{R}$។

## លំហាត់ទី ៦៤៣

ស្រាយបញ្ជាក់ថា

$$\frac{1}{log_xa\cdot log_xa^2}+\frac{1}{log_xa^2\cdot log_xa^3}+\ldots+\frac{1}{log_xa^{n-1}\cdot log_xa^n}$$

$=\dfrac{n-1}{n}log_a^2x$។

លំហាត់ទី ៦៤៤

ដោះស្រាយសមីការ $cosxcos2xcos4xcos8x=\dfrac{1}{16}$។

លំហាត់ទី ៦៤៥

រកលេខខ្ទង់ចុងក្រោយនៃចំនួន $13^{13}$។

លំហាត់ទី ៦៤៥

រកលេខខ្ទង់ចុងក្រោយនៃចំនួន $13^{13^{13}}$។

លំហាត់ទី ៦៤៦

រកលេខពីរខ្ទង់ចុងក្រោយនៃចំនួន $133333^{13333^{1333^{133^{13}}}}$។

លំហាត់ទី ៦៤៧

កន្លះបន្ទាត់ពុះមុំនៃត្រីកោណ $ABC$ ប្រសព្វគ្នាត្រង់ចំណុច $I$។ $M$ និង $N$ ជាចំណុចកណ្តាលរៀងគ្នានៃជ្រុង $AB$ និង $AC$។ $MN$ និង $CI$ ជួបគ្នាត្រង់ $P$។ $Q$ គឺជាចំណុចមួយដែល $MN$ កែង $PQ$ ហើយបន្ទាត់ $BI$ និង $NQ$ ស្របគ្នា។ រកមុំរវាង $AC$ និង $IQ$។

លំហាត់ទី ៦៤៧

$f$ ជាអនុគមន៍កំណត់ក្នុងសំណុំចំនួនពិតខុសពី $0$ និង $1$ ហើយផ្ទៀងផ្ទាត់លក្ខខណ្ឌខាងក្រោម:

(i) $f(1-x)=\dfrac{1}{f(x)}$;

(ii) $f\left(\dfrac{1}{x}\right)=\dfrac{1}{f(f(x))}$;

(iii) $f(f(f(x)))=x$។

១. ចូរគណនា $f(2), f(-1)$ និង $f\left(\dfrac{1}{2}\right)$។

២. កំណត់អនុគមន៍ $f(x)$។

លំហាត់ទី ៦៤៨

កំណត់គ្រប់គូនៃចំនួនគត់ $(x,y)$ ដើម្បីឱ្យកន្សោម $\left(x^2+3y^2\right)\cdot 2^{\left(1-x^2-y^2\right)}$ មានតម្លៃអតិបរមា។ តើតម្លៃអតិបរមានោះគឺប៉ុន្មាន?

លំហាត់ទី ៦៤៩

ចំពោះចំនួនគត់វិជ្ជមាន $n$ ក្រាបនៃអនុគមន៍ប៉ារ៉ាបូល $y=\left(n^2+n\right)x^2-(2n+1)x+1$ កាត់អ័ក្សអាប់ស៊ីសត្រង់ពីរចំណុច $A_n$ និង $B_n$។ គណនា $\sum\limits_{n=1}^{2012}A_nB_n$។

លំហាត់ទី ៦៥០

គេឱ្យ $x,y,z$ ជាចំនួនពិតវិជ្ជមាន ។ ស្រាយបញ្ជាក់ថា

$$\frac{1}{x^2+yz}+\frac{1}{y^2+zx}+\frac{1}{z^2+xy}\leq\frac{1}{2}\left(\frac{1}{xy}+\frac{1}{yz}+\frac{1}{zx}\right)$$ ។

**លំហាត់ទី ៦៥១**

គេឱ្យស្វ៊ីត $\{x_n\}$ ជាស្វ៊ីតបង្រួម កំណត់ដោយ $\begin{cases}x_1=1,\ x_2=2012\\ x_{n+1}=\sqrt[3]{x_{n+1}^2\cdot x_n}\end{cases}$ ។

គណនា $\lim\limits_{x\to+\infty}x_n$ ។

**លំហាត់ទី ៦៥២**

$ABC$ ជាត្រីកោណកែងមានជ្រុង $AB=13,BC=15,AC=14$ ។ ចំណុច $D,E,F$ នៅលើជ្រុង $AB,BC,CA$ រៀងគ្នា ដែល $\frac{AD}{AB}=x,\ \frac{BE}{BC}=y,\ \frac{CF}{CA}=z$ និង $x+y+z=\frac{2}{3},x^2+y^2+z^2=\frac{2}{5}$ ។ គណនាផ្ទៃក្រឡាត្រីកោណ $DEF$ ។

**លំហាត់ទី ៦៥៣**

ឧបមាថា $x_k,y_k\ (k=1,2,3,\dots,2012)$ ជាចំនួនពិតវិជ្ជមាន និង $x_1+x_2+\dots+x_{2012}=y_1+y_2+\dots+y_{2012}=1$ ។ ស្រាយបញ្ជាក់ថា $\sum\limits_{k=1}^{2012}\frac{x_ky_k}{x_k+y_k}\leq\frac{1}{2}$ ។

**លំហាត់ទី ៦៥៤**

គេឱ្យ $P_n=\prod\limits_{k=0}^{n}\left[1-\left(\frac{1}{3}\right)^{3^k}+\left(\frac{1}{9}\right)^{3^k}\right]$ ។ គណនា $\lim\limits_{n\to+\infty}P_n$ ។

**លំហាត់ទី ៦៥៥**

រកតម្លៃតូចបំផុតនៃ $x$ ដែល $x$ និង $y$ ជាចំនួនគត់វិជ្ជមាន ហើយ $\frac{2011}{2012}<\frac{x}{y}<\frac{2012}{2013}$ ។

**លំហាត់ទី ៦៥៦**

សិស្សប្រុស និង សិស្សស្រីមួយក្រុមបានចូលរួមប្រកួត ញ៉ាំភីហ្សានៅផ្សារទំនើបមួយ។ គេដឹងថាក្នុងភីហ្សាមួយត្រូវគេកាត់ជា ១២ដុំតូចៗ។ សិស្សប្រុសម្នាក់អាចញ៉ាំអស់ ៦ឬ ៧ដុំ និង សិស្សស្រីម្នាក់អាចញ៉ាំអស់ ២ ឬ ៣ដុំ។ បើគេដាក់ភីហ្សា ៤ ឃើញថាមិនគ្រប់គ្រាន់ទេ តែបើគេដាក់ភីហ្សា ៥វិញនោះវាច្រើនពេក។ តើមានសិស្សប្រុស និង សិស្សស្រីប៉ុន្មាននាក់ដែលបានចូលរួមប្រកួត ។

**លំហាត់ទី ៦៥៧**

រកតម្លៃតូចបំផុត និង ធំបំផុតនៃអនុគមន៍ $f(x)=x\left(2011+\sqrt{2013-x^2}\right)$ ។

**លំហាត់ទី ៦៥៨**

គណនាផលបូក $S_{2012}=cosa+cos2a+cos3a+\cdots+cos2012a$ ។

លំហាត់ទី ៦៥៩

បង្ហាញថា $A = 6^{2012} + 13^{2012} - 2^{2012} - 17^{2012}$ ចែកដាច់នឹង 44 ។

លំហាត់ទី ៦៦០

ដោះស្រាយសមីការ $sin^2 x^2 + sin^2 2x^2 = sin^2 3x^2 + sin^2 4x^2$ ។

លំហាត់ទី ៦៦១

ប្រអប់មួយមានបាតជាចតុកោណកែងដែលមានអង្កត់ទ្រូងប្រវែង $D(a) = \dfrac{a^2 - \sqrt{a^4+4} + 2}{a}$ ដែល $a >$ ។ រកប្រវែងអតិបរមានៃអង្កត់ទ្រូងបាតប្រអប់។ លំហាត់ទី ៦៦២

រកដែនកំណត់នៃអនុគមន៍ $f(x) = ln(\sqrt{x-1} - \sqrt{7-x}) + \sqrt{cosx}$។

លំហាត់ទី ៦៦៣

ពហុធា $r(x) = x^5 - 5x^3 - 3x^2 + 2x + 1$ មានឫសប្រាំផ្សេងគ្នា $a_1, a_2, a_3, a_4, a_5$
ហើយ $s(x) = -x^2 + 5$ ជាពហុធាមួយផ្សេងទៀត។
គណនាផលគុណ $p = s(a_1)s(a_2)s(a_3)s(a_4)s(a_5)$ ។

លំហាត់ទី ៦៦៤

អនុគមន៍ $f$ កំណត់ដោយ $f(x) = \dfrac{a^x}{a^x + \sqrt{a}}$ ដែល $a$ ជាចំនួនពិតវិជ្ជមានហើយខុសពី 1 ។ គណនាផលបូក $S = f\left(\dfrac{1}{2012}\right) + f\left(\dfrac{2}{2012}\right) + \cdots + f\left(\dfrac{2011}{2012}\right)$ ។

## លំហាត់ទី ៤២៤

គេមានទំនាក់ទំនង $(3-2i)Z+(3+2i)\overline{Z}-12=0\ (I)$ ។
ក- បង្ហាញថាសំណុំចំណុច $M$ ក្នុងប្លង់កុំផ្លិច ដែលមានអាភិក $Z$ ផ្ទៀងផ្ទាត់ទំនាក់ទំនង $(I)$ គឺជាបន្ទាត់ $L$ មួយដែលគេត្រូវកំណត់ ។
ខ- $A$ និង $B$ គឺជាពីរចំណុចដែលមានអាភិករៀងគ្នា $3+5i$ និង $-3+i$ ។
បង្ហាញថា បន្ទាត់ $L$ ជាមេដ្យាទ័រនៃអង្កត់ $[AB]$ ។

## ដំណោះស្រាយ

ក- បង្ហាញថាសំណុំចំណុច $M$ ក្នុងប្លង់កុំផ្លិច ដែលមានអាភិក $Z$ ផ្ទៀងផ្ទាត់ទំនាក់ទំនង $(I)$ គឺជាបន្ទាត់ $L$ មួយដែលគេត្រូវកំណត់

•តាង $Z=x+iy$ នោះ $\overline{Z}=x-iy$

•ចំណុច $M$ មានអាភិក $Z \Rightarrow M(x,y)$

•ជំនួស$Z$ និង $\overline{Z}$ ចូលក្នុង $(I)$ យើងបាន

$(3-2i)(x+iy)+(3+2i)(x-iy)-12=0$

$3x+3yi-2xi-2yi^2+3x-3yi+2xi-2yi^2-12=0$

$6x+4y-12=0 \Rightarrow y=-\dfrac{3}{2}x+3$



ដូចនេះ សំណុំចំណុច $M$ ដែលមានអាភិក $Z$ គឺជាបន្ទាត់ $L: y=-\frac{3}{2}x+3$

ខ- បង្ហាញថា បន្ទាត់ $L$ ជាមេដ្យាទ័រនៃអង្កត់ $[AB]$

ចំណុច $A$ មានអាភិក $3+5i \Rightarrow A(3,5)$

ចំណុច $B$ មានអាភិក $-3+i \Rightarrow B(-3,1)$

តាង $I(a,b)$ ជាចំណុចកណ្តាលនៃអង្កត់ $[AB]$

គេបាន $a=\frac{x_A+x_B}{2}=\frac{3-3}{2}=0,\ b=\frac{y_A+y_B}{2}=\frac{5+1}{3}=3$

នាំឱ្យ $I(0,3)$

•រកសមីការបន្ទាត់ $AB:\ y=mx+n$

$A(3,5)\in AB \Rightarrow 3m+n=5 \quad (1)$

$B(-3,1)\in AB \Rightarrow -3m+n=1 \quad (2)$

យក $(1)+(2)$ អង្គនិងអង្គយើងបាន $2n=6$ ឬ $n=3$

នោះ $m=\frac{2}{3}$

$AB:\ y=\frac{2}{3}x+3$ មានមេគុណប្រាប់ទិស $m=\frac{2}{3}$

$L:\ y=-\frac{3}{2}x+3$ មានមេគុណប្រាប់ទិស $m'=-\frac{3}{2}$

$\Rightarrow m\cdot m'=-1$ គឺ $L\perp AB\ (II)$

យក $I(0,3)$ ជំនួសក្នុងសមីការបន្ទាត់ $L:\ 3=-\frac{3}{2}\times 0+3$ ពិត

នាំឱ្យ $I\in L \Rightarrow L\cap AB$ ត្រង់ចំណុចកណ្តាល $I\ (III)$

តាម $(II)$ និង $(III)$ គេបាន $L$ កែងនឹង $AB$ ត្រង់ចំណុចកណ្តាល $I$

ដូចនេះ បន្ទាត់ $L$ ជាមេដ្យាទ័រនៃអង្កត់ $[AB]$

## លំហាត់ទី ៤២៥

ពហុធា $f(z)=az^{2018}+bz^{2017}+cz^{2016}$ មានមេគុណជាចំនួនពិតមិនធំជាង 2019 និង $f\left(\frac{1+\sqrt{3}i}{2}\right)=2015+2019\sqrt{3}i$ ។ ចូររកសំណល់ពេលដែលគេចែក $f(1)$ និង 1000 ។

## ដំណោះស្រាយ

តាង $\omega=\frac{1+\sqrt{3}i}{2}$ នោះ $\omega=e^{\frac{i\pi}{3}}$ គឺជា Primitive 6th roots នៃចំនួនឯកតា

យើងបាន $f(\omega)=a\omega^{2018}+b\omega^{2017}+c\omega^{2016}$

$=a\omega^2+b\omega+c$

យើងចង់រក $f(1)=a+b+c$

- ពិនិត្យមើលផ្នែកពិតនៃចំនួនកុំផ្លិច

$Re(\omega^2)=-\frac{1}{2}$ នោះ $Re(\omega)=2$

នាំឱ្យ $-\frac{1}{2}a+\frac{1}{2}b+c=2015$

$\Leftrightarrow -a+b+2c=4030$

- ពិនិត្យមើលផ្នែកនិម្មិតនៃចំនួនកុំផ្លិច

យើងមាន $Im(\omega^2)=Im(\omega)=\frac{\sqrt{3}}{2}$ នោះ $\frac{\sqrt{3}}{2}(a+b)=2019\sqrt{3}$

$\Leftrightarrow a+b=4038$

ដោយ $a$ និង $b$ មិនធំជាង 2019 នោះយើងត្រូវយក $a=b=2019$

$\Rightarrow c=\frac{4030}{2}=2015$

$f(1)=4038+2015=6053$

គេបានសំណល់ពេលចែក $f(1)$ នឹង 1000 គឺ 53

**រឺសនៃឯកតា**

•(រឺសនៃឯកតា) គេអោយ $n\geq 2$ ជាចំនួនគត់ និងតាង $\zeta=e^{\frac{2\pi i}{n}}$ $=cos\left(\frac{2\pi}{n}\right)+isin\left(\frac{2\pi}{n}\right)$ ។ គេថា $1,\ \zeta,\ \zeta^2,\dots,\zeta^{n-1}$ ជារឺសទី $n$ នៃឯកតា ។

•បើ $\zeta$ ជារឺសទី $n$ នៃឯកតា នោះ $\zeta$ ផ្ទៀងផ្ទាត់ $\zeta^n-1=0$ ។ បើ $\zeta\neq 1$ គេបាន $1+\zeta+\zeta^2+\cdots+\zeta^{n-1}=0$ ។

•គេអោយ $\zeta=e^{\frac{2\pi}{n}}$ នោះ $x^n-1=(x-1)(x-\zeta)\left(x-\zeta^2\right)\cdots\left(x-\zeta^{n-1}\right)$ ។

## រឹសនៃឯកតា

•គេអោយ $\zeta = e^{\frac{2\pi i}{n}}$ នោះ $1+x+x^2+\cdots+x^{n-1}=(x-1)(x-\zeta)\left(x-\zeta^2\right)\cdots\left(x-\zeta^{n-1}\right)$ ។

•$1+\zeta^m+\zeta^{2m}+\cdots+\zeta^{(n-1)m}$ គឺ $n$ បើ $n|m$ និង 0 បើក្រៅពីនេះ ។ •( Primitive root of unity ) $\zeta$ ជា primitive nth root of unity បើវាជារឹសទី $n$ នៃឯកតា ហើយ $1,\ \zeta,\ \zeta^2,...,\zeta^{n-1}$ សុទ្ធតែខុសៗគ្នា ។

•( Primitive root of unity v2 ) $\zeta = e^{\frac{2\pi i k}{n}}$ ជា primitive nth root of unity លុះត្រាតែ $gcd(k,n)=1$ ។

•( ពហុធាស៊ីក្លូតូមីក, Cyclotomic polynomial ) ពហុធាស៊ីក្លូតូមីកលំដាប់ $n$, $\Phi_n(x)$ គឺជាពហុធាដែលគ្រប់រឹសរបស់វាគឺជា the nth primitive roots of unity ។

•( Cyclotomic Polynomial facts ) ពហុធាស៊ីក្លូតូមីកលំដាប់ $n$ គឺជាពហុធាមិនអាចសម្រួលបានតែមួយគត់ មានមេគុណជាចំនួនគត់ ជាតួចែកនៃ $x^n-1$ តែមិនមែនជាតួចែកនៃ $x^k-1$ ចំពោះគ្រប់ $k<n$ ។

•ពហុធាស៊ីក្លូតូមីកលំដាប់ $n$ គឺជាពហុធាមីនីម៉ាល់របស់ the nth primitive roots of unity, i.e ចំពោះគ្រប់ Primitive nth root $\zeta$, $\Phi_n(x)$ , គឺជាពហុធាម៉ូនិកមានមេគុណជាចំនួនគត់ដឺក្រេតូចបំផុត ហើយមាន $\zeta$ ជារឹស ។

•( Geometry ) រឹសនៃឯកតាបង្កើតបានជាកំពូលនៃពហុកោណនិយ័តនៅលើរង្វង់ឯកតាក្នុងប្លង់កុំផ្លិច ។ ការគុណចំនួនកុំផ្លិចដោយ $\zeta = e^{\frac{2\pi i}{n}}$ គឺជារង្វិលតាមមុំ $\frac{2\pi}{n}$ ជៀបនឹងគល់តំរុយ ។

$$A = \lim_{n\to+\infty}\left(1-\frac{1}{2}\right)\left(1+\frac{1}{2}\right)\left(1-\frac{1}{3}\right)\left(1+\frac{1}{3}\right)\cdots\left(1-\frac{1}{n}\right)\left(1+\frac{1}{n}\right)$$

$$= \lim_{n\to+\infty}\left[\frac{1}{2}\times\frac{3}{2}\times\frac{2}{3}\times\frac{4}{3}\times\cdots\times\left(\frac{n-1}{n}\right)\left(1+\frac{1}{n}\right)\right]$$

$$A = \lim_{n\to+\infty}\frac{1}{2}\left(1+\frac{1}{n}\right)$$

ដូចនេះ $A = \frac{1}{2}$

ខ. $B = \lim\limits_{n\to+\infty}\left(\frac{n}{\sqrt{n^4+1}} + \frac{n}{\sqrt{n^4+2}} + \cdots + \frac{n}{\sqrt{n^4+n}}\right)$

តាង $\sum = \frac{n}{\sqrt{n^4+1}} + \frac{n}{\sqrt{n^4+2}} + \cdots + \frac{n}{\sqrt{n^4+n}}$

ដោយ $\epsilon = \frac{n}{\sqrt{n^4+n}} + \frac{n}{\sqrt{n^4+n}} + \cdots + \frac{n}{\sqrt{n^4+n}}$ ជាផលបូក $n$ តួនៃ $\frac{n}{\sqrt{n^4+n}}$

និង $\delta = \frac{n}{\sqrt{n^4+1}} + \frac{n}{\sqrt{n^4+1}} + \cdots + \frac{n}{\sqrt{n^4+1}}$ ជាផលបូក $n$ តួនៃ $\frac{n}{\sqrt{n^4+1}}$

គេបាន $\epsilon < \sum < \delta$ ឬ $n \times \frac{n}{\sqrt{n^4+n}} < \sum < n \times \frac{n}{\sqrt{n^4+1}}$

$$\Rightarrow \frac{n^2}{\sqrt{n^4\left(1+\frac{1}{n^3}\right)}} < \sum < \frac{n^2}{\sqrt{n^4\left(1+\frac{1}{n^4}\right)}}$$

$$\Rightarrow \lim_{n\to+\infty} \frac{n^2}{n^2\sqrt{\left(1+\frac{1}{n^3}\right)}} < \lim_{n\to+\infty} \sum < \lim_{n\to+\infty} \frac{n^2}{n^2\sqrt{\left(1+\frac{1}{n^4}\right)}}$$

$$\Rightarrow \lim_{n\to+\infty} \frac{1}{\sqrt{\left(1+\frac{1}{n^3}\right)}} < \lim_{n\to+\infty} \sum < \lim_{n\to+\infty} \frac{1}{\sqrt{\left(1+\frac{1}{n^4}\right)}}$$

$$1 < \lim_{n\to+\infty} \sum < 1$$

ដូចនេះ $B = 1$

## លំហាត់ទី ៤៦២

គេអោយចតុកោណប៉ោង $ABCD$ ដែលមាន $O$ ជាចំណុចប្រសព្វរវាងអង្កត់ទ្រូងទាំងពីរ ។ ស្រាយបញ្ជាក់ថា $S_{OAB} \cdot S_{OCD} = S_{OBC} \cdot S_{OAD}$ ។

### ដំណោះស្រាយ




តាង $h$ ជាវង្វាស់កម្ពស់ដែលគូសចេញពីកំពូល $B$ មកលើ $AC$

ដោយ $h$ ជាកម្ពស់នៃត្រីកោណ $OAB$ និង $OBC$ យើងបាន

$S_{OAB}=\frac{1}{2}h\cdot OA$ និង $S_{OBC}=\frac{1}{2}h\cdot OC$

នោះ $\frac{S_{OAB}}{S_{OBC}}=\frac{OA}{OC}$

ស្រដៀងគ្នាដែរ គេបាន $\frac{S_{OAD}}{S_{OCD}}=\frac{AO}{OC}$

$\Rightarrow\frac{S_{OAB}}{S_{OBC}}=\frac{S_{OAD}}{S_{OCD}}$

$\Rightarrow S_{OAB}\cdot S_{OCD}=S_{OBC}\cdot S_{OAD}$ ពិត

## លំហាត់ទី ៤៦៣

ក. ស្រាយថា $a+b\ge 2\sqrt{ab}$ ចំពោះគ្រប់ចំនួនគត់វិជ្ជមាន $a$ និង $b$ ។ គណនា $A=\lim_{x\to 0}(e^x+x)^{\frac{1}{x}}$ រួចទាញថា $A^{a+b}\ge A^{2\sqrt{ab}}$ ។

ខ. ស្រាយថា $\frac{2}{e^2}\le\int_0^2 e^{x-x^2}dx\le 2\sqrt[4]{e}$ ។

### ដំណោះស្រាយ

ក. ស្រាយថា $a+b\ge 2\sqrt{ab}$ ចំពោះគ្រប់ចំនួនគត់វិជ្ជមាន $a$ និង $b$

ចំពោះ $a>0,b>0$ យើងមាន $(a-b)^2\ge 0$

$a^2-2ab+b^2\ge 0$

$a^2+2ab+b^2\ge 4ab$

$(a+b)^2\ge 2ab$

$\Leftrightarrow a+b\ge 2\sqrt{ab}$ ពិត

•គណនា $A=\lim_{x\to 0}(e^x+x)^{\frac{1}{x}}$ រួចទាញថា $A^{a+b}\ge A^{2\sqrt{ab}}$

តាង $y=(e^x+x)^{\frac{1}{x}}$ នោះ $lny=\frac{1}{x}(e^x+x)$

$$\lim_{x\to 0}lny=\lim_{x\to 0}\frac{1}{x}ln(e^x+x)=\lim_{x\to 0}\frac{[ln(e^x+x)]'}{x'}=\lim_{x\to 0}\frac{\frac{e^x+1}{e^x+x}}{1}=2$$

ដូចនេះ $A=e^2$

យើងមាន $a+b\ge 2\sqrt{ab}$ ( សម្រាយខាងលើ ) និង $A=e^2>1$

តាមលក្ខណៈអនុគមន៍អ៊ិចស្ប៉ូណង់ស្យែល យើងបាន $A^{a+b}\ge A^{2\sqrt{ab}}$ ពិត

ខ. ស្រាយថា $\frac{2}{e^2} \le \int_0^2 e^{x-x^2}dx \le 2\sqrt[4]{e}$

យើងមាន $y = x - x^2$ ដែល $x \in [0;2]$

$y' = 1-2x$

$y' = 0$ កាលណា $1-2x=0$ ឬ $x = \frac{1}{2}$

| $x$ | $0$ | $\frac{1}{2}$ | $2$ |
|---|---|---|---|
| $fx$ | $+$ | $0$ | $-$ |
| $f(x)$ | $0$ ↗ | $\frac{1}{4}$ | ↘ $-2$ |

តាមតារាងអថេរភាព $-2 \le x - x^2 \le \frac{1}{4}$ ចំពោះ $x \in [0;2]$

$\Rightarrow e^{-2} \le e^{x-x^2} \le e^{\frac{1}{4}}$

$\Rightarrow \frac{1}{e^2} \le e^{x-x^2} \le \sqrt[4]{e}$

$\Rightarrow \int_0^2 \frac{1}{e^2}dx \le \int_0^2 e^{x-x^2} \le \int_0^2 \sqrt[4]{e}dx$

$\Leftrightarrow \left[\frac{x}{e^2}\right]_0^2 \le \int_0^2 e^{x-x^2}dx \le \left[\sqrt[4]{e}x\right]_0^2$

$\Leftrightarrow \frac{1}{e^2}(2-0) \le \int_0^2 e^{x-x^2}dx \le \sqrt[4]{e}(2-0)$

ដូចនេះ $\frac{2}{e^2} \le \int_0^2 e^{x-x^2}dx \le 2\sqrt[4]{e}$ ពិត

## លំហាត់ទី ៩៦៩

តាង $u_0, u_1, u_2, ..., u_n$ ជាស្វ៊ីតនៃចំនួនពិតដែលបំពេញទំនាក់ទំនង

$(3-u_{n+1})(6+u_n) = 18$ និង $u_0 = 3$ ។ គណនា $\sum_{k=0}^{2011} \frac{1}{u_k}$ ។

## ដំណោះស្រាយ

សម្មតិកម្ម $u_0, u_1, u_2, ..., u_n$ ជាស្វ៊ីតនៃចំនួនពិត

$$\begin{cases} u_0 = 3 \\ (3-u_{n+1})(6+u_n)=18 \end{cases}$$

យើងមាន $(3-u_{n+1})(6+u_n)=18$

$3u_n - 6u_{n+1} - u_{n+1}\cdot u_n = 0$

ចែកអង្គនឹង $u_{n+1}\cdot u_n$

$\Rightarrow \dfrac{3}{u_{n+1}} - \dfrac{6}{u_n} - 1 = 0 \ (1)$

តាង $v_n = \dfrac{1}{u_n}$ នោះ $v_{n+1} = \dfrac{1}{u_{n+1}}$

$(1) \Rightarrow 3v_{n+1} - 6v_n - 1 = 0$

$$v_{n+1} = 2v_n + \frac{1}{3}$$

$$v_{n+1} + \frac{1}{3} = 2\left(v_n + \frac{1}{3}\right)$$

តាង $a_n = v_n + \dfrac{1}{3} \Rightarrow a_{n+1} = 2a_n$

$\Rightarrow (a_n)$ ជាស្វ៊ីតធរណីមាត្រមានរេសុង $q=2$ និងតួទី1 $a_0 = v_0 + \dfrac{1}{3} = \dfrac{1}{u_0} + \dfrac{1}{3} = \dfrac{2}{3}$

$\Rightarrow a_n = a_0\cdot q^n = \dfrac{2}{3}\cdot 2^n$

គេបាន $v_n = \dfrac{1}{3}\cdot 2^{n+1} - \dfrac{1}{3}$

$$= \frac{1}{3}\left(2^{n+1}-1\right)$$

$$\sum_{k=0}^{2011}\frac{1}{u_k} = \sum_{k=0}^{2011} v_k$$

$$= \sum_{k=0}^{2011}\frac{1}{3}\left(2^{n+1}-1\right)$$

$$\sum_{k=0}^{2011}\frac{1}{u_k} = \frac{1}{3}\left(2+2^2+\cdots+2^{2012}-2012\right)$$

$$= \frac{1}{3}\left(2\cdot\frac{2^{2012}-1}{2-1} - 2012\right)$$

$$= \frac{1}{3}\left(2^{2013}-2014\right)$$

ដូចនេះ $\sum_{k=0}^{2011}\frac{1}{u_k}=\frac{1}{3}(2^{2013}-2014)$

## លំហាត់ទី ៤៦៥

គេឱ្យ $sinx+siny+sinz=0$ ។ កំណត់តម្លៃអតិបរមា និង អប្បបរមានៃកន្សោម $M=sin^2x+sin^4y+sin^6z$ ។

### ដំណោះស្រាយ

$\forall x,y,z\in\mathbb{R}$ យើងបាន $\begin{cases}0\le sin^2x\le 1 & (1)\\ 0\le sin^4y\le sin^2y\le 1 & (2)\\ 0\le sin^6z\le sin^4z\le sin^2z\le 1 & (3)\end{cases}$

យក $(1)+(2)+(3)$ យើងបាន

$0\le sin^2x+sin^4y+sin^6z\le 1+sin^2y+sin^4z\le 1+sin^2y+sin^2z\ (4)$

តែតាមសម្មតិកម្ម $sinx+siny+sinz=0$

$\Rightarrow siny+sinz=-sinx$

$\Rightarrow sin^2y+2sinysinz+sin^2z=sin^2x$

$\Rightarrow sin^2y+sin^2z=sin^2x-2sinxysiny$

តាម $(4)\Rightarrow 0\le sin^2x+sin^4y+sin^6z\le 1+sin^2x-2sinysinz\le 1+2sin^2x\le 2$

$0\le sin^2x+sin^4y+sin^6z\le 2$

ដូចនេះ $\text{Max}(M)=2$ និង $\text{min}(M)=0$

## លំហាត់ទី ៤៦៦

គណនា $I=\int_0^{\pi}e^{|cosx|}\left(2sin\left(\frac{1}{2}cosx\right)+3cosx\left(\frac{1}{2}cosx\right)sinx\right)dx$ ។

### ដំណោះស្រាយ

$$I=\int_0^{\pi}e^{|cosx|}\left(2sin\left(\frac{1}{2}cosx\right)+3cosx\left(\frac{1}{2}cosx\right)sinx\right)dx$$

$$=6\int_0^{\frac{\pi}{2}}e^{cosx}sinxcos\left(\frac{1}{2}cosx\right)dx$$

ព្រោះ $\int_0^{2a} f(x)dx = \begin{cases} 0 & \text{បើ } f(2a-x) = -f(x) \\ 2\int_0^{a} f(x)dx & \text{បើ } f(2a-x) = f(x) \end{cases}$

តាង $t = cosx$ នោះ $dt = -sinxdx$

| | | |
|---|---|---|
| $x$ | 0 | $\frac{\pi}{2}$ |
| $t$ | 1 | 0 |

$$I = 6\int_1^0 e^t cos\left(\frac{t}{2}\right)(-dt)$$

$$I = 6\int_0^1 e^t cos\left(\frac{t}{2}\right)dt$$

$$= \frac{2}{5}\left[e^t\left(sin\left(\frac{t}{2}\right) + 2cos\left(\frac{t}{2}\right)\right)\right]_0^1$$

$$= \frac{24}{5}\left(ecos\left(\frac{1}{2}\right) + \frac{e}{2}sin\left(\frac{1}{2}\right) - 1\right)$$

## លំហាត់ទី ៤៦៧

ពីរចំនួន $a$ និង $b$ ត្រូវបានជ្រើសរើសដោយចៃដន្យចេញពីសំណុំនៃចំនួនគត់ធម្មជាតិ $N = \{1,2,3,...,30\}$ ។ ប្រូបាបដែល $a^2 - b^2$ ចែកដាច់នឹង 3 ស្មើនឹង :

ក. $\frac{9}{87}$ ខ. $\frac{12}{87}$ គ. $\frac{15}{87}$ ឃ. $\frac{47}{87}$

## ដំណោះស្រាយ

ចំនួនរបៀបនៃការជ្រើសរើសពីរលេខចេញពី 1,2,3,..,30 គឺ $\binom{2}{30} = 435$

$a^2 - b^2$ ចែកដាច់នឹង 3 កាលណា $a,b$ សុទ្ធតែចែកដាច់នឹង 3 ឬ $a,b$ សុទ្ធតែមិនចែកដាច់នឹង 3

ចំនួនករណីស្របគឺ $\binom{2}{10} + \binom{2}{20} = 235$

ប្រូបាបគឺ $\frac{235}{435} = \frac{47}{87}$

ដូចនេះ ចម្លើយ ឃ.

## លំហាត់ទី ៤៦៨

ចូរកំណត់ចំនួនគត់វិជ្ជមាន $k$ តូចជាងគេ ដោយដឹងថាមានចំនួនគត់ $x_1, x_2, x_3, \ldots, x_k$ ដែល $x_1^3 + x_2^3 + x_3^3 + \cdots + x_k^3 = 2002^{2002}$ ។

### ដំណោះស្រាយ

យើងនិងបង្ហាញថា $2002^{2002}$ មិនអាចសរសេរជាផលបូកនៃបីគូបប្រាកដទេ

យើងមាន $2002 \equiv 4 \pmod 9$ នោះ $2002^3 \equiv 4^3 \equiv 1 \pmod 9$

គេបាន $2002^{2002} = \left(2002^3\right)^{667} \cdot 2002 \equiv 4 \pmod 9$

ម្យ៉ាងទៀត $x^3 \equiv 0, \pm 1 \pmod 9$ ចំពោះគ្រប់ចំនួនគត់ $x$

នោះ $x_1^3 + x_2^3 + x_3^3$ ចែកនឹង 9 មិនអាចមានសំណល់ 4 ទេ

ដូចនេះ $2002^{2002}$ មិនអាចជាផលបូកនៃបីគូបប្រាកដទេ

តែយើងនិងបង្ហាញថា $2002^{2002}$ អាចសរសេរជាផលបូកនៃបួនគូបប្រាកដបាន

យើងមាន $2002 = 1000 + 1000 + 1 + 1 = 10^3 + 10^3 + 1^3 + 1^3$

$$2002^{2002} = 2002^{2001} \cdot 2002 = \left(2002^{667}\right)^3 \cdot \left(10^3 + 10^3 + 1^3 + 1^3\right)$$

$$= \left(2002^{667} \cdot 10\right)^3 + \left(2002^{667} \cdot 10^3\right) + \left(2002^{667}\right)^3 + \left(2002^{667}\right)^3$$

នោះ $2002^{2002}$ អាចសរសេរជាផលបូកនៃបួនគូបប្រាកដបាន

ដូចនេះ ចំនួនគត់តូចបំផុតគឺ $k = 4$

## លំហាត់ទី ៤៦៩

គេឱ្យស្វ៊ីតចំនួនពិត $(u_n)_{n\in\mathbb{N}}$ ដោយ $u_n = \dfrac{1}{2!} + \dfrac{1}{3!} + \cdots + \dfrac{k}{(k+1)!}$, $k \in \mathbb{N}$ ។

គណនា $\lim\limits_{n\to+\infty} \sqrt[n]{u_1^n + u_2^n + \cdots + u_{2013}^n}$ ។

### ដំណោះស្រាយ

ប្រៀបធៀប $u_{n+1}$ និង $u_n$

$u_{n+1} - u_n = \dfrac{k+1}{(k+2)!} > 0$ នោះ $u_{n+1} > u_n$, $\forall k \in \mathbb{N}$

$$\Rightarrow u_{2013}^n < u_1^n + u_2^n + \cdots + u_{2013}^n < 2013 \cdot u_{2013}^n$$

$$\Rightarrow u_{2013} < \sqrt[n]{u_1^n + u_2^n + \cdots + u_{2013}^n} < \sqrt[n]{2013} \cdot u_{2013}$$

$$\Rightarrow \lim_{n\to+\infty} u_{2013} < \lim_{n\to+\infty} \sqrt[n]{u_1^n + u_2^n + \cdots + u_{2013}^n} < \lim_{n\to+\infty} \sqrt[n]{2013} \cdot u_{2013}$$

$$\Rightarrow \lim_{n\to+\infty} u_{2013} < \lim_{n\to+\infty} \sqrt[n]{u_1^n+u_2^n+\cdots+u_{2013}^n} < \lim_{n\to+\infty} 2013^{\frac{1}{n}}\cdot u_{2013}$$

$$\Rightarrow \lim_{n\to+\infty} \sqrt[n]{u_1^n+u_2^n+\cdots+u_{2013}^n} = u_{2013}\ (1)$$

រក $u_{2013}$

យើងមាន $\dfrac{k}{(k+1)!}=\dfrac{k+1}{k!(k+1)}-\dfrac{1}{(k+1)!}=\dfrac{1}{k!}-\dfrac{1}{(k+1)!}$

$$\Rightarrow u_{2013}=\left(\frac{1}{1!}-\frac{1}{2!}\right)+\left(\frac{1}{2!}-\frac{1}{3!}\right)+\cdots+\left(\frac{1}{2012!}-\frac{1}{2013!}\right)$$

$$u_{2013}=1-\frac{1}{2013!}\ (2)$$

តាម (1) និង (2) : $\lim\limits_{n\to+\infty} \sqrt[n]{u_1^n+u_2^n+\cdots+u_{2013}^n}=1-\dfrac{1}{2013!}$

ដូចនេះ $\lim\limits_{n\to+\infty} \sqrt[n]{u_1^n+u_2^n+\cdots+u_{2013}^n}=1-\dfrac{1}{2013!}$

## លំហាត់ទី ៤៧០

គេឱ្យ $a,b$ និង $c$ ជាចំនួនពិតវិជ្ជមានដែល $a+b+c=1$ ។ បង្ហាញថា $\left(\dfrac{1}{a}+\dfrac{1}{bc}\right)\left(\dfrac{1}{b}+\dfrac{1}{ca}\right)\left(\dfrac{1}{c}+\dfrac{1}{ab}\right)\geq 1728$ ។

### ដំណោះស្រាយ

តាមវិសមភាព AM-GM យើងបាន

$$\frac{1}{a}+\frac{1}{bc}=\frac{1}{a}+\frac{1}{3bc}+\frac{1}{3bc}+\frac{1}{3bc}\geq 4\cdot\frac{1}{\sqrt[4]{27ab^3c^3}}$$

$$\left(\frac{1}{a}+\frac{1}{bc}\right)\left(\frac{1}{b}+\frac{1}{ca}\right)\left(\frac{1}{c}+\frac{1}{ab}\right)\geq 4\cdot\frac{1}{\sqrt[4]{27ab^3c^3}}\cdot 4\cdot\frac{1}{\sqrt[4]{27ba^3c^3}}\cdot 4\cdot\frac{1}{\sqrt[4]{27ca^3b^3}}$$

$$\left(\frac{1}{a}+\frac{1}{bc}\right)\left(\frac{1}{b}+\frac{1}{ca}\right)\left(\frac{1}{c}+\frac{1}{ab}\right)\geq=\frac{64}{\sqrt[4]{3^9(abc)^7}}\ (1)$$

តែ $\dfrac{1}{27}=\left(\dfrac{a+b+c}{3}\right)^3\geq abc\ (2)$

តាម (1) និង (2) យើងបាន

$$\left(\frac{1}{a}+\frac{1}{bc}\right)\left(\frac{1}{b}+\frac{1}{ca}\right)\left(\frac{1}{c}+\frac{1}{ab}\right)\geq\frac{64}{\sqrt[4]{3^9\left(3^{-3}\right)^7}}=64\sqrt[4]{3^{12}}$$

$$\left(\frac{1}{a}+\frac{1}{bc}\right)\left(\frac{1}{b}+\frac{1}{ca}\right)\left(\frac{1}{c}+\frac{1}{ab}\right)\geq 1728 \text{ ពិត}$$

## លំហាត់ទី ៤៧១

គណនាដេរីវេទី $n$ នៃអនុគមន៍ $y = cosx + sinx$ ជាអនុគមន៍នៃ $n$ ។ រកតម្លៃ $x$ ជាអនុគមន៍នៃ $n$ ដើម្បីអោយ $y^{(n)} = 0$ និងអនុវត្តចំពោះ $n = 2013$ ។

### ដំណោះស្រាយ

យក $y_1 = cosx \Rightarrow y_1' = -sinx = cos\left(\frac{1\cdot\pi}{2} + x\right)$

$$\Rightarrow y_1'' = (-sinx)' = -cosx = cos\left(\frac{2\cdot\pi}{2} + x\right)$$

$$\Rightarrow y_1''' = (-cosx)' = sinx = cos\left(\frac{3\cdot\pi}{2} + x\right)$$

..............................................

តាមគំរូយើងទាញបាន $y_1^{(n)} = cos\left(\frac{n\cdot\pi}{2} + x\right)$

យក $y_2 = sinx \Rightarrow y_2' = cosx = sin\left(\frac{1\cdot\pi}{2} + x\right)$

$$\Rightarrow y_2'' = (cosx)' = -sinx = sin\left(\frac{2\cdot\pi}{2} + x\right)$$

$$\Rightarrow y_2''' = (-sinx)' = -cosx = sin\left(\frac{3\cdot\pi}{2} + x\right)$$

$$\Rightarrow y^{(4)} = (-cosx)' = sinx = sin\left(\frac{4\cdot\pi}{2} + x\right)$$

.....................................

តាមគំរូយើងទាញបាន $y_2^{(n)} = sin\left(\frac{n\cdot\pi}{2} + x\right)$

ដូចនេះ $y^{(n)} = y_1^{(n)} + y_2^{(n)} = cos\left(\frac{n\cdot\pi}{2} + x\right) + sin\left(\frac{n\cdot\pi}{2} + x\right)$

•រកតម្លៃ $x$ ជាអនុគមន៍នៃ $n$ ដើម្បីអោយ $y^{(n)} = 0$ និងអនុវត្តចំពោះ $n = 2013$

យើងមាន $y^{(n)} = cos\left(\frac{n\cdot\pi}{2} + x\right) + sin\left(\frac{n\cdot\pi}{2} + x\right)$

$y^{(n)} = 0$ នោះ $cos\left(\frac{n\cdot\pi}{2} + x\right) + sin\left(\frac{n\cdot\pi}{2} + x\right) = 0$

$\Rightarrow tan\left(\frac{n\pi}{2} + x\right) = -1 = tan\left(-\frac{\pi}{4}\right)$

$\Rightarrow \frac{n\pi}{2} + x = -\frac{\pi}{4} + k\pi,\ k \in \mathbb{Z} \Rightarrow x = -\left(\frac{n\pi}{2} + \frac{\pi}{4}\right) + k\pi$

ដូចនេះ $x=-\dfrac{(2n+1)\pi}{4}+k\pi,\ k\in\mathbb{Z}$

អនុវត្តចំពោះ $n=2013$

យើងមាន $tan\left(\dfrac{n\pi}{2}+x\right)=-1=tan\left(-\dfrac{\pi}{4}\right)$

$\Rightarrow tan\left(\dfrac{2013\pi}{2}+x\right)=tan\left(-\dfrac{\pi}{4}\right)$

$\Rightarrow tan\left(1006\pi+\dfrac{\pi}{2}+x\right)=tan\left(-\dfrac{\pi}{4}\right)$

$\Rightarrow tan\left(\dfrac{\pi}{2}+x\right)=tan\left(-\dfrac{\pi}{4}\right)$

$\Rightarrow \dfrac{\pi}{2}+x=-\dfrac{\pi}{4}+k\pi,\ k\in\mathbb{Z}$

$\Rightarrow x=-\dfrac{\pi}{2}-\dfrac{\pi}{4}+k\pi$

ដូចនេះ $x=-\dfrac{3\pi}{4}+k\pi,\ k\in\mathbb{Z}$

របៀបទី ២

$x=-\dfrac{(2n+1)\pi}{4}+k\pi,\ k\in\mathbb{Z}$ នោះ $x=-\dfrac{(2013\times2+1)\pi}{4}+k\pi$

$x=-\dfrac{4027\pi}{4}+k\pi$ ឬ $x=-\left(1006\pi+\dfrac{3\pi}{4}\right)+k\pi$

$\Rightarrow x=-\dfrac{3\pi}{4}+k\pi$ ព្រោះ $tan\left(1006\pi+\dfrac{3\pi}{4}\right)=tan\dfrac{3\pi}{4}$

## លំហាត់ទី ៤៧២

ក. ស្រាយបញ្ជាក់ថា ចំពោះគ្រប់ចំនួនពិតវិជ្ជមាន $a,b,c$ គេបាន

$$\sqrt[3]{(x+a)(y+b)(z+c)}\geq\sqrt[3]{xyz}+\sqrt[3]{abc}\ ។$$

ខ. ស្រាយថា $\dfrac{(2a+b+c)^2}{2a^2+(b+c)^2}+\dfrac{(2b+c+a)^2}{2b^2+(c+a)^2}+\dfrac{2c+a+b}{2c^2+(a+b)^2}\leq 8$

ចំពោះគ្រប់ចំនួនពិតវិជ្ជមាន $a,b,c$ ។

## ដំណោះស្រាយ

ក. ស្រាយបញ្ជាក់ថា ចំពោះគ្រប់ចំនួនពិតវិជ្ជមាន $a,b,c$ គេបាន

$$\sqrt[3]{(x+a)(y+b)(z+c)}\geq\sqrt[3]{xyz}+\sqrt[3]{abc}$$

យើងមាន $(x+a)(y+b)(z+c)=xyz+ayz+bxz+cxy+abz+acy+bcx+abc$

តាមវិសមភាព AM-GM យើងបាន

$ayz+bxz+cxy\geq 3\sqrt[3]{abcx^2y^2z^2}$ (1)

និង $abz+acy+bcx\geq 3\sqrt[3]{a^2b^2c^2xyz}$ (2)

យក (1)+(2) យើងបាន

$(x+a)(y+b)(z+c)\geq xyz+abc+\sqrt[3]{abcx^2y^2z^2}+\sqrt[3]{a^2b^2c^2xyz}$

$(x+a)(y+b)(z+c)\geq\left(\sqrt[3]{abc}+\sqrt[3]{xyz}\right)^3$

ដូចនេះ $\sqrt[3]{(x+a)(y+b)(z+c)}\geq\sqrt[3]{xyz}+\sqrt[3]{abc}$

ខ. ស្រាយថា $\dfrac{(2a+b+c)^2}{2a^2+(b+c)^2}+\dfrac{(2b+c+a)^2}{2b^2+(c+a)^2}+\dfrac{2c+a+b}{2c^2+(a+b)^2}\leq 8$

ចំពោះគ្រប់ចំនួនពិតវិជ្ជមាន $a,b,c$

តាង $T=\dfrac{(2a+b+c)^2}{2a^2+(b+c)^2}+\dfrac{(2b+c+a)^2}{2b^2+(c+a)^2}+\dfrac{2c+a+b}{2c^2+(a+b)^2}$

យក $S=a+b+c$ នោះយើងទាញបានថា

$T=\dfrac{(a+S)^2}{2a^2+(a-S)^2}+\dfrac{(b+S)^2}{2b^2+(b-S)^2}+\dfrac{2}{2c^2+(c-S)^2}$

យើងមាន $\dfrac{(a+S)^2}{2a^2+(a-S)^2}=\dfrac{a^2+2aS+S^2}{3a^2-2aS+S^2}$

$=\dfrac{1}{3}\times\dfrac{3a^2+6aS+3S^2}{3a^2-6aS+S^2}=\dfrac{1}{3}\left(1+\dfrac{8aS+2S^2}{3a^2-6aS+S^2}\right)$

$=\dfrac{1}{3}+\dfrac{8aS+2S^2}{(3a-S)^2+2S^2}$

ដោយ $(3a-S)^2\geq 0$ នោះ $(3a-S)^2+2S^2\geq 2S^2$

នោះ $\dfrac{8aS+2S^2}{(3a-S)^2+2S^2}\leq\dfrac{8aS+2S^2}{2S^2}=1+\dfrac{4a}{S}=1+\dfrac{4a}{a+b+c}$

យើងទាញបាន $\dfrac{8aS+2S^2}{(3a-S)^2+2S^2}\leq\dfrac{4}{3}+\dfrac{4a}{a+b+c}$

ដូចគ្នាដែរ $\dfrac{(b+S)^2}{2b^2+(b-S)^2}\leq\dfrac{4}{3}+\dfrac{4b}{a+b+c}$, $\dfrac{(c+S)^2}{2c^2+(c-S)^2}\leq\dfrac{4}{3}+\dfrac{4c}{a+b+c}$

សរុបមក $T\leq\dfrac{4}{3}+\dfrac{4a}{a+b+c}+\dfrac{4}{3}+\dfrac{4b}{a+b+c}+\dfrac{4}{3}+\dfrac{4c}{a+b+c}$

$T\leq 8$ ពិត

ដូចនេះ $\dfrac{(2a+b+c)^2}{2a^2+(b+c)^2}+\dfrac{(2b+c+a)^2}{2b^2+(c+a)^2}+\dfrac{2c+a+b}{2c^2+(a+b)^2}\leq 8$

ចំពោះគ្រប់ចំនួនពិតវិជ្ជមាន $a,b,c$

## លំហាត់ទី ៤៧៣

ដោះស្រាយសមីការឌីផេរ៉ង់ស្យែល $y''-4y'+8y=e^{2x}+cos2x$ ។

### ដំណោះស្រាយ

•សមីការសំគាល់ $\lambda^2-4\lambda+8=0$

មាន $\Delta'=(-2)^2-1\times8=-4=(2i)^2$

$\lambda=\dfrac{-(-2)\pm\sqrt{(2i)^2}}{1}=2\pm2i$ នោះ $\alpha=2,\beta=2$

ចម្លើយទូទៅនៃសមីការអូម៉ូហ្សែន $y''-4y'+8=0$ គឺ $y_c=(Acos\beta x+Bsin\beta x)e^{\alpha x}$

នោះ $y_c=(Acos2x+Bsin2x)e^{2x},\ A,B\in\mathbb{R}$

•តាង $y_1=Ce^{2x}$ ជាចម្លើយពិសេសនៃសមីការ $y''-4y'+8y=e^{2x}$ (1)

$\Rightarrow y_1^{'}=2Ce^{2x},\ y_1^{''}=4Ce^{2x}$

យក $y_1,y_1^{'},y_1^{''}$ ជំនួសចូល (1)

$4Ce^{2x}-4\left(2Ce^{2x}\right)+8Ce^{2x}=e^{2x}$

នាំអោយ $C=\dfrac{1}{4}$ ហើយ $y_1=\dfrac{1}{4}e^{2x}$

•តាង $y_2=Dcos2x+Esin2x$ ជាចម្លើយពិសេសនៃ $y''-4y'+8y=sin2x$ (2)

$\Rightarrow y_2^{'}=-2Dsin2x+2Ecos2x,\ y_2^{''}=-4Dcos2x-4Esin2x$

យក $y_2.y_2^{'},y_2^{''}$ ជំនួសចូល (2)

$-4Dcos2x-4Esin2x-4(-2Dsin2x+2Ecos2x)+Dcos2x+Esin2x=sinx$

$(4D-8E)cos2x+(4E+8D)sin2x=sin2x$

យើងទាញបាន $\begin{cases}4D-8E=0\\8D+4E=1\end{cases}$

នាំអោយ $D=\dfrac{1}{10},\ E=\dfrac{1}{20}$

គេបាន $y_2=\dfrac{1}{10}cos2x+\dfrac{1}{20}sin2x$

$y_p=y_1+y_2=\dfrac{1}{4}e^{2x}+\dfrac{1}{10}cos2x+\dfrac{1}{20}sin2x$

ចម្លើយទូទៅនៃសមីការឌីផេរ៉ង់ស្យែលគឺ $y=y_c+y_p$

ដូចនេះ $y=(Acos2x+Bsin2x)e^{2x}+\dfrac{1}{4}e^{2x}+\dfrac{1}{10}cos2x+\dfrac{1}{20}sin2x$

## លំហាត់ទី ៤៧៤

ក្នុងចតុមុខ $OABC$ យក $E$ ជាចំណុចកណ្ដាលនៃទ្រនុង $AB$ ហើយ $F$និង $P$ ចែកក្នុង $OC$ និង $OA$ តាមផលធៀប $\frac{FO}{FC}=\frac{2}{1}$ និង $\frac{PO}{PA}=\frac{1}{2}$ ។ យក $Q$ នៅលើទ្រនុង $BC$ ដែល $\overrightarrow{BQ}=t\overrightarrow{BC}$ ។ បើ $PQ$ ប្រសព្វ $EF$ ត្រង់ចំណុច $M$ ។ បង្ហាញថា $\overrightarrow{OM}=k\overrightarrow{OE}+(1-k)\overrightarrow{OF},(0<k<1)$ និង $\overrightarrow{OM}=m\overrightarrow{OP}+(1-m)\overrightarrow{OQ},(0<m<1)$ រួចកំណត់តម្លៃ $t$ ។

## ដំណោះស្រាយ




យើងមាន $PQ\cap EF=\{M\}$ នោះ

$$\begin{cases} M\in EF \\ M\in PQ \end{cases}$$

$$\overrightarrow{OM}=\overrightarrow{OF}+\overrightarrow{FM}=k\overrightarrow{FE}+\overrightarrow{OF},(0<k<1)$$
$$=k\left(\overrightarrow{OE}-\overrightarrow{OF}\right)+\overrightarrow{OF}$$
$$=k\overrightarrow{OE}-k\overrightarrow{OF}+\overrightarrow{OF}$$

ដូចនេះ $\overrightarrow{OM}=k\overrightarrow{OE}+(1-k)\overrightarrow{OF},(0<k<1)$

ម្យ៉ាងទៀត $\overrightarrow{OM}=\overrightarrow{OQ}+\overrightarrow{QM}$

$$\overrightarrow{OM}=\overrightarrow{OQ}+m\overrightarrow{QP}$$
$$=\overrightarrow{OQ}+m\left(\overrightarrow{OP}-\overrightarrow{OQ}\right)$$
$$=OQ+m\overrightarrow{OP}-m\overrightarrow{OQ}$$

ដូចនេះ $\overrightarrow{OM}=m\overrightarrow{OP}+(1-m)\overrightarrow{OQ},(0<m<1)$

•កំណត់តម្លៃ $t$

តាង $\overrightarrow{OA}=\overrightarrow{a}$, $\overrightarrow{OB}=\overrightarrow{b}$, $\overrightarrow{OC}=\overrightarrow{c}$ នោះ $\overrightarrow{OE}=\frac{1}{2}\overrightarrow{a}+\frac{1}{2}\overrightarrow{b}$

ដោយ $\frac{FO}{FC}=\frac{2}{1}\Rightarrow\overrightarrow{OF}=\frac{2}{3}\overrightarrow{c}$ និង $\frac{PO}{PA}=\frac{1}{2}\Rightarrow\overrightarrow{OP}=\frac{1}{3}\overrightarrow{a}$

ហើយ $\overrightarrow{OQ}=\overrightarrow{OB}+\overrightarrow{BQ}=\overrightarrow{b}+t\overrightarrow{BC}=\overrightarrow{b}+t\left(\overrightarrow{OC}-\overrightarrow{OB}\right)$

$$\overrightarrow{OQ}=\overrightarrow{b}+t\overrightarrow{c}-t\overrightarrow{b}=(1-t)\overrightarrow{b}+t\overrightarrow{c}$$

យើងបាន $\overrightarrow{OM} = k\overrightarrow{OE} + (1-k)\overrightarrow{OF} = \frac{k}{2}\vec{a} + \frac{k}{2}\vec{b} + \frac{2}{3}(1-k)\vec{c}$ (1)

និង $\overrightarrow{OM} = m\overrightarrow{OP} + (1-m)\overrightarrow{OQ} = \frac{m}{3}\vec{a} + (1-m)(1-t)\vec{b} + (1-m)t\vec{c}$ (2)

ផ្ទឹម (1) និង (2) យើងបាន

$$\begin{cases} \frac{k}{2} = \frac{m}{3} & (3) \\ \frac{k}{2} = (1-m)(1-t) & (4) \\ \frac{2}{3}(1-k) = (1-m)t & (5) \end{cases}$$

តាម (3) និង (4) គេបាន $\frac{m}{2} = 1 - t - m + mt \Rightarrow m = \frac{3-3t}{4-3t}$

តាម (5) យើងបាន $\frac{2}{3} - \frac{2}{3}\cdot\frac{2}{3}m = \left(1 - \frac{3-3t}{4-3t}\right)t$

$6 - 4\left(\frac{3-3t}{4-3t}\right) = 9\left(\frac{4-3t-3+3t}{4-3t}\right)t$

$24 - 18t - 12 + 12t = 9t$

$-15t = -12$ នោះ $t = \frac{12}{15}$

ដូចនេះ: $t = \frac{4}{5}$

## លំហាត់ទី ៤៧៥

គូប $ABCDEFGH$ មួយមានរង្វាស់ជ្រុង $a$ ។ $I$ ជាចំណុចកណ្តាលនៃ $AB$ ហើយ $J$ ជាចំណុចកណ្តាលនៃ $EH$ ។ រករង្វាស់ខ្លីបំផុតពី $I$ ទៅ $J$ តាមមុខខាងនៃគូប ។

## ដំណោះស្រាយ




ផ្លូវធ្វើដំណើរពី $I$ ទៅ $J$ កាត់តាមមុខខាងនៃគូបមានពីរគឺ $IMJ < IKLNJ$ (មើលរូបភាពជាក់ស្តែង)

ដូចនេះ យើងជ្រើសរើសយកផ្លូវ $IMJ = IM + MJ$

តាង $AM = x$ ដែល $0 < x < a \Rightarrow ME = a - x$

$IM^2 = \frac{a^2}{4} + x^2$ នោះ $IM = \sqrt{\frac{a^2}{4} + x^2}$

$MJ^2 = \frac{a^2}{4} + (a-x)^2$ នោះ $MJ = \sqrt{\frac{a^2}{4} + (a-x)^2}$

យើងយក $l(x) = IM + MJ$

$$l(x) = \sqrt{\frac{a^2}{4} + x^2} + \sqrt{\frac{a^2}{4} + (a-x)^2}$$

ដេរីវេ $l'(x) = \frac{2x}{\sqrt{4x^2 + a^2}} + \frac{2a - 2x}{\sqrt{4x^2 - 8ax + 5a^2}}$

$l'(x) = 0$ កាលណា$8a^3x = 4a^4$ ឬ $x = \frac{a}{2}$

តារាងអថេរភាព

| $x$ | $0$ | | $\frac{a}{2}$ | | $a$ |
|---|---|---|---|---|---|
| $l(x)$ | | $-$ | $0$ | $+$ | |
| $l(x)$ | | ↘ | អប្បបរមា | ↗ | |

$l(x)$ ខ្លីបំផុត ចំពោះ $x = \frac{a}{2}$

រង្វាស់ខ្លីបំផុតពី $I$ ទៅ $J$ គឺ $l\left(\frac{a}{2}\right) = a\sqrt{2}$ ឯកតាប្រវែង

## លំហាត់ទី ៤៧៦

ស្រាយបញ្ជាក់ថា លក្ខខណ្ឌចាំបាច់ និងគ្រប់គ្រាន់ដើម្បីអោយត្រីកោណ $ABC$ កែងត្រង់ $A$ គឺ $\frac{sinB + sinC}{cosB + cosC} = sinA$ ។

## ដំណោះស្រាយ

•លក្ខខណ្ឌចាំបាច់

សម្មតិកម្ម $\triangle ABC$ កែងត្រង់ $A$

ស្រាយថា $\frac{sinB+sinC}{cosB+cosC}=sinA$

គេមាន $\angle A=90^0$ នោះ $sinA=1$

បើ $\angle A=90^0$ នោះ $\angle B+\angle C=90^0$

$\Rightarrow sinB=cosC$ និង $sinC=cosB$

នាំអោយ $sinB+sinC=cosB+cosC$

នាំអោយ $\frac{sinB+sinC}{cosB+cosC}=1=sinA$

•លក្ខខណ្ឌគ្រប់គ្រាន់

សម្មតិកម្ម $\frac{sinB+sinC}{cosB+cosC}=1\ (1)$

ស្រាយថា $\triangle ABC$ កែងត្រង់ $A$

យើងមាន $\frac{sinB+sinC}{cosB+cosC}=\frac{2sin\frac{B+C}{2}cos\frac{B-C}{2}}{2cos\frac{B+C}{2}cos\frac{B-C}{2}}=tan\frac{B+C}{2}$

តែ $A+B+C=\pi$ នោះ $B+C=\pi-A$

$\Rightarrow \frac{B+C}{2}=\frac{\pi}{2}-\frac{A}{2}$

$tan\left(\frac{B+C}{2}\right)=tan\left(\frac{\pi}{2}-\frac{A}{2}\right)=cot\frac{A}{2}\ (2)$

តាម (1) និង (2) : $\frac{cos\frac{A}{2}}{sin\frac{A}{2}}=sinA$

$\Leftrightarrow \frac{cos\frac{A}{2}}{sin\frac{A}{2}}=2sin\frac{A}{2}cos\frac{A}{2}$

$\Leftrightarrow 1=2sin^2\frac{A}{2}$ ឬ $1-2sin^2\frac{A}{2}=0$

នាំអោយ $cosA=0$ និង $\angle A=90^0$

$\triangle ABC$ កែងត្រង់ $A$

ដូចនេះ ត្រីកោណ $ABC$ កែងត្រង់ $A$ លុះត្រាតែ $\frac{sinB+sinC}{cosB+cosC}=1$

## លំហាត់ទី ៨៧៧

គេគ្រោងថាឈ្នួលប្រចាំឆ្នាំនៃផ្ទះមួយកើនឡើង $6\%$ រៀងរាល់ឆ្នាំ ។ គេសំគាល់ដោយ $f(n)$ ឈ្នួលប្រចាំឆ្នាំនៅឆ្នាំ $2002+n$ $(n\in\mathbb{N})$ ។

១. សរសេរ $f(n+1)$ ជាអនុគមន៍នៃ $n$ រួចសរសេរ $f(n)$ ជាអនុគមន៍នៃ $f(0)$ និង $n$ ។

២. គេឧបមាថា $f(0)=80000$៖ តើឈ្នួលប្រចាំឆ្នាំនៃផ្ទះមួយនៅឆ្នាំ 2008 ត្រូវជាប៉ុន្មាន ?

៣. តើចាប់ពីឆ្នាំណាទៅទើបឈ្នួលផ្ទះប្រចាំឆ្នាំ កើនលើសពីពីរដងនៃឈ្នួលផ្ទះប្រចាំឆ្នាំនៅឆ្នាំ 2002 ?

## ដំណោះស្រាយ

១. សរសេរ $f(n+1)$ ជាអនុគមន៍នៃ $n$ រួចសរសេរ $f(n)$ ជាអនុគមន៍នៃ $f(0)$ និង $n$

$f(n+1)$ ជាឈ្នួលផ្ទះនៅឆ្នាំ $2002+(n+1)$ ដែលស្មើនឹងឈ្នួលផ្ទះ $f(n)$ នៅឆ្នាំ $2002+n$ បន្ថែម $6\%$ មានន័យថាគុណ $f(n)$ នឹង $1.06$ ។

$f(n+1)=f(n)\times(1.06)$

$f(n)$ ជាតួទី $n$ ស្វ៊ីតធរណីមាត្រដែលមានរេសុង $q=1.06$ និងតួទី ១ $f(0)$ ។

យើងបាន $f(n)=f(0)(1.06)^n$

២. រកឈ្នួលផ្ទះនៅឆ្នាំ 2008

$2008=2002+6$

$f(6)=(1.06)^6\cdot f(0)$

$\quad=(1.06)^6\cdot 80000=113481$

៣. កំណត់ឆ្នាំដើម្បីអោយឈ្នួលផ្ទះកើនឡើងលើសពីពីរដងឈ្នួលផ្ទះនៅឆ្នាំ 2002:

$f(n)=(1.06)^n\cdot f(0)$

$f(n)\geq 2f(0)$

$\Leftrightarrow (1.06)^n\cdot f(0)\geq 2f(0)$

$(1.06)^n\geq 2$

$(1.06)^{11}=1.8983$

$(1.06)^{12}=2.0122$

ដូចនេះ ចាប់ពីឆ្នាំ $2002+12=2014$ ទៅទើបឈ្នួលផ្ទះកើនឡើងលើសពីពីរដងឈ្នួលផ្ទះនៅឆ្នាំ 2002

## លំហាត់ទី ៤៧៨

ស្វ៊ីត $(x_n)$ កំណត់ដោយ $x_1=1, x_2=1$ និង $x_{n+1}=x_n+x_{n-1}$ ចំពោះ $n\geq 2$ ។
១- បង្ហាញថា $x_{k+1}\cdot x_{k+2}-x_k\cdot x_{k+3}=(-1)^k$ ចំពោះ $\forall k\in\mathbb{N}$ ។
២- គេតាង $arccot$ ជាអនុគមន៍ច្រាសនៃអនុគមន៍ $cot$ ។
បង្ហាញថា $arccotx_1-arccotx_3-arccotx_5-\cdots-arccotx_{2011}=arccotx_{2012}$ ។

## ដំណោះស្រាយ

១- បង្ហាញថា $x_{k+1}\cdot x_{k+2}-x_k\cdot x_{k+3}=(-1)^k$ ចំពោះ $\forall k\in\mathbb{N}$

-ចំពោះ $k=1$ គេបាន $x_2\cdot x_3-x_1\cdot x_4=1\times 2-1\times 3=-1=(-1)^1$

-ឧបមាថាពិតដក់ $n=p$ គឺថា $x_{p+1}\cdot x_{p+2}-x_p\cdot x_{p+3}=(-1)^p$

-សិក្សាលើករណី $k=p+1$

$$x_{p+2}\cdot x_{p+3}-x_{p+1}\cdot x_{p+4}=x_{p+2}\left(x_{p+1}+x_{p+2}\right)-x_{p+1}\left(x_{p+2}+x_{p+3}\right)$$
$$=\left(x_{p+2}\right)^2-x_{p+1}\left(x_{p+1}+x_{p+2}\right)=\left(x_{p+2}\right)^2-x_{p+1}\cdot x_{p+2}$$
$$=\left(x_{p+2}-x_{p+1}\right)\left(x_{p+1}+x_{p+1}\right)-x_{p+1}x_{p+2}$$
$$=\left(x_{p+1}+x_p-x_{p+1}\right)\left(x_{p+3}\right)-x_{p+1}x_{p+2}$$
$$=x_px_{p+3}-x_{p+1}x_{p+2}$$
$$=(-1)\left(x_{p+1}\cdot x_{p+2}-x_p\cdot x_{p+3}\right)=(-1)(-1)^p=(-1)^{p+1}$$

ដូចនេះ $x_{k+1}x_{k+2}-x_kx_{k+3}=(-1)^k$ ចំពោះគ្រប់ចំនួនគត់ធម្មជាតិ $k$

២- បង្ហាញថា $arccotx_1-arccotx_3-arccotx_5-\cdots-arccotx_{2011}=arccotx_{2012}$

គេដឹងថាបើ $a=cot\alpha, b=cot\beta\Rightarrow\alpha=arccota, \beta=arccotb$

$$cot(\alpha-\beta)=\frac{cot\alpha cot\beta+1}{cot\beta-cot\alpha}\Leftrightarrow\alpha-\beta=arccot\left(\frac{cot\alpha cot\beta+1}{cot\beta-cot\alpha}\right)$$

$$\Leftrightarrow arccota-arccotb=arccot\left(\frac{ab+1}{b-a}\right)$$

គេអាចសរសេរ

$$arccotx_{2i}-arccotx_{2i+1}=arccot\left(\frac{x_{2i}x_{2i+1}+1}{x_{2i+1}-x_{2i}}\right)$$
$$=arccot\left(\frac{x_{2i}x_{2i+1}+1}{x_{2i}+x_{2i-1}-x_{2i}}\right)$$
$$arccotx_{2i}-arccotx_{2i+1}=arccot\left(\frac{x_{2i}x_{2i+1}+1}{x_{2i-1}}\right)\quad(1)$$

តាមសំណួរទី ១ ខាងលើនិងយក $k=2i-1$ នោះគេបាន

$$x_{2i}\cdot x_{2i+1}-x_{2i-1}\cdot x_{2i+2}=-1\Rightarrow x_{2i}\cdot x_{2i+1}+1=x_{2i-1}\cdot x_{2i+2}$$

ដោយជួសតម្លៃ $i = 1,2,3,...,1005$ នោះគេបាន

$arccotx_1 - arccotx_3 = arccotx_4$ ( ព្រោះ $x_2 = x_1$ )

$arccotx_4 - arccotx_5 = arccotx_6$

......................................................

$arccotx_{2010} - arccotx_{2011} = arccotx_{2012}$

បូកអង្គ និង អង្គគេបាន

$arccotx_1 - arccotx_3 - arccotx_5 - \cdots - arccotx_{2011} = arccotx_{2012}$

## លំហាត់ទី ៤៧៩

អនុគមន៍ $f$ កំណត់ចំពោះគ្រប់ចំនួនពិត $x$ ដោយ $f(x) = cosx + cos\left(\sqrt{p}x\right)$ ដែល $p$ ជាចំនួនបឋម ។ បង្ហាញថា $f$ មិនមែនជាអនុគមន៍ខួបលើសំណុំចំនួនពិតទេ ។

### ដំណោះស្រាយ

ឧបមាថា $f$ មានខួប $T$ នោះគេបាន $f(x+T) = f(x)$ ចំពោះគ្រប់ចំនួនពិត $x$ ។

បានន័យថា $cos(x+T) + cos\left(x\sqrt{p} + T\sqrt{p}\right) = cosx + cos\left(x\sqrt{p}\right)$ ចំពោះគ្រប់ចំនួនពិត $x$ ។

ពិនិត្យចំពោះ $x = 0$ គេបាន : $cosT + cosT\sqrt{p} = 2 \Leftrightarrow cosT = 1 \wedge cosT\sqrt{p} = 1$

$T = 2k\pi \wedge T\sqrt{p} = m2\pi, k \in \mathbb{N}, m \in \mathbb{N}$ ហើយ $\sqrt{p} = \dfrac{m2\pi}{k2\pi} = \dfrac{m}{k}$

ដោយ $\sqrt{p} \in \overline{\mathbb{Q}_+} \wedge \dfrac{m}{k} \in \mathbb{Q}_+$ គេបាន $\sqrt{p} = \dfrac{m}{k}$ ជាករណីមិនអាចកើតមាន ។

ដូចនេះ $f$ មិនមែនជាអនុគមន៍ខួបលើសំណុំចំនួនពិតទេ

## លំហាត់ទី ៤៨០

គេឱ្យចំនួនពិត $u_1;u_2;...$ បំពេញទំនាក់ទំនង

$u_{n+1} = \dfrac{u_n^2 - u_{n-1} + 2u_n}{u_{n-1} + 1}$ និង $u_1 = 1; u_2 = 7$ ។ គណនាតម្លៃនៃ $u_5$ ។

### ដំណោះស្រាយ

សម្មតិកម្ម $u_{n+1} = \dfrac{u_n^2 - u_{n-1} + 2u_n}{u_{n-1} + 1}$

$$\Rightarrow u_{n+1} + 1 = \frac{u_n^2 - u_{n-1} + 2u_n}{u_{n-1} + 1} + 1$$

$\Rightarrow u_{n+1}+1=\dfrac{(u_n+1)^2}{u_{n-1}+1}$

តាង $v_n=u_{n+1}$ នោះ $v_{n+1}=\dfrac{v_n^2}{v_{n-1}}$

$\Rightarrow v_n^2=v_{n+1}\times v_{n-1}$

$\Rightarrow (v_n)$ ជាស្វ៊ីតធរណីមាត្រដែលមាន $v_1=u_1+1=2$ និង $v_9=u_9+1=8$

គេបាន $v_5^2=v_1\times v_9=16$

$v_5=\pm 4$

តែ $v_5=v_1\cdot q^4$ នោះ $v_5$ និង $v_1$ មានសញ្ញាដូចគ្នា

ទាញបាន $v_5=4$ ហើយ $u_5+1=4$

ដូចនេះ $u_5=3$

## លំហាត់ទី ៤៨១

វង្វង់ពីរកាត់គ្នាត្រង់ចំណុច $A$ និង $B$ ។ បន្ទាត់ចល័ត $(MN)$ កាត់តាម $A$ ហើយជួបរង្វង់ធំត្រង់ $M$ និងរង្វង់តូចត្រង់ $N$ ។ បង្ហាញថា $\dfrac{BM}{BN}$ មានតម្លៃថេរកាលណា $(MN)$ វិលជុំវិញចំណុច $A$ ។

## ដំណោះស្រាយ




ក្នុងរង្វង់ធំ $\widehat{AMB}=\dfrac{1}{2}\overparen{AB}$

ក្នុងរង្វង់តូច $\widehat{ANB} = \frac{1}{2}\widehat{AB}$

តាមមទ្រឹស្តីបទស៊ីនុស : $\frac{BM}{sin\widehat{ANB}} = \frac{BN}{sin\widehat{AMB}}$

គេទាញបាន $\frac{BM}{BN} = \frac{sin\widehat{ANB}}{sin\widehat{AMB}}$ ពិត

## លំហាត់ទី ៤៨២

គណនា $S_{2008} = (1\times3+2\times4+3\times5+\cdots+2008\times2010) - (1^2+2^2+\cdots+2008^2)$ ។

### ដំណោះស្រាយ

$$S = [1(2+1)+2(2+2)+3(2+3)+\cdots+2008(2+2008)]$$
$$-\left(1^2+2^2+\cdots+2008^2\right)$$
$$= 2(1+2+3+\cdots+2008)+\left(1^2+2^2+\cdots+2008^2\right)-\left(1^2+2^2+\cdots+2008^2\right)$$
$$= 2(1+2+3+\cdots+2008) = 2\cdot\frac{2008\times2009}{2}$$
$$= 2008\times2009$$

ដូចនេះ: $S = 2008^2 + 2008$

## លំហាត់ទី ៤៨៣

ស្វ៊ីតនៃចំនួនគត់រ៉ឺឡាទីប $(u_n)$ កំណត់ដោយ $u_1 = 1; u_2 = 1; u_3 = -1$ និង $u_n = u_{n-1}\times u_{n-3}$ ចំពោះ $n \geq 4$ ។ រកតម្លៃមួយតួដំបូង និងតួ 2008 នៃស្វ៊ីត $(u_n)$ ។

### ដំណោះស្រាយ

$u_1 = 1; u_2 = 1; u_3 = -1$

$u_4 = u_3\times u_1 = (-1)(1) = -1$

$u_5 = u_4\times u_2 = (-1)(1) = -1$

$u_6 = u_5\times u_3 = (-1)(-1) = 1$

$u_7 = u_6\times u_4 = 1(-1) = -1$

តាមរបៀបដូចគ្នា :

$u_8 = 1; u_9 = 1; u_{10} = -1; u_{11} = -1; u_{12} = -1; u_{13} = 1; u_{14} = -1$

$u_{15} = 1; u_{16} = 1; u_{17} = -1; u_{18} = -1; u_{19} = -1; u_{20} = 1; u_{21} = -1$

គេសង្កេតឃើញថា

$u_1=1;u_2=1;u_3=-1;u_4=-1;u_5=-1;u_6=1;u_7=-1$

$u_8=1;u_9=1;u_{10}=-1;u_{11}=-1;u_{12}=-1;u_{13}=1;u_{14}=-1$

$u_{15}=1;u_{16}=1;u_{17}=-1;u_{18}=-1;u_{19}=-1;u_{20}=1;u_{21}=-1$

គេបាន $(u_n)$ ជាស្វីតខួបដែលខួបនីមួយៗមាន 7 តួ

$2008=7\times 286+6$ នេះបញ្ជាក់ថា $u_{2008}$ ជាតួទី 6 នៅក្នុងខួបទី 287

ដូចនេះ $u_{2008}=1$

## លំហាត់ទី ៤៨៤

គេមានសមភាព

$14^2=\left(6\times 1^2+6\times 1+2\right)^2;\ 15^2=\left(6\times 1^2+6\times 1+3\right)^2$

$38^2=\left(6\times 2^2+6\times 2+2\right)^2;\ 39^2=\left(6\times 2^2+6\times 2+3\right)^2$

$74^2=\left(6\times 3^2+6\times 3+2\right)^2;\ 75^2=\left(6\times 3^2+6\times 3+3\right)^2$ ។

ដោយសង្កេតឧទាហរណ៍ខាងក្រោមនេះ ចូរទាញរករូបមន្តទូទៅ ហើយស្រាយបញ្ជាក់រូបមន្តទូទៅនោះផង :

$2^2+3^2+4^2+14^2=15^2;\ 4^2+5^2+6^2+38^2=39^2;$

$6^2+7^2+8^2+74^2=75^2$ ។

### ដំណោះស្រាយ

$2^2+3^2+4^2+14^2=(2\times 1)^2+(2\times 1+1)^2+(2\times 1+2)^2+\left(6\times 1^2+6\times 1+2\right)^2$

$=15^2=\left(6\times 1^2+6\times 1+3\right)^2$ ( គឺ $n=1$ )

$4^2+5^2+6^2+38^2=(2\times 2)^2+(2\times 2+1)^2+(2\times 2+2)^2+\left(6\times 2^2+6\times 2+2\right)^2$

$=39^2=\left(6\times 2^2+6\times 2+3\right)^2$ ( គឺ $n=2$ )

$6^2+7^2+8^2+74^2=(2\times 3)^2+(2\times 3+1)^2+(2\times 3+2)^2+\left(6\times 3^2+6\times 3+2\right)^2$

$=75^2=\left(6\times 3^2+6\times 3+3\right)^2$ ( គឺ $n=3$ )

ជាទូទៅ : $(2n)^2+(2n+1)^2+(2n+2)^2+\left(6n^2+6n+2\right)^2=\left(6n^2+6n+3\right)^2$

ចំពោះ $n=1,2,3..$

- ស្រាយបញ្ជាក់រូបមន្តទូទៅ :

$(2n)^2+(2n+1)^2+(2n+2)^2+\left(6n^2+6n+2\right)^2=36n^4+72n^3+72n^2+36n+9$

$\left(6n^2+6n+3\right)^2=36n^4+72n^3+72n^2+36n+9$

ដូចនេះ រូបមន្តពិតចំពោះ $n=1,2,3,...$

## លំហាត់ទី ៤៨៥

គេអោយអាំងតេក្រាល $I_n = \int_0^{\frac{\pi}{4}} tan^n x dx,\ n \in \mathbb{N}$ ។

ក- បង្ហាញថា $(I_n)$ ជាស្វ៊ីតចុះ ។

ខ- គណនា $I_n + I_{n-2},\ (n \geq 2)$ រួចទាញថា $\frac{1}{2(n+1)} \leq I_n \leq \frac{1}{2(n-1)}$ ។

## ដំណោះស្រាយ

ក- បង្ហាញថា $(I_n)$ ជាស្វ៊ីតចុះ

ចំពោះ $0 < x < \frac{\pi}{4}$ គេបាន $0 < tanx < 1$

នោះ $tan^n x < tan^{n-1} x < \cdots < tanx$

ដូចនេះ $(I_n)$ ជាស្វ៊ីតចុះ

ខ- គណនា $I_n + I_{n-2},\ (n \geq 2)$ រួចទាញថា $\frac{1}{2(n+1)} \leq I_n \leq \frac{1}{2(n-1)}$

យើងមាន $I_n = \int_0^{\frac{\pi}{4}} tan^n x dx$

$$I_n = \int_0^{\frac{\pi}{4}} tan^{n-2} x \cdot tan^2 x dx = \int_0^{\frac{\pi}{4}} tan^{n-2} x \left( \frac{1}{cos^2 x} - 1 \right) dx$$

$$= \int_0^{\frac{\pi}{4}} tan^{n-2} x \cdot \frac{dx}{cos^2 x} - \int_0^{\frac{\pi}{4}} tan^{n-2} x$$

$$= \left[ \frac{tan^{n-1} x}{n-1} \right]_0^{\frac{\pi}{4}} - I_{n-2}$$

ដូចនេះ $I_n + I_{n-2} = \frac{1}{n-1}$

ដោយ $I_n < I_{n-2}$ នោះ $I_n + I_n < I_n + I_{n-2}$

$\Rightarrow 2I_n < \frac{1}{n-1}$ ឬ $I_n < \frac{1}{2(n-1)}$ (1)

ម្យ៉ាងទៀត $I_{n+2} < I_n$ នោះ $I_{n+2} + I_n < I_n + I_n$

$\Rightarrow \frac{1}{n+1} < 2I_n$ ឬ $\frac{1}{2(n+1)} < I_n$ (2)

តាម (1) និង (2) យើងបាន
$$\frac{1}{2(n+1)} \le I_n \le \frac{1}{2(n-1)}$$

## លំហាត់ទី ៥៨៦

គេអោយ $a_i, i=1,...,6$ ជាចំនួនវិជ្ជមាន ដែល $a_1+a_2+a_3-a_4-a_5-a_6=3$ និង $a_1^2+a_2^2+a_3^2+a_4^2+a_5^2+a_6^2=9$ ។
ស្រាយបញ្ជាក់ថា
$$a_1a_2a_3a_4a_5a_6 \le 1 \text{ ។}$$

## ដំណោះស្រាយ

តាមវិសមភាព Cauchy-Schwarz
$$\begin{aligned}3+a_4+a_5+a_6=a_1+a_2+a_3 &\le \sqrt{\left(1^2+1^2+1^2\right)\left(a_1^2+a_2^2+a_3^2\right)}\\ &= \sqrt{3\left(a_1^2+a_2^2+a_3^2\right)}\\ &= \sqrt{3\left[9-\left(a_4^2+a_5^2+a_6^2\right)\right]}\\ &= \sqrt{27-\left(1^2+1^2+1^2\right)\left(a_4^2+a_5^2+a_6^2\right)}\\ &\le \sqrt{27-(a_4+a_5+a_6)^2}\end{aligned}$$

យើងទាញបាន
$$(3+(a_4+a_5+a_6))^2 \le 27-(a_4+a_5+a_6)^2$$
$$\Leftrightarrow (a_4+a_5+a_6)^2+3(a_4+a_5+a_6)-9 \le 0$$
$$\Rightarrow a_4+a_5+a_6 \le \frac{-3+3\sqrt{5}}{2} \quad (1)$$
$$\Rightarrow \frac{a_4+a_5+a_6}{3} \le \frac{-1+\sqrt{5}}{2}$$

តាមវិសមភាព AM-GM យើងបាន
$$\sqrt[3]{a_4a_5a_6} \le \frac{a_4+a_5+a_6}{3} \le \frac{-1+\sqrt{5}}{2} \quad (2)$$ តាម (1) យើងបាន
$$a_1+a_2+a_3=3+(a_4+a_5+a_6) \le 3+\frac{-3+3\sqrt{5}}{2}=\frac{3+3\sqrt{5}}{2}$$

នាំអោយ $\dfrac{a_1+a_2+a_3}{3} \le \dfrac{1+\sqrt{5}}{2}$

តាមវិសមភាព AM-GM យើងបាន

$$\sqrt[3]{a_1a_2a_3} \le \frac{a_1+a_2+a_3}{3} \le \frac{1+\sqrt{5}}{2} \quad (3)$$

តាម (2) និង (3) : $\sqrt[3]{a_1a_2a_3} \cdot \sqrt[3]{a_4a_5a_6} \le \frac{-1+\sqrt{5}}{2} \cdot \frac{1+\sqrt{5}}{2} = 1$

នោះ $a_1a_2a_3a_4a_5a_6 \le 1$

សមភាពកើតមានកាលណា $a_1 = a_2 = a_3 = \frac{1+\sqrt{5}}{2}$, $a_4 = a_5 = a_6 = \frac{-1+\sqrt{5}}{2}$

## លំហាត់ទី ៤៨៧

១. បើ $x+iy = \sqrt[3]{a+ib}$ ស្រាយបញ្ជាក់ថា $\frac{a}{x} + \frac{b}{y} = 4\left(x^2-y^2\right)$ ។

២. បើ $x_p = cos\left(\frac{\pi}{2^p}\right) + isin\left(\frac{\pi}{2^p}\right)$ ចូរបង្ហាញថា $\lim\limits_{n\to+\infty} x_1 \cdot x_2 \cdot x_3 \cdots x_n = -1$ ។

## ដំណោះស្រាយ

១. បើ $x+iy = \sqrt[3]{a+ib}$ ស្រាយបញ្ជាក់ថា $\frac{a}{x} + \frac{b}{y} = 4\left(x^2-y^2\right)$

យើងមាន $x+iy = \sqrt[3]{a+ib}$

$a+ib = (x+iy)^3$

$a+ib = x^3 + 3x^2iy + 3(iy)^2x + (iy)^3$

$a+ib = x^3 - 3xy^2 + i\left(3x^2y - y^3\right)$

គេទាញបាន $a = x^3 - 3xy^2$, $b = 3x^2y - y^3$

$\frac{a}{x} + \frac{b}{y} = x^2 - 3y^2 + 3x^2 - y^2$

$\frac{a}{x} + \frac{b}{y} = 4\left(x^2-y^2\right)$ ពិត

២. បង្ហាញថា $\lim\limits_{n\to+\infty} x_1 \cdot x_2 \cdot x_3 \cdots x_n = -1$

យើងមាន $x_p = cos\left(\frac{\pi}{2^p}\right) + isin\left(\frac{\pi}{2^p}\right)$

តាមរូបមន្តអឺលែរ

$x_p = e^{i\cdot\frac{\pi}{2^p}}$

តាង $A = \lim\limits_{n\to+\infty} x_1 \cdot x_2 \cdot x_3 \cdots x_n$

**រូបមន្តអឺលែរ**

$e^{i\theta} = cos\theta + isin\theta$

$$A=\lim_{n\to+\infty} e^{i\cdot\frac{\pi}{2}}\cdot e^{i\cdot\frac{\pi}{2^2}}\cdot e^{i\cdot\frac{\pi}{2^3}}\cdots e^{i\cdot\frac{\pi}{2^n}}$$

$$=\lim_{n\to+\infty} e^{i\pi\left(\frac{1}{2}+\frac{1}{2^2}+\frac{1}{2^3}+\cdots+\frac{1}{2^n}\right)}$$

$$=\lim_{n\to+\infty} e^{i\pi\left[1-\frac{1}{2^n}\right]}$$

$$\left[\because \frac{1}{2}+\frac{1}{2^2}+\frac{1}{2^3}+\cdots+\frac{1}{2^n}=\frac{\frac{1}{2}\left[1-\frac{1}{2^n}\right]}{1-\frac{1}{2}}=1-\frac{1}{2^n}\right]$$

$A=e^{i\pi}=cos\pi+isin\pi=-1$ ពិត

## លំហាត់ទី ៤៨៨

បង្ហាញថា $x^5-1=(x-1)\left[x^2+2xcos\frac{\pi}{5}+1\right]\left[x^2+2xcos\frac{3\pi}{5}+1\right]$ ។

## ដំណោះស្រាយ

បើ $x^5-1=0$ នោះ $x^5=1=cos0+isin0$

$x^5=cos2k\pi+isin2k\pi$

$$x=(cos2k\pi+isin2k\pi)^{\frac{1}{5}}=cos\frac{2k\pi}{5}+isin\frac{2k\pi}{5}$$

$$x=e^{i\frac{2k\pi}{5}}$$

ឱ្យតម្លៃ $k=0,1,2,3,4$ យើងទទួលបានឫសនៃសមីការដូចខាងក្រោម :

$x_0=1$

$$x_1=e^{i\frac{2\pi}{5}}=cos\frac{2\pi}{5}+isin\frac{2\pi}{5}$$

$$x_2=e^{i\frac{4\pi}{5}}=cos\frac{4\pi}{5}+isin\frac{4\pi}{5}$$

$$x_3 = e^{i\frac{6\pi}{5}} = cos\frac{6\pi}{5} + isin\frac{6\pi}{5}$$

$$= cos\left(2\pi - \frac{4\pi}{5}\right) + isin\left(2\pi - \frac{4\pi}{5}\right)$$

$$= cos\frac{4\pi}{5} - isin\frac{4\pi}{5} = e^{-i\frac{4\pi}{5}} = \overline{x_2} \quad \left[\begin{array}{l} \because cos(2\pi - \theta) = cos\theta \\ sin(2\pi - \theta) = -sin\theta \end{array}\right]$$

$$x_4 = e^{i\frac{8\pi}{5}} = cos\frac{8\pi}{5} + isin\frac{8\pi}{5} = cos\left(2\pi - \frac{2\pi}{5}\right) + isin\left(2\pi - \frac{2\pi}{5}\right)$$

$$= cos\frac{2\pi}{5} - isin\frac{2\pi}{5} = e^{-i\frac{2\pi}{5}} = \overline{x_1}$$

$x_0, x_1, x_2, x_3, x_4$ គឺជាឫសនៃសមីការ $x^5 - 1 = 0$

$$x^5 - 1 = (x - x_0)(x - x_1)(x - x_2)(x - x_3)(x - x_4)$$

$$= (x-1)\left(x - e^{\frac{2i\pi}{5}}\right)\left(x - e^{\frac{4i\pi}{5}}\right)\left(x - e^{-\frac{4i\pi}{5}}\right)\left(x - e^{-\frac{2i\pi}{5}}\right)$$

$$= (x-1)\left[x^2 - x\left(e^{\frac{2i\pi}{5}} + e^{-\frac{2i\pi}{5}}\right) + 1\right]\left[x^2 - x\left(e^{\frac{4i\pi}{5}} + e^{-\frac{4i\pi}{5}}\right) + 1\right]$$

$$= (x-1)\left[x^2 - x \cdot 2cos\frac{4\pi}{5} + 1\right]\left[x^2 - x \cdot 2cos\frac{2\pi}{5} + 1\right]$$

$$= (x-1)\left[x^2 - 2x\left(\pi - \frac{3\pi}{5}\right) + 1\right]\left[x^2 - 2x\left(\pi - \frac{\pi}{5}\right) + 1\right]$$

$$= (x-1)\left(x^2 + 2xcos\frac{3\pi}{5} + 1\right)\left(x^2 + 2xcos\frac{\pi}{5} + 1\right)$$

$$[\because cos(\pi - \theta) = -cos\theta]$$

## លំហាត់ទី ៤៨៩

អនុគមន៍ $f(x) = a_0 + a_1x + a_2x^2 + \cdots + a_nx^n$ មានលេខមេគុណ $a_i$ បំពេញលក្ខខណ្ឌ $0 \le a_i \le a_0$ ដែល $i = 1;2;3;...;n$ ។ គេយក $(f(x))^2 = b_0+b_1x+b_2x^2+\cdots+b_{n+1}x^{n+1}+\cdots+b_{2n}x^{2n}$ ។ បង្ហាញថា $b_{n+1} \le \frac{1}{2}(f(1))^2$ ។

## ដំណោះស្រាយ

បង្ហាញថា $b_{n+1} \le \frac{1}{2}(f(1))^2$

ដោយ $b_0+b_1x+b_2x^2+\cdots+b_{n+1}x^{n+1}+\cdots+b_{2n}x^{2n} = \left(a_0+a_1x+a_2x^2+\cdots+a_nx^n\right)^2$

នោះតាមរបៀបប្រដូចលេខមេគុណនៃ $x^{n+1}$ គេបាន : $b_{n+1} = a_1a_n+a_2a_{n-1}+a_3a_{n-2}+\cdots+a_{n-1}a_2+a_na_1$

គេបាន $b_{n+1} \le a_1a_0+a_2a_0+a_3a_0+\cdots+a_{n-1}a_0+a_na_0$

$$\begin{aligned}
2b_{n+1} &\le a_1(a_0+a_n)+a_2(a_0+a_{n-1})+\cdots+a_{n-1}(a_0+a_2)+a_n(a_0+a_1)\\
&\le a_1(a_0+\cdots+a_n)+a_2(a_0+\cdots+a_n)+\cdots+a_{n-1}(a_0+\cdots+a_n)\\
&\quad +a_n(a_0+\cdots+a_n)\\
&\le (a_0+a_1+a_2+\cdots+a_n)(a_0+a_1+a_2+\cdots+a_n)\\
&\le (a_0+a_1+a_2+\cdots+a_n)^2 = (f(1))^2
\end{aligned}$$

នាំអោយ $b_{n+1} \le \frac{1}{2}(f(1))^2$ ពិត

## លំហាត់ទី ៤៩០

គេមានស្វ៊ីតនៃចំនួន $x_1;x_2;x_3;...$ ដែលកំណត់ដោយ $x_1 = 1;x_2 = 1$ និង $x_n = x_{n-1}+x_{n-2}$ ចំពោះ $n \ge 3$ ។

ក. រកដប់តួដំបូងនៃស្វ៊ីតនោះ ។

ខ. គេយក $A = \begin{bmatrix} 1 & 1 \\ 1 & 0 \end{bmatrix}$ ជាម៉ាទ្រីសការេលំដាប់ $2$ ។ បង្ហាញថា $A^n = \begin{bmatrix} x_{n+1} & x_n \\ x_n & x_{n-1} \end{bmatrix}$ ចំពោះ $n = 2;3;4;...$ ។

## ដំណោះស្រាយ

ក. រកដប់តួដំបូងនៃស្វ៊ីតនោះ

$x_1 = 1; x_2 = 1; x_3 = 2; x_4 = 3; x_5 = 5; x_6 = 8; x_7 = 13; x_8 = 21; x_9 = 34; x_{10} = 55$

ខ. បង្ហាញថា $A^n = \begin{bmatrix} x_{n+1} & x_n \\ x_n & x_{n-1} \end{bmatrix}$ ចំពោះ $n = 2;3;4;...$

- ចំពោះ $n = 2$ :

$A^2 = \begin{bmatrix} 1 & 1 \\ 1 & 0 \end{bmatrix}\begin{bmatrix} 1 & 1 \\ 1 & 0 \end{bmatrix} = \begin{bmatrix} 1\cdot1+1\cdot1 & 1\cdot1+1\cdot0 \\ 1\cdot1+1\cdot0 & 1\cdot1+0\cdot0 \end{bmatrix} = \begin{bmatrix} 2 & 1 \\ 1 & 1 \end{bmatrix} = \begin{bmatrix} x_3 & x_2 \\ x_2 & x_1 \end{bmatrix} = \begin{bmatrix} x_{2+1} & x_2 \\ x_2 & x_{2-1} \end{bmatrix}$ ពិត

- ឧបមាថាទំនាក់ទំនងពិតរហូតដល់ $n = p$ : $A^p = \begin{bmatrix} x_{p+1} & x_p \\ x_p & x_{p-1} \end{bmatrix}$

- សិក្សាចំពោះ $n = p+1$:

$A^{p+1} = A^p \cdot A = \begin{bmatrix} x_{p+1} & x_p \\ x_p & x_{p-1} \end{bmatrix}\begin{bmatrix} 1 & 1 \\ 1 & 0 \end{bmatrix} = \begin{bmatrix} x_{p+1}+x_p & x_{p+1} \\ x_p+x_{p-1} & x_p \end{bmatrix} = \begin{bmatrix} x_{p+2} & x_{p+1} \\ x_{p+1} & x_p \end{bmatrix}$

ពិត

ដូចនេះ $A^n = \begin{bmatrix} x_{n+1} & x_n \\ x_n & x_{n-1} \end{bmatrix}$ ចំពោះ $n = 2;3;4;...$

### លំហាត់ទី ៤៩១

ត្រីកោណ $ABC$ មានមុំក្នុងទាំងបីជាមុំស្រួច ។ កន្លះបន្ទាត់ពុះក្នុងនៃមុំ $\angle BAC$ ជួបជ្រុង $[BC]$ ត្រង់ $D$ ហើយជួបរង្វង់ចារិកក្រៅត្រីកោណ $ABC$ ត្រង់ $E$ ។ តាមចំណុច $D$ គេគូសបន្ទាត់កែងនឹងជ្រុង $[AB]$ និង $[AC$ រៀងគ្នាត្រង់ចំណុច $M$ និង $N$ ។ បង្ហាញថា ចតុកោណ $AMEN$ និង ត្រីកោណ $ABC$ មានផ្ទៃក្រឡាស្មើគ្នា ។

## ដំណោះស្រាយ




គេមាន $S_{ABC} = \frac{1}{2}AB \times AC\sin\alpha$

ដែល $\widehat{BAC} = \alpha$

ត្រីកោណកែង $AMD \cong AND$

ហើយគេបាន $AD \perp MN$

គេបាន $S_{AMEN} = \frac{1}{2}AE \times MN$

ម្យ៉ាងទៀត $\widehat{ACD} = \widehat{AEB}$

$\widehat{CAD} = \widehat{EAB}$

នោះ $\triangle ACD$ ដូច $\triangle AEB$ (ករណីទី១ ម.ម)

វិបាក $\frac{AB}{AE} = \frac{AD}{AC}$ នាំឱ្យ $AB \times AC = AE \times AD$ (1)

ចតុកោណ $ADMN$ ចារឹកក្នុងរង្វង់មានអង្កត់ផ្ចិត $[AD]$ មួយ ព្រោះ $\widehat{M} = \widehat{N} = 90^0$

តាមទ្រឹស្តីបទស៊ីនុស ក្នុង $\triangle AMN$ : $\frac{MN}{\sin\alpha} = AD$

តាម (1) គេបាន $AB \times AC = AE \times \frac{MN}{\sin\alpha}$

$$\frac{1}{2}AB \times AC\sin\alpha = \frac{1}{2}AE \times MN$$

$$S_{ABC} = S_{AMEN}$$

## លំហាត់ទី ៤៩២

បង្ហាញថា $\sqrt{7} + \sqrt[3]{7} + \sqrt[4]{7} < 7$ ហើយ $\sqrt{4} + \sqrt[3]{4} + \sqrt[4]{4} > 4$ ។

### ដំណោះស្រាយ

គេដឹងថា : $\sqrt{7} < \sqrt{9}$ ; $\sqrt[3]{7} < \sqrt[3]{8}$ ; $\sqrt[4]{7} < \sqrt[4]{16}$

ដូចនេះ $\sqrt{7} + \sqrt[3]{7} + \sqrt[4]{7} < \sqrt{9} + \sqrt[3]{8} + \sqrt[4]{16} = 7$

តាមរបៀបដូចគ្នា : $\sqrt{4} = 2$ ; $\sqrt[3]{4} > \sqrt[3]{1}$ ; $\sqrt[4]{4} > \sqrt[4]{1}$

ដូចនេះ $\sqrt{4} + \sqrt[3]{4} + \sqrt[4]{4} > \sqrt{4} + \sqrt[3]{1} + \sqrt[4]{1} = 4$

## លំហាត់ទី ៤៩៣

គេឱ្យពហុធា $g(n) = n^4 + 2n^3 + 2n^2 + 2n + 1$ ចំពោះ $n = 1;2;3;...$ ។

បង្ហាញថា $g(n)$ មិនមែនជាការេនៃចំនួនគត់ រ៉ឺឡាទីបណាមួយឡើយ ។

## ដំណោះស្រាយ

$(n^2+n)^2 = n^4+2n^3+n^2 < n^4+2n^3+2n^2+2n+1 < n^4+2n^3+3n^2+2n+1$

$(n^2+n)^2 < n^4+2n^3+2n^2+2n+1 < (n^2+n+1)^2$

ដោយ $(n^2+n)^2$ និង $(n^2+n+1)^2$ ជាការេនៃចំនួនគត់រ៉ឺឡាទីបពីរតគ្នា នោះគេបាន :

$g(n)$ មិនមែនជាការេនៃចំនួនគត់ រ៉ឺឡាទីបណាមួយឡើយ ។

<u>របៀបទី ២</u>

$$g(n) = (n^4+2n^3+n^2)+(n^2+2n+1)$$
$$= n^2(n+1)^2+(n+1)^2$$
$$= (n+1)^2(n^2+1)$$

ដោយ $n^2+1$ គ្មានឫសនៅក្នុង $\mathbb{Z}$ នោះ $n^2+1$ មិនអាចជាការេនៃចំនួនគត់រ៉ឺឡាទីបណាមួយឡើយ ។

ដូចនេះ $g(n)$ មិនមែនជាការេនៃចំនួនគត់ រ៉ឺឡាទីបណាមួយឡើយ

## លំហាត់ទី ៤៩៤

ចំពោះគ្រប់ចំនួនគត់ រ៉ឺឡាទីបវិជ្ជមាន $n$ គេមាន :

$$f(n) = 1-\frac{1}{2}+\frac{1}{3}-\cdots+\frac{1}{2n-1}-\frac{1}{2n}$$ និង $$g(n)=\frac{1}{n+1}+\frac{1}{n+2}+\cdots+\frac{1}{2n}$$

។ បង្ហាញថា $f(n)=g(n)$ ចំពោះគ្រប់ចំនួនគត់ រ៉ឺឡាទីបវិជ្ជមាន $n$ ។

## ដំណោះស្រាយ

- ចំពោះ $n=1$ : $f(1)=1-\frac{1}{2}=\frac{1}{2}$ ; $g(1)=\frac{1}{1+1}=\frac{1}{2}$

ដូចនេះ $f(1)=g(1)$ ពិត

- ឧបមាថា សមភាពពិតដល់ $n=k$ : $f(k)=g(k)$
- សិក្សាចំពោះ $n=k+1$

$$f(k+1)-f(k) = \left(1-\frac{1}{2}+\frac{1}{3}-\cdots+\frac{1}{2(k+1)-1}-\frac{1}{2(k+1)}\right)-$$
$$\left(1-\frac{1}{2}+\frac{1}{3}-\cdots+\frac{1}{2k-1}+\frac{1}{2k}\right)$$
$$=\frac{1}{2k+1}-\frac{1}{2k+2} \quad (1)$$

$$g(k+1)-g(k)=\left(\frac{1}{k+1}+\frac{1}{k+2}+\cdots+\frac{1}{2k+2}\right)-\left(\frac{1}{k+1}+\frac{1}{k+2}+\cdots+\frac{1}{2k}\right)$$

$$=\frac{1}{2k+1}+\frac{1}{2k+2}-\frac{1}{k+1}=\frac{1}{2k+1}-\frac{1}{2k+2}\quad(2)$$

តាម (1) & (2) គេបាន $f(k+1)-f(k)=g(k+1)-g(k)$

ហើយ $f(k+1)=g(k+1)$ ពិត ព្រោះ $f(k)=g(k)$

ដូចនេះ $f(n)=g(n)$ ចំពោះគ្រប់ចំនួនគត់ វិជ្ជមាន $n$

របៀបទី ២

$$f(n)=\left(1+\frac{1}{3}+\cdots+\frac{1}{2n-1}\right)-\left(\frac{1}{2}+\frac{1}{4}+\cdots+\frac{1}{2n}\right)$$

$$f(n)=\left(1+\frac{1}{2}+\frac{1}{3}+\cdots+\frac{1}{2n-1}+\frac{1}{2n}\right)-2\left(\frac{1}{2}+\frac{1}{4}+\cdots+\frac{1}{2n}\right)$$

$$=\left(1+\frac{1}{2}+\frac{1}{3}+\cdots+\frac{1}{2n-1}+\frac{1}{2n}\right)-\left(1+\frac{1}{2}+\cdots+\frac{1}{n}\right)$$

$$=\frac{1}{n+1}+\frac{1}{n+2}+\cdots+\frac{1}{2n}=g(n)$$

## លំហាត់ទី ៤៩៥

គេឱ្យចំនួនគត់វិជ្ជមានពីរ : $X=111\cdots11$ ដែលមានលេខ 1 ចំនួន $m$ ដង

និង $Y=100\cdots05$ ដែលមានលេខ 0 ចំនួន $m-1$ ដង ។

បង្ហាញថា $1+XY$ ជាការេនៃមួយចំនួនគត់វិជ្ជមាន ហើយទាញរកឫសការេវិជ្ជមាននៃ $1+XY$ ។

## ដំណោះស្រាយ

គេបាន $X=1+10+10^2+\cdots+10^{m-1}=\dfrac{10^m-1}{9}$

$Y=10^m+5$

$$1+XY=1+\left(\frac{10^m-1}{9}\right)(10^m+5)$$

$$=\left(\frac{10^m+2}{3}\right)^2$$

$$=\left(\frac{10^m-10+12}{3}\right)^2$$

$$=\left(\frac{10\left(10^{m-1}-1\right)}{3}+4\right)^2$$

$1+XY=\left(3\left(10^{m-1}+10^{m-2}+\cdots+10^2+10\right)+4\right)^2$
$1+XY=(333\cdots34)^2$ ដែលមានលេខ 3 ចំនួន $m-1$ ដង
- រកឫសការេវិជ្ជមាននៃ $1+XY$ : $\sqrt{1+XY}=333\cdots34$ ដែលមានលេខ 3 ចំនួន $m-1$ ដង

## លំហាត់ទី ៤៩៦

គេតាង $s(n)$ ជាផលបូក $n$ តួដំបូងនៃស្វ៊ីត $0;1;1;2;2;3;3;4;4;\cdots;k;k;k+1;k+1;\cdots$ ។
ក. គណនា $s(n)$ ជាអនុគមន៍នៃ $n$ ។
ខ. បង្ហាញថា $s(a+b)-s(a-b)=ab$ ចំពោះគ្រប់ចំនួនគត់វ៉ិឡាទីបវិជ្ជមាន $a$ និង $b$ ដែល $a>b$ ។

### ដំណោះស្រាយ

ក. គណនា $s(n)$ ជាអនុគមន៍នៃ $n$
- បើ $n$ ជាចំនួនគត់គូ :

$$s(n)=\left(0+1+2+3+\cdots+\left(\frac{n}{2}-1\right)\right)+\left(1+2+3+\cdots+\frac{n}{2}\right)$$
$$=\frac{1}{2}\left(\frac{n}{2}-1\right)\left(1+\frac{n}{2}-1\right)+\frac{1}{2}\left(\frac{n}{2}\right)\left(\frac{n}{2}+1\right)=\frac{1}{4}n^2$$

- បើ $n$ ជាចំនួនគត់សេស :

$$s(n)=\left(0+1+2+3+\cdots+\frac{n-1}{2}\right)+\left(1+2+3+\cdots+\frac{n-1}{2}\right)$$
$$=2\times\frac{1}{2}\left(\frac{n-1}{2}\right)\left(1+\frac{n-1}{2}\right)=\frac{1}{4}\left(n^2-1\right)$$

ដូចនេះ $s(n)=\frac{1}{4}n^2$ ចំពោះ $n$ ជាចំនួនគត់គូ
$s(n)=\frac{1}{4}\left(n^2-1\right)$ ចំពោះ $n$ ជាចំនួនគត់សេស

ខ. បង្ហាញថា $s(a+b)-s(a-b)=ab$ ចំពោះគ្រប់ចំនួនគត់វ៉ិឡាទីបវិជ្ជមាន $a$ និង $b$ ដែល $a>b$
គេមាន $a+b+a-b=2a$ ជាចំនួនគត់គូ
នេះបញ្ជាក់ថា $a+b$ និង $a-b$ ជាចំនួនគត់ទាំងពីរ ឬ សេសទាំងពីរ
- បើ $a+b$ & $a-b$ ជាចំនួនគូ : $s(a+b)-s(a-b)=\frac{1}{4}(a+b)^2-\frac{1}{4}(a-b)^2=ab$
- បើ $a+b$ & $a-b$ ជាចំនួនសេស : $s(a+b)-s(a-b)=\frac{1}{4}\left((a+b)^2-1\right)-$

$$\frac{1}{4}\left((a-b)^2-1\right)=ab$$

## លំហាត់ទី ៤៩៧

គេឱ្យត្រីកោណកែង $ABC$ មួយ ដែលមាន $AC=1$, $\widehat{ACB}=90^0$ និង $\widehat{BAC}=x$ ។ $D$ ជាចំណុចមួយនៃអ៊ីប៉ូតេនុស $[AB]$ ហើយដែល $AD=1$ ។ $E$ ជាចំណុចមួយនៃ $[BC]$ ហើយដែល $\widehat{EDC}=x$ ។ បន្ទាត់ $(EF)$ កែងនឹង $[BC]$ ត្រង់ $E$ ហើយជួប $[AB]$ ត្រង់ $F$ ។ គណនា $\lim\limits_{x\to0}EF$ ។

## ដំណោះស្រាយ




ដោយ $(EF)\parallel(AC)$ គេបាន $\dfrac{EF}{AC}=\dfrac{BE}{BC}\Rightarrow EF=\dfrac{BE}{BC}$ ព្រោះ $AC=1$

តែ $\dfrac{BE}{BC}=\dfrac{BE}{BE+EC}\Rightarrow\dfrac{BC}{BE}=\dfrac{BE+EC}{BE}=1+\dfrac{EC}{BE}$

$EF=1:\left(1+\dfrac{BE}{EC}\right)\quad(1)$

ក្នុង $\triangle ACD$ : $\widehat{ACD}=\widehat{ADC}=90^0-\dfrac{x}{2}$

គេទាញបាន $\widehat{DCE}=\dfrac{x}{2}$

តាមទ្រឹស្តីបទស៊ីនុសក្នុង $\triangle CDE$ : $\dfrac{CE}{sinx}=\dfrac{DE}{sin\frac{x}{2}}$

$\dfrac{CE}{DE}=\dfrac{sinx}{sin\frac{x}{2}}=2cos\dfrac{x}{2}\Rightarrow CE=2cos\dfrac{x}{2}\cdot DE$

ក្នុង $\triangle BDE$ : $\widehat{EBD}=90^0-x$ ; $\widehat{BDE}=90^0-\dfrac{x}{2}$

តាមទ្រឹស្ដីបទស៊ីនុសក្នុង $\triangle BDE : \dfrac{DE}{BE} = \dfrac{sin(90^0 - x)}{sin\left(90^0 - \dfrac{x}{2}\right)} = \dfrac{cosx}{cos\dfrac{x}{2}}$

$\Rightarrow BE = \dfrac{DEcos\dfrac{x}{2}}{cosx}$

តាម (1) គេបាន $EF = 1 : \left(1 + \dfrac{BE}{EC}\right) = \dfrac{1}{1 + 2cosx}$

គេបាន $\lim\limits_{x \to 0} EF = \lim\limits_{x \to 0}\left(\dfrac{1}{1 + 2cosx}\right) = \dfrac{1}{3}$

## លំហាត់ទី ៤៩៨

គេឱ្យចំនួនបឋមបីផ្សេងគ្នា $p$ ; $q$ និង $r$ ។
បង្ហាញថា $\sqrt[3]{p}$ ; $\sqrt[3]{q}$ និង $\sqrt[3]{r}$ មិនមែនជា តួបី (មិនចាំបាច់បន្តបន្ទាប់គ្នា) នៃស្វ៊ីតនព្វន្តណាមួយឡើយ ។

### ដំណោះស្រាយ

ឧបមាថា $\sqrt[3]{p}$ ; $\sqrt[3]{q}$ និង $\sqrt[3]{r}$ ជាតួនៃស្វ៊ីតនព្វន្តណាមួយ

នោះមានចំនួនពិត $a$ ; $d$ និងចំនួនគត់ $b$ ; $c$ ដែល $\sqrt[3]{p} = a$ ; $\sqrt[3]{q} = a + bd$ ; $\sqrt[3]{r} = a + cd$

$d = \dfrac{\sqrt[3]{q} - \sqrt[3]{p}}{b} = \dfrac{\sqrt[3]{r} - \sqrt[3]{q}}{c}$

$c\left(\sqrt[3]{q} - \sqrt[3]{p}\right) = b\left(\sqrt[3]{r} - \sqrt[3]{q}\right)$

$(b - c)\sqrt[3]{p} = -c\sqrt[3]{q} + b\sqrt[3]{r}$

តាង $\alpha = b - c$ ; $\beta = -c$ ; $\gamma = b$ ដែលជាចំនួនគត់រ៉ឺឡាទីប ។

គេបាន $\alpha\sqrt[3]{p} = \beta\sqrt[3]{q} + \gamma\sqrt[3]{r}$ ហើយ $\alpha^3 p = \beta^3 q + \gamma^3 r + 3\alpha\beta\gamma\sqrt[3]{pqr}$

$\sqrt[3]{pqr} = \dfrac{\alpha^3 p - \beta^3 q - \gamma^3 r}{3\alpha\beta\gamma}$ ដែលផ្ទុយពីការពិតព្រោះអង្គទី១ អសនិទាន តែអង្គទី២ សនិទាន

ដូចនេះ $\sqrt[3]{p}$ ; $\sqrt[3]{q}$ និង $\sqrt[3]{r}$ មិនមែនជាតួនៃស្វ៊ីតនព្វន្តណាមួយទេ

## លំហាត់ទី ៤៩៩

គេឱ្យ $N = \underbrace{44...4}_{2010}\underbrace{88...8}_{2009}9$ ។ គណនា $\sqrt{N}$ ។

## ដំណោះស្រាយ

$$N=\underbrace{44...4}_{2010}\underbrace{88...8}_{2009}9$$
$$=\underbrace{44...4}_{2010}\times10^{2010}+\underbrace{88...8}_{2009}\times10+9$$
$$=\frac{4}{9}\left(10^{2010}-1\right)\cdot10^{2010}+\frac{8}{9}\left(10^{2009}-1\right)\cdot10+9$$
$$=\frac{4}{9}\left[\left(10^{2010}\right)^2-10^{2010}\right]+\frac{8}{9}\left(10^{2010}-10\right)+9$$
$$=\frac{1}{9}\left[4\left(10^{2010}\right)^2+4\cdot10^{2010}+1\right]=\frac{1}{9}\left(2\cdot10^{2010}+1\right)^2$$

គេបាន $\sqrt{N}=\dfrac{2\cdot10^{2010}+1}{3}$

$$=\frac{2\left(10^{2010}-1\right)}{3}+1$$

ដូចនេះ $\sqrt{N}=\underbrace{666...6}_{2009}7$

## លំហាត់ទី ៥០០

រកតម្លៃនៃ $M=\dfrac{1+2}{2}+\dfrac{1+2+3}{2^2}+\dfrac{1+2+3+4}{2^3}+\dfrac{1+2+3+4+5}{2^4}+\cdots$ ។

## ដំណោះស្រាយ

$$M=\frac{1+2}{2}+\frac{1+2+3}{2^2}+\frac{1+2+3+4}{2^3}+\frac{1+2+3+4+5}{2^4}+\cdots$$
$$\frac{M}{2}=\frac{1+2}{2^2}+\frac{1+2+3}{2^3}+\frac{1+2+3+4}{2^4}+\cdots$$
$$M-\frac{M}{2}=\frac{1+2}{2}+\frac{3}{2^2}+\frac{4}{2^3}+\cdots$$
$$\frac{M}{2}=\frac{3}{2}+\frac{3}{2^2}+\frac{4}{2^3}+\cdots$$
$$\Rightarrow\frac{M}{4}=\frac{3}{4}+\frac{3}{2^3}+\frac{4}{2^4}+\cdots$$
$$\frac{M}{2}-\frac{M}{4}=\frac{3}{2}+0+\frac{1}{2^3}+\frac{1}{2^4}+\cdots$$

$$\frac{M}{4}=\frac{3}{2}+\frac{\frac{1}{2^3}}{1-\frac{1}{2}}=\frac{3}{2}+\frac{1}{4}$$

ដូចនេះ $M=7$

## លំហាត់ទី ៥០១

តាង $\mathbb{N}$ ជាសំណុំចំនួនគត់វិជ្ជមាន ។ $f:\mathbb{N}\to\mathbb{N}$ ជាអនុគមន៍ដែលផ្ទៀងផ្ទាត់លក្ខខណ្ឌ $f(x+1)=f(x)+x$ ចំពោះ $x\in\mathbb{N}$ និង $f(1)=5$ ។ រកតម្លៃនៃ $f(2009)$ ។

### ដំណោះស្រាយ

$f(1)=5: f(x+1)-f(x)=x$

$$f(2)-f(1)=1$$
$$f(3)-f(2)=2$$
$$\cdots\cdots\cdots\cdots$$
$$f(n)-f(n-1)=n-1$$

$$f(n)-f(1)=\frac{(n-1)n}{2}$$

$$f(2009)=5+\frac{2008\cdot 2009}{2}$$

ដូចនេះ $f(2009)=2017041$

## លំហាត់ទី ៥០២

ស្រាយបញ្ជាក់ថា សមីការ $x^5+x=2009$ មានឫសវិជ្ជមានតែមួយគត់ ហើយឫសនោះជាចំនួនអសនិទាន ។ គេឱ្យ $4,5^5\approx 1845$ ; $4,6^5\approx 2059$ ។

### ដំណោះស្រាយ

តាងអនុគមន៍ $f(x)=x^5+x-2009$

$f'(x)=5x^4+1>0$

អនុគមន៍ $f$ កើនជានិច្ចលើ $\mathbb{R}$

$f(4,5)=4,5^5+4,5-2009$

$\quad\quad =1845+4,5-2009<0$

$f(4,6) = 4,6^5 + 4,6 - 2009$

$= 2059 + 4,6 - 2009 > 0$

គេបាន $f(4,5) \times f(4,6) < 0$

តាមទ្រឹស្តីបទតម្លៃកណ្តាល : $f(x) = 0$ មានឫសតែមួយគត់ $x_0$ ដែល $4,5 < x_0 < 4,6$ ។

ឧបមាថា $x_0 = \dfrac{p}{q}$ ជាចំនួនសនិទាន $p,q \in \mathbb{N}^*$ ; $(p;q) = 1$

សមីការទៅជា $\left(\dfrac{p}{q}\right)^5 + \dfrac{p}{q} - 2009 = 0$

$p^5 + p.q^4 = 2009q^5$

$p^5 = q^4(2009q - p) \vdots q$

$\Rightarrow p \vdots q$ មិនពិត

ដូចនេះ $x_0$ ជាចំនួនអសនិទាន

## លំហាត់ទី ៥០៣

ស្រាយបញ្ជាក់ថា ចំពោះគ្រប់ចំនួនពិតវិជ្ជមាន $a,b,c$

នោះ $\dfrac{a}{10b+11c} + \dfrac{b}{10c+11a} + \dfrac{c}{10a+11b} \geq \dfrac{1}{7}$ ។

### ដំណោះស្រាយ

តាង $x = 10$ ; $y = 11$ ; $x + y = 21$

ស្រាយថា $\dfrac{a}{xb+yc} + \dfrac{b}{xc+ya} + \dfrac{c}{xa+yb} \geq \dfrac{3}{x+y}$

តាង $A = xb + yc$

$B = xc + ya$

$C = xa + yb$

តាមវិសមភាព Cauchy-Schwarzs

$$(a+b+c)^2 = \left(\frac{\sqrt{a}}{\sqrt{A}} \cdot \sqrt{aA} + \frac{\sqrt{b}}{\sqrt{B}} \cdot \sqrt{bB} + \frac{\sqrt{c}}{\sqrt{C}} \cdot \sqrt{cC}\right)^2$$

$$(a+b+c)^2 \leq \left(\frac{a}{A} + \frac{b}{B} + \frac{c}{C}\right)(Aa + Bb + Cc) \ (1)$$

ដោយ $Aa + Bb + Cc = (xb + yc)a + (xc + ya)b + (xa + yb)c$

$= x(ab + bc + ca) + y(ac + ab + bc)$

$= (ab + bc + ac)(x + y)$

ហើយ $a^2 + b^2 + c^2 \geq ab + bc + ca$ ; $(a+b+c)^2 \geq 3(ab + bc + ca)$

$(1) \Rightarrow \frac{a}{A}+\frac{b}{B}+\frac{c}{C} \geq \frac{(a+b+c)^2}{(x+y)(ab+bc+ca)}$

ដូចនេះ $\frac{a}{A}+\frac{b}{B}+\frac{c}{C} \geq \frac{3}{x+y}=\frac{1}{7}$

## លំហាត់ទី ៥០៨

ចំណុច $M,K,L$ ត្រូវគេដៅរៀងគ្នាលើជ្រុង $AB$ , $BC$ , $CA$ នៃត្រីកោណ $ABC$ ។ ស្រាយបញ្ជាក់ថា យ៉ាងតិចក្រឡាផ្ទៃនៃត្រីកោណមួយ ក្នុងចំណោមក្រឡាផ្ទៃត្រីកោណ $MAL$, $KBM$ ឬ $LCK$ មិនតិចជាង $\frac{1}{4}$ នៃក្រឡាផ្ទៃត្រីកោណ $ABC$ ។

## ដំណោះស្រាយ




ស្រាយបញ្ជាក់ថា យ៉ាងតិចក្រឡាផ្ទៃនៃត្រីកោណមួយ ក្នុងចំណោមក្រឡាផ្ទៃត្រីកោណ $MAL$, $KBM$ ឬ $LCK$ មិនតិចជាង $\frac{1}{4}$ នៃក្រឡាផ្ទៃត្រីកោណ $ABC$

តាង $S=S_{ABC}$ ; $S_1=S_{AML}$

$S_2=S_{BMK}$ ; $S_3=S_{LCK}$

យើងមាន $\frac{S_1}{S}=\frac{AM}{AB}\cdot\frac{AL}{AC}$

$\frac{S_2}{S}=\frac{BM}{AB}\cdot\frac{BK}{BC}$

$\frac{S_3}{S}=\frac{CL}{AC}\cdot\frac{CK}{BC}$

ឧបមា $\frac{S_1}{S}>\frac{1}{4}$ ; $\frac{S_2}{S}>\frac{1}{4}$ ; $\frac{S_3}{S}>\frac{1}{4}$ ព្រមគ្នា

នោះ $\frac{AM}{AB}\cdot\frac{AL}{AC}\cdot\frac{BM}{AB}\cdot\frac{BK}{BC}\cdot\frac{CL}{AC}\cdot\frac{CK}{BC}>\frac{1}{64}$

រឺ $\frac{AM}{AB}\cdot\frac{BM}{AB}\cdot\frac{AL}{AC}\cdot\frac{CL}{AC}\cdot\frac{BK}{BC}\cdot\frac{CK}{BC}>\frac{1}{64}$ (1)

តាមវិសមភាព Cauchy

$\sqrt{AM\cdot BM}\le\frac{AM+BM}{2}=\frac{AB}{2}$

រឺ $\frac{AM}{AB}\cdot\frac{BM}{AB}\le\frac{1}{4}$

ដូចគ្នា $\frac{AL}{AC}\cdot\frac{CL}{AC}\le\frac{1}{4}$ ; $\frac{BK}{BC}\cdot\frac{CK}{BC}\le\frac{1}{4}$

គុណអង្គ $\frac{AM}{AB}\cdot\frac{BM}{AB}\cdot\frac{AL}{AC}\cdot\frac{CL}{AC}\cdot\frac{BK}{BC}\cdot\frac{CK}{BC}\le\frac{1}{64}$

ផ្ទុយពី (1) $\Rightarrow$ ឧបមាពិត

## លំហាត់ទី ៥០៥

គេឱ្យស្វ៊ីតនៃចំនួនពិត $\langle a_n\rangle_{n\ge1}$ កំណត់ដោយ $a_1=2,\ a_{n+1}=\frac{a_n^2+1}{2}$ ចំពោះ $n\ge 1$ ។ ស្រាយបញ្ជាក់ថា $\sum_{j=1}^{N}\frac{1}{a_j+1}<1$ ចំពោះគ្រប់ចំនួនគត់ធម្មជាតិ $N$ ។

### ដំណោះស្រាយ

- ចំពោះ $N=1$ ផលបូកគឺ $\frac{1}{a_1+1}=\frac{1}{3}<1$ ពិត

- ចំពោះ $N>1$ :

តាមទំនាក់ទំនងកំណើន គេឃើញថា $a_j>1$ ចំពោះគ្រប់ $j$

$$a_{j+1}-a_j=\frac{a_j^2+1}{2}-a_j=\frac{(a_j-1)^2}{2};$$

$$a_{j+1}-1=\frac{a_j^2+1}{a_j}-1=\frac{a_j^2-1}{2}=\frac{(a_j-1)(a_j+1)}{2}$$

នាំឱ្យ $\frac{1}{a_j+1}=\frac{1}{2}\left(\frac{a_j-1}{a_{j+1}-1}\right)$ ចំពោះគ្រប់ $j\ge1$

យើងបាន $\sum_{j=1}^{N}\frac{1}{a_j+1}=\frac{1}{2}\sum_{j=1}^{N}\frac{a_j-1}{a_{j+1}-1}=\frac{1}{2}\sum_{j=1}^{N}\frac{(a_j-1)^2}{(a_{j+1}-1)(a_j-1)}$

$$\sum_{j=1}^{N}\frac{1}{a_j+1}=\sum_{j=1}^{N}\frac{a_{j+1}-a_j}{(a_{j+1}-1)(a_j-1)}$$
$$=\sum_{j=1}^{N}\left(\frac{1}{a_j-1}-\frac{1}{a_{j+1}-1}\right)$$
$$=\frac{1}{a_1-1}-\frac{1}{a_{N+1}-1}<\frac{1}{a_1-1}=1 \quad \text{ពិត}$$

## លំហាត់ទី ៥០៦

គេឱ្យចំនួនគត់រ៉ឺឡាទីប $\alpha,\beta,\lambda$ និង $\mu$ ដែលផ្ទៀងផ្ទាត់សមភាព $\alpha\mu = 1+\beta\lambda$ ។ គេយក $x_0$ ជាតួចែករួមធំបំផុតនៃចំនួនគត់រ៉ឺឡាទីប $a$ និង $b$ ហើយយក $y_0$ ជាតួចែករួមធំបំផុតនៃ $\alpha a+\beta b$ និង $\lambda a+\mu b$ ។ ចូរប្រៀបធៀបចម្ងាយពីចំណុច $M_0(x_0,y_0)$ ទៅអ័ក្សទាំងពីរនៃតម្រុយអរត្តូណរម៉ាល់មួយ ។




ដោយ $x_0$ ជាតួចែករួមធំបំផុតនៃចំនួនគត់រ៉ឺឡាទីប $a$ និង $b$ ហើយយក $y_0$ ជាតួចែករួមធំបំផុតនៃ $\alpha a+\beta b$ និង $\lambda a+\mu b$

នោះគេបាន $(x_0|a \wedge x_0|b) \Rightarrow x_0|\left(\alpha a+\beta b\right)=A$ និង $(x_0|a \wedge x_0|b) \Rightarrow$ $x_0|\left(\lambda a+\mu b\right)=B$

ដូចនេះ $x_0|y_0 \quad (1)$

ម្យ៉ាងទៀត $y_0|A=\alpha a+\beta b \Rightarrow y_0|\left(\alpha\mu a+\beta\mu b\right)$

$y_0|B=\lambda a+\mu b \Rightarrow y_0|\left(\beta\lambda a+\beta\mu b\right)$

គេបាន $y_0|\left(\alpha\mu-\beta\lambda\right)b=b$ ព្រោះ $\alpha\mu-\beta\lambda=1$

ដោយ $(y_0|a \wedge y_0|b) \Rightarrow y_0|x_0 \quad (2)$

តាម $(1)\&(2) \Rightarrow x_0=y_0$

ដូចនេះ ចំណុច $M_0(x_0,y_0)$ មានចម្ងាយស្មើពីអ័ក្សទាំងពីរនៃតម្រុយអរត្តូណរម៉ាល់

## លំហាត់ទី ៥០៧

គេឱ្យអនុគមន៍ពហុធា $f(x)=a_nx^n+a_{n-1}x^{n-1}+\cdots+a_1x+a_0$ ដែលមានលេខមេគុណជាចំនួនគត់រ៉ឺឡាទីប ។ គេដឹងថាមានចំនួនគត់រ៉ឺឡាទីប $x_0$ ដែល $f(x_0)=p$ ជាចំនួនបឋម ។ បង្ហាញថា មានចំនួនគត់រ៉ឺឡាទីប $\beta$ ច្រើនរាប់មិនអស់ដែល $f(\beta)$ មិនមែនជាចំនួនបឋម ។

### ដំណោះស្រាយ

គេមាន $f(x_0)=a_nx_0^n+a_{n-1}x_0^{n-1}+\cdots+a_1x_0+a_0=p$

គេពិនិត្យ $f(x_0+kp),k\in\mathbb{Z}$

$f(x_0+kp)=a_n(x_0+kp)^n+a_{n-1}(x_0+kp)^{n-1}+\cdots+a_1(x_0+kp)+a_0$

$=\left(a_nx_0^n+a_n\sum_{i=1}^{n}C(n,i)x_0^{n-i}(kp)^i\right)+$

$\left(a_{n-1}x_0^{n-1}+a_{n-1}\sum_{i=1}^{n-1}C(n-1,i)x_0^{n-1-i}(kp)^i\right)+\cdots+(a_1x_0+a_1kp)+a_0$

$=\left(a_nx_0^n+a_{n-1}x_0^{n-1}+\cdots+a_1x_0+a_0\right)+\left(a_n\sum_{i=1}^{n}C(n,i)x_0^{n-i}(kp)^i+\cdots+a_1kp\right)$

$=p+p\left(a_n\sum_{i=1}^{n}C(n,i)x_0^{n-i}k^ip^{i-1}+a_{n-1}\sum_{i=1}^{n-1}C(n-1,i)x_0^{n-1-i}k^ip^{i-1}+\cdots+a_1k\right)$

$f(x_0+kp)=p\left(1+a_n\sum_{i=1}^{n}C(n,i)x_0^{n-i}k^ip^{i-1}+a_{n-1}\sum_{i=1}^{n-1}C(n-1,i)x_0^{n-1-i}k^ip^{i-1}\right.$
$\left.+\cdots+a_1k\right)$

គេទាញបាន $p|f(x_0+kp),k\in\mathbb{Z}$

ដូចនេះ មានចំនួនគត់រ៉ឺឡាទីប $\beta$ ច្រើនរាប់មិនអស់ដែល $f(\beta)$ មិនមែនជាចំនួនបឋម

## លំហាត់ទី ៥០៨

ស្វ៊ីត $(x_n)$ កំណត់ដោយ $x_1=1,x_2=1$ និង $x_{n+1}=x_n+x_{n-1}$ ចំពោះ $n\geq 2$ ។

ស្វ៊ីត $(y_n)$ កំណត់ដោយ $y_n=|x_{n+4}x_{n-2}-x_{n+2}x_n|$ ចំពោះ $n\geq 3$ ។

ស្វ៊ីត $(z_n)$ កំណត់ដោយ $z_n-9=4x_{n-2}x_nx_{n+2}x_{n+4}$ ចំពោះ $n\geq 3$ ។

១-បង្ហាញថា $(y_n)$ ជាស្វ៊ីតថេរចំពោះ $n\geq 3$ ។ ទាញរកតម្លៃតួ $y_{3042011}$ ។

២- បង្ហាញថា តួនីមួយៗនៃស្វ៊ីត $(z_n)$ ជាការេប្រាកដ ។

## ដំណោះស្រាយ

១-បង្ហាញថា $(y_n)$ ជាស្វ៊ីតថេរចំពោះ $n \geq 3$

$y_n = |x_{n+4}x_{n-2} - x_{n+2}x_n|$

$= |(x_{n+3} + x_{n+2})x_{n-2} - x_{n+2}x_n| = |x_{n+3}x_{n-2} + x_{n+2}(x_{n-2} - x_n)|$

$= |x_{n+3}x_{n-2} + x_{n+2}(x_{n-2} - x_{n-1} - x_{n-2})| = |x_{n+3}x_{n-2} - x_{n+2}x_{n-1}|$

$= |x_{n+3}(x_{n-1} - x_{n-3}) - x_{n+2}x_{n-1}| = |-x_{n+3}x_{n-3} - x_{n-1}(x_{n+2} - x_{n+3})|$

( ព្រោះ $x_{n-1} = x_{n-2} + x_{n-3} \Rightarrow x_{n-2} = x_{n-1} - x_{n-3}$ )

$= |-x_{n+3}x_{n-3} - x_{n-1}(x_{n+2} - x_{n+2} - x_{n+1})|$

$= |x_{n+3}x_{n-3} - x_{n+1}x_{n-1}|$

$y_n = \left|x_{(n-1)+4}x_{(n-1)-2} - x_{(n-1)+2}x_{(n-1)}\right|, \ \forall n \geq 3$

ដូចនេះ $(y_n)$ ជាស្វ៊ីតថេរចំពោះ $n \geq 3$

- ទាញរក $y_{3042011}$

$y_n = y_{n-1}, \ \forall n \geq 3 \Rightarrow y_{3042011} = y_{3042010} = \cdots = y_4 = y_3 = |x_7x_1 - x_5x_3| = |13 \cdot 1 - 5 \cdot 2| = 3$

២- បង្ហាញថា តួនីមួយៗនៃស្វ៊ីត $(z_n)$ ជាការេប្រាកដ

គេមាន $y_n = y_{n-1} = \cdots = y_{3042011} = 3$ ហើយគេបាន :

$y_n = |x_{n+4}x_{n-2} - x_{n+2}x_n| = 3 \Rightarrow x_{n+4}x_{n-2} - x_{n+2}x_n = \pm 3 \Rightarrow x_{n+4}x_{n-2} = x_{n+2}x_n \pm 3$

ម្យ៉ាងទៀត $z_n - 9 = 4x_nx_{n+2}(x_nx_{n+2} \pm 3) \Rightarrow z_n = (\pm 3)^2 + 2(\pm 3)(2x_nx_{n+2}) + (2x_nx_{n+2})^2$

$z_n = (\pm 3 + 2x_nx_{n+2})^2$ ជាការេប្រាកដចំពោះគ្រប់ $n \geq 3$

## លំហាត់ទី ៥០៩

គេឱ្យ $a$ និង $X$ ជាចំនួនគត់រ៉ឺឡាទីបដែល $a > 1, X > 0$ ។ $k$ ជាចំនួនគត់ រ៉ឺឡាទីប មិនអវិជ្ជមាន និង $c_j$ ជាចំនួនគត់រ៉ឺឡាទីបដែល $0 \leq c_j < a$ ចំពោះ $j = 0, 1, \ldots, k$ ។ បង្ហាញថា $X$ អាចសរសេរបានតែមួយបែបគត់ជារាង $X = \sum_{j=0}^{k} c_j a^j$ ។

## ដំណោះស្រាយ

- តាមវិធីចែកអឺគ្លីតបន្តបន្ទាប់គេបាន : $X = aq_0 + c_0, 0 \leq c_0 < a$

$q_0 = aq_1 + c_1, 0 \leq c_1 < a$

$q_1 = aq_2 + c_2, 0 \leq c_2 < a$

.................................

$q_{k-1} = a \times 0 + c_k, 0 < c_k < a$

គេបានស្វ៊ីតនៃផលចែក : $X > q_0 > q_1 > q_2 > \cdots > q_{k-1} > q_k = 0$

$X = aq_0 + c_0$

$= a(aq_1 + c_1) + c_0 = a^2 q_1 + ac_1 + c_0$

$= a^3 q_2 + c_2 a^2 + c_1 a + c_0$

.......................................

$= a^k q_{k-1} + c_{k-1} a^{k-1} + \cdots + c_1 a + c_0$

$= c_k a^k + c_{k-1} a^{k-1} + \cdots + c_1 a + c_0, \ (c_{k-1} = c_k)$ ដែល $0 \le c_j < a, j = 0, 1, \ldots, k$

ដូចនេះ $X = c_k a^k + c_{k-1} a^{k-1} + \cdots + c_1 a + c_0 = \sum_{j=0}^{k} c_j a^j$

- បង្ហាញថា $X$ អាចសរសេរបានតែមួយបែបគត់

ឧបមាថា $X$ អាចសរសេរបានពីរបែប :

$X = c_k a^k + c_{k-1} a^{k-1} + \cdots + c_1 a + c_0, 0 \le c_j < a$

$X = c'_k a^k + c'_{k-1} a^{k-1} + \cdots + c'_1 a + c'_0, 0 \le c'_j < a$

គេបាន $\left(c_k - c'_k\right) a^k + \left(c_{k-1} - c'_{k-1}\right) a^{k-1} + \cdots + \left(c_1 - c'_1\right) a + \left(c_0 - c'_0\right) = 0$

បើ $X$ អាចសរសេរបានពីរបែបនោះគេអាចរកបានចំនួនគត់ $j$ ដែលតូចជាងគេ ហើយ $c_j \neq c'_j$ ហើយគេបាន :

$\left(c_k - c'_k\right) a^k + \left(c_{k-1} - c'_{k-1}\right) a^{k-1} + \cdots + \left(c_{j+1} - c'_{j+1}\right) a^{j+1} + \left(c_j - c'_j\right) a^j = 0$

$\Rightarrow a^j \left( \left(c_k - c'_k\right) a^{k-j} + \left(c_{k-1} - c'_{k-1}\right) a^{k-1-j} + \cdots + \left(c_{j+1} - c'_1\right) a^1 + \left(c_j - c'_j\right) \right) = 0$

$\Rightarrow \left(c_k - c'_k\right) a^{k-j} + \left(c_{k-1} - c'_{k-1}\right) a^{k-1-j} + \cdots + \left(c_{j+1} - c'_1\right) a = c'_j - c_j$

$\Rightarrow \left( \left(c_k - c'_k\right) a^{k-j-1} + \left(c_{k-1} - c'_{k-1}\right) a^{k-1-j-1} + \cdots + \left(c_{j+1} - c'_{j+1}\right) \right) a = c'_j - c_j$

$\Rightarrow a | \left(c'_j - c_j\right)$

តែ $(0 \le c_j < a) \wedge \left(0 \le c'_j < a\right) \Rightarrow \left(-a < c'_j - c_j < a\right)$

នេះបញ្ជាក់ថា $a | \left(c'_j - c_j\right)$ ជាករណីមិនអាចមាន ។

ដូចនេះ $X$ អាចសរសេរបានតែមួយបែបគត់ជារាង $X = \sum_{j=0}^{k} c_j a^j$

## លំហាត់ទី ៥១០

រង្វង់មួយមានផ្ចិត $O$ និងកាំ $R$ ចារឹកក្រៅត្រីកោណ $ABC$ មួយដែលមានបរិមាត្រ $2p$ ។ ត្រីកោណ $ABC$ នេះចារឹកក្រៅរង្វង់មួយទៀតដែលមានផ្ចិត $I$ និងកាំ $r$ ។ បង្ហាញថា $4R+r=p\left(tan\frac{A}{2}+tan\frac{B}{2}+tan\frac{C}{2}\right)$ ។

## ដំណោះស្រាយ




តាមរូបមន្តកាំរង្វង់ចារឹកក្នុងត្រីកោណ $ABC$ គេបាន :

$$r=(p-a)tan\frac{A}{2}=(p-b)tan\frac{B}{2}=(p-c)tan\frac{C}{2}$$

$$\Rightarrow \frac{r}{p-a}=tan\frac{A}{2},\frac{r}{p-b}=tan\frac{B}{2},\frac{r}{p-c}=tan\frac{C}{2}$$

$$\Rightarrow tan\frac{A}{2}+tan\frac{B}{2}+tan\frac{C}{2}=\frac{r}{p-a}+\frac{r}{p-b}+\frac{r}{p-c}$$

តាង $K=tan\frac{A}{2}+tan\frac{B}{2}+tan\frac{C}{2}$

$$K=\frac{r\left[3p^2-2(a+b+c)p+ab+bc+ca\right]}{(p-a)(p-b)(p-c)}=\frac{r\left(-p^2+ab+bc+ca\right)}{(p-a)(p-b)(p-c)}\quad(1)$$

តាមរូបមន្តផ្ទៃក្រឡានៃត្រីកោណ $ABC$ :

$$S=\sqrt{p(p-a)(p-b)(p-c)}=pr$$

$$\Rightarrow p(p-a)(p-b)(p-c)=p^2r^2$$

គេបាន $(p-a)(p-b)(p-c)=pr^2 \quad (2)$

តាម (1) និង (2) យើងបាន $K=\frac{r\left(-p^2+ab+bc+ca\right)}{pr^2}=\frac{-p^2+ab+bc+ca}{pr}$

តាមរូបមន្តផ្សេងទៀតនៃផ្ទៃក្រឡាត្រីកោណ $ABC$ :

$$S=\frac{abc}{4R}=pr$$

$$\Rightarrow 4Rpr=abc$$

តាម (2) :

$$abc+(p-a)(p-b)(p-c)=4Rpr+pr^2$$

$$abc+\left(p^3-(a+b+c)p^2+(ab+bc+ca)p\right)-abc=pr(4R+r)$$

$$p\left(p^2-(a+b+c)p+ab+bc+ca\right)=pr(4R+r)$$

$$p^2-2p^2+ab+bc+ca=r(4R+r)$$

តាម (3) :

$$K=\frac{4(4R+r)}{pr}=\frac{4R+r}{p}$$

$$pK=4R+r$$

$$\Rightarrow p\left(tan\frac{A}{2}+tan\frac{B}{2}+tan\frac{C}{2}\right)=4R+r$$

ដូចនេះ $4R+r=p\left(tan\frac{A}{2}+tan\frac{B}{2}+tan\frac{C}{2}\right)$

## លំហាត់ទី ៥១១

គេបានប្រើទ្រុងចំនួន 99 គ្រឿងសម្រាប់ដឹកជញ្ជូនកូនមាន់ចំនួន $7y38x5$ ក្បាល ទៅកាន់កសិដ្ឋាន មួយ ។ រកលេខ $x$ និង $y$ ក្នុងរបាប់គោលដប់ដោយដឹងថា ក្នុងទ្រុងនីមួយៗមានចំនួនកូនមាន់ស្មើៗគ្នា ។

## ដំណោះស្រាយ

គេត្រូវរកលេខ $x$ និង $y$ ក្នុងប្រព័ន្ធរបាប់គោលដប់ដើម្បីឱ្យចំនួន $7y38x5$ ចែកដាច់នឹង 99 ។

គេមាន $gcd(9,11)=1$

ដើម្បីឱ្យ $7y38x5$ ចែកដាច់នឹង $99=9\times 11$ លុះត្រាតែ

$y+y+3+8+x\equiv 0\ (\mathrm{mod}\,9)$ និង $5+8+y-x-3-7\equiv 0\ (\mathrm{mod}\,11)$

$\Leftrightarrow (x+y\equiv 4\ (\mathrm{mod}\,9))\wedge(-x+y\equiv -3\ (\mathrm{mod}\,11))$

$\Leftrightarrow (x+y=9m+4)\wedge(-x+y=11n-3)$

ដោយ $0\le x,y\le 9\Rightarrow 0\le x+y\le 18, -9\le -x+y\le 9$ នោះគេទាញបាន :

$(x+y=4)\wedge(-x+y=3),(x+y=4)\wedge(-x+y=8),(x+y=13)\wedge(-x+y=-3),(x+y=13)\wedge(-x+y=8)$

ដូចនេះ $x=8, y=5$

## លំហាត់ទី ៥១២

សមីការ $ax^2+2010x+c=x$ គ្មានឫសទេនៅក្នុងសំណុំចំនួនពិត ។
បង្ហាញថា សមីការ $a\left(ax^2+2010x+c\right)+2010\left(ax^2+2010x+c\right)+c=x$ គ្មានឫសនៅក្នុងសំណុំចំនួនពិតដែរ ។

### ដំណោះស្រាយ

បង្ហាញថា សមីការ $a\left(ax^2+2010x+c\right)+2010\left(ax^2+2010x+c\right)+c=x$ គ្មានឫសនៅក្នុងសំណុំចំនួនពិតដែរ

តាង $t(x)=ax^2+2010x+c$

ដោយសមីការ $t(x)=x$ គ្មានឫសជាចំនួនពិត នោះឬមួយ $t(x)<x$ ឬមួយ $t(x)>x$ ចំពោះគ្រប់ចំនួនពិត $x$ ។

គេទាញបាន ឬមួយ $t(t(x))<t(x)<x$ ឬមួយ $t(t(x))>t(x)>x$ ចំពោះគ្រប់ចំនួនពិត $x$ ។ បានន័យថា :

- ឬមួយ $a\left(ax^2+2010x+c\right)+2010\left(ax^2+2010x+c\right)+c<x$ ចំពោះគ្រប់ចំនួនពិត $x$ ។
- ឬមួយ $a\left(ax^2+2010x+c\right)+2010\left(ax^2+2010x+c\right)+c>x$ ចំពោះគ្រប់ចំនួនពិត $x$ ។

ដូចនេះ សមីការ $a\left(ax^2+2010x+c\right)+2010\left(ax^2+2010x+c\right)+c=x$ គ្មានឫសនៅក្នុងសំណុំចំនួនពិតដែរ

## លំហាត់ទី ៥១៣

ពហុធា $P(x)=x^n+a_1x^{n-1}+a_2x^{n-2}+\cdots+a_{n-1}x+1$ មានលេខមេគុណ $a_1,a_2,\ldots,a_{n-1}$ ជាចំនួនមិនអវិជ្ជមាន ។
គេដឹងថាពហុធា $P(x)$ មាន $n$ ឫសសុទ្ធតែជាចំនួនពិត ។
បង្ហាញថា $P(2010)\geq\left(2\sqrt{2010}\right)^n$ ។

### ដំណោះស្រាយ

ដោយលេខមេគុណ $a_1,a_2,\ldots,a_{n-1}$ ជាចំនួនមិនអវិជ្ជមាន នោះ ឫស $x_1,x_2,\ldots,x_n$ ជាចំនួនពិតមិនវិជ្ជមាន ។

តាង $\alpha_i=-x_i,\ i=1,2,\ldots,n$ នោះគេបាន $\alpha_i\geq 0$ ហើយ $P(x)=(x+\alpha_1)(x+$

$\alpha_2)\cdots(x+\alpha_n)$

$P(2010)=(2010+\alpha_1)(2010+\alpha_2)\cdots(2010+\alpha_n)$

ម្យ៉ាងទៀត $2010+\alpha_i\geq 2\sqrt{2010\cdot\alpha_i},\ i=1,2,...,n$

គេបាន $P(2010)=(2010+\alpha_1)(2010+\alpha_2)\cdots(2010+\alpha_n)$

$\geq 2^n\sqrt{2010^n\cdot\alpha_1\cdot\alpha_2\cdots\alpha_n}$

ដូចនេះ $P(2010)\geq\left(2\sqrt{2010}\right)^n$ ព្រោះ $\alpha_1\cdot\alpha_2\cdots\alpha_n=1$

## លំហាត់ទី ៥១៨

គេមានចំនួនគត់វិជ្ជមាន $r$ ដែលជាសំណល់ក្នុងវិធីចែកអឺគ្លីតនៃចំនួនគត់វិជ្ជមាន $a$ និង $b$ ។

១. បង្ហាញថា $2^r-1$ ជាសំណល់ ក្នុងវិធីចែកអឺគ្លីតនៃចំនួនគត់វិជ្ជមាន $2^a-1$ និង $2^b-1$ ។

២. គេតាង $\mu$ ជាតួចែករួមធំបំផុតនៃ $a$ និង $b$ ។ បង្ហាញថា $2^\mu-1$ ជាតួចែករួមធំបំផុតនៃ $2^a-1$ និង $2^b-1$ ។

### ដំណោះស្រាយ

១. បង្ហាញថា $2^r-1$ ជាសំណល់ ក្នុងវិធីចែកអឺគ្លីតនៃចំនួនគត់វិជ្ជមាន $2^a-1$ និង $2^b-1$

តាមវិធីចែកអឺគ្លីត $a=bq+r, 0<r<b$ គេបាន :

$$2^a-1=2^{bq+r}-2^r+2^r-1=2^r\left(2^b-1\right)\left(\left(2^b\right)^{q-1}+\cdots+2^b+1\right)+(2^r-1)$$

$$=\left(2^b-1\right)\left(\left(2^{b(q-1)+r}+\cdots+2^{b+r}+2^r\right)\right)+(2^r-1), 0<2^r-1<2^b-1$$

ដូចនេះ $2^r-1$ ជាសំណល់ ក្នុងវិធីចែកអឺគ្លីតនៃចំនួនគត់វិជ្ជមាន $2^a-1$ និង $2^b-1$

២. បង្ហាញថា $2^\mu-1$ ជាតួចែក រួមធំបំផុតនៃ $2^a-1$ និង $2^b-1$ :

តាង $r_0=a, r_1=b$ ។ តាមវិធីចែកអឺគ្លីតបន្តបន្ទាប់ :

$r_0=r_1q_1+r_2\,(0<r_2<r_1), r_1=r_2q_2+r_3\,(0\leq r_3<r_2),...,r_{n-3}=r_{n-2}q_{n-2}+r_{n-1}\,(0\leq r_{n-1}<r_{n-2}), r_{n-2}=r_{n-1}q_{n-1}$

គេបាន $gcd(a,b)=r_{n-1}=\mu$

តាង $R_0=2^a-1, R_1=2^b-1$ ។ តាមវិធីចែកអឺគ្លីតបន្តបន្ទាប់ និង លទ្ធផលខាងលើ

$R_0=R_1Q_1+R_2, R_2=2^{r_1}-1$

$R_1=R_2Q_2+R_3, R_3=2^{r_2}-1$

.............................................

$R_{n-3}=R_{n-2}Q_{n-2}+R_{n-1}, R_{n-1}=2^{r_{n-1}}-1$

$R_{n-2} = R_{n-1}Q_{n-1}$

គេបាន $gcd(R_0, R_1) = 2^{\mu} - 1$

## លំហាត់ទី ៥១៥

រកសំណល់នៃវិធីចែក $2010^{2009}$ នឹង 13 ។

### ដំណោះស្រាយ

$2010^{2009} = (13 \times 154 + 8)^{2009}$

$\equiv 8^{2009} \pmod{13}$

ដោយ $(8;13) = 1$ តាម Fermat:

$8^{12} \equiv 1 \pmod{13}$

$\Rightarrow 8^{2009} = 8^{12\times 167+5}$

$\equiv 8^5 \pmod{13}$

$8^5 = (8^2)^2 \cdot 8$

$= (13 \times 5 - 1)^2 \cdot 8$

$\equiv 8 \pmod{13}$

ដូចនេះ $2010^{2009}$ ចែកនឹង 12 សំណល់ 8

## លំហាត់ទី ៥១៦

បង្ហាញថា $A = 1^{2008} + 2^{2008} + 3^{2008} + 4^{2008} - 5^{2008} - 6^{2008} - 7^{2008} - 8^{2008} - 9^{2008}$ ចែកដាច់នឹង 5 ។

### ដំណោះស្រាយ

គេមាន $A = (1^{2008} - 6^{2008}) + (2^{2008} - 7^{2008}) + (3^{2008} - 8^{2008}) + (4^{2008} - 9^{2008}) - 5^{2008}$

$A = (1-6)k_1 + (2-7)k_2 + (3-8)k_3 + (4-9)k_4 - 5k_5$

$= (-5)k_1 + (-5)k_2 + (-5)k_3 + (-5)k_4 - 5k_5$

$= 5(-k_1 - k_2 - k_3 - k_4 - k_5)$

ដែល $k_i$ ជាចំនួនគត់រ៉ឺឡាទីបវិជ្ជមាន ។

$A = 5K$ ដែល $K$ ជាចំនួនគត់រ៉ឺឡាទីបអវិជ្ជមាន ។

## លំហាត់ទី ៥១៧

រកតម្លៃធំបំផុតនៃ $A = sinx_1.sinx_2...sinx_{2010}$ ដោយដឹងថា $tanx_1.tanx_2...tanx_{2010} = 1$ ។

### ដំណោះស្រាយ

យើងមាន $1 = sin^2x_1 + cos^2x_1 \geq 2sinx_1cosx_1$

$1 = sin^2x_2 + cos^2x_2 \geq 2sinx_2cosx_2$

..................................

$1 = sin^2x_{2010} + cos^2x_{2010} \geq 2sinx_{2010}cosx_{2010}$

គុណអង្គ : $1 \geq 2^{2010}.A.cosx_1.cosx_2...cosx_{2010}$

ដោយ $tanx_1.tanx_2...tanx_{2010} = 1$

$\Rightarrow A = cosx_1.cosx_2...cosx_{2010}$

គេបាន $1 \geq 2^{2010}.A^2$

$$A \leq \frac{1}{2^{1005}}$$

ដូចនេះ $A$ ធំបំផុត $A = \frac{1}{2^{1005}}$

## លំហាត់ទី ៥១៨

រកគ្រប់គូ $(x, y)$ ជាឫសនៃសមីការ $2007^{sin^2x} + 2007^{cos^2x} = 2009 + cos2y$ ។

### ដំណោះស្រាយ

$2007^{sin^2x} + 2007^{cos^2x} = 2009 + cos2y$

$2007^{sin^2x} + 2007^{1-sin^2x} - 2008 = 1 + cos2y$

$$2007^{sin^2x} + \frac{2007}{2007^{sin^2x}} - 2008 = 2cos^2y \quad (1)$$

តាង $u = 2007^{sin^2x}$ ; $x \in \mathbb{R}$

លក្ខខណ្ឌ $1 \leq U \leq 2007$

ពី (1) $U + \frac{2007}{U} - 2008 = 2cos^2y$

$$\frac{U^2 - 2008U + 2007}{U} = 2cos^2y$$

$$\frac{(U-1)(U-2007)}{U}=2cos^2y \quad (2)$$

ដោយ $1\le U\le 2007 \Rightarrow \frac{(U-1)(U-2007)}{U}\le 0$

ម្យ៉ាងទៀត $cos^2y\ge 0$

(2) ទៅជា $\begin{cases}(U-1)(U-2007)=0\\ cos^2y=0\end{cases}$

$\Leftrightarrow \begin{cases}U=1\\ cosy=0\end{cases}$ ឬ $\begin{cases}U=2007\\ cosy=0\end{cases}$

$\Leftrightarrow \begin{cases}2007^{sin^2x}=1\\ cosy=0\end{cases}$ ឬ $\begin{cases}2007^{sin^2x}=2007\\ cosy=0\end{cases}$

$\Leftrightarrow \begin{cases}sinx=0\\ cosy=0\end{cases}$ ឬ $\begin{cases}sinx=\pm 1\\ cosy=0\end{cases}$

$\begin{cases}x=k\pi\\ y=\frac{\pi}{2}+k\pi\end{cases}$ ឬ $\begin{cases}x=\frac{\pi}{2}+k\pi\\ y=\frac{\pi}{2}+k'\pi\end{cases}$ ដែល $(k,k'\in\mathbb{Z})$

## លំហាត់ទី ៥១៩

រកពហុធា $P(x)$ ដឺក្រេទី៤ ផ្ទៀងផ្ទាត់លក្ខខណ្ឌពីរខាងក្រោម :

1) $P(0)=0$

2) $P(x)-P(x-1)=x(x+1)(2x+1)$ គ្រប់ $x\in\Re$ ។

### ដំណោះស្រាយ

សម្មតិកម្ម $\begin{cases}1)\ P(0)=0\\ 2)\ p(x)-P(x-1)=x(x+1)(2x+1) \text{ គ្រប់ } x\in\Re\end{cases}$

មាន : $x=0:\ P(-1)=0$

$x=-1:\ P(-2)=0$

$\Rightarrow x=0;-1;-2$ ជាឫសនៃ $P(x)=0$

តែ $P(x)$ ជាពហុធាដឺក្រេទី៤ គេបាន $P(x)=x(x+1)(x+2)(ax+b)$

$\Rightarrow P(x-1)=(x-1)x(x+1)[a(x-1)+b]$

$P(x)-P(x-1)=x(x+1)\left[(x+2)(ax+b)-(x-1)^2a-b(x-1)\right]$

តែ $P(x)-P(x)=x(x+1)(2x+1)$

ផ្ទឹមមេគុណ :

$2x+1=(x+2)(ax+b)-(x-1)^2a-(x-1)b$

$=ax^2+(2a+b)x+2b-ax^2+2ax-a-bx+b$

$=4ax+3b-a$

$\Rightarrow \begin{cases} 4a=2 \\ 3b-a=1 \end{cases}$ រឺ $\begin{cases} a=\frac{1}{2} \\ b=\frac{1}{2} \end{cases}$

ដូចនេះ $P(x)=\frac{1}{2}x(x+1)^2(x+2)=\frac{1}{2}x^4+2x^3+\frac{5}{2}x^2+x$

## លំហាត់ទី ៥២០

តាង $a_1;a_2;a_3...$ ជាស្វ៊ីតនៃចំនួនគត់ដែលបំពេញទំនាក់ទំនង $a_{n-1}+a_n=2n$ ចំពោះគ្រប់ $n\geq 2$ ។ បើ $a_1=100$ គណនា $a_{2009}$ ។

### ដំណោះស្រាយ

សម្មតិកម្ម $\begin{cases} a_{n-1}+a_n=2n \ ; \ n\geq 2 \\ a_1=100 \end{cases}$

យើងបាន $a_n=2n-a_{n-1}$

$n=2: \ a_2=4-a_1=-96$

$n=3: \ a_3=6-a_2=102$

សង្កេត : $a_{n-1}+a_n=2n$

$\Rightarrow a_{n-2}+a_{n-1}=2(n-1)$

---

ដកអង្គ : $a_n-a_{n-2}=2$

រឺ $a_n=2+a_{n-2}$

$\Rightarrow a_n=4+a_{n-4}$

----------------------

$a_n=4+a_{n-4}$

$=6+a_{n-6}$

$= 8 + a_{n-8}$

$= ..........$

$$a_n = \begin{cases} n-2-96 = n-98 \text{ បើ } n \text{ គូ} \\ n-1+100 = n+99 \text{ បើ } n \text{ សេស} \end{cases}$$

គេបាន $a_{2009} = 2009 + 99$

ដូចនេះ $a_{2009} = 2108$

## លំហាត់ទី ៥២១

កំណត់អនុគមន៍ $f : \mathfrak{R} \to \mathfrak{R}$ ដែលចំពោះគ្រប់ចំនួនពិត $x, y$
$f[x - f(y)] = 1 - x - y$ ។

### ដំណោះស្រាយ

$f[x - f(y)] = 1 - x - y \quad (1)$ $\bullet y = 0$ និង $x = a + f(0)$

$f(a + f(0) - f(0)) = 1 - a - f(0)$

$f(a) = 1 - a - f(0) \quad (2)$

$\bullet x = a$ ; $k = 1 - f(0)$ ថេរ

$\Rightarrow f(x) = -x + k \quad (3)$

គ្រប់ $x, y \in \mathbb{R}$ :

$f(x - f(y)) = -(x - f(y)) + k$

$= -x + (-y + k) + k$

$= -x - y + 2k \quad (4)$

(1) និង (4) :

$1 - x - y = -x - y + 2k$

$\Rightarrow k = \dfrac{1}{2}$

ដូចនេះ $f(x) = -x + \dfrac{1}{2}$ ; $x \in \mathbb{R}$

## លំហាត់ទី ៥២២

គេឱ្យរង្វង់ផ្ចិត $O$ កាំ $r$ និងត្រីកោណ $ABC$ ប្រែប្រួល ចារឹកក្រៅរង្វង់ ។ បន្ទាត់កាត់តាម $O$ កាត់ $AB$, $AC$ រៀងគ្នាត្រង់ $M$ និង $N$ ។ កំណត់ទីតាំងចំណុច $A$ និង អង្កត់ $MN$ ដើម្បីឱ្យផ្ទៃក្រឡាត្រីកោណ $AMN$ មានតម្លៃ តូចបំផុត ។

# ដំណោះស្រាយ




ឧបមាថា រង្វង់ផ្ចិត $O$ ប៉ះ $AB,AC$ ត្រង់ $H,K$ រៀងគ្នា

$S_{AMN}=S_{AOM}+S_{AON}$

$=\frac{1}{2}r(AM+AN)$

$\Rightarrow S_{AMN}\geq r\sqrt{AM.AN}$ (1)

គូស $MI\perp AN,\ I\in AC$

$\Rightarrow MI\leq MA$

$(1): S_{AMN}\geq r\sqrt{MI.AN}$

$S_{MAN}\geq r\sqrt{2S_{AMN}}$

$\Rightarrow S_{AMN}\geq 2r^2$

ដូចនេះ $S_{AMN}$ តូចបំផុតគឺ $S_{AMN}=2r^2$

សមភាព $\begin{cases}AM=AN\\AM=MI\end{cases}$ រឺ $\begin{cases}AM=AN\\\widehat{BAC}=90^0\end{cases}$

ទាញបាន $\triangle ABC$ កែងត្រង់ $A$ នោះ $AHOK$ ជាការេជ្រុង $r$

$\Rightarrow OA=r\sqrt{2}$

ដូចនេះ ចំណុច $A$ នៅលើរង្វង់ផ្ចិត $O$ កាំ $OA=r\sqrt{2}$ ។

ដោយ $AM=AN$ ; $\triangle AMN$ កែងសមបាត នោះ $OA\perp MN$

## លំហាត់ទី ៥២៣

គេឱ្យរង្វង់បីកាត់គ្នាពីរៗដូចរូបខាងក្រោម ។ សង់រូបឡើងវិញហើយបង្ហាញថាចំណុច $E,D$ និង $F$ នៅលើបន្ទាត់តែមួយ ។




### ដំណោះស្រាយ




គេមាន

$\widehat{EDB}=\widehat{MAB}$

$\widehat{MAB}=\widehat{BCF}$

គេបាន $\widehat{EDB}=\widehat{BCF}$

តែ $\widehat{BCF}+\widehat{BDF}=180^0$

នោះ $\widehat{EDB}+\widehat{BDF}=180^0$

ដូចនេះ ចំណុច $E,D$ និង $F$ នៅលើបន្ទាត់តែមួយ

## លំហាត់ទី ៥២៤

បង្ហាញថា $1^{2009}+2^{2009}+3^{2009}+\cdots+(n-1)^{2009}+n^{2009}$ ចែកមិនដាច់នឹង $n+2$ ចំពោះគ្រប់ចំនួនគត់វិជ្ជមាន $n$ ។

### ដំណោះស្រាយ

គេមាន

$S_n=1^{2009}+2^{2009}+3^{2009}+\cdots+(n-1)^{2009}+n^{2009}$

$2S_n=\left(n^{2009}+2^{2009}\right)+\left((n-1)^{2009}+3^{2009}\right)+\cdots+\left(2^{2009}+n^{2009}\right)+1^{2009}+$

$1^{2009}$
$=(n+2)k_1+(n+2)k_2+\cdots+(n+2)k_{n-1}+2$
$=(n+2)k+2$ ដែល $k=k_1+k_2+\cdots+k_{n-1}$
គេទាញបាន $2S_n$ ចែកមិនដាច់នឹង $n+2$
ដូចនេះ $S_n$ ចែកមិនដាច់នឹង $n+2$ ចំពោះគ្រប់ចំនួនគត់វិជ្ជមាន $n$

## លំហាត់ទី ៥២៥

គេមាន $f(x)=x^2-3x+3$ ។
ក. បង្ហាញថា បើ $f(x)=x$ នោះ $f(f(x))=x$ ។
ខ. រកឫសនៃសមីការ $f(x)=x$ ។ ទាញរកឫសនៃសមីការ $\left(x^2-3x+3\right)^2-3\left(x^2-3x+3\right)+3=x$ ។

### ដំណោះស្រាយ

ក. បង្ហាញថា បើ $f(x)=x$ នោះ $f(f(x))=x$
បើ $f(x)=x$ នោះ $f(f(x))=f(x)$
ដូចនេះ $f(f(x))=x$ ព្រោះ $f(x)=x$
ខ. រកឫសនៃសមីការ $f(x)=x$
សមីការ $f(x)=x$ អាចសរសេរជា $x^2-4x+3=x$ ដែលមានឫស $x_1=1$ ; $x_2=3$
♦ ទាញរកឫសនៃសមីការ $\left(x^2-3x+3\right)^2-3\left(x^2-3x+3\right)+3=x$
សមីការ $\left(x^2-3x+3\right)^2-3\left(x^2-3x+3\right)+3=x$ អាចសរសេរជា $f(f(x))=x$ ដែលជាសមីការវិបាកនៃសមីការ $f(x)=x$
គេទាញបាន $x_1=1$ ; $x_2=3$ ជាឫសនៃ $\left(x^2-3x+3\right)^2-3\left(x^2-3x+3\right)+3=x$
គឺ $x_1=1$ ; $x_2=3$ ជាឫសនៃ $x^4-6x^3+12x^2-10x+3=0$
$\left(x^2-4x+3\right)(x-1)^2=0$
សមីការមានឫស $x_1=1$ ; $x_2=3$

## លំហាត់ទី ៥២៦

គេតាង $n!=n(n-1)(n-2)\times\cdots\times2\times1$ ។ បង្ហាញថា ចំពោះគ្រប់ចំនួនគត់វិជ្ជមាន $n$ គេបាន :

$$1+\frac{2009}{1!}+\frac{(2009)(2010)}{2!}+\cdots+\frac{(2009)(2010)\cdots(2009+n-1)}{n!}=\frac{(2010)(2011)\cdots(2009+n)}{n!}$$ ។

## ដំណោះស្រាយ

- ចំពោះ $n=1$ : $1+\dfrac{2009}{1}=\dfrac{2010}{1}$ ជាសមភាពដែលពិត

- ឧបមាថា សមភាពពិតដល់ $n=k$ មានន័យថា :

$$1+\frac{2009}{1!}+\frac{(2009)(2010)}{2!}+\cdots+\frac{(2009)(2010)\cdots(2009+k-1)}{k!}$$
$$=\frac{(2010)(2011)\cdots(2009+k)}{(k)!}$$

- ពិនិត្យចំពោះ $n=k+1$

$$1+\frac{2009}{1!}+\frac{(2009)(2010)}{2!}+\cdots+\frac{(2009)(2010)\cdots(2009+k-1)}{k!}$$
$$+\frac{(2009)(2010)\cdots(2009+k)}{(k+1)!}$$
$$=\frac{(2010)(2011)\cdots(2009+k)}{(k)!}+\frac{(2009)(2010)\cdots(2009+k)}{(k+1)!}$$
$$=\frac{(2010)(2011)\cdots(2009+k)(k+1)}{(k+1)!}+\frac{(2009)(2010)\cdots(2009+k)}{(k+1)!}$$
$$=\frac{(2010)(2011)\cdots(2009+k)(2009+(k+1))}{(k+1)!}$$ គឺពិតចំពោះ $n=k+1$

## លំហាត់ទី ៥២៧

អនុគមន៍ $g$ កំណត់ចំពោះគ្រប់ចំនួនពិត $x$ ដោយ $g(x+1)+g(x-1)=\sqrt{2}g(x)$ ។

ក. គេតាង $g(x)=p$ និង $g(x-1)=q$ ចំពោះគ្រប់ចំនួនពិត $x$ ។

គណនា $g(x+1), g(x+2), g(x+3)$ និង $g(x+4)$ ជាអនុគមន៍នៃ $p$ និង $q$ ។

ខ. បង្ហាញថា $g$ ជាអនុគមន៍ខួប ។

## ដំណោះស្រាយ

ក. គណនា $g(x+1), g(x+2), g(x+3)$ និង $g(x+4)$ ជាអនុគមន៍នៃ $p$ និង $q$

គេមាន $g(x+1)=\sqrt{2}g(x)-g(x-1)$

ដោយ $g(x-1)=q$ ; $g(x)=p$ ចំពោះគ្រប់ $x\in\mathbb{R}$ នោះគេបាន

$g(x+1)=\sqrt{2}p-q$

$g(x+2)=\sqrt{2}g(x+1)-g(x)=\sqrt{2}\left(\sqrt{2}p-q\right)-p=p-\sqrt{2}q$ ចំពោះគ្រប់ $x\in\mathbb{R}$

$g(x+3)=\sqrt{2}g(x+2)-g(x+1)=\sqrt{2}\left(p-\sqrt{2}q\right)-\sqrt{2}p+q=-q$ ចំពោះគ្រប់

$x \in \mathbb{R}$

$g(x+4) = \sqrt{2}g(x+3) - g(x+2) = \sqrt{2}(-q) - p + \sqrt{2}q = -p = -g(x)$ ចំពោះគ្រប់ $x \in \mathbb{R}$

ខ. បង្ហាញថា $g$ ជាអនុគមន៍ខួប

$g(x+5) = \sqrt{2}g(x+4) - g(x+3) = -\sqrt{2}p + q$ ចំពោះគ្រប់ $x \in \mathbb{R}$

$g(x+6) = \sqrt{2}g(x+5) - g(x+4) = \sqrt{2}\left(p - \sqrt{2}q\right) - \sqrt{2}q + p = q$ ចំពោះគ្រប់ $x \in \mathbb{R}$

$g(x+7) = \sqrt{2}g(x+6) - g(x+5) = \sqrt{2}\left(\sqrt{2}q - p\right) - \left(-\sqrt{2}p + q\right) = q$ ចំពោះគ្រប់ $x \in \mathbb{R}$

$g(x+8) = \sqrt{2}g(x+7) - g(x+6) = \sqrt{2}q - \left(\sqrt{2}q - p\right) = p = g(x)$ ចំពោះគ្រប់ $x \in \mathbb{R}$

ដូចនេះ $g$ ជាអនុគមន៍ខួប

របៀបទី ២ : តាមសំណួរខាងលើ $g(x+4) = -g(x)$ នោះគេអាចសរសេរ

$g(x+8) = g((x+4)+4)$

$g(x+8) = -g(x+4) = -(-g(x)) = g(x)$ ចំពោះគ្រប់ $x \in \mathbb{R}$

ដូចនេះ $g$ ជាអនុគមន៍ខួប

## លំហាត់ទី ៥២៨

គេមានស្វីតនៃចំនួនពិត $(u_n)$ ដែលកំណត់ដោយ $u_1 = \dfrac{1}{2}$ និង $u_n = \left(\dfrac{2n-3}{2n}\right)u_{n-1}$ ចំពោះ $n = 2;3;\ldots$ ។

បង្ហាញថា $u_1 + u_2 + \cdots + u_n < 1$ ចំពោះគ្រប់ចំនួនគត់វិជ្ជមាន $n$ ។

## ដំណោះស្រាយ

- ចំពោះ $k \geq 2$ គេបាន $2ku_k = 2ku_{k-1} - 3u_{k-1}$ ហើយ $u_{k-1} = 2(k-1)u_{k-1} - 2ku_k$

ដោយប្តូរតម្លៃ $k = 2;\ldots;n+1$

$u_1 = 2u_1 - 4u_2$

$u_2 = 4u_2 - 6u_3$

............................

$u_{n-1} = 2(n-1)u_{n-1} - 2nu_n$

$u_n = 2nu_n - 2(n+1)u_{n+1}$

$$\sum_{i=1}^{n} u_i = 2u_1 - (2n+2)u_{n+1} = 1 - (2n+2)u_{n+1}$$

ដោយ $u_n > 0$ ចំពោះគ្រប់ $n$ នោះ $u_1 + u_2 + \cdots + u_n < 1$ ចំពោះគ្រប់ចំនួនគត់វិជ្ជមាន $n$

## លំហាត់ទី ៥២៩

ត្រីកោណកែង $ABC$ មួយមានអ៊ីប៉ូតេនុស $BC = a$ និងកម្ពស់ $AH = h$ ។ គេចែក $[BC]$ ជា $n$ ចំណែកស្មើគ្នា ដែល $n$ ជាចំនួនគត់សេស ។ គេយក $[PQ]$ ជាចំណែកដែលនៅកណ្ដាលគេ ហើយដែលវង្វាស់មុំ $P\widehat{A}Q = x$ ។

បង្ហាញថា $tanx = \dfrac{4nh}{a\left(n^2-1\right)}$ ។

## ដំណោះស្រាយ




តាង $M$ ជាចំណុចកណ្ដាលនៃ $[BC]$ ។

គេបាន $x = P\widehat{A}Q = P\widehat{A}H - Q\widehat{A}H$

$$tanx = tan\left(P\widehat{A}H - Q\widehat{A}H\right) = \frac{tanP\widehat{A}H - tanQ\widehat{A}H}{1 + tanP\widehat{A}H \times tanQ\widehat{A}H}$$

តែ $tanP\widehat{A}H = \dfrac{HP}{HA}$; $tanQ\widehat{A}H = \dfrac{HQ}{HA}$

$$tanx = \frac{(HP - HQ)\times HA}{HA^2 + HP \times HQ} = \frac{PQ \times HA}{HA^2 + HP \times HQ} \quad (1)$$

ដោយ $HP = HM + MP = HM + \dfrac{a}{2n}$ និង $HQ = HM - MQ = HM - \dfrac{a}{2n}$

$$HM^2 = AM^2 - Ah^2 = \frac{a^2 - 4h^2}{4}$$

$$HP \times HQ = HM^2 - \frac{a^2}{4n^2} = \frac{a^2-4h^2}{4} - \frac{a^2}{4n^2} = \frac{a^2n^2 - 4n^2h^2 - a^2}{4n^2}$$

$$tanx = \frac{ah}{n} \times \frac{4n^2}{4n^2h^2 + a^2n^2 - 4n^2h^2 - a^2} = \frac{4nh}{a\left(n^2-1\right)}$$

## លំហាត់ទី ៥៣០

គេឱ្យចំណុច $M$ មួយនៃកន្លះរង្វង់ដែលមានអង្កត់ផ្ចិត $[AB]$ ។ រកសំណុំចំណុច $M$ កាលណា $A$ ចល័តលើជ្រុង $[Ox)$ និង $B$ ចល័តលើជ្រុង $[Oy)$ នៃមុំកែង $xOy$ មួយដោយរក្សាប្រវែង $AB$ ថេរ ។




### ដំណោះស្រាយ




ចតុកោណ $AMBO$ ចារឹកក្នុងរង្វង់មួយ ។
គេតាង $M\widehat{A}B = \alpha$ ថេរ , $AB = 2R$ ថេរ
គេបាន $M\widehat{O}B = M\widehat{A}B = \alpha$ ថេរ
បានន័យថា $M$ នៅលើ $[OM)$ ដែល $M\widehat{O}y = \alpha$

លីមីត : - បើ $A = O$ នោះ $B = B_1$ ដែល $OB_1 = 2R$ ហើយ $M = M_1$ ដែល $OM_1 = 2R\cos\alpha$

- បើ $B = O$ នោះ $A = A_1$ ដែល $OA_1 = 2R$ ហើយ $M = M_2$ ដែល $OM_2 = 2R\sin\alpha$

សន្និដ្ឋាន :
សំណុំចំណុចនៃចំណុច $M$ គឺជា $[M_1M_2]$ នៃ $[OM)$ ដែល $M\widehat{O}y = \alpha$, $OM_1 = 2R\cos\alpha$ និង $OM_2 = 2R\sin\alpha$ ។

## លំហាត់ទី ៥៣១

បង្ហាញថា $3^{2n} + 2^{6n-5}$ ចែកដាច់នឹង $11$ ចំពោះគ្រប់ចំនួនគត់វិជ្ជមាន $n$ ។

### ដំណោះស្រាយ

ចំពោះ $n = 1$ គេបាន $3^2 + 2^{6\times1-5} = 11$ ចែកដាច់នឹង $11$ : ពិត
ឧបមាថាពិតដល់ $n = k$ គឺថា $3^{2k} + 2^{6k-5} = 11p,\ p \in \mathbb{Z}^+$
នាំឱ្យ $3^{2k} = 11p - 2^{6k-5},\ p \in \mathbb{Z}^+$
ពិនិត្យចំពោះ $n = k+1$ គេបាន $3^{2(k+1)} + 2^{6(k+1)-5} = 9\times3^{2k} + 2^6\times2^{6k-5}$
$= 9\times11p - 9\times2^{6k-5} + 2^6\times2^{6k-5} = 11\left(9p + 5\times2^{6k-5}\right)$ ចែកដាច់នឹង $11$ : ពិត

ដូចនេះ $3^{2n}+2^{6n-5}$ ចែកដាច់នឹង 11 ចំពោះគ្រប់ចំនួនគត់វិជ្ជមាន $n$

## លំហាត់ទី ៥៣២

គេឱ្យចំនួនគត់វិជ្ជមាន $a$ និង $b$ ដែល $2a^2+a=3b^2+b$ ។
បង្ហាញថា $a-b$ ; $2a+2b+1$ ; និង $3a+3b+1$ សុទ្ធតែជាការេប្រាកដ ។

### ដំណោះស្រាយ

ដោយ $2a^2+a=3b^2+b$ នោះគេបាន :
$a^2=a-b+3a^2-3b^2=(a-b)(3a+3b+1)$
$b^2=a-b+2a^2-2b^2=(a-b)(2a+2b+1)$
បើ $\delta$ ជាតួចែករួមធំបំផុតនៃ $3(a+b)+1$ & $2(a+b)+1$ នោះ
$\delta|(6a+6b+3-6a-6b-2)$ គឺ $\delta|1$
ដូចនេះ $PGCD(3(a+b)+1\&2(a+b)+1)=1$ ហើយ $PGCD\left(a^2;b^2\right)=a-b$
ម្យ៉ាងទៀត គេតាង $d=PGCD(a;b)$ នោះ $a=dp;\ b=dq$ ដែល
$PGCD(p;q)=1$
គេបាន $a^2=d^2p^2$ ; $b^2=d^2q^2$
ដោយ $PGCD\left(p^2;q^2\right)=1$ នោះ $d^2=PGCD\left(a^2;b^2\right)$
គេទាញបាន $a-b=d^2$ ; $3a+3b+1=p^2$ ; $2a+2b+1=q^2$

## លំហាត់ទី ៥៣៣

សំណុំ $E_n$ មួយមាន $n$ ធាតុដែល $n$ ជាចំនួនគត់វិជ្ជមាន ។ តាង $P(E_n)$ ជាសំណុំនៃសំណុំរងរបស់ $E_n$ ហើយ $Card(P(E_n))$ ជាចំនួនធាតុនៃ $P(E_n)$ ។ តាមវិចារដោយកំណើន បង្ហាញថា $Card(P(E_n))=2^n$ ។

### ដំណោះស្រាយ

- ចំពោះ $n=1$ : $E_1=\{a_1\}$ ហើយ $P(E_1)=\{\varnothing,\ a_1\}$ នោះគេបាន
$card(P(E_1))=2=2^1$
- ឧបមាថាសំណើពិតដល់ $n=k$ : គេបាន $E_k=\{a_1,a_2,a_3,...,a_k\}$ ហើយ
$Card(P(E_k))=2^k$
- ពិនិត្យចំពោះ $n=k+1$ : គេបាន $E_{k+1}=\{a_1,a_2,a_3,...,a_k,a_{k+1}\}=E_k\cup\{a_{k+1}\}$
ចំពោះ $k$ ធាតុដំបូងគេអាចបង្កើតសំណុំរងបានចំនួន $2^k$ (តាមសម្មតិកម្មកំណើន)
គេបញ្ចូលធាតុ $a_{k+1}$ ដែលនៅសល់ទៅក្នុងសំណុំរងនីមួយៗខាងលើ នោះគេនឹងបាន $2^k$

សំណុំរងផ្សេងទៀត ។
សរុបមក គេបាន $Card(P(E_{k+1}))=2^k+2^k=2^{k+1}$ : សំណើពិតដល់ $n=k+1$
ដូចនេះ $Card(P(E_n))=2^n$ ចំពោះគ្រប់ចំនួនគត់ $n\geq 1$

## លំហាត់ទី ៥៣៨

ត្រីកោណ $ABC$ មួយមានជ្រុង $BC=a$ ; $AC=b$ ដែល $a+b=(atanA+btanB)tan\frac{C}{2}$ ។ បង្ហាញថា $ABC$ ជាត្រីកោណសមបាត ។

## ដំណោះស្រាយ

ដោយ $a+b=(atanA+btanB)tan\frac{C}{2}$ នោះគេបាន :

$acosAcosBcos\frac{C}{2}+bcosAcosBcos\frac{C}{2}=asinAcosBsin\frac{C}{2}+bcosAsinBsin\frac{C}{2}$

$acosB\left(cosAcos\frac{C}{2}-sinAsin\frac{C}{2}\right)+bcosA\left(cosBcos\frac{C}{2}-sinBsin\frac{C}{2}\right)=0$

$acosBcos\left(A+\frac{C}{2}\right)+bcosAcos\left(B+\frac{C}{2}\right)=0 \quad (1)$

ដោយ $A+B+C=\pi$ នោះ $\frac{C}{2}=\frac{\pi}{2}-\frac{A}{2}-\frac{B}{2}$

(1) អាចសរសេរ $acosBcos\left(\frac{\pi}{2}+\frac{A}{2}-\frac{B}{2}\right)+bcosAcos\left(\frac{\pi}{2}+\frac{B}{2}-\frac{A}{2}\right)=0$

$-acosBsin\left(\frac{A}{2}-\frac{B}{2}\right)+bcosAsin\left(\frac{A}{2}-\frac{B}{2}\right)=0$

$sin\left(\frac{A}{2}-\frac{B}{2}\right)(-acosB+bcosA)=0$ សមមូល $sin\left(\frac{A}{2}-\frac{B}{2}\right)=0$ ឬ $-acosB+bcosA=0$

-ចំពោះ $sin\left(\frac{A}{2}-\frac{B}{2}\right)=0$ គេបាន $A=B$

ដូចនេះ $ABC$ ជាត្រីកោណសមបាតត្រង់កំពូល $C$ ។

-ចំពោះ $-acosB+bcosA=0$




គេបាន $acosB=bcosA$ នាំឱ្យ $HA=HB$

ដូចនេះ $ABC$ ជាត្រីកោណសមបាតត្រង់កំពូល $C$ ។

## លំហាត់ទី ៥៣៥

ស្វ៊ីត $(x_n)$ មួយកំណត់ដោយ $x_1 = 1$ និង $x_{n+1} = 1 + x_1x_2\cdots x_n$ ចំពោះ $n = 1,2,\ldots$ ។ គណនា $\lim\limits_{n\to+\infty} S_n$ ។

### ដំណោះស្រាយ

គេមាន $x_{i+1} = 1 + x_1x_2\cdots x_i$ ចំពោះ $i = 1,2,\ldots$

$x_{i+1} - 1 = x_1x_2\cdots x_i = x_i((x_1x_2\cdots x_{i-1}+1)-1)$

$x_{i+1} - 1 = x_i(x_i - 1)$ ព្រោះ $x_i = x_1x_2\cdots x_{i-1}+1$

ចំពោះ $i = 2,3,\ldots$ គេបាន $x_i > 1$ គឺ $x_i - 1 > 0$

គេអាចសរសេរ $\dfrac{1}{x_{i+1}-1} = \dfrac{1}{x_i(x_i-1)} = \dfrac{1}{x_i-1} - \dfrac{1}{x_i}$, $i = 2,3,\ldots$

$\dfrac{1}{x_i} = \dfrac{1}{x_i-1} - \dfrac{1}{x_{i+1}-1}$, $i = 2,3,\ldots$

គេបាន $S_n = \sum\limits_{k=1}^{n}\dfrac{1}{x_k} = \dfrac{1}{x_1} + \sum\limits_{k=2}^{n}\dfrac{1}{x_k} = \dfrac{1}{x_1} + \sum\limits_{k=2}^{n}\left(\dfrac{1}{x_k-1} - \dfrac{1}{x_{k+1}-1}\right)$

$S_n = \dfrac{1}{x_1} + \dfrac{1}{x_2-1} - \dfrac{1}{x_{n+1}-1} = 2 - \dfrac{1}{x_{n=1}-1}$ ព្រោះ $x_1 = 1, x_2 = 1+x_1 = 1+1 = 2$

តែ $x_{n+1} - 1 = x_1x_2\cdots x_n > x_1(1+x_1)^{n-1} = 2^{n-1}$

$\lim\limits_{n\to+\infty} 2^{n-1} = +\infty$ នោះ $\lim\limits_{n\to+\infty}(x_{n+1}-1) = +\infty$

នាំឱ្យ $\lim\limits_{n\to+\infty}\dfrac{1}{x_{n+1}-1} = 0$

ដូចនេះ $\lim\limits_{n\to+\infty} S_n = 2$

## លំហាត់ទី ៥៣៦

១. សិក្សាអថេរភាពនៃអនុគមន៍ $y = f(x) = \dfrac{x^2-1}{x^2+2}$ (គេមិនអោយសង់ក្រាបតាង $f$ ទេ) ។

២. $g$ ជាអនុគមន៍បង្រួមនៃអនុគមន៍ $f$ នៅលើ $[0;+\infty[$ ។ ពីអថេរភាពនៃអនុគមន៍ $f$ បញ្ជាក់អថេរភាពនៃអនុគមន៍ $g$ នៅលើ $[0;+\infty[$ ទាញរកអនុគមន៍ច្រាស $g^{-1}$ នៃអនុគមន៍ $g$ ។ សង់ខ្សែកោង $(C')$ និង $(C'')$ តាង $g$ និង $g^{-1}$ ។

# ដំណោះស្រាយ

១. សិក្សាអថេរភាពនៃអនុគមន៍ $y=f(x)=\dfrac{x^2-1}{x^2+2}$ ( មិនសង់ក្រាបតាង $f$ )

♦ ដែនកំណត់

ចំពោះ $\forall x\in\mathbb{R}:\ x^2\ge 0$

$\Rightarrow x^2+2>0$

ដូចនេះ $\mathscr{D}=\mathbb{R}$

♦ ទិសដៅអថេរភាព

$$f'(x)=\frac{2x\left(x^2+2\right)-2x\left(x^2-1\right)}{\left(x^2+2\right)^2}$$
$$=\frac{2x\left(x^2+2-x^2+1\right)}{\left(x^2+2\right)^2}=\frac{6x}{\left(x^2+2\right)^2}$$

- ចំណុចបរមា : ចំពោះ $\forall x\in\mathscr{D},\ \left(x^2+2\right)^2>0$ នោះ $f'(x)$ មានសញ្ញាដូច $6x$ រឺដូច $x$

តារាងសញ្ញា $f'(x)$

| $x$ | $-\infty$ | | $0$ | | $+\infty$ |
|---|---|---|---|---|---|
| $f(x)$ | | $-$ | $0$ | $+$ | |

តាមតារាងសញ្ញានៃ $f'(x)$ អនុគមន៍ $f$ មានអប្បបរមាមួយត្រង់ $x=0$ គឺ $f(0)=-\dfrac{1}{2}$ ។

-លីមីត និង អាស៊ីមតូត

$$\lim_{x\to-\infty}f(x)=\lim_{x\to-\infty}\frac{x^2-1}{x^2+2}=\lim_{x\to-\infty}\frac{x^2\left(1-\frac{1}{x^2}\right)}{x^2\left(1+\frac{2}{x^2}\right)}=\lim_{x\to-\infty}\frac{1-\frac{1}{x^2}}{1+\frac{2}{x^2}}=1$$

$$\lim_{x\to+\infty}f(x)=\lim_{x\to+\infty}\frac{x^2-1}{x^2+2}=\lim_{x\to+\infty}\frac{x^2\left(1-\frac{1}{x^2}\right)}{x^2\left(1+\frac{2}{x^2}\right)}=\lim_{x\to+\infty}\frac{1-\frac{1}{x^2}}{1+\frac{2}{x^2}}=1$$

បន្ទាត់ $(\Delta):\ y=1$ ជាអាស៊ីមតូតដេកនៃខ្សែកោង $(C)$ តាង $f$ ។ -កំណត់ទីតាំងធៀបរវាងខ្សែកោង $(C)$ និង អាស៊ីមតូតដេក

តាង $h(x)=f(x)-1=\dfrac{x^2-1}{x^2+2}-1=\dfrac{-3}{x^2+2}<0$ ចំពោះ $\forall x\in\mathscr{D}$ នោះខ្សែកោង $(C)$ នៅក្រោមអាស៊ីមតូតដេក ។

តារាងអថេរភាព

| $x$ | $-\infty$ | | 0 | | $+\infty$ |
|---|---|---|---|---|---|
| $f(x)$ | | $-$ | 0 | $+$ | |
| $f(x)$ | 1 ↘ | | $-\frac{1}{2}$ | ↗ | |

២. ពីអថេរភាពនៃអនុគមន៍ $f$ បញ្ជាក់អថេរភាពនៃអនុគមន៍ $g$ នៅលើ $[0;+\infty[$ ទាញរក អនុគមន៍ច្រាស $g^{-1}$ នៃអនុគមន៍ $g$

យើងបាន $g$ ជាអនុគមន៍បង្រួមនៃអនុគមន៍ $f$ នៅលើ $[0;+\infty[$

$g:[0;+\infty[\to[0;1[$

$$:x\mapsto g(x)=\frac{x^2-1}{x^2+2}$$

ជាអនុគមន៍កើនដាច់ខាតនៅលើ $[0;+\infty[$ នោះ $g$ ជាអនុវត្តន៍១ទល់១ពី $[0;+\infty[$ ទៅ $[0;1[$ ហើយមានអនុវត្តន៍ច្រាសមួយតាងដោយ $g^{-1}$ កំណត់ដូចខាងក្រោម :

$g^{-1}:[0;1[\to[0;+\infty[$

$$:y\mapsto x=g^{-1}(y)$$

ចំពោះ $\forall y\in[0;1[,\ y=\dfrac{x^2-1}{x^2+2}$

$\Leftrightarrow x^2y+2y=x^2-1$

$\Leftrightarrow x^2y-x^2=-1-2y$

$\Leftrightarrow (y-1)x^2=-1-2y$

$\Leftrightarrow x^2=\dfrac{-1-2y}{y-1},\ y\neq 1$

$\Leftrightarrow x^2=\dfrac{2y+1}{1-y}>0$

$\Rightarrow x=\sqrt{\dfrac{2y+1}{1-y}}$

យើងបាន :

$g^{-1}:[0;1[\to[0;+\infty[$

$$:y\mapsto x=g^{-1}(y)=\sqrt{\frac{2y+1}{1-y}}$$

ដោយប្តូរ $x$ ជា $y$ និង $y$ ជា $x$ វិញ

$g^{-1}:[0;1[\to[0;+\infty[$

$:x\mapsto y=g^{-1}(x)=\sqrt{\dfrac{2x+1}{1-x}}$

-សង់ខ្សែកោង $(C')$ និង $(C'')$ តាង $g$ និង $g^{-1}$

| $x$ | $0$ $\qquad\qquad\qquad$ $+\infty$ |
|---|---|
| $g(x)$ | 0 $\qquad$ + |
| $g(x)$ | $-\frac{1}{2}$ $\nearrow$ $1$ |

តារាងតម្លៃនៃ $y=\dfrac{x^2-1}{x^2+2}$

| $x$ | $0$ | $1$ | $2$ | $3$ |
|---|---|---|---|---|
| $y$ | $-\frac{1}{2}$ | $0$ | $\frac{1}{2}$ | $\frac{8}{11}$ |




គេបានខ្សែកោង $(C'')$ តាង $g^{-1}$ ដោយធ្វើបំលែងឆ្លុះធៀបនឹងបន្ទាត់ពុះទី ១ មានសមីការ

$y = x$ នៃខ្សែកោង $(C')$ តាង $g(x) = \dfrac{x^2-1}{x^2+2}$ ។

$(C'')$ មានអាស៊ីមតូតឈរ $x = 1$ និងកាត់តាម $\left(-\frac{1}{2};0\right)$, $(0;1)$ , $\left(\frac{1}{2};2\right)$ ។

## លំហាត់ទី ៥៣៧

អនុគមន៍ $f(x;y)$ មួយផ្ទៀងផ្ទាត់លក្ខខណ្ឌទាំងបីដូចខាងក្រោមចំពោះគ្រប់ចំនួនគត់មិនអវិជ្ជមាន $x$ និង $y$ :

$(i)$ $f(0;y) = 1+y$

$(ii)$ $f(x+1;0) = f(x;1)$

$(iii)$ $f(x+1;y+1) = f(x;f(x+1;y))$ ។

ក. គណនា $f(1;n)$, $f(2;n)$ និង $f(3;n)$ ជាអនុគមន៍នៃ $n$ ។

ខ. គណនា $f(4;2009)$ ។

## ដំណោះស្រាយ

ក. គណនា $f(1;n)$, $f(2;n)$ និង $f(3;n)$ ជាអនុគមន៍នៃ $n$

គេមាន $f(1;n) = f(0;f(1;n-1)) = 1+f(1;n-1)$ ; $n \geq 1$

តាង $p_n = f(1;n)$ គេបាន $p_0 = f(1;0) = f(0;1) = 1+1 = 2;$

$p_n = p_{n-1}+1$ ចំពោះ $n \geq 1$

គេបាន $(p_n)$ ជាស្វ៊ីតនព្វន្តដែលមាន $p_0 = 2; d = 1$

ដូចនេះ $f(1;n) = P_n = p_0 + nd = n+2$

គេមាន $f(2;n) = f(1;f(2;n-1)) = f(2;n-1)+2$ ; $n \geq 1$

តាង $q_n = f(2;n)$ គេបាន $q_0 = f(2;0) = f(1;1) = p_1 = 1+2 = 3$ ;

$q_n = q_{n-1}+2$

គេបាន $(q_n)$ ជាស្វ៊ីតនព្វន្តដែលមាន $q_0 = 3;\ d' = 2$

ដូចនេះ $f(2;n) = q_n = q_0 + nd' = 2n+3$

គេមាន $f(3;n) = f(2;f(3;n-1)) = 2f(3;n-1)+3$ ចំពោះ $n \geq 1$

$f(3;n)+3 = 2(f(3;n-1)+3)$

តាង $u_n = f(3;n)+3$ នោះគេបាន $u_0 = f(3;0)+3 = f(2;1)+3 = (2\times 1+3)+3 = 8$

គេបាន $(u_n)$ ជាស្វ៊ីតធរណីមាត្រដែលមាន $u_0 = 8$ ; $q = 2$

ហើយ $u_n = u_0 q^n = 2^{n+3}$

ដូចនេះ $f(3;n) = 2^{n+3}-3$

ខ. គណនា $f(4;2009)$

គេមាន $f(4;n)=f(3;f(4;n-1))=2^{f(4;n-1)+3}-3$ , $n\geq 1$

$f(4;0)=f(3;1)=2^4-3=2^{2^2}-3$ មាននិទស្សន្ត 2ចំនួន $0+2$ដង

$f(4;1)=2^{f(4;0)+3}-3=2^{16}-3=2^{2^{2^2}}-3$ មាននិទស្សន្ត 2 ចំនួន $1+2$ ដង

..................................................

$f(4;n)=2^{2^{2^{\cdot^{\cdot^{2}}}}}-3$ មាននិទស្សន្ត 2 ចំនួន $n+2$ ដង

ដោយយក $n=2009$ នោះ $f(4;2009)=2^{2^{2^{2^{\cdot^{\cdot^{2}}}}}}$ មាននិទស្សន្ត 2 ចំនួន $2009+2=$ 2011 ដង

## លំហាត់ទី ៥៣៨

បើ $a+b+c=1$ ; $a^2+b^2+c^2=9$ និង $a^3+b^3+c^3=1$ ចូររក $\frac{1}{a}+\frac{1}{b}+\frac{1}{c}$ ។

## ដំណោះស្រាយ

គេមាន $\frac{1}{a}+\frac{1}{b}+\frac{1}{c}=\frac{ab+bc+ca}{abc}$ ...(1)

តែ $(a+b+c)^2=a^2+b^2+c^2+2(ab+bc+ca)$

$1^2=9+2(ab+bc+ca)$

$ab+bc+ca=-4$

ហើយ $a^3+b^3+c^3-3abc=(a+b+c)\left(a^2+b^2+c^2-ab-bc-ca\right)$

$1-3abc=1[9-(ab+bc+ca)]$

$1-3abc=9-(-4)$

$abc=-4$

តាម (1) : $\frac{1}{a}+\frac{1}{b}+\frac{1}{c}=\frac{-4}{-4}=1$

## លំហាត់ទី ៥៣៩

គេឱ្យចំណុច $O$ ជាគល់តម្រុយនៃប្រព័ន្ធកូអរដោនេមានបីវិមាត្រ ហើយតាង $A,B$ និង $C$ ជាចំណុចនៅលើអ័ក្សវិជ្ជមាន $x,y$ និង $z$ រៀងគ្នា ។ បើ $OA=\sqrt[4]{75}$ និង $\angle BAC=30^0$ ចូរគណនា $100S_{\triangle ABC}$ ( $S_{\triangle ABC}$ ជាផ្ទៃក្រឡានៃត្រីកោណ $ABC$ ) ។

## ដំណោះស្រាយ

រំលឹក

១. ផ្ទៃក្រឡានៃត្រីកោណ $ABC$




$$S=\frac{1}{2}AB\cdot AC\cdot sinA=\frac{1}{2}BA\cdot BC\cdot sinB=\frac{1}{2}CA\cdot CB\cdot sinC$$

២. ផ្ទៃក្រឡាត្រីកោណ

ក្នុងតម្រុយអរតូណរម៉ាល់ (វិមាត្របី) បើគេមានបីចំណុច $A,B$ និង $C$ រត់មិនត្រង់គ្នា នោះផ្ទៃក្រឡាត្រីកោណ $ABC$ គឺ :

$$S=\frac{1}{2}\left|\overrightarrow{AB}\times\overrightarrow{AC}\right|=\frac{1}{2}\left|\overrightarrow{BC}\times\overrightarrow{BA}\right|=\frac{1}{2}\left|\overrightarrow{CA}\times\overrightarrow{CB}\right|$$

៣. ក) ផលគុណស្កាលែ(ប្រើមុំ)




$$\overrightarrow{AB}\cdot\overrightarrow{AC}=\left|\overrightarrow{AB}\right|\cdot\left|\overrightarrow{AC}\right|\cdot cos\angle BAC$$

ខ ) ផលគុណស្កាលែ ( ប្រើកូអរដោនេ )
បើគេមានពីរវ៉ិចទ័រ $\overrightarrow{U}=(x_1,y_1,z_1)$ និង $\overrightarrow{V}=(x_2,y_2,z_2)$ នោះផលគុណស្កាលែ
$\overrightarrow{U}\cdot\overrightarrow{V}=x_1x_2+y_1y_2+z_1z_2$ ។

តាម $S_{\triangle ABC}=\dfrac{\left|\overrightarrow{AB}\times\overrightarrow{AC}\right|}{2}=\dfrac{\left|\overrightarrow{AB}\right|\cdot\left|\overrightarrow{AC}\right|\cdot sin30^0}{2}$

ដោយ $A,B$ និង $C$ ជាចំណុចនៅលើអ័ក្សរ៉ឺផ្លមាន $x,y$ និង $z$ រៀងគ្នា យើងអាចយក
$A\left(\sqrt[4]{75},0,0\right)$ ; $B(0,b,0)$ និង $C(0,0,c)$

$\Rightarrow \overrightarrow{AB}=\left(-\sqrt[4]{75},b,0\right)$ និង $\overrightarrow{AC}=\left(-\sqrt[4]{75},0,c\right)$

តាមផលគុណស្កាលែ $\overrightarrow{AB}\cdot\overrightarrow{AC}=|AB|\cdot|AC|\cdot cos30^0=\sqrt{75}$

នោះ $|AB|\cdot|AC|=10$

យើងបាន $S_{\triangle ABC}=\dfrac{\left|\overrightarrow{AB}\right|\cdot\left|\overrightarrow{AC}\right|\cdot sin30^0}{2}=\dfrac{10}{4}=\dfrac{5}{2}$

នាំឱ្យ $100S_{\triangle ABC}=100\times\dfrac{5}{2}=250$

## លំហាត់ទី ៥៤០

ស៊ីត $a_1,a_2,a_3,\ldots$ កំណត់ដោយ $a_1=1$ និង ចំពោះ $n\geq 2$,

$$a_n=(a_1+a_2+\cdots+a_{n-1})\times n \text{ ។}$$

ស្រាយបញ្ជាក់ថា $a_{2020}$ ចែកដាច់នឹង $2020^2$ ។

## ដំណោះស្រាយ

តាង $b_n=a_1+a_2+\cdots+a_n$ នោះ $b_{n-1}=a_1+a_2+\cdots+a_{n-1}$

ដោយ $a_n=(a_1+a_2+\cdots+a_{n-1})\times n$ នោះ $b_n-b_{n-1}=b_{n-1}\times n$

គេទាញបានថា $b_n=(n+1)b_{n-1}$ ចំពោះ $n\geq 2$

ធ្វើបែបនេះជាបន្តទៀត គេបាន :

$b_n=(n+1)b_{n-1}=(n+1)nb_{n-2}=(n+1)n(n-1)b_{n-3}=\cdots=(n+1)n(n-1)\cdot 3b_1=\dfrac{1}{2}(n+1)!$

នាំឱ្យ $a_n=b_n-b_{n-1}=\dfrac{1}{2}(n+1)!-\dfrac{1}{2}n!=\dfrac{n}{2}\times n!$

ចំពោះ $n=2020$ : $a_{2020}=\dfrac{2020}{2}\times 2020!=2020^2\times\dfrac{2019!}{2}$ ចែកដាច់នឹង $2020$

## លំហាត់ទី ៥៨១

ស្រាយបញ្ជាក់ថា $cos\frac{\pi}{7}+cos\frac{3\pi}{7}+cos\frac{5\pi}{7}=\frac{1}{2}$ ។

### ដំណោះស្រាយ

តាង $z=cos\frac{\pi}{7}+isin\frac{\pi}{7}$

នោះ $z^7=cos\pi+isin\pi=-1$

ម្យ៉ាងទៀត $cos\frac{\pi}{7}+cos\frac{3\pi}{7}+cos\frac{5\pi}{7}=\frac{1}{2}\left(z+\frac{1}{z}\right)+\frac{1}{2}\left(z^3+\frac{1}{z^3}\right)+\frac{1}{2}\left(z^5+\frac{1}{z^5}\right)$

$$=\frac{z^{10}+z^8+z^6+z^4+z^2+1}{2z^5}$$

ដោយ $z^7+1=0$ នោះ $z^{10}=-z^3$ និង $z^8=-z$ ហើយគេបាន

$$z^{10}+z^8+z^6+z^4+z^2+1=z^6+z^4-z^3+z^2-z+1$$

$$=z^6-z^5+z^4-z^3+z^2-z+1+z^5=\frac{z^7+1}{z+1}+z^5=z^5$$

$\Rightarrow cos\frac{\pi}{7}+cos\frac{3\pi}{7}+cos\frac{5\pi}{7}=\frac{z^5}{2z^5}=\frac{1}{2}$ ពិត

## លំហាត់ទី ៥៨២

ដាក់ជាផលគុណកត្តា $a^{10}+a^5+1$ ។

### ដំណោះស្រាយ

យើងមាន $a^{10}+a^5+1=\frac{(a^5)^3-1}{a^5-1}$

$$=\frac{(a^3)^5-1}{(a-1)\left(a^4+a^3+a^2+a+1\right)}=\frac{(a^3-1)\left(a^{12}+a^9+a^6+a^3+1\right)}{(a-1)\left(a^4+a^3+a^2+a+1\right)}$$

តែ $\frac{a^{12}+a^9+a^6+a^3+1}{a^4+a^3+a^2+a+1}=a^8-a^7+a^5-a^4+a^3-a+1$

ដូចនេះ $a^{10}+a^5+1=\left(a^2+a+1\right)\left(a^8-a^7+a^5-a^4+a^3-a+1\right)$

## លំហាត់ទី ៥៨៣

ដោះស្រាយសមីការ $x+3\left(2-3x^2\right)^2=2$ ។

## ដំណោះស្រាយ

<u>របៀបទី ១</u>:

$x+3\left(2-3x^2\right)^2=2 \quad (1)$

តាង $y=2-3x^2$ នោះសមីការទៅជា $x+3y^2=2 \quad (2)$

គេបានប្រព័ន្ធសមីការ $\begin{cases} x=2-3y^2 & (3) \\ y=2-3x^2 & (4) \end{cases}$

យក $(3)-(4)$: $x-y=-3\left(y^2-x^2\right)$

$\Leftrightarrow (x-y)(1-3x-3y)=0$

ចំពោះ $x-y=0$ នោះ $x=y$ ហើយតាម $(2)$ គេបាន

$$3x^2+x-2=0 \quad (5)$$

ដោះស្រាយសមីការ $(5)$ គេបាន $x_1=-1$ និង $x_2=\dfrac{2}{3}$

ចំពោះ $1-3x-3y=0$ នោះ $y=\dfrac{1-3x}{3}$ ហើយតាម $(2)$ គេបាន

$$9x^2-3x-5=0 \quad (6)$$

ដោះស្រាយសមីការ $(6)$ គេបាន $x_{3,4}=\dfrac{1\pm\sqrt{21}}{6}$

ដូចនេះ សមីការមានឫស $x_1=1,\ x_2=\dfrac{2}{3},\ x_3=\dfrac{1+\sqrt{21}}{6},\ x_4=\dfrac{1-\sqrt{21}}{6}$

<u>របៀបទី ២</u>:

$$x+3\left(2-3x^2\right)^2=2 \quad (2)$$

$\Leftrightarrow 27x^4-36x^2+x+10=0$

$\Leftrightarrow (x+1)\left(27x^3-27x^2-9x+10\right)=0$

$\Leftrightarrow (x+1)(3x-2)\left(9x^2-3x-5\right)=0$

- ចំពោះ $x+1=0$ នោះ $x=-1$
- ចំពោះ $3x-2=0$ នោះ $x=\dfrac{2}{3}$
- ចំពោះ $9x^2-3x-5=0$ នោះ $x_{3,4}=\dfrac{1\pm\sqrt{21}}{6}$

ដូចនេះ សមីការមានឫស $x_1=1,\ x_2=\dfrac{2}{3},\ x_3=\dfrac{1+\sqrt{21}}{6},\ x_4=\dfrac{1-\sqrt{21}}{6}$

## លំហាត់ទី ៥៨៤

គេឱ្យ $a,b,c,d$ ផ្ទៀងផ្ទាត់ $\begin{cases} a^2+b^2=a+b & (1) \\ c^2+d^2=-(c+d) & (2) \end{cases}$ ។

ស្រាយបញ្ជាក់ថា $(a-c)^2+(b-d)^2\le 8$ ។

### ដំណោះស្រាយ




តាម $(1):\Leftrightarrow \left(a-\frac{1}{2}\right)^2+\left(b-\frac{1}{2}\right)^2=\frac{1}{2}$

$\Rightarrow$ ចំណុច $M(a;b)$ ស្ថិតនៅលើរង្វង់មានផ្ចិត $I\left(\frac{1}{2};\frac{1}{2}\right)$ និងកាំ $\frac{1}{\sqrt{2}}$

$(2):\Leftrightarrow \left(a+\frac{1}{2}\right)^2+\left(b+\frac{1}{2}\right)^2=\frac{1}{2}$

$\Rightarrow$ ចំណុច $N(c;d)$ ស្ថិតនៅលើរង្វង់មានផ្ចិត $J\left(-\frac{1}{2};-\frac{1}{2}\right)$ និងកាំ $\frac{1}{\sqrt{2}}$

គេបាន $\begin{cases} M_1N_1=M_1O+ON_1=2\sqrt{2} \\ MN\le M_1N_1 \end{cases}$ ( តាមរូបជាក់ស្តែង )

$\Rightarrow \sqrt{(a-c)^2+(b-d)^2}\le 2\sqrt{2}$

$\Rightarrow (a-c)^2+(b-d)^2\le 8$ ពិត

## លំហាត់ទី ៥៨៥

រកតម្លៃ $p\in\mathbb{N}$ ផ្ទៀងផ្ទាត់សមីការ $(x-p)(x-2011)+1=(x+m)(x+n)$ ចំពោះគ្រប់ $x\in\mathbb{R};\ m,n\in\mathbb{Z}$ ។

## ដំណោះស្រាយ

សមីការ $(x-p)(x-2011)+1=(x+m)(x+n)$ ចំពោះគ្រប់ $x\in\mathbb{R};\ m,n\in\mathbb{Z}$
គេបាន
$x^2-2011x-px+2011p+1=x^2+x(m+n)+mn$
ផ្ទឹមមេគុណគេបាន $\begin{cases} m+n=-(2011+p) & (1)\\ mn=2011p+1 & (2)\end{cases}$

$p=-2011-(m+n)$
$mn=-2011^2-2011(m+n)+1$
$\Rightarrow mn+2011m+2011^2+2011n=1$

(i) $\begin{cases} m+2011=1\\ n+2011=1\end{cases}$ ឬ $\begin{cases} m=-2010\\ n=-2010\end{cases}$

នោះ $p=-2011-(-4020)=2009$

(ii) $\begin{cases} m+2011=-1\\ n+2011=-1\end{cases}$ ឬ $\begin{cases} m=-2012\\ n=-2012\end{cases}$

នោះ $p=-2011-(-4024)=2013$
ដូចនេះ $p=\{2009,2013\}$

## លំហាត់ទី ៥៤៦

ផលគុណនៃ 7 នឹង ចំនួនដែលមាន 6 ខ្ទង់ $\overline{abcdef}$ ស្មើនឹងផលគុណនៃ 6 នឹង ចំនួនដែលមានលេខ 6 ខ្ទង់ $\overline{defabc}$ ។ រកចំនួនដែលមាន 6 ខ្ទង់ទាំងពីរ ។

## ដំណោះស្រាយ

សម្មតិកម្ម $7.\overline{abcdef}=6.\overline{defabc}$ (1)
តាង $x=\overline{abc},\ y=\overline{def}$
$(1)\Rightarrow 7.\left(10^3x+y\right)=6\left(10^3y+x\right)$

$6994x=5993y$

ដោយ $gcd(6994,5993)=13$

$538x=461y$

ដូចនេះ ចំនួនទាំងពីរគឺ 461538 និង 538461

## លំហាត់ទី ៥៤៧

គេឱ្យ $x_0 = 2010$ និង $x_{n+1} = \dfrac{1+x_n}{1-x_n}$ ចំពោះ $n \geq 0$ ។ គណនា $x_{2012}$ ។

### ដំណោះស្រាយ

រក $x_1 = \dfrac{1+x_0}{1-x_0} = \dfrac{1+2010}{1-2010} = -\dfrac{2011}{2009}$

$$x_2 = \frac{1+x_1}{1-x_1} = \frac{1-\frac{2011}{2009}}{1+\frac{2011}{2009}} = \frac{-2}{4020} = -\frac{1}{2010}$$

$$x_3 = \frac{1+x_2}{1-x_2} = \frac{1-\frac{1}{2010}}{1+\frac{1}{2010}} = \frac{2009}{2011}$$

$$x_4 = \frac{1+x_3}{1-x_3} = \frac{1+\frac{2009}{2011}}{1-\frac{2009}{2011}} = \frac{4020}{2} = 2010$$

ទាញបាន $x_0 = x_4$

$\Rightarrow (x_n)$ មានខួបស្មើ 4 នោះ $x_{4k+4} = x_{4k},\ k = 0,1,2,\ldots$

ដូចនេះ $x_{2012} = x_0 = 2010$

## លំហាត់ទី ៥៤៨

ស្រាយបញ្ជាក់ថា ផលបូកនៃគ្រប់ចំនួនគត់មាន 2013 ខ្ទង់ ស្មើនឹង $494\underbrace{99\ldots9}_{2010}55\underbrace{00\ldots0}_{2011}$ ។

### ដំណោះស្រាយ

ចំនួនគត់មាន 2013 ខ្ទង់តូចបំផុតគឺ $10^{2012}$ និងធំបំផុតគឺ $10^{2013}-1$ នោះផលបូកចំនួនទាំង 2013 តួគឺ :

$S = 10^{2012}+(10^{2012}+1)+\cdots+(10^{2013}-2)+(10^{2013}-1)$ ជាផលបូកស្វ៊ីតនព្វន្តដែលមានចំនួនតួ $(10^{2013}-1)-10^{2010}+1 = 9.10^{2012}$

$$\Rightarrow S=\frac{9.10^{2012}}{2}\left(10^{2012}+10^{2013}-1\right)$$

$$S=45.10^{2011}\left(11.10^{2012}-1\right)$$

$$=495.10^{4023}-(100-55).10^{2011}$$

$$=494.10^{4023}+10^{4023}-10^{2013}+55.10^{2011}$$

$$=494.10^{4023}+10^{2013}\left(10^{2010}-1\right)+55.10^{2011}$$

$$=494.10^{4023}+\underbrace{99...9}_{2010}.10^{2013}+55.10^{2011}$$

ដូចនេះ $S=494\underbrace{99...9}_{2010}55\underbrace{00...0}_{2011}$

## លំហាត់ទី ៥៤៩

គេឱ្យស្វ៊ីត Fibonacci ដែលកំណត់ដោយ $a_1=a_2=1$ និង $a_{n+2}=a_n+a_{n+1}$ ។

ស្រាយបញ្ជាក់ថា $\frac{1}{2}+\frac{1}{2^2}+\frac{2}{2^3}+\frac{3}{2^4}+\frac{5}{2^5}+\cdots+\frac{a_n}{2^n}<2$ ។

## ដំណោះស្រាយ

ស្វ៊ីត Fibonacci ដែលកំណត់ដោយ $a_1=a_2=1$ និង $a_{n+2}=a_n+a_{n+1}$

រក $a_3=2,\ a_4=3,\ a_5=5,\ldots$

តាង $S=\frac{1}{2}+\frac{1}{2^2}+\frac{2}{2^3}+\frac{3}{2^4}+\frac{5}{2^5}+\cdots+\frac{a_n}{2^n}$ (1)

$$\frac{S}{2}=\frac{a_1}{2^2}+\frac{a_2}{2^3}+\frac{a_3}{2^4}+\cdots+\frac{an}{2^{n+1}} \quad (2)$$

$(1)+(2)$

$$\frac{3}{2}S=\frac{a_1}{2}+\frac{a_1+a_2}{2^2}+\frac{a_2+a_3}{2^3}+\cdots+\frac{a_{n-1}+a_n}{2^n}+\frac{a_n}{2^{n+1}}$$

ដោយប្រើ $a_{n+2}=a_n+a_{n+1}$

$$\frac{3}{2}S=\frac{a_1}{2}+\frac{a_3}{2^2}+\frac{a_4}{2^3}+\cdots+\frac{a_{n+1}}{2^{n+1}}+\frac{a_n}{2^{n+2}}$$

$$\Rightarrow\frac{3}{4}S=\frac{a_1}{2^2}+\frac{a_3}{2^3}+\frac{a_4}{2^4}+\cdots+\frac{a_{n+1}}{2^{n+1}}+\frac{a_n}{2^{n+2}} \quad (3)$$

យក $(1)-(3)$ : $\frac{1}{4}S=\frac{a_1}{4}+\frac{a_2}{4}-\frac{a_{n+1}}{2^{n+1}}-\frac{a_n}{2^{n+2}}$

$$S=a_1+a_2-\frac{2a_{n+1}+a_n}{2^n}$$

$$S = 2 - \frac{a_{n+1} + a_{n+1} + a_n}{2^n}$$

$$S = 2 - \frac{a_{n+3}}{2^n} < 2$$

ដូចនេះ $S < 2$

## លំហាត់ទី ៥៥០

គេឱ្យអនុគមន៍ $f$ ដោយ $f : \mathbb{N} \times \mathbb{N} \to \mathbb{N}$ ផ្ទៀងផ្ទាត់ទំនាក់ទំនងខាងក្រោម

$$\begin{cases} f(1,1) = 2 \\ f(m+1,n) = f(m,n) + m \\ f(m,n+1) = f(m,n) - n \end{cases}$$

គ្រប់ $m,n \in \mathbb{N}$ ។ រកគ្រប់គូចំនួនគត់វិជ្ជមានដែល $f(a,b) = 2013$ ។

## ដំណោះស្រាយ

$$\begin{cases} f(1,1) = 2 \\ f(m+1,n) = f(m,n) + m \\ f(m,n+1) = f(m,n) - n \end{cases}$$

គ្រប់ $m,n \in \mathbb{N}$

$$\Rightarrow f(a,b) = f(a-1,b) + (a-1)$$

$$= f(a-2,b) + (a-1) + (a-2)$$

$$= \ldots$$

$$= f(1,b) + (a-1) + (a-2) + \cdots + 1$$

$$= f(1,b) + \frac{(a-1)a}{2} \quad (1)$$ ហើយ $f(1,b) = f(1,b-1) - (b-1)$

$$= f(1,b-2) - (b-1) - (b-2)$$

$$= \ldots$$

$$= f(1,1) - (b-1) - (b-2) - \cdots - 1$$

$$= f(1,1) - \frac{(b-1)b}{2} \quad (2)$$

(1) និង (2) $f(a,b) = f(1,1) + \dfrac{(a-1)a}{2} - \dfrac{(b-1)b}{2}$

$$2013 = 2 + \frac{a^2 - b^2 + b - a}{2}$$
$$(a-b)(a+b-1) = 2\cdot 2011$$

ដោយ 2011 ជាចំនួនបឋម$\Rightarrow a - b < a + b - 1$

$$(i):\begin{cases} a - b = 1 \\ a + b - 1 = 4022 \end{cases}$$
$$a = 2012,\ b = 2011$$
$$(ii):\begin{cases} a - b = 2 \\ a + b - 1 = 2011 \end{cases}$$
$$a = 1007,\ b = 1005$$

ដូចនេះ $\boxed{(a,b) = (2012,2011),(1007,1005)}$

## លំហាត់ទី ៥៥១

គេឱ្យឡាទេសកោណនិយ័ត $ABCDEFGHIJKL$ និង $R$ ជាកាំរង្វង់ចារឹកក្រៅឡាទេសកោណនិយ័ត ( ពហុកោណនិយ័តមាន 12 ជ្រុងប៉ុនគ្នា ) ។

ក ) ស្រាយបញ្ជាក់ថា $\frac{AB}{AF} + \frac{AF}{AB} = 4$

ខ ) គណនាជាអនុគមន៍នៃ $R$ ផលបូក $S = AB^2 + AC^2 + AD^2 + AE^2 + AF^2$ ។

## ដំណោះស្រាយ

ក ) ស្រាយបញ្ជាក់ថា $\frac{AB}{AF} + \frac{AF}{AB} = 4$




មាន $\overset{\frown}{AB} = \overset{\frown}{BC} = \overset{\frown}{CD} = \overset{\frown}{DE} = \overset{\frown}{EF} = \frac{2\pi}{12} = \frac{\pi}{6}$

តាមទ្រឹស្តបទ sin ក្នុងត្រីកោណ $ABC, AFG$

$AB = 2R\sin\frac{\pi}{12}$ , $AF = 2R\sin\frac{5\pi}{12}$

$\Rightarrow \frac{AB}{AF} + \frac{AF}{AB} = \frac{\sin\frac{\pi}{12}}{\sin\frac{5\pi}{12}} + \frac{\sin\frac{5\pi}{12}}{\sin\frac{\pi}{12}}$

$\frac{\sin^2\frac{\pi}{12} + \cos^2\frac{\pi}{12}}{\frac{1}{2}\left[\cos\frac{4\pi}{12} - \cos\frac{6\pi}{12}\right]} = \frac{1}{\frac{1}{2}\left(\frac{1}{2} - 0\right)} = 4$

ដូច្នេះ $\boxed{\frac{AB}{AF} + \frac{AF}{AB} = 4}$

ខ) គណនាជាអនុគមន៍នៃ $R$ ផលបូក $S = AB^2 + AC^2 + AD^2 + AE^2 + AF^2$

ដោយប្រើទ្រឹស្តីបទ sin គេបាន

$AC = 2R\sin\frac{2\pi}{12}$ , $AD = 2R\sin\frac{3\pi}{12}$

និង $AE = 2R\sin\frac{4\pi}{12}$

$\Rightarrow S = AB^2 + AC^2 + AD^2 + AE^2 + AF^2$

$= 4R^2\left(\sin^2\frac{\pi}{12} + \sin^2\frac{\pi}{6} + \sin^2\frac{\pi}{4} + \sin^2\frac{\pi}{3} + \sin^2\frac{5\pi}{6}\right)$

$= 4R^2\left(\sin^2\frac{\pi}{12} + \cos^2\frac{\pi}{12} + \frac{1}{4} + \frac{2}{4} + \frac{3}{4}\right)$

$= 4R^2 \cdot \frac{10}{4}$

ដូចនេះ $\boxed{S = 10R^2}$

## លំហាត់ទី ៥៥២

គេឱ្យចំនួន $N = 1 + 10^3 + \frac{10^3(10^3-1)}{1\cdot 2} + \frac{10^3(10^3-1)(10^3-2)}{1\cdot 2\cdot 3} + \cdots + \frac{10^3(10^3-1)}{1\cdot 2} + 10^3 + 1$ ។ តើ $N$ មានប៉ុន្មានខ្ទង់ បើគេដឹងថា $lg2 = 0.3010$ ?

## ដំណោះស្រាយ

រកចំនួនខ្ទង់នៃ $N = 1 + 10^3 + \frac{10^3(10^3-1)}{1\cdot 2} + \frac{10^3(10^3-1)(10^3-2)}{1\cdot 2\cdot 3} + \cdots +$

$$\frac{10^3\left(10^3-1\right)}{1\cdot 2}+10^3+1$$

តាង $n=10^3$ នោះ $C(n,0)=C(n,n)=1$

$$C(n,1)=C(n,n-1)=n$$

$$C(n,2)=\frac{n!}{(n-2)!2!}=\frac{(n-1)n}{1\cdot 2}$$

គេបាន $N=C(n,0)+C(n,1)+C(n,2)+\cdots+C(n,n)$

$$=(1+1)^n$$

$$lgN=lg2^n=nlg2$$

$$lgN=10^3(0.3010)\quad(lg2=0.3010)$$

$$N=10^301$$

ដូច្នេះ $N$ មាន 302 ខ្ទង់

## លំហាត់ទី ៥៥៣

គេឱ្យពហុធា $P(x)=\left(1+x+x^2+\cdots+x^{2010}\right)^2-x^{2010}$ ។
ចូរដាក់ $P(x)$ ជាផលគុណនៃពីរពហុធា ។

### ដំណោះស្រាយ

$$P(x)=\left(1+x+x^2+\cdots+x^{2010}\right)^2-x^{2010}$$

$$P(x)=\left[\left(1+x+x^2+\cdots+x^{2009}\right)+x^{2010}\right]^2-x^{2010}$$

$$=\left(1+x+x^2+\cdots+x^{2009}\right)^2+x^{2\cdot 2010}$$

$$+2\cdot x^{2010}\left(1+x+x^2+\cdots+x^{2009}\right)-x^{2010}$$

$$=\left(1+x+x^2+\cdots+x^{2009}\right)\times\left(1+x+x^2+\cdots+x^{2009}+2\cdot x^{2010}\right)+$$

$$x^{2010}\left(x^{2010}-1\right)$$

$$=\left(1+x+x^2+\cdots+x^{2009}\right)\times\left(1+x+x^2+\cdots+x^{2009}+2\cdot x^{2010}\right)+$$

$$x^{2010}(x-1)\left(x^{2009}+\cdots+x^2+x+1\right)$$

ដូច្នេះ $P(x)=\left(1+x+x^2+\cdots+x^{2009}\right)\left(1+x+x^2+\cdots+x^{2011}\right)$

## លំហាត់ទី ៥៥៤

តាង $f:\mathbb{R}\to\mathbb{R}$ ជាអនុគមន៍ដែល $f(0)=1$ និងចំពោះ $x,y\in\mathbb{R}$
$f(xy+1)=f(x).f(y)-f(y)-x+2$ ។ រក $f(2010)$ ។

## ដំណោះស្រាយ

មាន $f(xy+1)=f(x).f(y)-f(y)-x+2$ (1) ចំពោះ $x,y\in\mathbb{R}$

ប្តូរអថេរ $x$ និង $y$ ជំនួសចូល (1) គេបាន

$$f(yx+1)=f(y).f(x)-f(x)-y+2 \ (2)$$

យក $(1)-(2):\ f(x)-f(y)+y-x=0$

ឱ្យ $y=0 \quad f(x)-f(0)-x=0$

ដោយ $f(0)=1 \quad f(x)x+1$

ដូច្នេះ $\boxed{f(2010)=2011}$

## លំហាត់ទី ៥៥៥

ចូរពិនិត្យមើលស្វ៊ីតខាងក្រោម

$$u_1=1$$
$$u_2=3+5$$
$$u_3=7+9+11$$
$$u_4=13+15+17+19$$
$$\ldots$$

ស្រាយបញ្ជាក់ថា គ្រប់តួនៃស្វ៊ីត $\{u_n\}$ ជាគូបនៃចំនួនគត់ធម្មជាតិ ។

## ដំណោះស្រាយ

ស្រាយបញ្ជាក់ថា គ្រប់តួនៃស្វ៊ីត $\{u_n\}$ ជាគូបនៃចំនួនគត់ធម្មជាតិ

$$u_1=1$$
$$u_2=3+5$$
$$u_3=7+9+11$$
$$u_4=13+15+17+19$$
$$\ldots$$

តាងផលបូក $S_n=u_1+u_2+u_3+\cdots+u_n$

$$=1+(3+5)+(7+9+11)+\cdots$$

ឧបមាថា $S_n$ ជាផលបូកស្វ៊ីតនព្វន្តមាន $k$ តួ

$$S_n=\frac{k}{2}[2\cdot 1+(k-1)\cdot 2]=k^2$$

ដែល $k = 1+2+3+\cdots+n = \frac{n}{2}(n+1)$

$\Rightarrow S_n = \left[\frac{n}{2}(n+1)\right]^2$

ទាញបាន $S_{n-1} = \frac{(n-1)n}{2}$

$u_n = S_n - S_{n-1} = \left[\frac{n}{2}(n+1)\right]^2 - \left[\frac{n}{2}(n-1)\right]^2$

នោះ $u_n = n^3$

ដូចនេះ គ្រប់តួនៃស្វ៊ីត $\{u_n\}$ ជាគូបនៃចំនួនគត់ធម្មជាតិ

## លំហាត់ទី ៥៥៦

គេអោយអនុគមន៍ $f(x) = (x^3+12x-31)^{2020}$ ។

ចូរគណនា $f(a)$ បើ $a = \sqrt[3]{16+8\sqrt{5}} + \sqrt[3]{8-16\sqrt{5}}$ ។

### ដំណោះស្រាយ

យើងមាន $f(x) = (x^3+12x-31)^{2020}$ នោះ $f(a) = (a^3+12a-31)^{2020}$

ដោយ $a = \sqrt[3]{16+8\sqrt{5}} + \sqrt[3]{8-16\sqrt{5}}$

$$a^3 = \left(\sqrt[3]{16+8\sqrt{3}}\right)^3 + 3\left(\sqrt[3]{16+8\sqrt{3}}\right)\left(\sqrt[3]{16-8\sqrt{5}}\right)$$

$$\left(\sqrt[3]{16+8\sqrt{5}} + \sqrt[3]{8-16\sqrt{5}}\right) + \left(\sqrt[3]{16-8\sqrt{5}}\right)^3$$

$$= 16+8\sqrt{5}+3\left(\sqrt[3]{\left(16+8\sqrt{5}\right)\left(16-8\sqrt{5}\right)}\right)a+16-8\sqrt{5}$$

$$= 32+3a(-4)$$

នោះ $a^3+12a-31=1$

យើងបាន $f(a) = (1)^{2020} = 1$

ដូច្នេះ $f(a) = 1$

## លំហាត់ទី ៥៥៧

ស្រាយបញ្ជាក់ថា វិសមភាព $\frac{cosA}{a^3} + \frac{cosB}{b^3} + \frac{cosC}{c^3} \geq \frac{3}{2abc}$ ពិតចំពោះគ្រប់ត្រីកោណ $ABC$ ដែលមាន រង្វាស់ជ្រុង $a,b,c$ និងមុំឈម $\angle A, \angle B, \angle C$ រៀងគ្នា ។

## ដំណោះស្រាយ

តាមទ្រឹស្តីបទ Cosinus:

$a^2=b^2+c^2-2bccosA$

$2bccosA=b^2+c^2-a^2$

$cosA=\dfrac{b^2+c^2-a^2}{2bc}$

នោះ $\dfrac{cosA}{a^3}=\dfrac{b^2+c^2-a^2}{2a^3bc}$

ដូចគ្នាដែរ $\dfrac{cosB}{b^3}=\dfrac{a^2+c^2-b^2}{2b^3ac}$, $\dfrac{cosC}{c^3}=\dfrac{a^2+b^2-c^2}{2c^3ab}$

យើងបាន $\dfrac{cosA}{a^3}+\dfrac{cosB}{b^3}+\dfrac{cosC}{c^3}=\dfrac{1}{2abc}\left(\dfrac{b^2+c^2-a^2}{a^2}+\dfrac{c^2+a^2-b^2}{b^2}+\dfrac{a^2+b^2-c^2}{c^2}\right)$

$$\frac{cosA}{a^3}+\frac{cosB}{b^3}+\frac{cosC}{c^3}=\frac{1}{2abc}\left\{\left[\left(\frac{a}{b}\right)^2+\left(\frac{b}{a}\right)^2\right]+\left[\left(\frac{a}{c}\right)^2+\left(\frac{c}{a}\right)^2\right]+\left[\left(\frac{b}{c}\right)^2+\left(\frac{c}{b}\right)^2\right]-3\right\}$$

តែចំពោះ $x>0$ គេមានវិសមភាព $x+\dfrac{1}{x}\geq 2$

នោះ $\dfrac{cosA}{a^3}+\dfrac{cosB}{b^3}+\dfrac{cosC}{c^3}\geq\dfrac{1}{2abc}(2+2+2-3)$

$\dfrac{cosA}{a^3}+\dfrac{cosB}{b^3}+\dfrac{cosC}{c^3}\geq\dfrac{3}{2abc}$ ពិត

## លំហាត់ទី ៥៥៨

គេអោយ $a,b,c$ ជាបីចំនួនពិតវិជ្ជមាន ។

ស្រាយបញ្ជាក់ថា $\dfrac{a^2+1}{b+c}+\dfrac{b^2+1}{c+a}+\dfrac{c^2+1}{a+b}\geq 3$ ។

## ដំណោះស្រាយ

យើងមានវិសមភាពងាយ $a^2+1\geq 2a, b^2+1\geq 2b, c^2+1\geq 2c$

នោះ $\dfrac{a^2+1}{b+c}+\dfrac{b^2+1}{c+a}+\dfrac{c^2+1}{a+b}\geq\dfrac{2a}{b+c}+\dfrac{2b}{a+c}+\dfrac{2c}{a+b}$

យើងគ្រាន់តែស្រាយថា $\dfrac{2a}{b+c}+\dfrac{2b}{a+c}+\dfrac{2c}{a+b}\geq 3$ នោះយើងនិងអាចបញ្ជាក់បានថា វិសមភាពដើមពិត

$$\frac{2a}{b+c}+2+\frac{2b}{a+c}+2+\frac{2c}{a+b}+2\geq 9$$

$$(2a+2b+2c)\left(\frac{1}{b+c}+\frac{1}{c+a}+\frac{1}{a+b}\right)\geq 9 \quad (1)$$

តាង $x=b+c, y=c+a, z=a+b$ វិសមភាព (1) សមមូលទៅជា

$(x+y+z)\left(\frac{1}{x}+\frac{1}{y}+\frac{1}{z}\right)\geq 9$ ជាវិបាកនៃវិសមភាព AM-GM

ដូច្នេះ $\boxed{\frac{a^2+1}{b+c}+\frac{b^2+1}{c+a}+\frac{c^2+1}{a+b}\geq 3}$ ពិត

## លំហាត់ទី ៥៥៩

គេអោយ $f(x)=-x^2-2ax-b\ (a\neq 0)$ ។

គេដឹងថា $f(1)=3$ និង តម្លៃអតិបរមានៃ $f$ គឺ 4 ។ កំណត់តម្លៃ $a$ និង $b$ ។

**(អាហារូបករណ៍ប្រទេសជប៉ុន)**

## ដំណោះស្រាយ

គេមាន $f(1)=3$ នោះ $-1-2a+b=3\quad ...(1)$

ក្រាបនៃអនុគមន៍ខាងលើជាប៉ារ៉ាបូល ដែលបែរភាពផតចុះក្រោម

តម្លៃអតិបរមា $y=4$ គឺជាអរដោនេនៃកំពូលប៉ារ៉ាបូល

កូអរដោនេកំពូល $V\left(-\frac{b}{2a},\frac{4ac-b^2}{4a}\right)$

$\Rightarrow \frac{4ac-b^2}{-4}=4$ ឬ $\frac{-4b-4a^2}{-4}=4$

$b+a^2=4\quad ...(2)$

តាម $(1): b=4+2a$ ជំនួសចូល $(2)$

$\Rightarrow 4+2a+a^2=4$

$a^2+2a=0$

$a(a+2)=0$

$a=0, a=-2$

•បើ $a=0$ នោះ $b=-2$

•បើ $a=-2$ នោះ $b=0$

ដូច្នេះ $\boxed{a=-2, b=0}$

## លំហាត់ទី ៥៦០

តាង $f:\mathrm{R}\to\mathrm{R}$ ជាអនុគមន៍ដែល $f(0)=1$ និងចំពោះ $x,y\in\mathrm{R}$

$f(xy+1)=f(x).f(y)-f(y)-x+2$ ។ រក $f(2010)$ ។

## ដំណោះស្រាយ

មាន $f(xy+1)=f(x).f(y)-f(y)-x+2 \quad ...(1)$

ចំពោះ $x,y\in R$

ប្តូរអថេរ $x$ និង $y$ ចូល (1) គេបាន

$f(yx+1)=f(y).f(x)-f(x)-y+2 \quad ...(2)$

យក $(1)-(2)$ : $f(x)-f(y)+y-x=0$

ឱ្យ $y=0$ $\quad f(x)-f(0)=x-0$

ដោយ $f(0)=1$ $\quad f(x)=x+1$

ដូច្នេះ $\boxed{f(2010)=2011}$

## លំហាត់ទី ៥៦១

១. ត្រីកោណ $ABC$ មានមេដ្យាន $AM$ ។ បង្ហាញសមភាព $AB^2+AC^2=2AM^2+\dfrac{BC^2}{2}$ ។

២. ត្រីកោណ $ABC$ មាន $G$ ជាទីប្រជុំទម្ងន់ ។ តាង $a=BC, b=CA, c=AB$ ។ ស្រាយបញ្ជាក់ថា $GA^2+GB^2+GC^2=\dfrac{1}{3}(a^2+b^2+c^2)$ ។

## ដំណោះស្រាយ

១. បង្ហាញសមភាព $AB^2+AC^2=2AM^2+\dfrac{BC^2}{2}$




តាមទ្រឹស្តីបទពីតាគ័រ :

$AB^2=AH^2+BH^2$

$AC^2=AH^2+CH^2$

នោះ $AB^2+AC^2=2AH^2+BH^2+CH^2$

$AB^2+AC^2=2(AM^2-HM^2)+(BM-HM)^2+(CM+HM)^2$

$AB^2+AC^2=2AM^2-2HM^2+BM^2-2BM.HM+HM^2+CM^2+2CM.MH+MH^2$

$AB^2+AC^2=2AM^2+BM^2+CM^2$

$AB^2+AC^2=2AM^2+\left(\frac{BC}{2}\right)^2+\left(\frac{BC}{2}\right)^2$

$AB^2+AC^2=2AM^2+\frac{BC^2}{2}$ ពិត

២. ស្រាយបញ្ជាក់ថា $GA^2+GB^2+GC^2=\frac{1}{3}(a^2+b^2+c^2)$

យើងមាន $GA=\frac{2}{3}AM$

$GA^2=\left(\frac{2}{3}AM\right)^2=\frac{4}{9}AM^2$




តាមទ្រឹស្តីបទមេដ្យាន $AM^2=\frac{1}{2}\left(AB^2+AC^2-\frac{BC^2}{2}\right)$

$AM^2=\frac{1}{2}\left(c^2+b^2-\frac{a^2}{2}\right)$

នាំអោយ $GA^2=\frac{4}{9}\times\frac{1}{2}\left(c^2+b^2-\frac{a^2}{2}\right)$

$GA^2=\frac{2}{9}\left(c^2+b^2-\frac{a^2}{2}\right)$

ដូចគ្នាដែរ $GB^2=\frac{2}{9}\left(a^2+c^2-\frac{b^2}{2}\right)$, $GC^2=\frac{2}{9}\left(a^2+b^2-\frac{c^2}{2}\right)$

$GA^2+GB^2+GC^2=\frac{2}{9}\left(b^2+c^2-\frac{a^2}{2}+a^2+c^2-\frac{b^2}{2}+a^2+b^2-\frac{c^2}{2}\right)$

$GA^2+GB^2+GC^2=\frac{1}{3}(a^2+b^2+c^2)$ ពិត

## លំហាត់ទី ៥៦១

ត្រីកោណ $ABC$ កែងត្រង់ $A$ ។ ការេ $MNPQ$ ចារឹកក្នុងត្រីកោណកែង $ABC$ ដែល $M$ នៅលើ $AB$, $N$ និង $P$ នៅលើ $BC$ និង $Q$ នៅលើ $CA$ ។ ដូចគ្នាការេដែលមានជ្រុង $a_1,a_2,a_3$ ចារឹកក្នុងត្រីកោណកែង $QPC$ ,$MBN$ និង $AMQ$ រៀងគ្នា ដោយមានកំពូល 2 នៃការេនៅលើអ៊ីប៉ូតេនុស និងកំពូលមួយនៅលើជ្រុងមុំកែងនីមួយៗនៃត្រីកោណកែង ។

ស្រាយបញ្ជាក់ថា $\frac{1}{a_1^2}+\frac{1}{a_2^2}=\frac{1}{a_3^2}$ ។

## ដំណោះស្រាយ

ត្រីកោណកែង $QPC,BNM,MAQ$ និង $ABC$ ដូចគ្នា នោះផលធៀបជ្រុងការេចារឹកក្នុងត្រីកោណកែងទាំងបួន សមាមាត្រគ្នានឹងជ្រុងត្រូវគ្នានៃត្រីកោណកែង ។

តាង $a$ ជាជ្រុងការេ $MNPQ$

$$\frac{a_1}{a}=\frac{PQ}{AB}=\frac{a}{AB}\Rightarrow AB=\frac{a^2}{a_1}$$

$$\frac{a_2}{a}=\frac{MN}{AC}=\frac{a}{AC}\Rightarrow AC=\frac{a^2}{a_2}$$

$$\frac{a_3}{a}=\frac{MQ}{BC}=\frac{a}{BC}\Rightarrow BC=\frac{a^2}{a_3}$$

ពីតាត់ត្រីកោណកែង $ABC:\ AB^2+AC^2=BC^2$

$$\Leftrightarrow \frac{a^4}{a_1^2}+\frac{a^4}{a_2^2}=\frac{a^4}{a_3^2}$$

ដូចនេះ $\boxed{\frac{1}{a_1^2}+\frac{1}{a_2^2}=\frac{1}{a_3^2}}$




## លំហាត់ទី ៥៦២

ស្រាយបញ្ជាក់ថា ចំនួនគត់តូចបំផុតដែលធំជាង $(\sqrt{3}+1)^{4020}$ ចែកដាច់នឹង $2^{2011}$ ។

## ដំណោះស្រាយ

របៀបទី ១:

តាង $m=2010$ និង $I_m=(\sqrt{3}+1)^{2m}+(\sqrt{3}-1)^{2m}$

$$(\sqrt{3}+1)^{2m}=(\sqrt{3})^{2m}+\binom{1}{2m}(\sqrt{3})^{2m-1}+\cdots+\binom{2m-1}{2m}\sqrt{3}+1$$

$$(\sqrt{3}-1)^{2m}=(\sqrt{3})^{2m}-\binom{1}{2m}(\sqrt{3})^{2m-1}+\cdots-\binom{2m-1}{2m}\sqrt{3}+1$$

បូកអង្គ $I_m = 2\left(3^m + 3^{m-1} + \cdots + 1\right) \vdots 2$

$\Rightarrow I_m$ គត់

ដោយសារ $0 < \sqrt{3} - 1 < 1$ នោះ $(\sqrt{3}-1)^{2m} < 1$

ដូចនេះ $I_m$ ត្រូវតែជាចំនួនគត់តូចបំផុតធំជាង $(\sqrt{3}+1)^{2m}$

របៀបទី ២:

តាង $I_m = (4+2\sqrt{3})^m + (4-2\sqrt{3})^m$

យក $a = 4+2\sqrt{3},\ b = 4-2\sqrt{3}$ នោះ $\begin{cases} a+b=8 \\ ab=4 \end{cases}$

$a, b$ ជាឫសនៃសមីការ $x^2 - 8x + 4 = 0$

$$\begin{cases} a^2 - 8a + 4 = 0 | a^{m-1} \\ b^2 - 8b + 4 = 0 | b^{m-1} \end{cases}$$

---

បូកអង្គ $a^{m+1} + b^{m+1} = 8(a^m + b^m) - 4\left(a^{m-1} + b^{m-1}\right)$

$$I_{m+1} = 8I_m - 4I_{m-1}$$

មាន $I_0 = 2,\ I_1 = 8$ ជាចំនួនគត់

ឧបមាថា $I_m$ ជាចំនួនគត់ នោះ $I_{m+1} = 8I_m - 4I_{m-1}$ ជាចំនួនគត់

ដោយ $0 < (4-2\sqrt{3})^m < 1$

$I_m$ ត្រូវតែជាចំនួនគត់តូចបំផុតធំជាង $(\sqrt{3}+1)^{2m}$

ស្រាយបញ្ជាក់ថា $I_m \vdots 2^{m+1}$

មាន $I_1 = 8 \vdots 2^{1+1}$

ឧបមា $I_k \vdots 2^{k+1}$ គ្រប់ $m = 1, 2, .., k$

យើងនិងស្រាយថា $I_{k+1} \vdots 2^{k+2}$

ពី $I_{k+1} = 8I_k - 4I_{k-1}$

មាន $I_{k-1} \vdots 2^k \Rightarrow 4I_{k-1} \vdots 2^{k+2}$

$I_k \vdots 2^{k+1} \Rightarrow 8I_k \vdots 2^{k+2}$

គេបាន $I_{k+1} \vdots 2^{k+2}$ ពិត

ដូចនេះ $\boxed{I_{2020} = (4+2\sqrt{3})^{2010} + (4-2\sqrt{3})^{2010} \vdots 2^{2011}}$

## លំហាត់ទី ៥៦៣

១. សរសេរ $x^4 + 4y^4$ ជាផលគុណនៃពីរពហុធាដឺក្រេទីពីរនៃ $x$ និង $y$ :

២. បង្ហាញថា $n^4 + 4^n$ មិនមែនជាចំនួនបឋមទេ ចំពោះគ្រប់ចំនួនគត់វ៉ឺឡាទីប $n > 1$ ។

## ដំណោះស្រាយ

១. សរសេរ $x^4+4y^4$ ជាផលគុណនៃពីរពហុធាដឺក្រេទីពីរនៃ $x$ និង $y$ :

$x^4+4y^4=\left(x^4+4x^2y^2+4y^4\right)-4x^2y^2=\left(x^2+2y^2+2xy\right)\left(x^2+2y^2-2xy\right)$

២. បង្ហាញថា $n^4+4^n$ មិនមែនជាចំនួនបឋមទេ ចំពោះគ្រប់ចំនួនគត់វិជ្ជមាន $n>1$

ចំពោះគ្រប់ចំនួនគត់វិជ្ជមាន $n>1$ គេមានពីរករណី :

- បើ $n=2k$ ដែល $k=1,2,\ldots$ គេបាន $n^4+4^n=16\left(k^4+16k-1\right)$ ដែលមិនមែនជាចំនួនបឋមទេ ។

- បើ $n=2k+1$ ដែល $k=1,2,\ldots$ គេបាន $n^4+4^n=n^4+4^{2k+1}=n^4+4\left(2^k\right)^4$ $=\left(n^2+2^{2k+1}+n.2^{k+1}\right)\left(n^2+2^{2k+1}-n.2^{k+1}\right)$ ដែលមិនមែនជាចំនួនបឋមទេ ។

## លំហាត់ទី ៥៦៤

រកអនុគមន៍ $g$ ដែលផ្ទៀងផ្ទាត់សមីការ $g(x)+g\left(\frac{1}{1-x}\right)=x$ ចំពោះគ្រប់ចំនួនពិត $x$ ដែល $x\neq 0, x\neq 1$ ។

## ដំណោះស្រាយ

-ជំនួស $x$ ដោយ $\frac{1}{1-x}$ គេបាន $g\left(\frac{1}{1-x}\right)+g(1-\frac{1}{x})=\frac{1}{1-x}$

-ជំនួស $x$ ដោយ $1-\frac{1}{x}$ គេបាន $g\left(1-\frac{1}{x}\right)+g(x)=1-\frac{1}{x}$

គេបាន $g(x)+g\left(1-\frac{1}{x}\right)=x,\quad -g\left(\frac{1}{1-x}\right)-g\left(1-\frac{1}{x}\right)=-\frac{1}{1-x},$

$g\left(1-\frac{1}{x}\right)+g(x)=1-\frac{1}{x}$

ដោយបូកអង្គ និង អង្គ គេបាន $g(x)=\frac{1}{2}\left(x+1-\frac{1}{x}-\frac{1}{1-x}\right)$ ចំពោះ $x\neq 0, x\neq 1$ ។

## លំហាត់ទី ៥៦៥

រកគ្រប់ចំនួនគត់វិជ្ជមាន $n$ ដើម្បីឱ្យ $n^2-19n+99$ ជាការេប្រាកដ ។

## ដំណោះស្រាយ

$n^2-19n+99$ ជាការេប្រាកដលុះត្រាតែ

$$n^2-19n+99=k^2,\ k\in\mathbb{N}$$

$$n^2-19n+99-k^2=0$$

$\Delta = (-19)^2 - 4(1)(99 - k^2)$

$= 361 - 396 + 4k^2$

$= 4k^2 - 35$

$n$ ជាចំនួនគត់លុះត្រាតែ $4k^2 - 35 = t^2,\ t \in \mathbb{N}$

$\Leftrightarrow 4k^2 - t^2 = 35$

$\Leftrightarrow (2k - t)(2k + t) = 35$

ដោយ $k, t \in \mathbb{N}$ នោះ $2k - t < 2k + t$

ដោយ $35 = 1 \times 35 = 5 \times 7$

•ចំពោះ $35 = 1 \times 35$ គេបាន

$$\begin{cases} 2k - t = 1 \\ 2k + t = 35 \end{cases}$$

$4k = 36$

$k = 9$

$\Delta = 4(9)^2 - 35 = 289 = 17^2$

$n_1 = \dfrac{19 - 17}{2} = 1$

$n_2 = \dfrac{19 + 17}{2} = 18$

•ចំពោះ $35 = 5 \times 7$ គេបាន

$$\begin{cases} 2k - t = 5 \\ 2k + t = 7 \end{cases}$$

$4k = 12$

$k = 3,\ \Delta = 1$

$n_1 = \dfrac{19 - 1}{2} = 9$

$n_2 = \dfrac{19 + 1}{2} = 10$

ដូចនេះ $n \in \{1, 9, 10, 18\}$

របៀបទី ២

-ករណី $n = 1$ គេបាន $n^2 - 19n + 99 = 9^2$ ជាការេប្រាកដ

គេបាន $n = 1$ ជាចម្លើយ

- ករណី $2 \le n < 11$ គេបាន

$n^2 - 19n + 99 = (n-1)^2 - 17n + 98$ ជាការេប្រាកដបើ $-17n + 98 = 0$

$\Rightarrow n = \dfrac{98}{17} \notin \mathbb{N}$

$n^2 - 19n + 99 = (n-2)^2 - 15n + 95$ ជាការេប្រាកដបើ $-15n + 95 = 0$

$\Rightarrow n = \dfrac{19}{3} \notin \mathbb{N}$

$n^2 - 19n + 99 = (n-3)^2 - 13n + 90$ ជាការេប្រាកដបើ $-13n + 90 = 0$

$\Rightarrow n = \dfrac{90}{13} \notin \mathbb{N}$

$n^2 - 19n + 99 = (n-4)^2 - 11n + 83$ ជាការេប្រាកដបើ $-11n + 83 = 0$

$\Rightarrow n = \dfrac{83}{11} \notin \mathbb{N}$

$n^2 - 19n + 99 = (n-5)^2 - 9n + 74$ ជាការេប្រាកដបើ $-9n + 74 = 0$

$\Rightarrow n = \dfrac{74}{9} \notin \mathbb{N}$

$n^2 - 19n + 99 = (n-6)^2 - 7n + 63$ ជាការេប្រាកដបើ $-7n + 63 = 0$

$n = \dfrac{63}{9} = 7 \in \mathbb{N}$

គេបាន $n = 9$ ជាចម្លើយ

$n^2 - 19n + 99 = (n-7)^2 - 5n + 50$ ជាការេប្រាកដបើ $-5n + 50 = 0$

$\Rightarrow n = \dfrac{50}{5} = 10 \in \mathbb{N}$

គេបាន $n = 10$ ជាចម្លើយ

$n^2 - 19n + 99 = (n-8)^2 - 3n + 35$ ជាការេប្រាកដបើ $-3n + 35 = 0$

$\Rightarrow n = \dfrac{35}{3} \notin \mathbb{N}$

$n^2 - 19n + 99 = (n-9)^2 - n + 18$ ជាការេប្រាកដបើ $-n + 18 = 0$

$\Rightarrow n = 18 \in \mathbb{N}$

គេបាន $n = 18$ ជាចម្លើយ

$n^2 - 19n + 99 = (n-10)^2 + n - 1$ ជាការេប្រាកដបើ $n - 1 = 0$

$n = 1 \in \mathbb{N}$

គេបាន $n = 1$ ជាចម្លើយ

- ករណី $n > 11$

$n^2 - 19n + 99 = (n-10)^2 + n - 1$

$\Rightarrow n^2 - 19n + 99 > (n-10)^2$

$n^2 - 19n + 99 = (n-8)^2 - 3n + 35$

$\Rightarrow n^2 - 19n + 99 < (n-8)^2$

$\Rightarrow (n-10)^2 < n^2 - 19n + 99 < (n-8)^2$

$\Rightarrow n^2 - 19n + 99 = (n-9)^2$

$n^2 - 19n + 99 = n^2 - 18n + 81$

$\Rightarrow n = 18$

ដូចនេះ $n \in \{1, 9, 10, 18\}$

## លំហាត់ទី ៥៦៦

គេឱ្យចំនួនពិត $x, y \in (-2, 2)$ និង $xy = -1$ ។

ស្រាយបំភ្លឺថា $\dfrac{4}{4-x^2} + \dfrac{9}{9-y^2} \geq \dfrac{12}{5}$ ។

### ដំណោះស្រាយ

ចំពោះគ្រប់ $x, y \in (-2, 2)$ គេបាន

$\dfrac{4}{4-x^2} > 0, \ \dfrac{9}{9-y^2} > 0$

តាមវិសមភាពកូស៊ី

$$\frac{4}{4-x^2} + \frac{9}{9-y^2} \geq 2\sqrt{\left(\frac{4}{4-x^2}\right)\left(\frac{9}{9-y^2}\right)}$$

$$\geq \frac{12}{\sqrt{36 - 9x^2 - 4y^2 + x^2y^2}}$$

$$\geq \frac{12}{\sqrt{37 - (9x^2 + 4y^2)}} \quad (1) \text{ ព្រោះ } xy = -1$$

ដោយ $9x^2 + 4y^2 \geq 2\sqrt{(9x^2)(4y^2)}$

$\geq 12$

$-(9x^2 + 4y^2) \leq -12$

$37 - (9x^2 + 4y^2) \leq 25$

$\sqrt{37 - (9x^2 + 4y^2)} \leq 5$

$$\Rightarrow \frac{1}{\sqrt{37 - (9x^2 + 4y^2)}} \geq \frac{1}{5}$$

$$\frac{12}{\sqrt{37 - (9x^2 + 4y^2)}} \geq \frac{12}{5} \quad (2)$$

តាម (1) និង (2) គេបាន
$\frac{4}{4-x^2}+\frac{9}{9-y^2}\geq\frac{12}{5}$ ពិត

## លំហាត់ទី ៥៦៧

ឧបមា ពហុធា $p(x)=x^5+x^2+1$ មានឫសប្រាំ $r_1,r_2,r_3,r_4,r_5$ និង $q(x)=x^2-2$ ។ ចូរគណនា $q(r_1)q(r_2)q(r_3)q(r_4)q(r_5)$ ។

### ដំណោះស្រាយ

យើងមាន $r_1,r_2,r_3,r_4,r_5$ ជាឫសនៃ $p(x)$

$\Rightarrow p(x)=(x-r_1)(x-r_2)(x-r_3)(x-r_4)(x-r_5)$

ដោយ $q(x)=x^2-2$

$$q(r_1)=r_1^2-2$$
$$q(r_2)=r_2^2-2$$
$$q(r_3)=r_3^2-2$$
$$q(r_4)=r_4^2-2$$
$$q(r_5)=r_5^2-2$$

$\Rightarrow q(r_1)q(r_2)q(r_3)q(r_4)q(r_5)=(r_1^2-2)(r_2^2-2)(r_3^2-2)(r_4^2-2)(r_5^2-2)$

$=(r_1-\sqrt{2})(r_1+\sqrt{2})(r_2-\sqrt{2})(r_2+\sqrt{2})(3_2-\sqrt{2})(r_3+\sqrt{2})(r_4-\sqrt{2})$
$(r_4+\sqrt{2})(r_5-\sqrt{2})(r_5+\sqrt{2})$

$=(\sqrt{2}-r_1)(-\sqrt{2}-r_1)(\sqrt{2}-r_2)(-\sqrt{2}-r_2)(\sqrt{2}-r_3)(-\sqrt{2}-r_3)$
$(\sqrt{2}-r_4)(-\sqrt{2}-r_4)(\sqrt{2}-r_5)(-\sqrt{2}-r_5)$

$=\left[(\sqrt{2}-r_1)(\sqrt{2}-r_2)(\sqrt{2}-r_3)(\sqrt{2}-r_4)(\sqrt{2}-r_5)\right]$
$\left[(-\sqrt{2}-r_1)(-\sqrt{2}-r_2)(-\sqrt{2}-r_3)(-\sqrt{2}-r_4)(-\sqrt{2}-r_5)\right]$

$=p(\sqrt{2})\times p(-\sqrt{2})$

$=\left[(\sqrt{2})^5+\sqrt{2}^2+1\right]\left[(-\sqrt{2})^5+(-\sqrt{2})^2+1\right]$ ព្រោះ $p(x)=x^5+x^2+1$

$=(4\sqrt{2}+2+1)(-4\sqrt{2}+1+1)$

$=(3+4\sqrt{2})(3-4\sqrt{2})$

$=9-32=-23$

ដូចនេះ $q(r_1)q(r_2)q(r_3)q(r_4)q(r_5)=-23$

## លំហាត់ទី ៥៦៨

ក. រកចំនួនកុំផ្លិច $z$ ដែលផ្ទៀងផ្ទាត់ $z^7+1=0$ ។

ខ. ទាញបញ្ជាក់ថា $cos\frac{\pi}{7}-cos\frac{2\pi}{7}+cos\frac{3\pi}{7}=\frac{1}{2}$ ។

## ដំណោះស្រាយ

ក. រកចំនួនកុំផ្លិច $z$

យើងមាន $z^7+1=0 \Rightarrow z^7=-1$

$\Rightarrow z$ ជាឫសទី 7 នៃ $-1=cos\pi+isin\pi$

គឺ $z_k=cos\left(\frac{\pi+2k\pi}{7}\right)+isin\left(\frac{\pi+2k\pi}{7}\right)$ ដែល $k=0,1,..,6$

$k=0 \Rightarrow z_0=cos\frac{\pi}{7}+isin\frac{\pi}{7}$

$k=1 \Rightarrow z_1=cos\frac{3\pi}{7}+isin\frac{3\pi}{7}$

$k=2 \Rightarrow z_2=cos\frac{5\pi}{7}+isin\frac{5\pi}{7}$

$k=3 \Rightarrow z_3=cos\pi+isin\pi$

$k=4 \Rightarrow z_4=cos\frac{9\pi}{7}+isin\frac{9\pi}{7}$

$k=5 \Rightarrow z_5=cos\frac{11\pi}{7}+isin\frac{11\pi}{7}$

$k=6 \Rightarrow z_6=cos\frac{13\pi}{7}+isin\frac{13\pi}{7}$

ខ. ទាញថា $cos\frac{\pi}{7}-cos\frac{2\pi}{7}+cos\frac{3\pi}{7}=\frac{1}{2}$

គណនា $\left(cos\frac{\pi}{7}+isin\frac{\pi}{7}\right)+\cdots+\left(cos\frac{13\pi}{7}+isin\frac{13\pi}{7}\right)=0$

$\left(cos\frac{\pi}{7}+cos\frac{3\pi}{7}+cos\frac{5\pi}{7}+\cdots+cos\frac{13\pi}{7}\right)+$

$i\left(sin\frac{\pi}{7}+sin\frac{3\pi}{7}+sin\frac{5\pi}{7}+\cdots+sin\frac{13\pi}{7}\right)=0$

$\Rightarrow cos\frac{\pi}{7}+cos\frac{3\pi}{7}+cos\frac{5\pi}{7}+\cdots+cos\frac{13\pi}{7}=0$

$cos\frac{\pi}{7}+cos\frac{3\pi}{7}-cos\frac{2\pi}{7}-1-cos\frac{2\pi}{7}+cos\frac{3\pi}{7}+cos\frac{\pi}{7}=0$

$2cos\frac{\pi}{7}-2cos\frac{2\pi}{7}+2cos\frac{3\pi}{7}=1$

ដូចនេះ $cos\frac{\pi}{7}-cos\frac{2\pi}{7}+cos\frac{3\pi}{7}=\frac{1}{2}$

## លំហាត់ទី ៥៦៩

គេឱ្យ $O$ ជាចំណុចប្រសព្វរវាងអង្កត់ទ្រូង $AC$ និង $BD$ នៃប្រលេឡូក្រាម $ABCD$ ដែលមាន $\angle CAB=\angle DBC=2\angle DBA$ ។ គណនាផលធៀបនៃមុំ $\angle ACB$ និង $\angle AOB$ ។

### ដំណោះស្រាយ

គណនា $\frac{\angle ACB}{\angle AOB}$

តាង $\angle DBA=\alpha,\ 0<\alpha<60^0$ យើងបាន

$\angle BAC=\angle DBC=2\alpha$

$\angle AOB=180^0-3\alpha$

$\angle ACB=180^0-5\alpha$




តាមទ្រឹស្តីបទកូស៊ីនុសចំពោះ $\triangle AOB$ និង $\triangle BOC$

$\frac{OA}{sin\alpha}=\frac{OB}{sin2\alpha}\Rightarrow\frac{OA}{OB}=\frac{sin\alpha}{sin2\alpha}$

$\frac{OC}{sin2\alpha}=\frac{OB}{sin(180^0-5\alpha)}\Rightarrow\frac{OC}{OB}=\frac{sin2\alpha}{sin5\alpha}$

ដោយ $OC=OA\Rightarrow\frac{sin\alpha}{sin2\alpha}=\frac{sin2\alpha}{sin5\alpha}$

$sin^2 2\alpha=sin\alpha sin5\alpha$

$1-cos^2 2\alpha=\frac{1}{2}(cos4\alpha-cos6\alpha)$

$2-2cos^2 2\alpha=2cos^2 2\alpha-1-\left(4cos^3 2\alpha-3cos2\alpha\right)$

$2-2cos^2 2\alpha=2cos^2 2\alpha-1-4cos^3 2\alpha+3cos2\alpha$

$4cos^3 2\alpha-4cos^2 2\alpha-3cos2\alpha+3=0$

$4cos^2 2\alpha(cos2\alpha-1)-3(cos2\alpha-1)=0$

$\left(4cos^2 2\alpha-3\right)(cos2\alpha-1)=0$

គេទាញបាន

$\bullet cos2\alpha - 1 = 0$

$cos2\alpha = 1 = cos0$

$2\alpha = 0 \Rightarrow \alpha = 0$ មិនយក

$\bullet 4cos^2 2\alpha - 3 = 0$

$cos^2 2\alpha = \frac{3}{4}$

$cos2\alpha = \frac{\sqrt{3}}{2} = cos30^0$

$2\alpha = 30^0$

$\Rightarrow \alpha = 15^0$

គេបាន $\frac{\angle ACB}{\angle AOB} = \frac{180^0 - 5\times 15^0}{180^0 - 3\times 15^0} = \frac{105^0}{135^0}$

ដូចនេះ $\frac{\angle ACB}{\angle AOB} = \frac{7}{9}$

## លំហាត់ទី ៥៧០

រកចំនួនគត់គូដែលមានលេខបួនខ្ទង់ខុសៗគ្នានៅចន្លោះ 2000 និង 5000 ។

## ដំណោះស្រាយ

ចំនួនគត់គូដែលមានលេខបួនខ្ទង់ខុសៗគ្នា នៅចន្លោះ 2000 និង 5000 មាន :

លេខខ្ទង់ពាន់ $2,3,4$ និង លេខខ្ទង់រាយ $0,2,4,6,8$

+ ករណីចំនួននោះផ្ដើមដោយលេខ 2 គេបាន

ព្រឹត្តិការណ៍ជ្រើសរើស លេខខ្ទង់ពាន់មាន 1 របៀប

លេខខ្ទង់រាយមាន 4 របៀប

លេខខ្ទង់ដប់មាន 8 របៀប

លេខខ្ទង់រយមាន 7 របៀប

តាមគោលការណ៍ផលគុណ $1\times 4\times 8\times 7 = 224$

+ ករណីចំនួននោះផ្ដើមដោយលេខ 3 គេបាន

ព្រឹត្តិការណ៍ជ្រើសរើស លេខខ្ទង់ពាន់មាន 1 របៀប

លេខខ្ទង់រាយមាន 5 របៀប

លេខខ្ទង់ដប់មាន 8 របៀប

លេខខ្ទង់រយមាន 7 របៀប

តាមគោលការណ៍ផលគុណ $1\times 5\times 8\times 7 = 280$

+ ករណីចំនួននោះផ្ដើមដោយលេខ 4

ដូចករណីចំនួននោះផ្ដើមដោយលេខ 2 ដែរ គឺ 224
ដូចនេះ ចំនួនគត់គូសរុប $224+280+224=728$ ចំនួន

## លំហាត់ទី ៥៧១

គេឱ្យចំនួនគត់វិជ្ជមាន $a,b,a',b',d,d'$ ដែល $GCD(a,b)=d$ និង $GCD(a',b')=d'$ ។ ស្រាយបញ្ជាក់ថា $GCD(aa',bb',ab',a'b)=dd'$ ។

### ដំណោះស្រាយ

យើងមាន $GCD(a,b)=d \Rightarrow a=a_1d,\ b=b_1d$ ដែល $GCD(a_1,b_1)=1$

$GCD(a',b')=d' \Rightarrow a'=a_2d',\ b'=b_2d'$ ដែល $GCD(a_2,b_2)=1$

$\Rightarrow GCD(aa',bb',ab',a'b)=GCD(a_1a_1dd',b_1b_2dd',a_1b_2dd',a_2b_1dd')$

$=dd'GCD(a_1a_2,b_1b_2,a_1b_2,a_2b_1)$

ដោយ $GCD(a_1a_2,a_2b_1)=a_2$

$GCD(a_1b_2,b_1b_2)=b_2$

$\Rightarrow GCD(a_1a_2,b_1b_2,a_1b_2,a_2b_1)=GCD(a_2,b_2)=1$

ដូចនេះ $GCD(aa',bb',ab',a'b)=dd'$

## លំហាត់ទី ៥៧២

គេឱ្យស្វ៊ីត $(a_n)$ កំណត់ដោយ $a_n=\dfrac{n(n-1)}{2}cos\dfrac{n(n-1\pi)}{2}$ ។
គណនា $a_1+a_2+\cdots+a_{2020}$ ។

### ដំណោះស្រាយ

យើងមាន $a_n=\dfrac{n(n-1)}{2}cos\dfrac{n(n-1\pi)}{2}$

$$a_1=\frac{1(1-1)}{2}cos\frac{1(1-1)\pi}{2}=1\times 0$$

$$a_2=\frac{2(2-1)}{2}cos\frac{2(2-1)\pi}{2}=1\times 1\times(-1)=-1$$

$$a_3=\frac{3(3-1)}{2}cos\frac{3(3-1)\pi}{2}=3\times 1\times(-1)=-3$$

$$a_4=\frac{4(4-1)}{2}cos\frac{4(4-1)\pi}{2}=2\times 3\times 1=6$$

$$a_5=\frac{5(5-1)}{2}cos\frac{5(5-1)\pi}{2}=5\times 2\times 1$$

$$a_6=\frac{6(6-1)}{2}cos\frac{6(6-1)\pi}{2}=3\times5\times(-1)=-15$$
$$a_7=\frac{7(7-1)}{2}cos\frac{7(7-1)\pi}{2}=7\times3\times(-1)=-21$$
$$a_8=\frac{8(8-1)}{2}cos\frac{8(8-1)\pi}{2}=4\times7\times1=28$$

គេបាន $a_1+a_2+a_3+a_4=2$

$a_5+a_6+a_7+a_8=2$

..............................

$$a_{2017}=\frac{2017(2017-1)}{2}cos\frac{2017(2017-1)\pi}{2}=2017\times1008\times1$$
$$a_{2018}=\frac{2018(2018-1)}{2}cos\frac{2018(2018-1)\pi}{2}=1009\times2017\times(-1)$$
$$a_{2019}=\frac{2019(2019-1)}{2}cos\frac{2019(2019-1)\pi}{2}=2019\times1009\times(-1)$$
$$a_{2020}=\frac{2020(2020-1)}{2}cos\frac{2020(2020-1)\pi}{2}=1010\times2019\times1$$

$\Rightarrow a_{2017}+a_{2018}+a_{2019}+a_{2020}=2017(1008-1009)+2019(-1009+1010)=2$

ដោយ $2020=4\times505$

ដូចនេះ $a_1+a_2+\cdots+a_{2020}=2\times505=1010$

## លំហាត់ទី ៥៧៣

គេឱ្យ $\triangle ABC$ កែងត្រង់ $C$ និងមានប្រវែងជ្រុងទាំងបីជាចំនួនវិជ្ជមាន ។ កម្ពស់គូសចេញពីកំពូល $C$ កាត់អ៊ីប៉ូតេនុស $AB$ ត្រង់ចំណុច $D$ ដែល $BD=24389$ ។ គណនា $sin\angle BAC$ ។

## ដំណោះស្រាយ



$$\sin\angle BAC = \sin(90^0 - \angle ABC)$$
$$= \cos\angle ABC$$
$$= \frac{BD}{BC} \quad (\triangle BDC \text{ កែងត្រង់ } D)$$
$$= \frac{24389}{BC} = \frac{29^3}{BC}$$

តាមទ្រឹស្តីបទពីតាគ័រក្នុងត្រីកោណកែង $BDC$

$BC^2 - CD^2 = BD^2 \Rightarrow CD$ ជាចំនួនគត់

$(BC - CD)(BC + CD) = 29^6$

ដោយ $BC, CD$ ជាចំនួនគត់ នោះ $BC - CD, BC + CD$ ជាចំនួនគត់ដែរ ហើយដែល $BC - CD < BC + CD$

ម្យ៉ាងទៀត $29^6 = 1 \times 29^6 = 29 \times 29^5 = 29^2 \times 29^4$

- ចំពោះ $29^6 = 1 \times 29^6$ គេបាន

$$\begin{cases} BC - CD = 1 \\ BC + CD = 29^6 \end{cases}$$

$$2BC = 1 + 29^6$$
$$BC = \frac{1 + 29^6}{2} \in \mathbb{N}$$

តែ $\sin\angle BAC = \dfrac{BC}{AB}$

$$\Rightarrow \frac{29^3}{BC} = \frac{BC}{AB}$$

$$\Rightarrow AB = \frac{BC^2}{29^3} = \frac{(1 + 29^6)^2}{4 \times 29^3} \notin \mathbb{N}$$

$$BC = \frac{29\left(1 + 29^4\right)}{2} \in \mathbb{N} \text{ (ស្រាយដូចគ្នា)}$$

- ចំពោះ $29^6 = 29^2 \times 29^4$ គេបាន

$$+\begin{cases} BC - CD = 29^2 \\ BC + CD = 29^4 \end{cases}$$

$$2BC = 29^2\left(1 + 29^2\right)$$
$$BC = \frac{29^2\left(1 + 29^2\right)}{2} \in \mathbb{N}$$

$$AB=\frac{BC^2}{29^3}=\frac{29^4\left(1+29^2\right)}{4\times 29^3}$$

$$AB=\frac{29\left(1+29^2\right)^2}{4}\in\mathbb{N}$$

$$AC^2=AB^2-BC^2$$

$$=\frac{29^2\left(1+29^2\right)^4}{4^2}-\frac{29^4\left(1+29^2\right)^2}{4}$$

$$=\frac{29^2\left(1+29^2\right)^2}{4}\left[\frac{\left(1+29^2\right)^2}{4}-29^2\right]$$

$$=\frac{29^2\left(1+29^2\right)^2}{4}\times\frac{\left(1-29^2\right)^2}{4}$$

$$AC=\frac{29\left(1+29^2\right)\left(1-29^2\right)}{4}\in\mathbb{N}$$

ករណីនេះ គេបាន

$$\sin\angle BAC=\frac{29^3\times 2}{29^2\left(1+29^2\right)}=\frac{29\times 2}{842}$$

$$=\frac{29}{421}$$

ដូចនេះ $\boxed{\sin\angle BAC=\frac{29}{421}}$

## លំហាត់ទី ៥៧៨

គេឱ្យអនុគមន៍ $f$ កំណត់លើ $\mathbb{N}$ ដោយ $f(1)=11, f(2)=22, f(3)=33, f(4)=44$ និង $f(n)=f(n-1)-f(n-2)+f(n-3)-f(n-4)$ ចំពោះគ្រប់ $n\geq 5$ ។ គណនា $f(2020)$ ។

## ដំណោះស្រាយ

យើងមាន $f(n)=f(n-1)-f(n-2)+f(n-3)-f(n-4)$

$$f(n-1)=f(n-2)-f(n-3)+f(n-4)-f(n-5)$$

---

$$f(n)=-f(n-5)$$

$$f(n)=-[-f(n-5-5)]$$

$$f(n)=(-1)^2[f(n-5\times 2)]$$

$f(n)=(-1)^2[-f(n-5\times 2-5)]$

$f(n)=(-1)^3 f(n-5\times 3)$

ជាទូទៅ $f(n)=(-1)^k f(n-5\times k)$

$\Rightarrow f(2020)=(-1)^{403} f(2020-5\times 403)$

$=-f(5)$

$=-[f(4)-f(3)+f(2)-f(1)]$

$=-(44-33+22-11)$

$=-22$

ដូចនេះ $\boxed{f(2020)=-22}$

## លំហាត់ទី ៥៧៥

គេឱ្យចតុកោណព្នាយ $ABCD$ មានបាត $AD \parallel BC$ ។ $E$ ជាចំណុចចល័តមួយនៅលើអង្កត់ $AB$ ។ $O_1$ និង $O_2$ ជាផ្ចិតរង្វង់ចារឹកក្រៅ $\triangle AED$ និង $\triangle BEC$ រៀងគ្នា ។ បង្ហាញថា $O_1O_2$ មានប្រវែងថេរ ។

## ដំណោះស្រាយ




បង្ហាញថា $O_1O_2$ មានប្រវែងថេរ

តាមទ្រឹស្តីបទស៊ីនុសចំពោះ $\triangle EAD$ និង $\triangle EBC$

$$\frac{ED}{sin\angle A}=2O_1E \Rightarrow ED=2.O_1E sin\angle A$$

$\frac{EC}{sin\angle B} = 2O_2E \Rightarrow EC = 2.O_2Esin\angle B$

$= 2O_2Esin\angle A$ ព្រោះ $\angle A + \angle B = 180^0$

$\Rightarrow \frac{ED}{EC} = \frac{2O_1Esin\angle A}{2O_2Esin\angle A} = \frac{O_1E}{O_2E}$

$\Rightarrow \frac{ED}{O_1E} = \frac{EC}{O_2E} \quad (1)$

តាង $H,I$ ជាចំណុចកណ្ដាលរៀងគ្នានៃ $AC,BE$ យើងបាន :

$\Delta O_1HE$ កែងត្រង់ $H$

$\Rightarrow \angle O_1EH = 90^0 - \angle EO_1H$

$= 90^0 - \angle EDA$

$\Delta O_2IE$ កែងត្រង់ $I$

$\Rightarrow \angle O_2EI = 90^0 - \angle EO_2I$

$= 90^0 - \angle ECB$

$\angle O_1EH + \angle O_2EI = 180^0 - (\angle EDA + \angle ECB)$

$180^0 - \angle O_1EO_2 = 180^0 - \angle DEC$

$\angle O_1EO_2 = \angle DEC \quad (2)$

តាម (1) និង (2) : $\Delta O_1EO_2 \sim \Delta DEC$ ( ករណីដំនូចទី ២ )

វិបាក $\frac{O_1O_2}{CD} = \frac{O_1E}{DE} = \frac{O_1E}{2O_1Esin\angle A}$

$= \frac{1}{2sin\angle A}$

$\Rightarrow O_1O_2 = \frac{CD}{2sin\angle A}$

ដោយ $CD$ ថេរ និង $sin\angle A$ ថេរ

ដូចនេះ $O_1O_2$ មានប្រវែងថេរ

## លំហាត់ទី ៥៧៦

ក្នុងត្រីកោណកែង $XYZ$ មួយមាន $\widehat{X} = 90^0, YZ = x, ZX = y$ និង $XY = z$ ។
បង្ហាញថា $x^n > y^n + z^n$ ចំពោះគ្រប់ចំនួនគត់រ៉ឺឡាទីប $n$ ដែល $n \geq 3$ ។

## ដំណោះស្រាយ

- ចំពោះ $n = 3$

គេមាន $x^2 = y^2 + z^2 \Rightarrow x^3 = xy^2 + xz^2$

តែ $x > y \Rightarrow xy^2 > y^3$ ហើយ $x > z \Rightarrow xz^2 > z^3$
គេទាញបាន $x^3 > y^3 + z^3$
-ឧបមាថា $x^k > y^k + z^k$ ចំពោះ $k \geq 3$
- ពិនិត្យចំពោះ $k+1$
$x^k > y^k + z^k \Rightarrow x^{k+1} > xy^k + xz^k$
តែ $x > y \Rightarrow xy^k > y^{k+1}$ ហើយ
$x > z \Rightarrow xz^k > z^{k+1}$
គេទាញបាន $x^{k+1} > y^{k+1} + z^{k+1}$ ពិត




## លំហាត់ទី ៥៧៧

គេបានបេះផ្លែស្វាយមករៀបគរជា 11 គំនរស្មើៗគ្នា ហើយនៅសល់ផ្លែស្វាយចំនួន 6 ផ្លែទៀត ។ តែបើគេយកផ្លែស្វាយទាំងនោះមករៀបជា 17 គំនរស្មើៗគ្នាវិញ នោះពុំមានផ្លែស្វាយនៅសល់ទេ ។ រកចំនួនផ្លែស្វាយតិចបំផុតដែលគេបានបេះ ។

### ដំណោះស្រាយ

តាង $M$ ជាចំនួនផ្លែស្វាយតិចបំផុតដែលគេបានបេះ
- ដោយដឹងថាបើគេរៀបគរជា 11 គំនរស្មើៗគ្នា ហើយនៅសល់ផ្លែស្វាយចំនួន 6 ផ្លែទៀត នោះគេបាន: $M \equiv 6 \pmod{11} \Rightarrow M = 11k + 6,\ k > 1$
- ដោយដឹងថាបើគេរៀបជា 17 គំនរស្មើៗគ្នា គ្មានសល់ផ្លែស្វាយទេ នោះគេបាន
$M \equiv 0 \pmod{17} \Rightarrow M = 11k + 6 \equiv 0 \pmod{17}$
$\Rightarrow 11k \equiv -6 \equiv 11 \pmod{17}$
តែ $gcd(11,17) = 1$ នោះ $k \equiv 1 \pmod{17} \Rightarrow k = 17m + 1,\ m \geq 1$
ដើម្បីបានចំនួនផ្លែស្វាយតិចបំផុតដែលគេបានបេះ គេគ្រាន់តែយក $m = 1$ ជាការស្រេច :
$m = 1 \Rightarrow k = 18$ ហើយ $M = 11 \cdot 18 + 6 = 204$ ផ្លែ

## លំហាត់ទី ៥៧៨

ចតុកោណប៉ោង $ABCD$ មួយមានជ្រុង $AB = a, BC = b, CD = c, DA = d$ រង្វាស់មុំ $A\hat{B}C = x$ និង $A\hat{D}C = y$ ។ រកលក្ខខណ្ឌដើម្បីឱ្យចតុកោណ $ABCD$ មានផ្ទៃក្រឡាអតិបរមា ។

### ដំណោះស្រាយ

- រកផ្ទៃក្រឡានៃ $ABCD$ ជាអនុគមន៍នៃ $a;b;c;d;x$ និង $y$

ចតុកោណ $ABCD$ មានផ្ទៃក្រឡា $S=\frac{1}{2}absinx+\frac{1}{2}cdsiny$




អង្កត់ទ្រូង $[AC]$ មានប្រវែង $L=a^2+b^2-2abcosx=c^2+d^2-2cdcosy$
ដោយរកដេរីវេធៀបនឹង $x$ គេបាន :

$S'(x)=\frac{1}{2}abcosx+\frac{1}{2}cdcosy\cdot y' \quad (1)$

$L'(x)=2absinx=2cdsiny\cdot y'$

$$absinx=cdsiny\cdot y' \Rightarrow y'=\frac{absinx}{cdsiny}$$

តាម $(1)\Rightarrow S'(x)=\frac{1}{2}ab\times\frac{sinxcosy+cosxsiny}{siny}=\frac{1}{2}ab\times\frac{sin(x+y)}{siny}$

មានសញ្ញាដូច $sin(x+y)$

$S'(x)=0\Leftrightarrow sin(x+y)=0\Leftrightarrow x+y=\pi$

បើ $0<x+y<\pi\Leftrightarrow S'(x)>0$

បើ $2\pi>x+y>\pi\Leftrightarrow S'(x)<0$

បានន័យថា $S(x)$ មានអតិបរមាលុះត្រាតែ $x+y=\pi$

ដូចនេះ ចតុកោណ $ABCD$ មានផ្ទៃអតិបរមាលុះត្រាតែ $ABCD$ ចារឹកក្នុងរង្វង់

## លំហាត់ទី ៥៧៩

ស្វ៊ីតនៃចំនួន $(u_n)$ កំណត់ដោយ $u_1=1;\ u_2=1$ និង $u_n=u_{n-1}+u_{n-2}$ ចំពោះ $n=3;4;\ldots$ ។

តាង $a=\frac{1+\sqrt{5}}{2}$ និង $b=\frac{1-\sqrt{5}}{2}$ ។

១. បង្ហាញថា $u_n>a^{n-2}$ ចំពោះគ្រប់ចំនួនគត់ $n\geq 3$ ។

២. បង្ហាញថា $u_n=\frac{1}{\sqrt{5}}(a^n-b^n)$ ចំពោះគ្រប់ចំនួនគត់រ៉ឺឡាទីបវិជ្ជមាន $n$ ។

## ដំណោះស្រាយ

១. បង្ហាញថា $u_n > a^{n-2}$ ចំពោះគ្រប់ចំនួនគត់ $n \geq 3$

- ចំពោះ $n = 3$ គេបាន $u_3 = 2$ ហើយ $a^{3-2} = a = \dfrac{1+\sqrt{5}}{2} < 2$

បានន័យថា $u_3 > a^{3-2}$

- ឧបមាថា $u_p > a^{p-2}$ ចំពោះ $p \geq 3$

- សិក្សាចំពោះ $p+1$

តាមសម្មតិកម្មអនុមានរួម គេបាន $u_p > a^{p-2}$, $u_{p-1} > a^{p-3}$

ដោយបូកអង្គ និង អង្គ គេបាន $u_p + u_{p-1} > a^{p-2} + a^{p-3}$ ហើយ

$u_{p+1} > a^{p-2} + a^{p-3} \quad (1)$

តែគេដឹងថា $a = \dfrac{1+\sqrt{5}}{2}$ ជាឫសនៃសមីការ $x^2 = x+1$ នោះគេបាន $a^2 = a+1$

ដោយគុណនឹង $a^{p-3}$ គេបាន $a^{p-1} = a^{p-2} + a^{p-3} \quad (2)$

តាម (1) និង (2) $\Rightarrow u_{p+1} > a^{(p+1)-2}$

ដូចនេះ $u_n > a^{n-2}$ ចំពោះគ្រប់ចំនួនគត់ $n \geq 3$

២. បង្ហាញថា $u_n = \dfrac{1}{\sqrt{5}}(a^n - b^n)$ ចំពោះគ្រប់ចំនួនគត់រ៉ឺឡាទីបវិជ្ជមាន $n$

- ចំពោះ $n = 1$ គេបាន $1 = u_1 = \dfrac{1}{\sqrt{5}}(a-b) = \dfrac{1}{2\sqrt{5}}(1+\sqrt{5}-1+\sqrt{5}) = 1$

- ឧបមាថា $u_k = \dfrac{1}{\sqrt{5}}\left(a^k - b^k\right)$

- សិក្សាចំពោះ $k+1$

គេមាន $u_{k+1} = u_k + u_{k-1} = \dfrac{1}{\sqrt{5}}\left(\left(a^k + a^{k-1}\right) - \left(b^k + b^{k-1}\right)\right) \quad (3)$

តែ $a$ និង $b$ ជាឫសនៃសមីការ $x^2 = x+1$ នោះ $a^2 = a+1$ និង $b^2 = b+1$

គេបាន $a^{k+1} = a^k + a^{k-1}$ និង $b^{k+1} = b^k + b^{k-1}$

តាម (3) $\Rightarrow u_{k+1} = \dfrac{1}{\sqrt{5}}\left(a^{k+1} - b^{k+1}\right)$

ដូចនេះ $u_n = \dfrac{1}{\sqrt{5}}(a^n - b^n)$ ចំពោះគ្រប់ចំនួនគត់រ៉ឺឡាទីបវិជ្ជមាន $n$

## លំហាត់ទី ៥៨០

គណនាផលបូក $S = \dfrac{1}{2^1} - \dfrac{2^1}{2^2} + \dfrac{3}{2^3} - \dfrac{4}{2^4} + \cdots - \dfrac{2010}{2^{2010}} + \dfrac{2011}{2^{2011}}$ ។

## ដំណោះស្រាយ

$$S=\frac{1}{2^1}-\frac{2^1}{2^2}+\frac{3}{2^3}-\frac{4}{2^4}+\cdots-\frac{2010}{2^{2010}}+\frac{2011}{2^{2011}}\quad(1)$$

$$2S=1-\frac{2}{2}+\frac{3}{2^2}-\frac{4}{2^3}+\cdots-\frac{2010}{2^{2009}}+\frac{2011}{2^{2010}}\quad(2)$$

$(1)+(2)$:

$$3S=1-\frac{1}{2}+\frac{1}{2^2}-\frac{1}{2^3}+\cdots+\frac{1}{2^{2010}}+\frac{2011}{2^{2011}}$$

$$=\frac{1-\left(-\frac{1}{2}\right)^{2011}}{1+\frac{1}{2}}+\frac{2011}{2^{2011}}$$

$$=\frac{2}{3}\cdot\left(\frac{2^{2011}+1}{2^{2011}}\right)+\frac{2011}{2^{2011}}$$

$$=\frac{1}{3.2^{2011}}\left(2^{2012}+6035\right)$$

ដូចនេះ $\boxed{S=\frac{1}{9.2^{2011}}\left(2^{2012}+6035\right)}$

## លំហាត់ទី ៥៨១

គេឱ្យចំនួនគត់វិជ្ជមាន $I_n=8^n+9^{3n+1}+25^{3n+1}$ ចំពោះ $n=0,1,2,...,2011$ ។ រក $gcd(I_0,I_1,I_2,...,I_{2011})$ ។

### ដំណោះស្រាយ

តាង $d=gcd(I_0,I_1,I_2,...,I_{2011})$

$\Rightarrow d|I_0$

ដោយ $I_n=8^n+9^{3n+1}+25^{3n+1}$ ចំពោះ $n=0,1,2,...,2011$

$I_0=1+9+25=35=5\times 7$

$\Rightarrow d|5\times 7$

ម្យ៉ាងទៀត $I_n=2^{3n}+9^{3n+1}+25^{3n+1}$

$I_n=2^{3n}+(10-1)^{3n+1}+26^{3n+1}$

$\equiv 2^{3n}+(-1)^{3n+1}\pmod 5$

$I_1\equiv 8+1\equiv 4\pmod 5$

$\Rightarrow d\nmid 5$

$I_n=8^n+9\times 9^{3n}+25\times 25^{3n}$

$\equiv 1+2\times 2^{3n}+4\times 4^{3n}$

$\equiv 1+2+4 \equiv 0 \pmod 7$

$\Rightarrow 7|I_n$ គ្រប់ $n = 0, 1, 2, \ldots, 2011$

ដូចនេះ $\boxed{d = 7}$

## លំហាត់ទី ៥៨២

បង្ហាញថា ចំនួនគត់ $N = 5^{5^{2011}} + 5^{5^{2010}} + 1$ មិនមែនជាចំនួនបឋម ។

### ដំណោះស្រាយ

តាង $x = 5^{5^{2010}}$

$$N = x^5 + x + 1$$
$$= x^5 - x^2 + x^2 + x + 1$$
$$= x^2(x-1)(x^2+x+1) + x^2 + x + 1$$
$$= (x^2+x+1)\left[x^2(x-1)+1\right]$$
$$= (x^2+x+1)(x^3-x^2+1)$$

ដោយ $x^2+x+1, x^3-x^2+1 > 1$ ចំពោះ $x = 5^{5^{2010}}$

ដូចនេះ $\boxed{N \text{ មិនមែនជាចំនួនបឋមទេ}}$

## លំហាត់ទី ៥៨៣

ដោះស្រាយសមីការខាងក្រោមក្នុងសំណុំចំនួនគត់រ៉ឺឡាទីប :

$x^2 + x + 503 = y^2$ ។

### ដំណោះស្រាយ

$$x^2 + x + 503 = y^2$$
$$4x^2 + 4x + 2012 = 4y^2$$
$$4y^2 - (2x+1)^2 = 2011$$
$$(|2y| - |2x+1|)(|2y| + |2x+1|) = 2011$$

ដោយ 2011 ជាចំនួនបឋម

$$\begin{cases} |2y| - |2x+1| = 1 \\ |2y| + |2x+1| = 2011 \end{cases} +$$

$$4|y| = 2012$$
$$|y| = 503$$

$y=\pm 503$

គេបាន $|2x+1|=2|y|-1=1005$

$2x+1=\pm 1005$

$\Rightarrow \left[\begin{array}{l} x=502 \\ x=-503 \end{array}\right.$

ដូចនេះ $(x,y)=(502,503)$
$=(502,-503)$
$=(-503,503)$
$=(-503,-503)$

## លំហាត់ទី ៥៨៨

រកគ្រប់អនុគមន៍ $f:\mathbf{R}-\left\{\frac{2}{3}\right\}\to\mathbf{R}$ ដែលបំពេញសមីការអនុគមន៍ខាងក្រោម :

$\frac{1}{2}f\left(\frac{2x}{3x-2}\right)+f(x)=503x$ ។

### ដំណោះស្រាយ

សម្មតិកម្ម $\frac{1}{2}f\left(\frac{2x}{3x-2}\right)+f(x)=503x \quad (1)$

តាង $u=\frac{2x}{3x-2}\Rightarrow x=\frac{2u}{3u-2}$

គេបាន $\frac{1}{2}f(u)+f\left(\frac{2u}{3u-2}\right)=\frac{1006}{3u-2}$

ឬ $\frac{1}{2}f(x)+f\left(\frac{2x}{3x-2}\right)=\frac{1006}{3x-2} \quad (2)$

$(1)-(2)$ គេបាន

$\frac{3}{4}f(x)=503x-\frac{503x}{3x-2}$

$\frac{3}{4}f(x)=\frac{1509x(x-1)}{3x-2}$

ដូចនេះ $f(x)=\frac{2012x(x-1)}{(3x-2)}$

## លំហាត់ទី ៥៨៥

គេឱ្យពហុធា $P(x)=\sum_{k=0}^{2011}\frac{1}{(2011+k+1)}x^4$ ។

ស្រាយបញ្ជាក់ថា សមីការ $P(x^2)=P^2(x)$ គ្មានឫសជាចំនួនពិត ។

### ដំណោះស្រាយ

សម្មតិកម្ម $P(x)=\sum_{k=0}^{2011}\frac{1}{(2011+k+1)}x^4$

តាង $a_k=\frac{1}{2011+k+1}>0$

$\Rightarrow P(x)=\sum_{k=0}^{2011}a_kx^k$

តាមវិសមភាព Cauchy-Schwarz

$$P^2(x)\left(\sum_{k=0}^{2011}\sqrt{a_k}.\sqrt{a_k}x^k\right)$$

$$\leq\left(\sum_{k=0}^{2011}a_k\right)\left(\sum_{k=0}^{2011}a_k.x^{2k}\right)$$

$P^2(x)\leq P(1)\cdot P(x^2)$

ដោយ $P(1)\sum_{k=0}^{2011}a_k$

$$=\sum_{k=0}^{2011}\left(\frac{1}{2011+k+1}\right)<1$$

ដូចនេះ $P^2(x)<P(x^2)$ នោះសមីការ $P^2(x)=P(x^2)$ គ្មានឫស

## លំហាត់ទី ៥៨៦

គេឱ្យចតុកោណ $ABCD$ ចារឹកក្នុងរង្វង់ ហើយមានផ្ទៃក្រឡា $S$ ។

គេឱ្យ $AB=a,BC=b,CD=c,AD=d$ និង $p$ ជាកន្លះបរិមាត្រ ។

ក) ស្រាយបញ្ជាក់ថា $S=\sqrt{(p-a)(p-b)(p-c)(p-d)}$ ។

ខ) បើ $S=\left(\frac{p}{2}\right)^2$ បង្ហាញថា $ABCD$ ជាការេ ។

### ដំណោះស្រាយ

ក ) ស្រាយបញ្ជាក់ថា $S=\sqrt{(p-a)(p-b)(p-c)(p-d)}$




$$S=S_{ABCD}=S_{ABC}+S_{ACD}$$
$$=\frac{1}{2}absinB+\frac{1}{2}cdsinD$$
$$=\frac{1}{2}sinB(ab+cd),\ B+D=\pi$$
$$4S=2sinB(ab+cd)\quad(1)$$
$$AC^2=a^2+b^2-2abcosB$$
$$AC^2=c^2+d^2-2cdcosD$$
$$=c^2+d^2+2cdcosB$$
$$\Rightarrow a^2+b^2-2abcosB=c^2+d^2+2cdcosB$$
$$2cosB(ab+cd)=a^2+b^2-c^2-d^2\quad(2)$$

លើកអង្គ (1) &(2) ជាការេ

$$4sin^2B(ab+cd)^2=16S^2$$
$$4cos^2B(ab+cd)^2=(a^2+b^2-c^2-d^2)^2$$

---

$$4(ab+cd)^2=16S^2+(a^2+b^2-c^2-d^2)^2$$
$$16S^2=(2ab+2cd)^2-(a^2+b^2-c^2-d^2)^2$$
$$=\left[(a+b)^2-(c-d)^2\right]\left[(c+d)^2-(a-b)^2\right]$$
$$=(2p-2d)(2p-2c)(2p-2a)(2p-2b)$$
$$=16(p-a)(p-b)(p-c)(p-d)$$

ដូចនេះ $\boxed{S=\sqrt{(p-a)(p-b)(p-c)(p-d)}}$

ខ ) បើ $S=\left(\frac{p}{2}\right)^2$ បង្ហាញថា $ABCD$ ជាការេ

$$\sqrt{(p-a)(p-b)(p-c)(p-d)}=\left(\frac{p}{2}\right)^2$$

$\Rightarrow \sqrt[4]{(p-a)(p-b)(p-c)(p-d)} = \frac{p}{2}$

ដោយ $\frac{p}{2} = \frac{(p-a)+(p-b)+(p-c)+(p-d)}{4}$

តាមវិសមភាព Cauchy

$\frac{p}{2} \geq \sqrt[4]{(p-a)(p-b)(p-c)(p-d)}$

សមភាព : $p-a = p-b = p-c = p-d$

$\Rightarrow ABCD$ ជាការេ

## លំហាត់ទី ៥៨៧

ក ) រកតម្លៃនៃ $A = 2011^3 - 2010.2011^3 - 2010^2.2011 + 2010^3$ ។

ខ ) រកតម្លៃនៃ $B = 403^5 - 402^2(403^3 + 2.403^2 + 3.403 + 4)$ ។

## ដំណោះស្រាយ

ក ) រកតម្លៃនៃ $A = 2011^3 - 2010.2011^3 - 2010^2.2011 + 2010^3$

$A = 2011^3 - 2010.2011^3 - 2010^2.2011 + 2010^3$

$= 2011^2(2011 - 2010) + 2010^2(2010 - 2011)$

$= 2011^2 - 2010^2$

$= 2011 + 2011$

ដូចនេះ $\boxed{A = 4021}$

ខ ) រកតម្លៃនៃ $B = 403^5 - 402^2(403^3 + 2.403^2 + 3.403 + 4)$

តាង $x = 403$

$B = x^5 - (x-1)^2(x^3 + 2x^2 + 3x + 4)$

$= x^5 - (x^2 - 2x + 1)(x^3 + 2x^2 + 3x + 1)$

$= x^5 - x^5 - 2x^4 - 3x^3 - 4x^2 + 4x^3 + 2x^4 + 6x^2 + 8x - x^3 - 2x^2 - 3x - 4$

$= 5x - 4$

$B = 5 \times 403 - 4$

ដូចនេះ $\boxed{B = 2011}$

## លំហាត់ទី ៥៨៨

គណនាផលបូកតួមិនកំណត់នៃស្វ៊ីតខាងក្រោម :

$S=\frac{1^3}{3^1}+\frac{2^3}{3^2}+\frac{3^3}{3^3}+\frac{4^3}{3^4}+\frac{5^3}{3^5}+\cdots$ ។

### ដំណោះស្រាយ

$$S=\frac{1^3}{3^1}+\frac{2^3}{3^2}+\frac{3^3}{3^3}+\frac{4^3}{3^4}+\frac{5^3}{3^5}+\cdots$$

$$\frac{S}{3}=\frac{1}{3^2}+\frac{2^3}{3^3}+\frac{3^3}{3^4}+\frac{4^3}{3^5}+\frac{5^3}{3^6}+\cdots$$

$$S-\frac{S}{3}=\frac{2S}{3}=\frac{1}{3}+\frac{2^3-1}{3^3}+\frac{3^3-2^3}{3^3}+\cdots$$

$$\frac{2S}{9}=\frac{1}{3^2}+\frac{2^3-1^3}{3^3}+\frac{3^3-2^3}{3^3}+\cdots$$

$$\frac{2S}{3}-\frac{2S}{9}=\frac{1}{3}+\frac{2^3-2\cdot1^3}{3^2}+\frac{3^3-2\cdot2^3+1}{3^3}+\cdots$$

$$=\frac{1}{3}+\frac{2}{3}+\frac{3^2-2\cdot2^3+1^3}{3^3}+\cdots$$

$$=1+\frac{3^2-2\cdot2^3+1^3}{3^3}+\cdots$$

ដោយ $(k+1)^3-2k^3+(k-1)^3=6k$

$$\Rightarrow\frac{4S}{9}=1+\frac{6\cdot2}{3^3}+\frac{6\cdot3}{3^4}+\cdots$$

$$\Rightarrow\frac{4S}{27}=\frac{1}{3}+\frac{12}{3^4}+\frac{18}{3^5}+\cdots$$

$$\frac{4S}{9}-\frac{4S}{27}=\frac{8S}{27}=\frac{2}{3}+\frac{12}{3^3}+\frac{6}{3^4}+\frac{6}{3^5}+\cdots$$

$$\frac{8S}{27}=\frac{10}{9}+6\left(\frac{1}{3^4}+\frac{1}{3^5}+\cdots\right)$$

$$=\frac{10}{9}+6\cdot\frac{\frac{1}{3^4}}{1-\frac{1}{3}}=\frac{11}{9}$$

ដូចនេះ $\boxed{S=\frac{11}{9}}$

## លំហាត់ទី ៥៨៩

គេឱ្យ $f(n)=\dfrac{1}{\sqrt[3]{n^2+2n+1}+\sqrt[3]{n^2-1}+\sqrt[3]{n^2-2n+1}}$ គ្រប់ $n\in\mathbf{N}$ ។
គណនាផលបូក $S=f(1)+f(3)+f(5)+\cdots+f(10^6-3)+f(10^6-1)$ ។

## ដំណោះស្រាយ

តាង $x=\sqrt[3]{n+1}$

$y=\sqrt[3]{n-1}$

$xy=\sqrt[3]{n^2-1}$

$\Rightarrow f(n)=\dfrac{1}{x^2+xy+y^2}$

$f(n)=\dfrac{x-y}{x^3-y^3}$

$=\dfrac{x-y}{n+1-n+1}$

$f(n)=\dfrac{1}{2}(x-y)$

ឬ $f(n)=\dfrac{1}{2}\left(\sqrt[3]{n+1}-\sqrt[3]{n-1}\right)$

$f(1)=\dfrac{1}{2}\left(\sqrt[3]{2}-\sqrt[3]{0}\right)$

$f(3)=\dfrac{1}{2}\left(\sqrt[3]{4}-\sqrt[3]{2}\right)$

$f(5)=\dfrac{1}{2}\left(\sqrt[3]{6}-\sqrt[3]{4}\right)$

..................................................

$f(10^6-1)=\dfrac{1}{2}\left(\sqrt[3]{10^6}-\sqrt[3]{10^6-2}\right)$

---

បូកអង្គ $S=\dfrac{1}{2}\left(\sqrt[3]{10^6}-0\right)=50$

ដូចនេះ $\boxed{S=50}$

## លំហាត់ទី ៥៩០

បន្ទាត់៣ផ្សេងគ្នា ត្រូវបានគូសនៅក្នុងប្លង់ ។ ឧបមាថាមាន $n$ រង្វង់យ៉ាងពិតប្រាកដនៅក្នុងប្លង់ដែលប៉ះនឹងបន្ទាត់ទាំង៣ ។ រកតម្លៃដែលអាចមាននៃ $n$ ដោយគូសរូបបញ្ជាក់ ។

### ដំណោះស្រាយ

$n$ រង្វង់ប៉ះនឹងបន្ទាត់ទាំង៣ នៅក្នុងប្លង់:

មាន៣ករណី :

- ករណីបន្ទាត់ទាំង 3 ស្របគ្នា :

គ្មានរង្វង់ប៉ះបន្ទាត់ទាំង 3 $\Rightarrow n = 0$







- ករណីបន្ទាត់ពីរស្របគ្នា កាត់ដោយបន្ទាត់ទីបី

$\Rightarrow$ មានរង្វង់ 2 ប៉ះនឹងបន្ទាត់ទាំង3

នោះ $n = 2$




- ករណីបន្ទាត់ទាំង3 កាត់គ្នា នោះមានរង្វង់4 ប៉ះនឹងរង្វង់ទាំង3 $\Rightarrow n = 4$

## លំហាត់ទី ៥៩១

តាង $u_0, u_1, u_2, ..., u_n$ ជាស៊្វីតនៃចំនួនពិត ដែលបំពេញទំនាក់ទំនងខាងក្រោម :

$(3 - u_{n+1})(6 + u_n) = 18$ និង $u_0 = 3$ ។ គណនា $\sum_{k=0}^{2011} \frac{1}{u_k}$ ។

## ដំណោះស្រាយ

សម្មតិកម្ម $u_0, u_1, u_2, ..., u_n$ ជាស្វ៊ីតនៃចំនួនពិត

$$\begin{cases} u_0 = 3 \\ (3 - u_{n+1})(6 + u_n) = 18 \end{cases}$$

មាន $(3 - u_{n+1})(6 + u_n) = 18$

$$3u_n - 6u_{n+1} - u_{n+1} \cdot u_n = 0$$

ចែកអង្គនឹង $u_{n+1} \cdot u_n$

$$\Rightarrow \frac{3}{u_{n+1}} - \frac{6}{u_n} - 1 = 0 \quad (1)$$

តាង $v_n = \frac{1}{u_n} \Rightarrow v_{n+1} = \frac{1}{u_{n+1}}$

$(1) \Rightarrow 3v_{n+1} - 6v_n - 1 = 0$

$$v_{n+1} = 2v_n + \frac{1}{3}$$

$$v_{n+1} + \frac{1}{3} = 2\left(v_n + \frac{1}{3}\right)$$

តាង $a_n = v_n + \frac{1}{3}$

$\Rightarrow a_{n+1} = 2a_n$

$\Rightarrow (a_n)$ ជាស្វ៊ីតធរណីមាត្រដែលមានរេសុង $q = 2$ និងតួទី ១ $a_0 = v_0 + \frac{1}{3} = \frac{1}{u_0} + \frac{1}{3}$

$a_0 = \frac{2}{3}$

$$\Rightarrow a_n = a_0 \cdot q^n = \frac{2}{3} \cdot 2^n = \frac{1}{3} \cdot 2^{n+1}$$

គេបាន $v_n = \frac{1}{3} \cdot 2^{n+1} - \frac{1}{3} = \frac{1}{3}\left(2^{n+1} - 1\right)$

$$\sum_{k=0}^{2011} \frac{1}{u_k} = \sum_{k=0}^{2011} v_k$$

$$= \sum_{k=0}^{2011} \frac{1}{3}\left(2^{n+1} - 1\right)$$

$$\sum_{k=0}^{2011} \frac{1}{u_k} = \frac{1}{3}(2 + 2^2 + \cdots + 2^{2012} - 2012)$$

$= \frac{1}{3}\left(2 \cdot \frac{2^{2012}-1}{2-1} - 2012\right)$

$= \frac{1}{3}(2^{2013} - 2014)$ ដូចនេះ: $\boxed{\sum_{k=0}^{2011} \frac{1}{u_k} = \frac{1}{3}(2^{2013} - 2014)}$

## លំហាត់ទី ៥៩២

ស្វ៊ែរ $S_1$ មួយមានកាំ $r$ ចារឹកក្នុងកោនមួយមានមុំនៅត្រង់កំពូលនៃមុខកាត់តាមអ័ក្សស្មើ $\frac{\pi}{3}$ ។

ក) រកផលធៀប $\frac{V_1}{V}$ រវាងមាឌ $V_1$ និង មាឌ $V$ នៃស្វ៊ែរ $S_1$ និង កោន ។

ខ) ហៅ $S_2$ ជាស្វ៊ែរនៅក្នុងកោន ប៉ះនឹងជនេត្រនៃកោន ហើយប៉ះនឹងស្វ៊ែរ $S_1$

$S_3$ ជាស្វ៊ែរនៅក្នុងកោន ប៉ះនឹងជនេត្រនៃកោន ហើយប៉ះនឹងស្វ៊ែរ $S_2$

..........................................................................................................

$S_{k+1}$ ជាស្វ៊ែរនៅក្នុងកោន ប៉ះនឹងជនេត្រនៃកោន ហើយប៉ះនឹងស្វ៊ែរ $S_k$

ស្រាយបញ្ជាក់ថាគ្រប់ $n \in \mathbf{N}$ ផលបូកមាឌនៃស្វ៊ែរ $S_1, S_2, ..., S_n$ តូចជាង $\frac{1}{2}V$ ។

### ដំណោះស្រាយ

ក) រកផលធៀប $\frac{V_1}{V}$ រវាងមាឌ $V_1$ និង មាឌ $V$ នៃស្វ៊ែរ $S_1$ និង កោន







តាង $SA_1B_1$ មុខកាត់តាមអ័ក្ស $SH_1$នៃកោន ដែលមុំ $A_1\widehat{S}B_1 = \frac{\pi}{3}$

$\Rightarrow \triangle SA_1B_1$ សម័ង្ស
ស្វ៊ែរ $S_1$ ចារឹកក្នុងកោន
តាង $O_1$ ជាផ្ចិតរង្វង់ចារឹកក្នុង $\triangle$ សម័ង្ស $SA_1B_1$
$\Rightarrow O_1$ ជាទីប្រជុំទម្ងន់
$\Rightarrow SH_1 = 3O_1H_1 = 3R$

$SH_1 = A_1B_1 \cdot \dfrac{\sqrt{3}}{2}$

$A_1B-1 = \dfrac{6r}{\sqrt{3}} = 2r\sqrt{3}$

គេបាន $V = \dfrac{1}{3}\left(\pi \cdot \dfrac{A_1B_1^2}{4}\right) \cdot SH_1$

$= \dfrac{1}{3} \cdot \pi \cdot 3r^2 \cdot 3r$

$= 3\pi r^2$

$V_1 = \dfrac{4}{3}\pi r^3$ (មាឌស្វ៊ែរ $S_1$)

ដូចនេះ $\boxed{\dfrac{V_1}{V} = \dfrac{4}{9}}$

ខ) ស្រាយបញ្ជាក់ថា $V_1 + V_2 + \cdots + V_n < \dfrac{1}{2}V$ គ្រប់ $n \in \mathbf{N}$

តាងស្វ៊ែរ $S_1, S_2, \ldots, S_n$ មានមាឌរៀងគ្នា $V_1, V_2, \ldots, V_n$
$A_2B_2, A_3B_3, \ldots, A_nB_n$ បន្ទាត់រួមរវាងស្វ៊ែរ $S_2, S_3, \ldots, S_k$ រៀងគ្នានឹងស្វ៊ែរ $S_1, S_2, \ldots,$
$S_k$ នោះ $A_1B_1 \parallel A_2B_2 \parallel \ldots \parallel A_nB_n$
យក $O_1, O_2, \ldots, O_n$ ជាផ្ចិតរង្វង់ចារឹកក្នុង $\triangle SA_1B_1, \triangle SA_2B_2, \ldots, \triangle SA_nB_n$
មានកាំរៀងគ្នា $r_1, r_2, \ldots, r_n$

យើងមាន $r = r_1 = O_1H_1 = \dfrac{1}{3}SH_1 = SH_2$

$r_2 = O_2H_2 = \dfrac{1}{3}SH_2 = \dfrac{1}{3}r$

$\Rightarrow r_3 = \dfrac{1}{3}r_2 = \dfrac{1}{3^2}r$

$r_4 = \dfrac{1}{3}r_3 = \dfrac{1}{3^3}r$

..........................

$$r_n=\frac{1}{3^{n-1}}r \text{ គ្រប់ } n\ge 2$$

គេបាន $V_1+V_2+\cdots+V_n=\frac{4}{3}\pi r^3+\frac{4}{3}\pi r_2^3+\cdots+\frac{4}{3}\pi r_n^3$

$$=\frac{4}{3}\pi\left[r^3+\left(\frac{1}{3}r\right)^3+\cdots+\left(\frac{1}{3^{n-1}}r\right)^3\right]$$

$$=\frac{4}{3}\pi r^3\left[1+\frac{1}{3^3}+\left(\frac{1}{3^3}\right)^2+\cdots+\left(\frac{1}{3^3}\right)^{n-1}\right]$$

$$=\frac{4}{3}\pi r^3\cdot\frac{1-\left(\frac{1}{3}\right)^n}{1-\frac{1}{27}}$$

$$=\frac{4}{3}\pi r^3\cdot\frac{27}{26}\left[1-\left(\frac{1}{3^3}\right)^n\right]$$

$$=\frac{18\pi r^3}{13}\left[1-\left(\frac{1}{3^3}\right)^n\right]<\frac{18\pi r^3}{13}$$

ដូចនេះ $\frac{\sum_{i=1}^n V_i}{V}<\frac{\frac{18\pi r^3}{13}}{3\pi r^3}=\frac{6}{13}<\frac{1}{2}$

$$\boxed{\sum_{i=1}^n V_i<\frac{1}{2}V}$$

## លំហាត់ទី ៥៩៣

គេឱ្យ $c>0$ និង $a,b\ge c$ ។ ស្រាយបញ្ជាក់ថា $\sqrt{c(a-c)}+\sqrt{c(b-c)}\le\sqrt{ab}$ ។

## ដំណោះស្រាយ

វិសមភាពអាចសរសេរទៅជា $\sqrt{\frac{c}{b}\cdot\frac{a-c}{a}}+\sqrt{\frac{c}{a}\cdot\frac{b-c}{b}}\le 1$

ចំពោះ $x,y$ វិជ្ជមាន គេមាន $\sqrt{xy}\le\frac{x+y}{2}$ (វិសមភាព AM-GM)

នោះ $\sqrt{\frac{c}{b}\cdot\frac{a-c}{a}}+\sqrt{\frac{c}{a}\cdot\frac{b-c}{b}}\le\frac{\frac{c}{b}+\frac{a-c}{a}}{2}+\frac{\frac{c}{a}+\frac{b-c}{b}}{2}$

$$\sqrt{\frac{c}{b}\cdot\frac{a-c}{c}}+\sqrt{\frac{c}{a}\cdot\frac{b-c}{b}}\le\frac{\frac{c}{b}+1-\frac{c}{a}+\frac{c}{a}+1-\frac{c}{b}}{2}=1$$ ពិត

ជាសមភាពកាលណា $\begin{cases}\frac{c}{b}=\frac{a-c}{a}\\ \frac{c}{a}=\frac{b-c}{b}\end{cases}\Leftrightarrow\frac{1}{a}+\frac{1}{b}=\frac{1}{c}$

ឬ $a=b=2c$

## លំហាត់ទី ៥៩៥

គណនាអាំងតេក្រាល $I(k)=\int_0^{\infty}\frac{\sin kx\cos^k x}{x}dx$ ដែល $k$ ជាចំនួនគត់វិជ្ជមាន ។

## ដំណោះស្រាយ

តាមទ្រឹស្តីបទទ្វេធា គេមាន $(e^{2ix}+1)^k=\sum_{r=0}^{k}\binom{k}{r}e^{2rxi}$ (1)

តែ $(e^{2ix}+1)^k=e^{kix}(e^{ix}+e^{-ix})^k=(\cos kx+i\sin kx)2^k\cdot\cos^k x$ (2)

តាម (1) &(2) គេបាន

$$2^k\sin kx\cos^k x=\sum_{r=0}^{k}\binom{k}{r}\sin 2rx=\sum_{r=1}^{k}\binom{k}{r}\sin 2rx$$

នាំអោយ $I(k)=\frac{1}{2^k}\int_0^{\infty}\frac{\sin 2rx}{x}dx$

តែ $\int_0^{\infty}\frac{\sin x}{x}dx=\frac{\pi}{2}$ នោះ $I(k)=\frac{\pi}{2^{k+1}}\sum_{r=1}^{k}\binom{k}{r}$

$$I(k)=\frac{\pi}{2^{k+1}}\left[\binom{k}{1}+\binom{k}{2}+\cdots+\binom{k}{k}\right]=\frac{\pi}{2^{k+1}}(2^k-1)$$

ដូចនេះ $\boxed{I(k)=\frac{\pi}{2}\left(1-\frac{1}{2^k}\right)}$




$$\int_0^{\infty}\frac{\sin x}{x}dx=\frac{\pi}{2}\ldots??$$

យើងពិនិត្យអាំងតេក្រាលមួយចំនួនខាងក្រោម :

**EX :** គណនាអាំងតេក្រាលខាងក្រោម

ក. $\int_0^{\infty} \frac{dx}{x^2+a^2},\ a>0$

ខ. $\int_{-\infty}^{+\infty} \frac{dx}{x^2+1}$

គ. $\int_{-\infty}^{0} e^x dx$

ដំណោះស្រាយ

ក. $\int_0^{\infty} \frac{dx}{x^2+a^2},\ a>0$

$$\begin{aligned}\int_0^{\infty} \frac{dx}{x^2+a^2} &= \lim_{p\to+\infty}\int_0^{p} \frac{dx}{x^2+a^2}\\ &= \lim_{p\to+\infty}\left[\frac{1}{a}\cdot tan^{-1}\frac{x}{a}\right]_0^p\\ &= \lim_{p\to+\infty}\frac{1}{a}\cdot tan^{-1}\frac{p}{a} = \frac{\pi}{2a}\end{aligned}$$

ខ. $\int_{-\infty}^{+\infty} \frac{dx}{x^2+1}$

$$\begin{aligned}\int_{-\infty}^{+\infty} \frac{dx}{x^2+1} &= \int_{-\infty}^{0} \frac{dx}{x^2+1} + \int_0^{+\infty} \frac{dx}{x^2+1}\\ &= \lim_{p\to-\infty}\int_p^{0} \frac{dx}{x^2+1} + \lim_{p\to+\infty}\int_0^{p} \frac{dx}{x^2+1}\\ &= \lim_{p\to-\infty}\left(tan^{-1}a - tan^{-1}p\right) + \lim_{p\to+\infty}\left(tan^{-1}p - tan^{-1}a\right)\\ &= tan^{-1}a + \frac{\pi}{2} + \frac{\pi}{2} - tan^{-1}a = \pi\end{aligned}$$

គ. $\int_{-\infty}^{0} e^x dx$

$$\begin{aligned}\int_{-\infty}^{0} e^x dx = \int_0^{\infty} e^{-x} dx &= \lim_{p\to+\infty}\int_0^{p} e^{-x} dx\\ &= \lim_{p\to+\infty}(1-e^{-p}) = 1\end{aligned}$$

**EX :** គណនាអាំងតេក្រាល

$$\int_{-\infty}^{+\infty} x.e^{-x^2} dx \text{ ។}$$

ដំណោះស្រាយ

យើងមាន $\int_{-\infty}^{+\infty} x.e^{-x^2}dx = \int_{-\infty}^{a} xe^{-x^2}dx + \int_{a}^{+\infty} xe^{-x^2}dx$

ដោយ $\int_{-\infty}^{a} xe^{-x^2}dx = \lim_{p\to-\infty}\int_{p}^{a} xe^{-x^2}dx$

$= \lim_{p\to-\infty}\frac{\left(e^{p^2}-e^{-p^2}\right)}{2} = \frac{-e^{-a^2}}{2}$

និង $\int_{a}^{\infty} xe^{-x^2}dx = \lim_{p\to\infty}\int_{a}^{p} xe^{-x^2}dx$

$= \lim_{p\to\infty}\frac{\left(e^{-a^2}-e^{-p^2}\right)}{2} = \frac{e^{-a^2}}{2}$

នាំអោយ $\int_{-\infty}^{+\infty} x.e^{-x^2}dx = \left(\frac{-e^{-a^2}}{2}\right) + \left(\frac{e^{-a^2}}{2}\right) = 0$

**EX :** គណនា $\int_{0}^{+\infty} e^{-ax}cosbxdx$ រួចទាញរក $\int_{0}^{\infty}\frac{sinbx}{x}dx$ ។

ដំណោះស្រាយ

យើងមាន $\int_{0}^{+\infty} e^{-ax}cosbxdx = \lim_{p\to\infty}\int_{0}^{p} e^{-ax}cosbxdx$

$= \lim_{p\to\infty}\left[\frac{e^{-ax}(bsinbx - acosbx)}{a^2+b^2}\right]_0^p$

$= \lim_{p\to\infty}\left[\frac{e^{-ap}(bsinbp - acosbp)}{a^2+b^2} + \frac{a}{a^2+b^2}\right]$

$\Rightarrow \int_{0}^{\infty} e^{-ax}cosbxdx = \frac{a}{a^2+b^2}$ ( ព្រោះ $\lim_{p\to\infty} e^{-ap} = 0$ ) $(i)$

តាង $I = \int_{0}^{\infty}\frac{e^{-ax}sinbx}{x}, a > 0 \quad (ii)$

ធ្វើដេរីវេក្រោមសញ្ញាអាំងតេក្រាល យើងបាន

$$\frac{dI}{db} = \int_{0}^{\infty} e^{-ax}cosbxdx = \frac{a}{a^2+b^2}$$

អាំងតេក្រាលធៀប $b$:

$I = a\cdot\frac{1}{a}\cdot tan^{-1}\left(\frac{b}{a}\right) + C$

$I = tan^{-1}\left(\frac{b}{a}\right) + C \quad (iii)$

បើ $b = 0$ តាម $(ii)$, $I = 0$ ហើយតាម $(iii) \Rightarrow C = 0$

នាំអោយ $\int_0^{\infty}\frac{e^{-ax}sinbx}{x}dx = tan^{-1}\left(\frac{b}{a}\right)$
ពេល $a \to 0$ យើងបាន
$$\int_0^{\infty}\frac{sinbx}{x}dx = \frac{\pi}{2} \text{ ឬ } -\frac{\pi}{2} \text{ អាស្រ័យ } b>0 \text{ ឬ } b<0 \text{ ។}$$
•ករណីពិសេស ចំពោះ $b=1$ នោះ $\int_0^{\infty}\frac{sinx}{x}dx = \frac{\pi}{2}$ ។

សំគាល់ :គេអាចស្រាយ $\int_0^{\infty}\frac{sinx}{x}dx = \frac{\pi}{2}$ ដោយប្រើបំលែងឡាប្លាស ឬ អនុគមន៍អថេរកុំផ្លិច ។

## លំហាត់ទី ៥៩៥

គណនាអាំងតេក្រាល $I = \int_0^{\frac{\pi}{2}} ln(sinx)dx$ ។

## ដំណោះស្រាយ

$$I = \int_0^{\frac{\pi}{2}} ln(sinx)dx = \int_0^{\frac{\pi}{2}} ln\left[sin\left(\frac{\pi}{2}-x\right)\right]dx = \int_0^{\frac{\pi}{2}} ln(cosx)dx$$
នាំអោយ $2I = \int_0^{\frac{\pi}{2}}[ln(sinx)+ln(cosx)]dx = \int_0^{\frac{\pi}{2}} ln\left(\frac{sin2x}{2}\right)dx$
$$2I = \int_0^{\frac{\pi}{2}}(sin2x)dx - \int_0^{\frac{\pi}{2}} ln2dx$$
◇ ចំពោះ $\int_0^{\frac{\pi}{2}} ln(sin2x)dx$
តាង $t=2x$ នោះ $dt = 2dx$
នោះ $\int_0^{\frac{\pi}{2}} ln(sin2x)dx = \int_0^{\pi} ln(sint)dt = \frac{1}{2}\cdot 2I = I$
តែ $a^3+b^3+c^3=3$ នោះ $3\left(a^5+b^5+c^5\right)+6\geq 15$
នោះ $a^5+b^5+c^5\geq 3$ ពិត
ដូចនេះ $\boxed{a^5+b^5+c^5\geq 3}$

IV. រកចំនួនទូកធំ និង ចំនួនទូកតូចដែលត្រូវជួល
តាង $x$ ជាចំនួនទូកធំ $0<x\leq 8$, $y$ ជាចំនួនទូកតូច $0<y\leq 19$

គេបាន $12x+5y=99 \quad (1)$

បើ $x=7, y=2$ នោះ $12\times 7+5\times 2=99 \quad (2)$ ផ្ទៀងផ្ទាត់

យក $(1)-(2)$ អង្គ និង អង្គ : $12(x-7)+5(y-2)=0$ ឬ $12(x-7)=-5(y-2)$

នោះ $y-2=12k,\ k\in\mathbb{Z}$ ឬ $x-7=5t,\ t\in\mathbb{Z}$ ឬ $x=7+5t$

តែ $0<x\le 8 \Leftrightarrow 0<7+5t\le 8$

$\Leftrightarrow -7<5t\le 1$

$\Leftrightarrow -\frac{7}{5}<t\le\frac{1}{5}$ នោះ $t=0$ ឬ $t=-1$

បើ $t=-1$ នោះ $x=2$ និង $y=15$

បើ $t=0$ នោះ $x=7$ និង $y=3$

ដូចនេះ គេអាចជួលទូកធំ 2 និង ទូកតូច 15 ឬ ទូកធំ 7 និងទូកតូច 3

V. ១. ស្រាយបញ្ជាក់ថា $m_a^2=\frac{2b^2+2c^2-a^2}{4}$




យើងមាន $\overrightarrow{AA'}=\overrightarrow{AC}+\overrightarrow{CA'}$ និង $\overrightarrow{AA'}=\overrightarrow{AB}+\overrightarrow{BA'}$

នោះ $2\overrightarrow{AA'}=\overrightarrow{AB}+\overrightarrow{AC}+\overrightarrow{CA'}+\overrightarrow{BA'}$

តែ $A'$ ជាចំណុចកណ្តាលនៃ $BC$ នោះ $\overrightarrow{BA'}+\overrightarrow{CA'}=0$

នាំអោយ $2\overrightarrow{AA'}=\overrightarrow{AB}+\overrightarrow{AC}$

$4\overrightarrow{AA'}^2=\overrightarrow{AB}^2+\overrightarrow{AC}^2+2\overrightarrow{AB}\cdot\overrightarrow{AC}$ ឬ $4m_a^2=c^2+b^2+2\overrightarrow{AB}\cdot\overrightarrow{AC} \quad (1)$

តែ $\overrightarrow{BC}=\overrightarrow{CA}-\overrightarrow{CB}$ នោះ $\overrightarrow{BC}^2=\overrightarrow{AC}^2+\overrightarrow{AB}^2-2\overrightarrow{AB}\cdot\overrightarrow{AC}$ ឬ $2\overrightarrow{AB}\cdot\overrightarrow{AC}=b^2+c^2-a^2 \quad (2)$

យក (2) ជំនួសក្នុង (1) : $4m_a^2=c^2+b^2+b^2+c^2-a^2=2b^2+2c^2-a^2$

ដូចនេះ $m_a^2=\frac{2b^2+2c^2-a^2}{4}$

២. បង្ហាញថា $m_a^2+m_b^2+m_c^2=3R(2+2cosAcosBcosC)$ ដែល $R$ ជាកាំរង្វង់ចារឹកក្រៅត្រីកោណ $ABC$

តាមសំនួរខាងលើ គេមាន $m_a^2=\dfrac{2b^2+2c^2-a^2}{4}$, $m_b^2=\dfrac{2a^2+2c^2-b^2}{4}$, $m_c^2=\dfrac{2a^2+2b^2-c^2}{4}$

នោះ $m_a^2+m_b^2+m_c^2=\dfrac{3}{4}\left(a^2+b^2+c^2\right)\quad(*)$

តាមទ្រឹស្តីបទស៊ីនុស $\dfrac{a}{sinA}=\dfrac{b}{sinB}=\dfrac{c}{sinC}=2R$

$\Rightarrow\dfrac{a^2}{sin^2A}=\dfrac{b^2}{sin^2B}=\dfrac{c^2}{sin^2C}=4R^2=\dfrac{a^2+b^2+c^2}{sin^2A+sin^2B+sin^2C}$

$\Rightarrow a^2+b^2+c^2=4R^2\left(sin^2A+sin^2B+sin^2C\right)\quad(**)$

យក $(**)$ ជំនួសចូល $(*)$ យើងបាន

$$\begin{aligned}m_a^2+m_b^2+m_c^2&=\frac{3}{4}\times4R^2\left(sin^2A+sin^2B+sin^2C\right)\\&=3R^2\left(\frac{1-cos2A}{2}+\frac{1-cos2B}{2}+\frac{1-cos2C}{2}\right)\\&=3R^2\left[2-\frac{1}{2}\times2cos(A+B)cos(A-B)-cos^2(A+B)\right]\\&=3R^2[2-cos(A+B)(cos(A-B)-cos(A+B))]\\&=3R^2[2-cos(A+B)\times2cosAcos(-B)]\end{aligned}$$

តែ $A+B+C=\pi$ នោះ $cos(A+B)=-cosC$

នោះ $m_a^2+m_b^2+m_c^2=3R^2(2+2cosAcosBcosC)$ ពិត

ដូចនេះ $\boxed{m_a^2+m_b^2+m_c^2=3R^2(2+2cosAcosBcosC)}$

VI. រកសំណល់ពេលចែក $\left(n^2+n+41\right)^2$ នឹង 12

ដោយ $n(n-1)(n+1)(n+2)$ ចែកដាច់នឹង 12 ផលគុណចំនួនគត់តគ្នា

$$\begin{aligned}\left(n^2+n+41\right)^2&\equiv\left(n^2+n+5\right)^2&&(\bmod 12)\\&\equiv\left(n^4+n^2+25+2n^3+10n^2+10n\right)&&(\bmod 12)\\&\equiv\left(n^4+11n^2+2n^3+10n+1\right)&&(\bmod 12)\\&\equiv\left[n\left(n^3+2n^2+11n+10\right)+1\right]&&(\bmod 12)\\&\equiv n\left[n^2(n+2)-(n+2)+1\right]&&(\bmod 12)\\&\equiv\left[n(n+2)(n^2-1)+1\right]&&(\bmod 12)\\&\equiv[(n-1)n(n+1)(n+2)+1]&&(\bmod 12)\\&\equiv1&&(\bmod 12)\end{aligned}$$

ដូចនេះ: សំណល់នៃការចែក $(n^2+n+41)^2$ នឹង $12$ គឺ $1$

# ប្រលងជ្រើសរើសសិស្សខេត្តសៀមរាប
# ផ្នែកគណិតវិទ្យា រូបវិទ្យា និង អក្សរសិល្ប៍ខ្មែរ ថ្នាក់ទី៩ និងថ្នាក់ទី ១២
# សម័យប្រលង ២៧ កុម្ភៈ ២០២០
# វិញ្ញាសា : គណិតវិទ្យាទី ២ រយៈពេល ៣ ម៉ោង

I. ១. គណនា $|1-|1+x||$ បើ $x<-2$ ។
២. ដោះស្រាយសមីការ $2^x+3^x+6^x-4^x-9^x-1=0$ ។

II. ១. ក្នុងត្រីកោណ $ABC$ មួយមានមុំ $\angle A=2\angle B$ ។ $a,b,c$ ជារង្វាស់ជ្រុងឈមនៃមុំ $A,B,C$ រៀងគ្នា ។ បង្ហាញថា $a^2=b(b+c)$ ។
២. ចូរកំណត់គ្រប់ត្រីកោណដែលមានជ្រុងជាចំនួនគត់តគ្នា និងមុំមួយរបស់វាស្មើនឹងទ្វេដង នៃមុំផ្សេងទៀត ។

III. ចូរបំពេញលេខក្នុងប្រអប់ $\dfrac{1}{\square\square\square\square}+\dfrac{1}{1988}=\dfrac{1}{\square\square\square\square}$ ។

IV. ១.បើ $a_1,a_2,a_3,...,a_n$ ចែកមិនដាច់នឹង $3$ ចូរបង្ហាញថា $S=\sum\limits_{k=1}^{9}a_k^2$ ចែកដាច់នឹង $3$ ។
២. គណនាផលបូក
$$\sum=\frac{3}{1!+2!+3!}+\frac{4}{2!+3!+4!}+\cdots+\frac{2020}{2018!+2019!+2020!}$$ ។

V. គេអោយស្វ៊ីត $(a_n)_{n\geq 1}$ ដែល $a_1=2$ និង $a_{n+1}=\dfrac{a_n}{2}+\dfrac{1}{a_n}$ ចំពោះគ្រប់ $n\in\mathbb{N}$ ។ គណនា $a_n$ ជាអនុគមន៍នៃ $n$ ។

VI. អនុគមន៍ $f:\mathbb{R}\to\mathbb{R}$ ផ្ទៀងផ្ទាត់ $f(x)+f(y)=f(x+y)-xy-1$ គ្រប់ $x,y\in\mathbb{R}$ ។ បើ $f(1)=1$ ចូររកចំនួនគត់ $n$ ដើម្បីអោយ $f(n)=n$ ។

## អត្រាកំរែណ

I. ១. គណនា $|1-|1+x||$ បើ $x<-2$
គេមាន $x<-2$ នោះ $1+x<-1<0$

$\Rightarrow |1+x| = -(1+x) = -1-x$

គេបាន $|1-|1+x|| = |1-(-1-x)| = |2+x|$

តែ $x < -2 \Rightarrow x+2 < 0$

សរុបមក $|1-|1+x|| = -2-x$

ដូចនេះ $\boxed{|1-|1+x|| = -2-x \text{ បើ } x < -2}$

២. ដោះស្រាយសមីការ $2^x + 3^x + 6^x - 4^x - 9^x - 1 = 0$

សមីការអាចសរសេរ $2^x + 3^x + 2^x \times 3^x - (2^x)^2 - (3^x)^2 - 1 = 0$

តាង $a = 2^x, b = 3^x$ នោះ $a + b + ab - a^2 - b^2 - 1 = 0$

ឬ $a^2 + b^2 + 1 - a - b - ab = 0$

គុណអង្គទាំងសងខាងនឹង 2 គេបាន

$2a^2 + 2b^2 + 2 - 2a - 2b - 2ab = 0$

$a^2 - 2a + 1 + a^2 - 2ab + b^2 + b^2 - 2b + 1 = 0$

$(a-1)^2 + (a-b)^2 + (b-1)^2 = 0$

នោះ $\begin{cases} a-1=0 \\ a-b=0 \\ b-1=0 \end{cases}$ ឬ $\begin{cases} a=1 \\ a=b \\ b=1 \end{cases}$

នាំអោយ $\begin{cases} 2^x = 1 = 2^0 \\ 3^x = 1 = 3^0 \end{cases}$

ដូចនេះ $\boxed{x = 0}$

II. ១. បង្ហាញថា $a^2 = b(b+c)$




តាមទ្រឹស្តីបទស៊ីនុស : $\dfrac{a}{sin2x} = \dfrac{b}{sinx} = \dfrac{c}{sin(\pi - 3x)} = \dfrac{c}{sin3x}$

$\dfrac{a}{2sinxcosx} = b = \dfrac{c}{3sinx - 4sin^3x}$

$\dfrac{a}{2cosx} = b = \dfrac{c}{3 - 4sin^2x}$

$\Rightarrow \dfrac{a}{2cosx} = b = \dfrac{c}{3-4\left(1-cos^2x\right)}$

ទាញបាន $\dfrac{a}{2cosx} = b$ និង $b = \dfrac{c}{4cos^2x-1}$

នោះ $cosx = \dfrac{a}{2b}$ និង $b = \dfrac{c}{4\left(\dfrac{a}{2b}\right)^2-1}$

$\Rightarrow b = \dfrac{cb^2}{a^2-b^2}$

$\Rightarrow b\left(a^2-b^2\right) = cb^2$

$\Rightarrow a^2 = b(b+c)$ ពិត

ដូចនេះ $\boxed{a^2 = b(b+c)}$

២. កំណត់គ្រប់ត្រីកោណដែលមានជ្រុងជាចំនួនគត់តគ្នា និងមុំមួយរបស់វាស្មើនឹងទ្វេដង នៃមុំផ្សេងទៀត




តាង $x, x+1, x+2$ ជារង្វាស់ជ្រុងឈមនៃមុំ $A,B,C$ រៀងគ្នាដែល $x \in \mathbb{N}$

តាមទ្រឹស្តីបទកូស៊ីនុស $cosA = \dfrac{(x+1)^2+(x+2)^2-x^2}{2(x+1)(x+2)} = \dfrac{x+5}{2(x+2)}$

$$cosB = \dfrac{x^2+(x+2)^2-(x+1)^2}{2x(x+2)} = \dfrac{x+1}{2x}$$

$$cosC = \dfrac{x^2+(x+1)^2-(x+2)^2}{2x(x+1)} = \dfrac{x-3}{2x}$$

- ករណីមុំ $C = 2A$ នោះ $cosC = cos2A = 2cos^2A - 1$

$\Rightarrow \dfrac{x-3}{2x} = 2\left[\dfrac{x+5}{2(x+2)}\right]^2 - 1$

$\Leftrightarrow (x-3)(x+2)^2 = x(x+5)^2 - 2x(x+2)^2$

$\Leftrightarrow 2x^3 - x^2 - 25x - 12 = 0$

$\Leftrightarrow (x-4)\left(2x^2+7x+3\right) = 0$

បើ $x - 4 = 0$ នោះ $x = 4$

បើ $2x^2+7x+3=0$ គ្មាន $x\in\mathbb{N}$
នាំអោយគេទទួលបានត្រីកោណមានជ្រុង $4,5,6$
- ករណីមុំ $B=2A$ នោះ $cosB=cos2A=2cos^2A-1$

$$\Rightarrow \frac{x+1}{2x}=\frac{2(x+5)^2}{4(x+2)^2}-1$$

$$\Leftrightarrow (x+1)(x+2)^2=x(x+5)^2-2x(x+2)^2$$

$$\Leftrightarrow 2x^3+2x^2-9x+4=0$$

$$\Leftrightarrow (x-1)\left(2x^2+5x-4\right)=0$$

បើ $x-1=0$ នោះ $x=1$
បើ $2x^2+5x-4=0$ គ្មាន $x\in\mathbb{N}$
ចំពោះ $x=1$ នោះ $x+(x+1)>(x+2)$ មិនផ្ទៀងផ្ទាត់
- ករណី $C=2B$ នោះ $cosC=cos2B=2cos^2B-1$

$$\Rightarrow \frac{x-3}{2x}=\frac{2(x+1)^2}{4x^2}-1$$

$$\Leftrightarrow x(x-3)=(x+1)^2-2x^2$$

$$\Leftrightarrow 2x^2-5x-1=0$$ គ្មាន $x\in\mathbb{N}$

ដូចនេះ ត្រីកោណដែលមានមុំមួយស្មើទ្វេដងនៃមុំមួយទៀត គឺមានរង្វាស់ជ្រុង $4,5,6$

III. ចូរបំពេញលេខក្នុងប្រអប់ $\frac{1}{\square\square\square\square}+\frac{1}{1988}=\frac{1}{\square\square\square\square}$

គេមាន $1988=1\times 2^2\times 7\times 71$

ដោយ $\frac{1}{\square\square\square\square}+\frac{1}{1988}=\frac{1}{\square\square\square\square}$ នោះ $\frac{1}{\square\square\square\square}-\frac{1}{\square\square\square\square}=\frac{1}{1988}$

+ ដោយ $\frac{1}{2}-\frac{1}{7}=\frac{5}{14}$

គុណនឹង $\frac{1}{5\times 2\times 71}\Rightarrow \frac{1}{1420}-\frac{1}{4970}=\frac{1}{1988}$

$$\Rightarrow \frac{1}{4970}+\frac{1}{1988}=\frac{1}{1420}$$

+ ដោយ $1-\frac{1}{2^2}=\frac{3}{4}$

គុណនឹង $\frac{1}{3\times 7\times 71}$ នោះ $\frac{1}{1491}-\frac{1}{5964}=\frac{1}{1988}$

$$\Rightarrow \frac{1}{5964}+\frac{1}{1988}=\frac{1}{1491}$$

+ ដោយ $\frac{1}{14}-\frac{1}{71}=\frac{57}{994}$

គុណនឹង $\frac{1}{57\times 2}\Rightarrow\frac{1}{1596}-\frac{1}{8094}=\frac{1}{1988}$

$\Rightarrow\frac{1}{8094}+\frac{1}{1988}=\frac{1}{1596}$

+ ដោយ $\frac{1}{28}-\frac{1}{71}=\frac{43}{1988}$

គុណនឹង $\frac{1}{43}\Rightarrow\frac{1}{1204}-\frac{1}{3053}=\frac{1}{1988}$

$\Rightarrow\frac{1}{3053}+\frac{1}{1988}=\frac{1}{1204}$

+ ដោយ $\frac{1}{4}-\frac{1}{7}=\frac{3}{28}$

គុណនឹង $\frac{1}{3\times 71}\Rightarrow\frac{1}{852}-\frac{1}{1491}=\frac{1}{1988}$

$\Rightarrow\frac{1}{1491}+\frac{1}{1988}=\frac{1}{852}$ មិនយកជាចម្លើយ

IV. ១. បង្ហាញថា $S=\sum_{k=1}^{9}a_k^2$ ចែកដាច់នឹង 3

បើ $a_k, k=1,2,3,\ldots,9$ ចែកមិនដាច់នឹង 3 បានន័យថា $a_k=3t_k\pm 1$ ឬ $a_k=3t_k\pm 2,\ t_k\in\mathbb{N}$

- ករណី $a_k=3t_k\pm 1$ នោះ $a_k^2=(3t_k\pm 1)^2=9t_k^2\pm 6t_k+1$

$a_k^2=3\left(3t_k^2\pm 2t_k\right)+1$

នោះ $a_k^2=3q_k+1$ ដែល $q_k=3t_k^2\pm 2t_k,\ q_k\in\mathbb{N}$

$\Rightarrow\sum_{k=1}^{9}a_k^2=\sum_{k=1}^{9}(3q_k+1)=\sum_{k=1}^{9}3q_k+\sum_{k=1}^{9}1$

$\Rightarrow\sum_{k=1}^{9}a_k^2=3\sum_{k=1}^{9}q_k+9=3\left(\sum_{k=1}^{9}q_k+3\right)$ ចែកដាច់នឹង 3

បើ $a_k, k=1,2,3,\ldots,9$ ចែកមិនដាច់នឹង 3 បានន័យថា $a_k=3t_k\pm 1$ ឬ $a_k=3t_k\pm 2,\ t_k\in\mathbb{N}$

- ករណី $a_k=3t_k\pm 2$ នោះ $a_k^2=(3t_k\pm 2)^2=9t_k^2\pm 12t_k+4$

$a_k^2=3\left(3t_k^2\pm 4t_k\right)+4$

នោះ $a_k^2=3s_k+1$ ដែល $s_k=3t_k^2\pm 4t_k,\ s_k\in\mathbb{N}$

$\Rightarrow\sum_{k=1}^{9}a_k^2=\sum_{k=1}^{9}(3s_k+4)=\sum_{k=1}^{9}3s_k+\sum_{k=1}^{9}4$

$$\Rightarrow \sum_{k=1}^{9} a_k^2 = 3\sum_{k=1}^{9} s_k + 36 = 3\left(\sum_{k=1}^{9} s_k + 12\right)$$ ចែកដាច់នឹង 3

ដូចនេះ បើ $a_1, a_2, a_3, ..., a_n$ ចែកមិនដាច់នឹង 3 នោះ $S = \sum_{k=1}^{9} a_k^2$

ចែកដាច់នឹង 3

២. គណនាផលបូក

$$\sum = \frac{3}{1!+2!+3!} + \frac{4}{2!+3!+4!} + \cdots + \frac{2020}{2018!+2019!+2020!}$$

យើងមាន $\frac{n}{(n-2)!+(n-1)!+n!} = \frac{1}{(n-2)!} \times \frac{n}{1+(n-1)+(n-1)n}$

$$= \frac{1}{(n-2)!} \times \frac{n}{n^2} = \frac{1}{(n-2)!} \times \frac{n-1}{n(n-1)}$$

$$= \frac{n-1}{n!} = \frac{n}{(n-1)!n} - \frac{1}{n!} = \frac{1}{(n-1)!} - \frac{1}{n!}$$

យើងបាន $\sum = \frac{1}{2!} - \frac{1}{3!} + \frac{1}{3!} - \frac{1}{4!} + \cdots + \frac{1}{2019!} - \frac{1}{2020!}$

ដូចនេះ $\boxed{\sum = \frac{1}{2!} - \frac{1}{2020!}}$

V. គណនា $a_n$ ជាអនុគមន៍នៃ $n$

$a_1 = 2$ និង $a_{n+1} = \frac{a_n}{2} + \frac{1}{a_n}$ ចំពោះគ្រប់ $n \in \mathbb{N}$

សមីការសំគាល់ $x = \frac{x}{2} + \frac{1}{x}$

នោះ $2x^2 = x^2 + 2$

$\Rightarrow x = \pm\sqrt{2}$

ដោយ $\frac{a_{n+1}+\sqrt{2}}{a_{n+1}-\sqrt{2}} = \frac{\frac{a_n}{2} + \frac{1}{a_n} + \sqrt{2}}{\frac{a_n}{2} + \frac{1}{a_n} - \sqrt{2}} = \frac{a_n^2 + 2\sqrt{2}a_n + \sqrt{2}^2}{a_n^2 - 2\sqrt{2}a_n + \sqrt{2}^2}$

$$\Rightarrow \frac{a_{n+1}+\sqrt{2}}{a_{n+1}-\sqrt{2}} = \left(\frac{a_n+\sqrt{2}}{a_n-\sqrt{2}}\right)^2$$

$$\Rightarrow \frac{a_2+\sqrt{2}}{a_2-\sqrt{2}} = \left(\frac{a_1+\sqrt{2}}{a_1-\sqrt{2}}\right)^2$$

$$\Rightarrow \frac{a_3+\sqrt{2}}{a_3-\sqrt{2}} = \left(\frac{a_2+\sqrt{2}}{a_2-\sqrt{2}}\right)^2 = \left(\frac{a_1+\sqrt{2}}{a_1-\sqrt{2}}\right)^{2^2}$$

ឧបមាថា $\left(\frac{a_k+\sqrt{2}}{a_k-\sqrt{2}}\right) = \left(\frac{a_1+\sqrt{2}}{a_1-\sqrt{2}}\right)^{2^{k-1}}$

យើងនិងស្រាយថា $\frac{a_{k+1}+\sqrt{2}}{a_{k+1}-\sqrt{2}} = \left(\frac{a_1+\sqrt{2}}{a_1-\sqrt{2}}\right)^{2^k}$

ដោយ $\frac{a_{k+1}+\sqrt{2}}{a_{k+1}-\sqrt{2}} = \left(\frac{a_k+\sqrt{2}}{a_k-\sqrt{2}}\right)^2 = \left[\left(\frac{a_1+\sqrt{2}}{a_1-\sqrt{2}}\right)^{2^{k-1}}\right]^2 = \left(\frac{a_1+\sqrt{2}}{a_1-\sqrt{2}}\right)^{2^k}$

ពិត

$$\Rightarrow \frac{a_n+\sqrt{2}}{a_n-\sqrt{2}} = \left(\frac{a_1+\sqrt{2}}{a_1-\sqrt{2}}\right)^{2^{n-1}} = \left(\frac{2+\sqrt{2}}{2-\sqrt{2}}\right)^{2^{n-1}} = \left(\frac{\sqrt{2}+1}{\sqrt{2}-1}\right)^{2^{n-1}} = (\sqrt{2}+1)^{2^n}$$

$$\Rightarrow a_n+\sqrt{2} = (\sqrt{2}+1)^{2^n}(a_n-\sqrt{2}) = a_n(\sqrt{2}+1)^{2^n} - \sqrt{2}(\sqrt{2}+1)^{2^n}$$

$$\Leftrightarrow a_n\left[(\sqrt{2}+1)^{2^n}-1\right] = \sqrt{2}\left[1+(\sqrt{2}+1)^{2^n}\right]$$

ដូចនេះ $\boxed{a_n = \frac{\sqrt{2}\left[1+(\sqrt{2}+1)^{2^n}\right]}{(\sqrt{2}+1)^{2^n}-1}}$

VI. រកចំនួនគត់ $n$ ដើម្បីអោយ $f(n)=n$

គេមាន $f(x)+f(y)=f(x+y)-xy-1$ គ្រប់ $x,y\in\mathbf{R}$

បើ $y=1$ នោះ $f(x)+f(1)=f(x+1)-x-1$

$f(x)+1=f(x+1)-x+1$ នោះ $f(x+1)-f(x)=x+2$

បើគ្រប់ $n\in\mathbf{Z}$ គេបាន $f(n)-f(n-1)=n+1 \Rightarrow f(k)-f(k-1)=k+1$

បើ $k=2$ នោះ $f(2)-f(1)=3$

បើ $k=3$ នោះ $f(3)-f(2)=4$

..... ..... ......................

បើ $k=n$ នោះ $f(n)-f(n-1)=n+1$

---

$f(n)-f(1)=3+4+\cdots+(n+1)$

$$f(n)=f(1)+\frac{(n-1)(3+n+1)}{2}=1+\frac{(n-1)(n+4)}{2}$$

$f(n)=\dfrac{n^2+3n-2}{2}$

យើងបាន $f(n)=n$ គឺ $n^2+n-2=0$

ដូចនេះ: $\boxed{n=1 \text{ ឬ } n=-2}$

## ប្រឡងជ្រើសរើសសិស្សពូកែវិទ្យាល័យបាក់ទូក
## ផ្នែកគណិតវិទ្យា រូបវិទ្យា និង អក្សរសិល្ប៍ខ្មែរ ថ្នាក់ទី៩ និងថ្នាក់ទី ១២
## សម័យប្រលង ១៦ មករា ២០២០
## វិញ្ញាសា : គណិតវិទ្យាទី ២ រយ:ពេល ៣ ម៉ោង

I. គណនាតម្លៃអប្បបរមានៃកន្សោម $M=x^2+x^2+y^2-3x-3y+2023$ ។

II. ចូររកខួប $T$ នៃអនុគមន៍ $f(x)=tan\dfrac{x}{5}+sin\dfrac{2x}{3}$ ។

III. គេឱ្យស្វីត $(u_n)$ កំណត់ចំពោះ $\forall n\in\mathbb{N}$ ដោយ $u_1=1, u_{n+1}=u_n+2^n$ ។ គណនា $u_n$ ជាអនុគមន៍នៃ $n$ រួចទាញរក $\lim\limits_{n\to\infty}u_n$ ។

IV. គេឱ្យត្រីធា $f(x)=x^2-x-6$ កំណត់លើ $\mathbb{R}$ ។ ស្រាយបញ្ជាក់ថា គ្រប់ $x\in\mathbb{R}$ គេបាន $f(sinx), f(cosx)$ ជាចំនួនអវិជ្ជមានឬសូន្យ ។

V. គេឱ្យ $a_1=111111111, a_2=222222221, a_3=333333332$
$,a_4=444444443$ (1) ។
បង្ហាញថា $a_3^2>a_2^2+a_1^2$ និង $a_4^2>a_3^2+a_2^2$ រួចប្រៀបធៀប $A=\sqrt{a_3^2-a_2^2-a_1^2}$
និង $B=\sqrt{a_4^2-a_3^2-a_2^2}$ ។

VI. គេឱ្យ $f(z)=z^4+az^3+bz^2+cz+d$ ដែល $a,b,c,d\in\mathbb{R}$ និង $z\in\mathbb{C}$ ។ កំណត់ $a,b,c,d$ បើគេដឹងថា $f(i)=0$ និង $f(1+i)=1+2i$, $\left(i^2=-1\right)$ ។

VII. គេឱ្យចតុកោណស្មើ $ABCD$ មួយ មានរង្វង់កាំ $R$ ចារឹកក្រៅត្រីកោណ $ABD$ និង រង្វង់កាំ $R'$ ចារឹកក្រៅត្រីកោណ $ABC$ ។ គណនាផ្ទៃក្រឡាចតុកោណស្មើ $ABCD$ ជាអនុគមន៍នៃ $R$ និង $R'$ ។

## អត្រាកំណែ

I. គណនាតម្លៃអប្បបរមានៃកន្សោម $M=x^2+x^2+y^2-3x-3y+2023$

$M=\left(x^2-2x+1\right)+\left(y^2-2y+1\right)+(xy-x)-(y-1)+2020$

$M=(x-1)^2+(y-1)^2+x(y-1)-(y-1)+2020$
$M=(x-1)^2+(y-1)^2+(x-1)(y-1)+2020$
$M=\left[(x-1)^2+(y-1)^2+2(x-1)\left(\frac{y-1}{2}\right)+\left(\frac{y-1}{2}\right)^2\right]+\frac{3}{4}(y-1)^2+$
$2020$
$M=\left((x-1)+\left(\frac{y-1}{2}\right)\right)^2+\frac{3}{4}(y-1)^2+2020$
យើងបាន $M\geq 2020$ បើ $x=y=1$
ដូចនេះ តម្លៃអប្បបរមាគឺ $M=2020$ ចំពោះ $x=y=1$

II. រកខួប $T$ នៃអនុគមន៍ $f(x)=tan\frac{x}{5}+sin\frac{2x}{3}$
តាង $g(x)=tan\frac{x}{5}=tan\left(\frac{x}{5}+k\pi\right)=tan\frac{1}{5}(x+5k\pi)$
$\Rightarrow g(x)=g(x+5k\pi),\ k\in\mathbb{Z}$
នោះខួប $T_1=5\pi$
និង $h(x)=sin\frac{2x}{3}=sin\left(\frac{2x}{3}+2k\pi\right)=sin\frac{2}{3}(x+3k\pi)$
$\Rightarrow h(x)=h(x+2k\pi),\ k\in\mathbb{Z}$
នោះខួប $T_2=3\pi$
ខួប $T=PPCM(T_1,T_2)=PPCM(5\pi,3\pi)=15\pi$

III. គណនា $u_n$ ជាអនុគមន៍នៃ $n$ រួចទាញរក $\lim\limits_{n\to\infty}u_n$
យើងមាន $u_1=1, u_{n+1}=u_n+2^n$
$u_{n+1}=u_n+2^n \quad \Leftrightarrow u_n-u_{n-1}=2^{n-1}$
$u_{n-1}=u_{n-2}+2^{n-2} \quad \Leftrightarrow u_{n-1}-u_{n-2}=2^{n-2}$
$u_{n-2}=u_{n-3}+2^{n-3} \quad \Leftrightarrow u_{n-2}-u_{n-3}=2^{n-3}$
$u_{n-3}=u_{n-4}+2^{n-4} \quad \Leftrightarrow u_{n-3}-u_{n-4}=2^{n-4}$
$u_{n-4}=u_{n-5}+2^{n-5} \quad \Leftrightarrow u_{n-4}-u_{n-5}=2^{n-5}$
.................... $\Leftrightarrow$ ........................
$u_4=u_3+2^3 \quad \Leftrightarrow u_4-u_3=2^3$
$u_3=u_2+2^2 \quad \Leftrightarrow u_3-u_2=2^2$
$u_2=u_1+2^1 \quad \Leftrightarrow u_2-u_1=2^1$
ជាលទ្ធផល ផលសងខាងលើកំណត់បានក្នុងទំនាក់ទំនងខាងក្រោម
$u_n=(u_n-u_{n-1})+(u_{n-1}-u_{n-2})+(u_{n-2}-u_{n-3})+(u_{n-3}-u_{n-4})+\ldots+$

$(u_5-u_4)$
$+(u_4-u_3)+(u_3-u_2)+(u_2-u_1)+u_1$
យើងបាន $u_n=2^{n-1}+2^{n-2}+2^{n-3}+2^{n-4}+2^{n-5}+...+2^3+2^2+2^1+u_1$
$u_n=2^{n-1}+2^{n-2}+2^{n-3}+2^{n-4}+2^{n-5}+...+2^3+2^2+2^1+1$ ព្រោះ $u_1=1$
$\Rightarrow u_n$ ជាផលបូក $n$ តួនៃស្វ៊ីតធរណីមាត្រដែលមានតួទី១ ស្មើនឹង $1$ និង ផលធៀបរួម
$q=\dfrac{2^1}{1}=2$
យើងបាន $u_n=\dfrac{2(2^n-1)}{2-1}=2^n-1$
ដូចនេះ $u_n=2^n-1$
របៀបទី ២៖ យើងមាន $u_1=1, u_{n+1}=u_n+2^n$
$n=1\Rightarrow u_1=1$
$n=2\Rightarrow u_2=u_1+2^1=1+2=3=2^2-1$
$n=3\Rightarrow u_3=u_2+2^2=3+4=7=2^3-1$
$n=4\Rightarrow u_4=u_3+2^3=7+8=2^4-1$
$n=5\Rightarrow u_5=u_4+2^4=15+16=2^5-1$
..............................................
..............................................
..............................................
តាមលំនាំគំរូនេះ យើងទាញបាន $u_n=2^n-1$
ទាញរក $\lim\limits_{n\to\infty} u_n$
$\Rightarrow \lim\limits_{n\to\infty} u_n=\lim\limits_{n\to\infty}(2^n-1)=\infty$

IV. ស្រាយបញ្ជាក់ថា គ្រប់ $x\in\mathbb{R}$ គេបាន $f(sinx), f(cosx)$ ជាចំនួនអវិជ្ជមានឬសូន្យ
យើងបាន $f(x)=(x+2)(x-3)$
បើ $f(x)=0\Rightarrow x=-2, x=3$

តារាងសញ្ញា

| $x$ | $-\infty$ | | $-2$ | | $3$ | | $+\infty$ |
|---|---|---|---|---|---|---|---|
| $f(x)$ | | $+$ | $0$ | $-$ | $0$ | $+$ | |

ចំពោះ $\forall x\in\alpha,\ -1\le sinx\le 1$ និង $-1\le cosx\le 1$
ដោយចន្លោះ $[-1,1]\subset[-2,3]$
ដូចនេះ $f(sinx)\le 0, f(cosx)\le 0$

V. បង្ហាញថា $a_3^2 > a_2^2 + a_1^2$ និង $a_4^2 > a_3^2 + a_2^2$ រួចប្រៀបធៀប $A = \sqrt{a_3^2 - a_2^2 - a_1^2}$ និង $B = \sqrt{a_4^2 - a_3^2 - a_2^2}$

យើងមាន

$a_1 = 111111111, a_2 = 222222221 = 2a_1 - 1, a_3 = 333333332 = 3a_1 - 1,$

$a_4 = 444444443 = 4a_1 - 1$

យើងបាន

$$a_3^2 - a_2^2 - a_1^2 = (3a_1 - 1)^2 - (2a_1 - 1)^2 - a_1^2$$
$$= 9a_1^2 - 6a_1 + 1 - 4a_1^2 + 4a_1 - 1 - a_1^2$$
$$= 4a_1^2 - 2a_1 = 2a_1(2a_1 - 1) > 0 \text{ ព្រោះ } 2a_1 > 1$$

ដូចនេះ $a_3^2 > a_2^2 + a_1^2$

$$a_4^2 - a_3^2 - a_2^2 = (4a_1 - 1)^2 - (3a_1 - 1)^2 - (2a_1 - 1)^2$$
$$= 16a_1^2 - 8a_1 + 1 - 9a_1^2 + 6a_1 - 1 - 4a_1^2 + 4a_1 - 1$$
$$= 3a_1^2 + 2a_1 - 1 = (a_1 + 1)(3a_1 - 1) > 0 \text{ ព្រោះ } 3a_1 > 1$$

ដូចនេះ $a_4^2 > a_3^2 + a_2^2$

រួចប្រៀបធៀប $A = \sqrt{a_3^2 - a_2^2 - a_1^2}$ និង $B = \sqrt{a_4^2 - a_3^2 - a_2^2}$

$$A^2 - B^2 = a_3^2 - a_2^2 - a_1^2 - a_4^2 + a_3^2 + a_2^2$$
$$= 2a_3^2 - a_1^2 - a_4^2$$
$$= 18a_1^2 - 12a_1 + 2 - a_1^2 - 16a_1^2 + 8a_1 - 1$$
$$= a_1^2 - 4a_1 + 1 = a_1(a_1 - 4) + 1 > 0 \text{ ព្រោះ } a_1 > 4$$

ដូចនេះ $A > B$

VI. កំណត់ $a, b, c, d$ បើគេដឹងថា $f(i) = 0$ និង $f(1+i) = 1 + 2i, \left(i^2 = -1\right)$

រក $f(i) = i^4 + bi^3 + bi^2 + ci + d$

$$= 1 - ai - b + ci + d$$
$$= 1 - b + d + (c - a)i$$

បើ $f(i) = 0$ នោះ $\begin{cases} 1 - b + d = 0 \\ c - a = 0 \end{cases} \Rightarrow \begin{cases} d = b - 1 \\ c = a \end{cases}$

រក $f(1+i)=(1+i)^4+a(1+i)^3+b(1+i)^2+a(1+i)+b-1$

$=\left(1+2i+i^2\right)^2+a\left(1+2i+i^2\right)^2(1+i)+b\left(1+2i+i^2\right)$

$+a(1+i)+b-1$

$=-4+2ai(1+i)+a(1+i)+2bi+b-1$

$=-4+2ai-2a+a+ai+2bi+b-1$

$=-5+3ai-a+2bi+b$

$=-5-a+b+(3a+2b)i$

បើ $f(1+i)=1+2i$ នោះ $\begin{cases}-5-a+b=1 & (1)\\ 3a+2b=2 & (2)\end{cases}$

$(1)\Rightarrow b=a+6$

$(2)\Rightarrow 3a+2a+12=2$

$\Rightarrow 5a=2-12=-10\Rightarrow a=-2$

$b=a+6=-2+6=4$

$c=a=-2, d=b-1=4-1=3$

ដូចនេះ $a=-2, b=4, c=-2, d=3$

VII. គណនាផ្ទៃក្រឡាចតុកោណស្មើ $ABCD$ ជាអនុគមន៍នៃ $R$ និង $R'$

តាង $AC=x,\ BD=y$

$O$ ជាផ្ចិតរង្វង់ចារឹកក្រៅត្រីកោណ $ABD$

$O'$ ជាផ្ចិតរង្វង់ចារឹកក្រៅត្រីកោណ $ABC$

$I$ ជាចំណុចប្រសព្វរវាងអង្កត់ទ្រូងចតុកោណស្មើ

$BI=BO+O'I\Rightarrow O'I=BI-BO'$

$BI=\frac{1}{2}BD=\frac{1}{2}y$ និង $AO'=BO'=R'$

$\Rightarrow O'I=\frac{1}{2}y-R'$

ក្នុងត្រីកោណ $AIO'$ កែងត្រង់កំពូល $I$

$AO'^2=AI^2+IO'^2$ (ទ្រឹស្តីបទពីតាគ័រ)

$R'^2=\left(\frac{1}{2}x\right)^2+\left(\frac{1}{2}y-R'\right)^2$




$$R'^2 = \frac{1}{4}x^2 + \frac{1}{4}y^2 - yR' + R'^2$$
$$0 = \frac{1}{4}x^2 + \frac{1}{4}y^2 - yR'$$
$$x^2 = 4yR' - y^2$$
$$x = 2\sqrt{yR' - \frac{1}{4}y^2}$$
$$S_{\triangle ABD} = S_{\triangle ABC} \Leftrightarrow \frac{AB \cdot AD \cdot BD}{4R} = \frac{AB \cdot AC \cdot BC}{4R'}$$
$$\Leftrightarrow \frac{AB^2 \cdot y}{4R} = \frac{AB^2 \cdot x^2}{4R'}$$
$$\Leftrightarrow \frac{y}{R} = \frac{x}{R'} \Leftrightarrow x = \frac{y \cdot R'}{R}$$
$$\Leftrightarrow \frac{y \cdot R'}{R} = 2\sqrt{yR' - \frac{1}{4}y^2} \Leftrightarrow \frac{y^2 \cdot R'^2}{R^2} = 4\left(yR' - \frac{1}{4}y^2\right)$$
$$\Leftrightarrow y^2R'^2 + R^2y^2 = 4R^2 \cdot y$$
$$\Leftrightarrow y\left(R^2 + R'^2\right) = 4R'^2R'$$
$$\Leftrightarrow y = \frac{4R^2R'}{R'^2 + R^2}$$
$$\Leftrightarrow x = \frac{R'}{R}y = \frac{R'}{R} \cdot \frac{4R^2R'}{R'^2 + R^2} = \frac{4RR'^2}{R'^2 + R^2}$$

ផ្ទៃក្រឡាចតុកោណស្មើ $ABCD$ : $S_{ABCD}=\frac{1}{2}xy=\frac{1}{2}\cdot\frac{4RR^2}{R'^2+R^2}\cdot\frac{4R^2R'}{R'^2+R^2}=\frac{8R^3R'^3}{(R'^2+R^2)^2}$

ដូចនេះ $S_{ABCD}=\frac{8R^3R'^3}{(R'^2+R^2)^2}$ ឯកតាផ្ទៃ

## ប្រលងជ្រើសរើសសិស្សពូកែវិទ្យាល័យបាក់ទូក
## ផ្នែកគណិតវិទ្យា រូបវិទ្យា និង អក្សរសិល្ប៍ខ្មែរ ថ្នាក់ទី៩ និងថ្នាក់ទី ១២
## សម័យប្រលង ១៦ មករា ២០២០
## វិញ្ញាសា : គណិតវិទ្យាទី ១ រយៈពេល ៣ ម៉ោង

I. ដោះស្រាយសមីការ $\sqrt[3]{1+x}-\sqrt[3]{1-x}=\sqrt[6]{1-x^2}$ ។

II. គេឱ្យពហុធា $p(x)=x^3+ax^2+bx+c$ ។ បើ $x_1,x_2,x_3$ ជាឫសនៃសមីការ $p(x)=0$ ហើយ $p'(x)$ ជាដេរីវេនៃ $p(x)$ ចូរស្រាយបំភ្លឺថា $\frac{x_1}{p'(x_1)}+\frac{x_2}{p'(x_2)}+\frac{x_3}{p'(x_3)}=0$ ។

III. គណនា $S=\sum_{k=1}^{2020}\frac{k+2}{k!+(k+1)!+(k+2)!}$ ។

IV. កំណត់តម្លៃ $m$ ដើម្បីឱ្យអនុគមន៍ $f(x)=\frac{x^2+(m+1)x+2}{x+1}$ កើនលើចន្លោះ $[0,+\infty)$ ។

V. គេឱ្យ $a,b,c,d\in\mathbb{N}$ ដោយដឹងថា $a\ge b\ge c\ge d$ ។
ចូរបង្ហាញថាសមីការ $x^4-ax^3-bx^2-cx-d=0$ គ្មានឫសជាចំនួនគត់ ។

VI. គេឱ្យ $a,b,c,x,y,z$ ជាប្រាំមួយចំនួនពិតវិជ្ជមានផ្ទៀងផ្ទាត់ $x+y+z=a+b+c$ និង $xyz=abc$ ។ សន្មត់ថា $a\le x,y,z\le c$ និង $a<b<c$ ។
ចូរស្រាយថា $x=a,y=b$ និង $z=c$ ។

VII. គេឱ្យចតុកោណ $ABCD$ ចារឹកក្នុងរង្វង់មួយមាន $AB=a,BC=b,CD=c,DA=d$ និង $p=\frac{a+b+c+d}{2}$ ។ ស្រាយបញ្ជាក់ថា ផ្ទៃក្រឡាចតុកោណ $ABCD$ នេះគឺ $S=\sqrt{(p-a)(p-b)(p-c)(p-d)}$ ។

# អត្រាកំណែ

I. ដោះស្រាយសមីការ $\sqrt[3]{1+x}-\sqrt[3]{1-x}=\sqrt[6]{1-x^2}$

សមីការមានន័យលុះត្រាតែ $1-x^2\geq 0$

$\Rightarrow -1\leq x\leq 1$ ឬ $x\in[-1,1]$

សមីការអាចសរសេរទៅជា

$$\sqrt[3]{1+x}-\sqrt[3]{1-x}=\sqrt[6]{1-x}\sqrt[6]{1+x}$$

ចែកអង្គទាំងពីរនឹង $\sqrt[3]{1+x}$ យើងបាន

$$1-\frac{\sqrt[3]{1-x}}{\sqrt[3]{1+x}}=\frac{\sqrt[6]{1-x}\cdot\sqrt[6]{1+x}}{\sqrt[3]{1+x}}$$

$$1-\sqrt[6]{\left(\frac{1-x}{1+x}\right)^2}=\sqrt[6]{\frac{1-x}{1+x}}$$

តាង $t=\sqrt[6]{\frac{1-x}{1+x}}\Rightarrow 1-t^2=t$ ឬ $t^2+t-1=0$

$\Delta=1+4=5$

$$\Rightarrow t=\frac{-1\pm\sqrt{5}}{2}$$

$\Rightarrow t_1=\frac{-1-\sqrt{5}}{2}<0$ មិនយក

$\Rightarrow 0<t_2=\frac{-1+\sqrt{5}}{2}<1$ យក

$$\Rightarrow\sqrt[6]{\frac{1-x}{1+x}}=\frac{\sqrt{5}-1}{2}\Rightarrow\frac{1-x}{1+x}=\left(\frac{\sqrt{5}-1}{2}\right)^6$$

$$\Rightarrow\frac{1-x}{1+x}=\frac{(\sqrt{5}-1)^6}{2^6}$$

ដូចនេះ $x=\dfrac{2^6-(\sqrt{5}-1)^6}{2^6+(\sqrt{5}-1)^6}$

II. ស្រាយបំភ្លឺថា $\frac{x_1}{p'(x_1)}+\frac{x_2}{p'(x_2)}+\frac{x_3}{p'(x_3)}=0$

បើ $x_1,x_2,x_3$ ជាឫសនៃសមីការ $p(x)=0$

នោះ $p(x)=(x-x_1)(x-x_2)(x-x_3)$

$\Rightarrow p'(x)=(x-x_2)(x-x_3)+(x-x_1)(x-x_1)+(x-x_1)(x-x_2)$

យើងបាន $p'(x_1)=(x_1-x_2)(x_1-x_3)$

$p'(x_2)=(x_2-x_1)(x_2-x_3)$

$p'(x_3)=(x_3-x_1)(x_3-x_1)$

នោះ $\dfrac{x_1}{p'(x_1)}+\dfrac{x_2}{p'(x_2)}+\dfrac{x_3}{p'(x_3)}=\dfrac{x_1}{(x_1-x_2)(x_1-x_3)}+\dfrac{x_2}{(x_2-x_1)(x_2-x_3)}$

$+\dfrac{x_3}{(x_3-x_2)(x_3-x_1)}$

$$=\frac{x_1}{(x_1-x_2)(x_1-x_3)}-\frac{x_2}{(x_1-x_2)(x_2-x_3)}+\frac{x_3}{(x_2-x_3)(x_1-x_3)}$$

$$=\frac{x_1(x_2-x_3)-x_2(x_1-x_3)+x_3(x_1-x_2)}{(x_1-x_2)(x_1-x_3)(x_2-x_3)}$$

$$=\frac{x_1x_2-x_1x_3-x_1x_2+x_2x_3+x_1x_3-x_2x_3}{(x_1-x_2)(x_1-x_3)(x_2-x_3)}$$

$$=\frac{0}{(x_1-x_2)(x_1-x_3)(x_2-x_3)}=0$$ ពិត

III. គណនា $S=\displaystyle\sum_{k=1}^{2020}\frac{k+2}{k!+(k+1)!+(k+2)!}$

តាង $a_k=\dfrac{k+2}{k!+(k+1)!+(k+2)!}$

$$=\frac{k+2}{k![1+(k+1)+(k+1)(k+2)]}$$

$$=\frac{k+2}{k!\left(1+k+1+k^2+3k+2\right)}$$

$$=\frac{k+2}{k!(k+2)^2}=\frac{1}{k!(k+2)}$$

$$=\frac{k+1}{(k+2)!}=\frac{(k+2)-1}{(k+2)!}$$

$$=\frac{1}{(k+1)!}-\frac{1}{(k+2)!}$$

$\Rightarrow S=\displaystyle\sum_{k=1}^{2020}\left[\frac{1}{(k+1)!}-\frac{1}{(k+2)!}\right]$

$\Rightarrow S=\dfrac{1}{2!}-\dfrac{1}{3!}+\dfrac{1}{3!}-\dfrac{1}{4!}+\cdots+\dfrac{1}{2021!}-\dfrac{1}{2022!}$

ដូចនេះ $S=\dfrac{1}{2!}-\dfrac{1}{2022!}$

IV. កំណត់តម្លៃ $m$ ដើម្បីឱ្យអនុគមន៍ $f(x)=\dfrac{x^2+(m+1)x+2}{x+1}$ កើនលើចន្លោះ $[0,+\infty)$

អនុគមន៍ $f(x)=\dfrac{x^2+(m+1)x+2}{x+1}$

ដែនកំណត់ $\mathbb{D}=\mathbb{R}-\{-1\}$

ដេរីវេ $f'(x)=\dfrac{x^2+2x+2m}{(x+1)^2}$

$f$ កើនលើ $[0,+\infty)$ លុះត្រាតែ $f'(x)\geq 0$ លើ $[0,+\infty)$

$\Delta'=1-2m$

• ករណី $\Delta'\leq 0\Rightarrow 1-2m\leq 0\Rightarrow m\geq\dfrac{1}{2}$

$$\begin{cases}\Delta'\leq 0\\ a=1>0\end{cases}\Rightarrow f'(x)\geq 0,\forall x\in\mathbb{D}$$

$\Rightarrow f'(x)\geq 0$ លើ $[0,+\infty)$

• ករណី $\Delta'>0\Rightarrow 1-2m>0\Rightarrow m<\dfrac{1}{2}$

$\Rightarrow\sqrt{\Delta'}=\sqrt{1-2m}$

$\Rightarrow x_1=-1-\sqrt{1-2m},x_2=-1+\sqrt{1+2m}$

តារាងសញ្ញា $f'(x)$

| $x$ | $-\infty$ | | $-1-\sqrt{1-2m}$ | | $-1+\sqrt{1-2m}$ | | $+\infty$ |
|---|---|---|---|---|---|---|---|
| $f'(x)$ | | $+$ | $0$ | $-$ | $0$ | $+$ | |

ចង់ឱ្យ $f$ កើនលើ $[0,+\infty)$ ត្រូវឱ្យ $-1+\sqrt{1-2m}\leq 0$

$\Rightarrow\sqrt{1-2m}\leq 1\Rightarrow m\geq 0\Rightarrow 0\leq m<\dfrac{1}{2}$

ប្រជុំចម្លើយនៃករណីទាំងពីរ គេបាន $m\in[0,+\infty)$

ដូចនេះ $m\in[0,+\infty)$

V. បង្ហាញថាសមីការ $x^4-ax^3-bx^2-cx-d=0$ គ្មានឫសជាចំនួនគត់

ឧបមថា $\alpha$ ជាឫសគត់វិជ្ជមាននៃ $f(x)=0$

នោះ $f(x)=0$ យើងបាន

$$\alpha^4-a\alpha^3-b\alpha^2-c\alpha-d=0$$

ឬ $d=\alpha\left(\alpha^3-a\alpha^2-b\alpha-c\right)$

នោះ $\alpha|d\Rightarrow\alpha\leq d\quad(*)$

ដោយ $\alpha^3(\alpha-a)=\alpha^4-a\alpha^3=b\alpha^2+c\alpha+d>0$

នោះ $\alpha>a$

តែ $a\geq b\geq c\geq d$ នោះ $\alpha>d$ ផ្ទុយពីការពិត ( តាម $(*)$)

សម្រាយបញ្ជាក់នេះ មានន័យថាសមីការ :

$x^3-ax^3-bx^2-cx-d=0$ គ្មានឫសជាចំនួនគត់

VI. ស្រាយថា $x=a,y=b$ និង $z=c$

ដោយ $a\leq x,y,z\leq c$ នោះ $\frac{c}{z}\geq 1$ និង $\frac{a}{x}\leq 1$

ដោយ $xyz=abc$ តាមវិសមភាព AM-GM គេបាន

$\frac{c}{z}+\frac{b}{y}+\frac{a}{x}\geq 3\sqrt[3]{\frac{abc}{xyz}}=3$

យើងទាញបាន $\frac{c}{z}-1\geq 1,\frac{c}{z}+\frac{b}{y}+\frac{a}{x}-3\geq 0$

ហើយដោយ $1-\frac{a}{x}\geq 0$ នោះ $\frac{c}{z}+\frac{b}{y}-2\geq 1-\frac{a}{x}\geq 0$

$T=(a+b+c)-(x+y+z)$

$=x\left(\frac{a}{x}-1\right)+y\left(\frac{b}{y}-1\right)+z\left(\frac{c}{z}-1\right)$

$=x\left(\frac{c}{z}+\frac{b}{y}+\frac{a}{x}-3\right)+(y-x)\left(\frac{c}{z}+\frac{b}{y}-2\right)+(z-y)\left(\frac{c}{z}-1\right)\geq 0$

ដោយ $a+b+c=x+y+z$ នោះ $T=0$

នោះវិសមភាពពិត លុះត្រាតែ $a=x,b=y,c=z$

ដូចនេះ $a=x,b=y,c=z$

VII. ស្រាយបញ្ជាក់ថា ផ្ទៃក្រឡា$S=\sqrt{(p-a)(p-b)(p-c)(p-d)}$



ចតុកោណ $ABCD$ ចារឹកក្នុងរង្វង់

យើងបាន $B+D=180^0 \Rightarrow B=180^0-D$

$$\Rightarrow \begin{cases} sinB = sin\left(180^0-D\right) \\ cosB = cos\left(180^0-D\right) \end{cases}$$

$$\Rightarrow \begin{cases} sinB = sinD \\ cosB = -cosD \end{cases}$$

$$\begin{aligned} S_{ABCD} &= S_{ABC}+S_{ACD} \\ &= \frac{1}{2}absinB+\frac{1}{2}cdsinD \\ &= \frac{1}{2}absinB+\frac{1}{2}cdsinB \\ &= \frac{1}{2}(ab+cd)sinB \\ &= \frac{1}{2}(ab+cd)\sqrt{sin^2B} \\ &= \frac{1}{2}(ab+cd)\sqrt{1-cos^2B} \end{aligned}$$

តាង $x=AC$ តាមទ្រឹស្តីបទកូស៊ីនុស

ក្នុងត្រីកោណ $ABC$ : $x^2=a^2+b^2-2abcosB \quad (1)$

ក្នុងត្រីកោណ $ADC$ : $x^2=c^2+d^2-2cdcosD$

$$x^2=c^2+d^2+2cdcosB \quad (2)$$

តាម (1) និង(2)

$$a^2+b^2-2abcosB=c^2+d^2+2cdcosB$$

$$\Rightarrow cosB=\frac{\left(a^2+b^2\right)-\left(c^2+d^2\right)}{2(ab+cd)}$$

យើងបាន $S_{ABCD}=\dfrac{1}{2}(ab+cd)\sqrt{1-\left[\dfrac{\left(a^2+b^2\right)-\left(c^2+d^2\right)}{2(ab+cd)}\right]}$

$$=\frac{1}{2}(ab+cd)\frac{\sqrt{4(ab+cd)^2-\left[\left(a^2+b^2\right)-\left(c^2+d^2\right)\right]}}{2(ab+cd)}$$

$$=\frac{1}{4}\sqrt{4(ab+cd)^2-\left[\left(a^2+b^2\right)-\left(c^2+d^2\right)\right]}$$

$$=\frac{1}{4}\sqrt{\left[(c+d)^2-(a-b)^2\right]\left[(a+b)^2-(c-d)^2\right]}$$

$= \sqrt{(p-a)(p-b)(p-c)(p-d)}$

ដូចនេះ $S = \sqrt{(p-a)(p-b)(p-c)(p-d)}$

## ប្រលងជ្រើសរើសសិស្សពូកែទូទាំងខេត្តតាកែវ
## ផ្នែកគណិតវិទ្យា រូបវិទ្យា និង អក្សរសិល្ប៍ខ្មែរ ថ្នាក់ទី៩ និងថ្នាក់ទី ១២
## សម័យប្រលង ០២ មីនា ២០២០
## វិញ្ញាសា : គណិតវិទ្យាទី ១ រយៈពេល ៣ ម៉ោង

I. ដោយមិនប្រើតារាងត្រីកោណមាត្រ និងមិនរកតម្លៃ $sin\dfrac{\pi}{10}$ ចូរគណនាតម្លៃ $A = 8sin^3\dfrac{\pi}{10} + 8sin^2\dfrac{\pi}{10}$ ។

II. គេឱ្យ $f(n) = \left(n^2+n+1\right)^2 + 1$ ដែល $n \in \mathbb{N}$ និង $n \geq 1$ ។ តាង $a_n = \dfrac{f(1)}{f(2)} \times \dfrac{f(3)}{f(4)} \times \cdots \times \dfrac{f(2n-1)}{f(2n+1)} = \prod_{i=1}^{n}\left(\dfrac{f(2i-1)}{f(2i+1)}\right)$ ។ គណនា $a_n$ ជាអនុគមន៍នៃ $n$ រួចទាញរក $\lim\limits_{n\to+\infty} n\sqrt{a_n}$ ។

III. គេឱ្យបីចំនួនវិជ្ជមាន $a,b$ និង $c$ ផ្ទៀងផ្ទាត់ $ab+bc+ca=1$ ។ គណនាតម្លៃនៃកន្សោម :

$$M = a\sqrt{\frac{\left(1+b^2\right)\left(1+c^2\right)}{1+a^2}} + b\sqrt{\frac{\left(1+c^2\right)\left(1+a^2\right)}{1+b^2}} + c\sqrt{\frac{\left(1+a^2\right)\left(1+b^2\right)}{1+c^2}}$$ ។

IV. ឧបមាថាឫសនៃសមីការ $x^{2020} = 1$ ក្នុងសំណុំចំនួនកុំផ្លិចតាងដោយ $x_0, x_1, x_2, \ldots, x_{2019}$ ។ តាង $S$ និង $P$ ជាផលបូកនិងផលគុណឫសទាំងអស់របស់សមីការខាងលើ និងយក $f(x) = (x-x_1)(x-x_2)\ldots(x-x_{2019})$ ។ ចូរគណនា $S,P$ និង $f(1)$ ។

V. គេឱ្យត្រីកោណ $ABC$ មាន $BC=a, AC=b$ និង $AB=c$ ។ រង្វង់ចារឹកក្នុងត្រីកោណ $ABC$ មានផ្ចិត $I$ និងកាំ $r$ ហើយរង្វង់ចារឹកក្រៅត្រីកោណ $ABC$ មានកាំ $R$ ។ ស្រាយបញ្ជាក់ថា $IC^2 = ab - 4Rr$ ។

## អត្រាកំណែ

I. គណនាតម្លៃ $A = 8sin^3\frac{\pi}{10} + 8sin^2\frac{\pi}{10}$

យើងមាន $cos\frac{4\pi}{10} = sin\frac{\pi}{10}$ ( មុំបំពេញ )

$\Leftrightarrow 2cos^2\frac{2\pi}{10} - 1 = sin\frac{\pi}{10}$

$\Leftrightarrow 2\left(1 - 2sin^2\frac{\pi}{10}\right)^2 - 1 = sin\frac{\pi}{10}$

$\Leftrightarrow 2\left(1 - 4sin^2\frac{\pi}{10} + 4sin^4\frac{\pi}{10}\right) - 1 = sin\frac{\pi}{10}$

$\Leftrightarrow 8sin^4\frac{\pi}{10} - 8sin^2\frac{\pi}{10} - sin\frac{\pi}{10} + 1 = 0$

$\Leftrightarrow \left(sin\frac{\pi}{10}\right)\left(8sin^3\frac{\pi}{10} + 8sin^2\frac{\pi}{10} - 1\right) = 0$

$\Leftrightarrow 8sin^3\frac{\pi}{10} + 8sin^2\frac{\pi}{10} - 1 = 0$ ( ព្រោះ $sin\frac{\pi}{10} \neq 1$ )

$\Leftrightarrow 8sin^3\frac{\pi}{10} + 8sin^2\frac{\pi}{10} = 1$

ដូចនេះ $A = 1$

II. គណនា $a_n$ ជាអនុគមន៍នៃ $n$ រួចទាញរក $\lim_{n\to+\infty} n\sqrt{a_n}$

យើងបាន $f(n) = \left(n^2 + n + 1\right)^2 + 1$

$= \left[\left(n^2 + 1\right) + n\right]^2 + 1$

$= \left(n^2 + 1\right)^2 + 2n\left(n^2 + 1\right) + n^2 + 1$

$f(n) = \left(n^2 + 1\right)\left[(n+1)^2 + 1\right]$

$$\Rightarrow \frac{f(2n-1)}{f(2n+1)} = \frac{\left(4n^2 - 4n + 1\right)\left(4n^2 + 1\right)}{\left(4n^2 + 1\right)\left(4n^2 + 4n + 2\right)} = \frac{(2n-1)^2 + 1}{(2n+1)^2 + 1}$$

នោះ $a_n = \frac{1^2 + 1}{3^2 + 1} \cdot \frac{3^2 + 1}{5^2 + 1} \cdot \frac{5^2 + 1}{7^2 + 1} \cdots \frac{(2n-3)^2 + 1}{(2n-1)^2 + 1} \cdot \frac{(2n-1)^2 + 1}{(2n+1)^2 + 1}$

$\Rightarrow a_n = \frac{1^2 + 1}{(2n+1)^2 + 1} = \frac{1}{2n^2 + 2n + 1}$

ដូចនេះ $a_n = \frac{1}{2n^2 + 2n + 1}$

ទាញរក $\lim_{n\to+\infty} n\sqrt{a_n}$

$$\lim_{n\to+\infty} n\sqrt{a_n} = \lim_{n\to+\infty} \frac{n}{\sqrt{2n^2 + 2n + 1}} = \lim_{n\to+\infty} \frac{1}{\sqrt{2 + \frac{2}{n} + \frac{1}{n^2}}} = \frac{1}{\sqrt{2}} = \frac{\sqrt{2}}{2}$$

ដូចនេះ $\lim\limits_{n\to+\infty} n\sqrt{a_n}=\dfrac{\sqrt{2}}{2}$

III. គណនាតម្លៃនៃកន្សោម $M$

ចំពោះ $a,b,c>0$ យើងតាង $a=tan\alpha, b=tan\beta, c=tan\gamma$ ដែល $\alpha,\beta,\gamma\in\left(0,\dfrac{\pi}{2}\right)$

ដោយ $ab+bc+ca=1$ យើងបាន

$tan\alpha tan\beta+tan\beta tan\gamma+tan\gamma tan\alpha=1$

$\Leftrightarrow tan\alpha tan\beta+tan\beta tan\gamma=1-tan\gamma tan\alpha$

$\Leftrightarrow (tan\alpha+tan\gamma)tan\beta=1-tan\gamma tan\alpha$

$\Leftrightarrow \dfrac{tan\alpha+tan\gamma}{1-tan\alpha tan\gamma}=\dfrac{1}{tan\beta}$

$\Leftrightarrow tan(\alpha+\gamma)=cot\beta$

$\Leftrightarrow \alpha+\beta+\gamma=\dfrac{\pi}{2}$

យើងបាន $a\sqrt{\dfrac{\left(1+b^2\right)\left(1+c^2\right)}{1+a^2}}=(tan\alpha)\sqrt{\dfrac{\left(1+tan^2\beta\right)\left(1+tan^2\gamma\right)}{1+tan^2\alpha}}$

$=\left(\dfrac{sin\alpha}{cos\alpha}\right)\sqrt{\dfrac{cos^2\alpha}{cos^2\beta cos^2\gamma}}$

$\Rightarrow a\sqrt{\dfrac{\left(1+b^2\right)\left(1+c^2\right)}{1+a^2}}=\dfrac{sin\alpha}{cos\beta cos\gamma}=\dfrac{cos(\beta+\gamma)}{cos\beta cos\gamma}$

$\Rightarrow a\sqrt{\dfrac{\left(1+b^2\right)\left(1+c^2\right)}{1+a^2}}=1-tan\beta tan\gamma=1-bc$

ដូចគ្នាដែរ $b\sqrt{\dfrac{\left(1+c^2\right)\left(1+a^2\right)}{1+b^2}}=1-ca, c\sqrt{\dfrac{\left(1+a^2\right)\left(1+b^2\right)}{1+c^2}}=1-ab$

យើងទាញបាន $M=(1-bc)+(1-ca)+(1-ab)=3-1=2$

ដូចនេះ $M=2$

IV. គណនា $S,P$ និង $f(1)$

យើងមាន $1=cos0+isin0$

នោះ $x_k=cos\dfrac{2k\pi}{2020}+isin\dfrac{2k\pi}{2020}$

បើ $k=0;\ x_0=1$

បើ $k=1;\ x_1=cos\dfrac{2\pi}{2020}+isin\dfrac{2\pi}{2020}$

បើ $k=2;\ x_2 = cos\dfrac{4\pi}{2020} + isin\dfrac{4\pi}{2020} = x_1^2$

បើ $k=3;\ x_3 = cos\dfrac{6\pi}{2020} + isin\dfrac{6\pi}{2020} = x_1^3$

.............................................................................................

បើ $k=2019;\ x_{2019} = cos\dfrac{2\cdot 2019\pi}{2020} + isin\dfrac{2\cdot 2019\pi}{2020} = x_1^{2019}$

យើងទាញបាន

$$S = x_0 + x_1 + x_2 + \cdots + x_{2019}$$

$S = 1 + x_1^2 + x_1^3 + \cdots + x_1^{2019}$

$S = \dfrac{1-x_1^{2019}}{1-x_1} = \dfrac{1-1}{1-x_1} = 0,\ (x_1^{2019} = 1, x_1 \neq 1)$

$P = x_0 \cdot x_1 \cdot x_2 \cdots x_{2019}$

$P = 1\cdot x_1 \cdot x_1^2 \cdot x_1^3 \cdots x_1^{2019} = x_1^{1+2+3+\cdots+2019}$

$P = x_1^{2019\cdot 1010} = \left(cos\dfrac{2\pi}{2020} + isin\dfrac{2\pi}{2020}\right)^{2019/cdot1010}$

$P = cos2019\pi + isin2019\pi = -1$

ម្យ៉ាងទៀត

$$x^{2020} - 1 = (x-1)\left(x^{2019} + x^{2018} + \cdots + 1\right)$$

តែ $x^{2020} - 1 = (x-x_0)(x-x_1)(x-x_2)\cdots(x-x_{2019})$

$\Rightarrow f(x) = x^{2019} + x^{2018} + x^{2017} + \cdots + 1$

$\Rightarrow f(1) = \underbrace{1+1+1+\cdots+1}_{2020} = 2020$

ដូចនេះ $S = 0, P = -1$ និង $f(1) = 2020$

V. ស្រាយបញ្ជាក់ថា $IC^2 = ab - 4Rr$



តាង $\angle ACB = \alpha$ និង $D$ ជាចំណុចដែលរង្វង់ប៉ះជ្រុង $BC$
ក្នុងត្រីកោណ $CID$ យើងមាន :

$$\sin\frac{\alpha}{2} = \frac{ID}{IC}$$

$$\Rightarrow IC = \frac{ID}{\sin\frac{\alpha}{2}} = \frac{r}{\sin\frac{\alpha}{2}}$$

$$\Rightarrow IC^2 = \frac{r^2}{\sin^2\frac{\alpha}{2}}$$

តែ $\sin^2\frac{\alpha}{2} = \frac{1}{2}(1-\cos\alpha) = \frac{1}{2}\left(1 - \frac{a^2+b^2-c^2}{2ab}\right)$

$$= \frac{c^2-(a-b)^2}{4ab} = \frac{(c+a-b)(b+c-a)}{4ab}$$

យក $p = \frac{a+b+c}{2}$ នោះ $c+a-b = 2(p-b), b+c-a = 2(p-a)$

$$\Rightarrow IC^2 = \frac{abr^2}{(p-b)(p-a)}$$

តែ $S = pr = \frac{abc}{4R} = \sqrt{p(p-a)(p-b)(p-c)}$

$$\Rightarrow (p-b)(p-a) = \frac{S^2}{p(p-c)}$$

$$\Rightarrow IC^2 = \frac{abr^2p(p-c)}{S^2} = \frac{abr^2p(p-c)}{p^2r^2}$$

$\Rightarrow IC^2 = ab - \frac{4Rrp}{p} = ab - 4Rr$ ពិត

ដូចនេះ $IC^2 = ab - 4Rr$

# ប្រលងជ្រើសរើសសិស្សពូកែថ្នាក់ខេត្តតាកែវ
# ផ្នែកគណិតវិទ្យា រូបវិទ្យា និង អក្សរសិល្ប៍ខ្មែរ ថ្នាក់ទី៩ និងថ្នាក់ទី ១២
# សម័យប្រលង ០២ មីនា ២០២០
# វិញ្ញាសា : គណិតវិទ្យាទី ២ រយៈពេល ៣ ម៉ោង

I. ក. ដីចំការបីកន្លែង ចំការទី១មានរាងចតុកោណកែង ចំការទី២រាងការេ និងចំការទី៣មានរាងពហុកោណស្មើរស្មើជ្រុង ដែលមានចំនួនជ្រុងមិនកំណត់ ។ ចំការទាំងបីមានបរិមាត្រស្មើគ្នា ។ ចូរប្រៀបធៀបផ្ទៃក្រឡាចំការទាំងបី។

ខ. រកចំនួនគត់ធម្មជាតិ $n$ ដែលនាំឱ្យប្រភាគ $\dfrac{n^2+n+6}{n+1}$ ជាចំនួនគត់វិជ្ជមាន ។

II. $(z_n)_{n\in\mathbb{N}}$ ជាស្វ៊ីតនៃចំនួនកុំផ្លិចដែលកំណត់ដោយៈ
$z_n = 2\sqrt{2}(-1+i)$ ហើយគ្រប់ចំនួនគត់ធម្មជាតិ $n, z_{n+1}$ មានអាគុយម៉ង់នៅក្នុងចន្លោះ $\left[\dfrac{\pi}{2},\pi\right], z_{n+1}^4 = z_n$ ។
១. កំណត់ម៉ូឌុល និងអាគុយម៉ង់នៃ $z_1$ ។
២. គេសន្មត់ $r_n = |z_n|$ និង $v_n = ln r_n$ ។
បង្ហាញថា $(v_n)_{n\in\mathbb{N}}$ ជាស្វ៊ីតធរណីមាត្រដែលត្រូវបញ្ជាក់តួទី១ និងផលធៀបរួមរបស់វា ។

III. $f$ ជាអនុគមន៍ដែលមានអថេរពិត $x$ កំណត់ដោយ $y = f(x) = \left(x^2-3x+1\right)e^x$ ។
១. សិក្សាទិសដៅអថេរភាព និងសង់ខ្សែកោង $(C)$ តាងអនុគមន៍ $f$ នៅក្នុងតម្រុយអរតូណរម៉ាល់ $(0,\vec{i},\vec{j})$ ។
២. ក. បង្ហាញថា $f$ ជាចម្លើយមួយនៃសមីការ $y''-2y'+y=2e^x$ ។
ខ. គណនា $F(x)=2e^x+2y-y'$ និងបង្ហាញថាវាជាព្រីមីទីវមួយនៃអនុគមន៍ $f$ ។ ៣. គណនាផ្ទៃក្រឡាផ្នែកប្លង់ដែលខណ្ឌដោយខ្សែកោង និងអ័ក្ស $x'ox$ ដែល $x \geq 0$ ។

IV. នៅក្នុងតម្រុយអរតូណរម៉ាល់ $(0,\vec{i},\vec{j},\vec{k})$ ដែលមានទិសដៅវិជ្ជមាននៃលំហ គេឱ្យ ៤ចំណុច $A,B,C$ និង $D$ ដែលមានកូអរដោនេរៀងគ្នា $(-1,0,2);(3,2,-4);$ $(1,-4,2)$ និង $(5,-2,4)$ ។ $I$ និង $K$ ជាចំណុចកណ្តាលរៀងគ្នានៃអង្កត់ $[AB]$ និង $[CD]$ ហើយ $J\in[BC]$ ដែល $BJ=\dfrac{1}{4}\cdot BC$ ។
១. កំណត់កូអរដោនេនៃចំណុច $I,J$ និង $K$ ។

២. ក. បង្ហាញថាចំណុច $I, J, K$ មិនរត់ត្រង់គ្នា ។

ខ. ផ្ទៀងផ្ទាត់ថា ប្លង់ $(IJK)$ មានសមីការ $8x+9y+5z-12=0$ ។

គ. កំណត់សមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(AD)$ និងបង្ហាញថា ប្លង់ $(IJK)$ កាត់តាមបន្ទាត់ $(AD)$ ត្រង់ចំណុច $L$ មួយដែលគេត្រូវកំណត់កូអរដោនេ។

ឃ. បង្ហាញថា $\overrightarrow{AL} = \frac{1}{4}\overrightarrow{AD}$ ។

## អត្រាកំណែ

I. ក. ប្រៀបធៀបផ្ទៃក្រឡាដីចំការ

តាង $S_1$ ផ្ទៃក្រឡាចំការរាងចតុកោណកែងដែលមាន $x$ និង $y$ ជាវិមាត្រ គឺ $S_1 = xy$

$S_2$ ផ្ទៃក្រឡាដីចំការការេដែលមាន $a$ ជារង្វាស់ជ្រុងគឺ $S_2 = a^2$

$S_3$ ផ្ទៃក្រឡាដីចំការរាងពហុកោណស្មើរស្មើជ្រុង (រង្វង់កាំ $r$) គឺ $S_3 = \pi r^2$

យក $p$ ជាបរិមាត្រនៃចំការ នោះ $2(x+y) = 4a = 2\pi r = p$

គេបាន $S_1 \le S_2 \le S_3$

ខ. រកចំនួនគត់ធម្មជាតិ $n$

តាង $N = \dfrac{n^2+n+6}{n+1} = n + \dfrac{6}{n+1}$

$N$ ជាចំនួនគត់វិជ្ជមានលុះត្រាតែ 6 ចែកដាច់នឹងចំនួនគត់វិជ្ជមាន $n+1$ នោះគេបាន $n \in \{0,1,2,5\}$

II. ១. កំណត់ $|z_1|$ និង $arg(z_1)$

គេមាន $\begin{cases} z_0 = 2\sqrt{2}(-1+i) \\ z_{n+1}^4 = z_n,\ n \in \mathbb{N},\ arg(z_{n+1}) \in \left[\dfrac{\pi}{2}, \pi\right] \end{cases}$

$$z_0 = 2\sqrt{2}(-1+i) = 4\left(-\frac{\sqrt{2}}{2} + \frac{\sqrt{2}}{2}i\right) = 4\left(cos\frac{3\pi}{4} + isin\frac{3\pi}{4}\right)$$

$|z_0| = 4,\ arg(z_0) = \dfrac{3\pi}{4}$

ដោយ $z_{n+1}^4 = z_n$ នោះ $z_1^4 = z_0$ ឬ $z_1 = \sqrt[4]{z_0}$

$\bullet |z_1| = \left|\sqrt[4]{z_0}\right| = \sqrt[4]{|z_0|} = \sqrt[4]{4}$

$\bullet arg(z_1) = \dfrac{arg(z_0)}{4} + \dfrac{2k\pi}{4} = \dfrac{3\pi}{16} + \dfrac{k\pi}{2},\ k = 1 \Rightarrow arg(z_1) = \dfrac{11\pi}{16}$

ដូចនេះ $|z_1| = \sqrt[4]{4},\ arg(z_1) = \dfrac{11\pi}{16}$

២. បង្ហាញថា $(v_n)_{n\in\mathbb{N}}$ ជាស្វ៊ីតធរណីមាត្រដោយបញ្ជាក់ $v_0$ និង $q$

$v_n = lnr_n = ln|z_n| \Rightarrow v_0 = lnr_0 = ln|z_0| = ln4 = 2ln2$

$\frac{v_{n+1}}{v_n} = \frac{ln|z_{n+1}|}{ln|z_n|} = \frac{ln\left|\sqrt[4]{z_n}\right|}{ln|z_n|} = \frac{1}{4}$ : ថេរ

ដូចនេះ $(v_n)_{n\in\mathbb{N}}$ ជាស្វ៊ីតធរណីមាត្រដែលមាន $v_0 = 2ln2, q = \frac{1}{4}$

III. ១. សិក្សាអថេរភាព និងសង់ខ្សែកោង $(C)$ តាង $f$:

$C:\ y = f(x) = \left(x^2 - 3x + 1\right)e^x$

•ដែនកំណត់ : $D = \mathbb{R} = (-\infty, +\infty)$

•លីមីត

$\lim\limits_{x\to-\infty} f(x) = \lim\limits_{x\to-\infty}\left(x^2 - 3x + 1\right)e^x = \lim\limits_{x\to-\infty}\left(1 - \frac{3}{x} + \frac{1}{x^2}\right)x^2e^x = 0$

ព្រោះ $\lim\limits_{x\to-\infty} x^2e^x = 0$

$\lim\limits_{x\to+\infty} f(x) = \lim\limits_{x\to+\infty}\left(1 - \frac{3}{x} + \frac{1}{x^2}\right)x^2e^x = +\infty$

ព្រោះ $\lim\limits_{x\to+\infty} x^2e^x = +\infty$

•ដេរីវេ និងសញ្ញា $f'(x)$

$f'(x) = \left(x^2 - 3x + 1\right)'e^x + (e^x)'\left(x^2 - 3x + 1\right) = \left(x^2 - x - 2\right)e^x$

$f''(x) = \left(x^2 + x - 3\right)e^x$

$f'(x)$ មានសញ្ញាដូច $x^2 - x - 2$, $x^2 - x - 2 = 0$ មាន $x = -1, x = 2$

•តារាងអថេរភាពនៃ $f$

| $x$ | $-\infty$ | | $-1$ | | $2$ | | $+\infty$ |
|---|---|---|---|---|---|---|---|
| $f(x)$ | ‖ | $+$ | $0$ | $-$ | $0$ | $+$ | |
| $f(x)$ | $0$ | ↗ | $f(-1)$ | ↘ | $f(2)$ | ↗ | $+\infty$ |

•សង់ខ្សែកោង $(C)$: $y = f(x) = \left(x^2 - 3x + 1\right)e^x$

- ប្រសព្វជាមួយអ័ក្ស $y'oy$ : $x = 0, y = 1$

-ប្រសព្វជាមួយអ័ក្ស $x'ox$ : $y = 0 \Rightarrow x^2 - 3x + 1 = 0,\ x = \frac{3 \pm \sqrt{5}}{2}$

- អាប់ស៊ីសចំណុចរបត់ : $y'' = 0 \Rightarrow x^2 - x - 3 = 0,\ x = \frac{1 \pm \sqrt{13}}{2}$

-អាស៊ីមតូតដេក :$y = 0$




២. ក. បង្ហាញថា $f$ ជាចម្លើយមួយនៃសមីការ $y''-2y'+y=2e^x$ $(E)$

$y=\left(x^2-3x+1\right)e^x,\ y'=\left(x^2-x-2\right)e^x,\ y''=\left(x^2+x-3\right)e^x$

$y''-2y'+y=\left(x^2+x-3-2x2+2x+4+x^2-3x+1\right)e^x=2e^x$

អនុគមន៍ $y=f(x)$ ផ្ទៀងផ្ទាត់សមីការ $y''-2y'+y=2e^x$

ដូចនេះ $f$ ជាចម្លើយមួយនៃសមីការ $y''-2y'+y=2e^x$

២. គណនា $F(x)$

$F(x)=2e^x+2y-y'=\left(2+2x^2-6x+2-x^2+x+2\right)e^x$

$F(x)=\left(x^2-5x+6\right)e^x$

បង្ហាញថា $F(x)$ ជាព្រីមីទីវមួយនៃ $f(x)$:

យើងបាន

$$F'(x)=(2x-5+x^2-5x+6)e^x=\left(x^2-3x+1\right)e^x=f(x)$$

ដូចនេះ $F(x)$ ជាព្រីមីទីវមួយនៃ $f(x)$

៣. គណនាផ្ទៃក្រឡា

តាង $A$ ជាផ្ទៃក្រឡាដែលកំណត់បានដោយខ្សែកោង $C$ អ័ក្ស $x'ox$ ដែល $x\geq 0$

យើងបាន $A=\int_0^{\frac{3-\sqrt5}{2}} f(x)dx-\int_{\frac{3-\sqrt5}{2}}^{\frac{3+\sqrt5}{2}} f(x)dx$

តែ $\int f(x)dx=F(x)$

$\Rightarrow A=\left[\left(x^2-5x+6\right)e^x\right]_0^{\frac{3-\sqrt5}{2}}-\left[\left(x^2-5x+6\right)e^x\right]_0^{\frac{3+\sqrt5}{2}}$

$A=(4+2\sqrt5)e^{\frac{3-\sqrt5}{2}}+(\sqrt5-2)e^{\frac{3+\sqrt5}{2}}-6$ ឯកតាផ្ទៃ

ឬ តាង $S$ ជាផ្ទៃក្រឡាដែលកំណត់បានដោយខ្សែកោង $C$ អ័ក្ស $x'ox$ ដែល $x\ge 0$

គេបាន $S=A+\int_{\frac{3+\sqrt5}{2}}^{\alpha} f(x)dx=+\infty,\ \alpha>\frac{3+\sqrt5}{2}$ ផ្ទៃក្រឡាធំមិនកំណត់ ។

IV. ១. កំណត់កូអរដោនេចំណុច $I,J$ និង $K$

$A(-1,0,2);\ B(3,2,-4);\ C(1,-4,2)$ និង $D(5,-2,4)$

$I$ ជាចំណុចកណ្តាល $[AB]$ នោះ $I(1,1,-1)$

តាង $J\left(x_j,y_j,z_j\right)$

ដោយ $JB=\frac{1}{4}BC$

យើងបាន $\left(x_j-3,y_j-2,z_j+4\right)=\frac{1}{4}(-2,-6,6$

$\Rightarrow x_j-3=-\frac{1}{2},y_j-2=-\frac{3}{2},z_j+4=\frac{3}{2}$

$\Rightarrow J\left(\frac{5}{2},\frac{1}{2},-\frac{5}{2}\right)$

$K$ ជាចំណុចកណ្តាល $[CD]$ នោះ $K(3,-3,3)$

ដូចនេះ $I(1,1,-1),J\left(\frac{5}{2},\frac{1}{2},-\frac{5}{2}\right)$ និង $K(3,-3,3)$

២. ក.បង្ហាញថាចំណុច $I,J,K$ មិនរត់ត្រង់គ្នា

យើងគណនា $\overrightarrow{IJ}\times\overrightarrow{IK}$

$\overrightarrow{IJ}=\left(\frac{3}{2},-\frac{1}{2},-\frac{3}{2}\right)$

$\overrightarrow{IK}=(2,-4,4)$

យើងបាន

$$\overrightarrow{IJ}\times\overrightarrow{IK}=\begin{vmatrix}\vec{i} & \vec{j} & \vec{k}\\ \frac{3}{2} & -\frac{1}{2} & -\frac{3}{2}\\ 2 & -4 & 4\end{vmatrix}=\begin{vmatrix}-\frac{1}{2} & -\frac{3}{2}\\ -4 & 4\end{vmatrix}\vec{i}-\begin{vmatrix}\frac{3}{2} & -\frac{3}{2}\\ 2 & 4\end{vmatrix}\vec{j}+\begin{vmatrix}\frac{3}{2} & -\frac{1}{2}\\ 2 & -4\end{vmatrix}\vec{k}$$

$$=(-2-6)\vec{i}-(6+3)\vec{j}+(-6+1)\vec{k}$$

$$=-8\vec{i}-9\vec{j}-5\vec{k}$$

ដោយ $\overrightarrow{IJ}\times\overrightarrow{IK}\neq\vec{0}$ នោះចំណុច $I,J,K$ មិនរត់ត្រង់គ្នា ។

ខ. ផ្ទៀងផ្ទាត់ថា ប្លង់ $(IJK)$ មានសមីការ $8x+9y+5z-12=0$

ប្លង់ $(IJK)$ កាត់តាមចំណុច $I(1,1,-1)$ និង មានវ៉ិចទ័រណរម៉ាល់ $\vec{n}=\overrightarrow{IJ}\times\overrightarrow{IK}$ កំណត់ដោយ :

$$(IJK):\ a(x-x_I)+b(y-y_I)+c(z-z_I)=0$$

$$-8(x-1)-9(y-1)-5(z+1)=0$$

$$-8x-9y-5z+12=0$$

ដូចនេះ ប្លង់ $(IJK)$ គឺ $8x+9y+5z-12=0$

គ. កំណត់សមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(AD)$ និងបង្ហាញថាប្លង់ $(IJK)$ កាត់បន្ទាត់ $(AD)$ ត្រង់ចំណុច $L$ មួយដែលគេត្រូវកំណត់កូអរដោនេ

បន្ទាត់ $(AD)$ កាត់តាមចំណុច $A(-1,0,2)$ និងមានវ៉ិចទ័រប្រាប់ទិស $\overrightarrow{AD}=(6,-2,2)$ មានសមីការប៉ារ៉ាម៉ែត្រកំណត់ដោយ :

$$(AD):\begin{cases}x=x_A+at\\ y=y_A+bt\\ z=z_A+ct\end{cases}\quad \text{ដែល } t\in\mathbb{R}$$

$$\Rightarrow(AD):\begin{cases}x=-1+6t\\ y=0+(-2)t\\ z=2+2t\end{cases}\quad t\in\mathbb{R}$$

ដូចនេះ សមីការប៉ារ៉ាម៉ែត្រនៃបន្ទាត់ $(AD)$ គឺ $x=-1+6t, y=-2t, z=2+2t$ ដែល $t\in\mathbb{R}$

•បង្ហាញថា ប្លង់ $(IJK)$ កាត់ $(AD)$ ត្រង់ $L$ ដែលគេត្រូវកំណត់កូអរដោនេ

$L=(IJK)\cap(AD)$ នោះកូអរដោនេចំណុច $L$ ( បើមាន ) ជាចម្លើយនៃប្រព័ន្ធសមីការ

$$\begin{cases}8x+9y+5z-12=0 & (1\\ (x,y,z)=(-1+6t,-2t,2+2t) & (2)\end{cases}$$

យក (2) ជំនួសចូល (1) សមីការអញ្ញាត $t$ មានឫស $t=\frac{1}{4}$

នោះ $(IJK)$ កាត់ $(AD)$ ត្រង់ $L$

បើ $t=\frac{1}{4}$, $L\in(AD)$ គេបាន $L\left(\frac{1}{2},-\frac{1}{2},\frac{5}{2}\right)$

ដូចនេះ $(IJK)$ កាត់ $(AD)$ ត្រង់ចំណុច $L\left(\frac{1}{2},-\frac{1}{2},\frac{5}{2}\right)$

ឃ. បង្ហាញថា $\overrightarrow{AL}=\frac{1}{4}\overrightarrow{AD}$

$$\left.\begin{array}{r}\overrightarrow{AD}=(6,-2,2)\\ \overrightarrow{AL}=\left(\frac{3}{2},-\frac{1}{2},\frac{1}{2}\right)\end{array}\right\}\Rightarrow \frac{6}{\frac{3}{2}}=\frac{-2}{-\frac{1}{2}}=\frac{2}{\frac{1}{2}}=4$$

$$\overrightarrow{AD}=4\cdot\overrightarrow{AL}\ \Rightarrow\overrightarrow{AL}=\frac{1}{4}\overrightarrow{AD}$$

ដូចនេះ $\overrightarrow{AL}=\frac{1}{4}\overrightarrow{AD}$

# ប្រលងជ្រើសរើសគ្រូបង្រៀនកម្រិតឧត្តម
# បរិញ្ញាបត្រ+១ ជំនាន់ទី ២៨ ឆ្នាំ ២០១៩
# វិញ្ញាសា : គណិតវិទ្យាទី រយៈពេល ៣ ម៉ោង

I. ១. ចូរស្រាយបញ្ជាក់ថា $(cos8x+cos2x)^2+(sin8x+sin2x)^2=4cos^3 3x$ ។ បន្ទាប់មករកតម្លៃ $x$ ចំពោះ $(cos8x+cos2x)^2+(sin8x+sin2x)^2=3$ ដែល $0^0<x<180^0$ ។

២. គេឱ្យកន្សោម $S_n=\sum_{r=1}^{n} e^{rx}(r-re^{-x}+e^{-x})$ ដែល $x$ ជាចំនួនពិត និង $x\neq 0$ ។ ចូរស្រាយតាមវិចារកំណើនថាផលបូក $S_n=ne^{nx}$ ចំពោះគ្រប់ចំនួនគត់វិជ្ជមាន $n$ ។

៣. គេឱ្យតួនៃស្វ៊ីត $x_1,x_2,x_3,...,x_n$ ជាស្វ៊ីតធរណីមាត្រវិជ្ជមានកើន និងតួនៃស្វ៊ីតនីមួយៗផ្សេងទៀតគឺ $y_1,y_2,y_3,...,y_n$ កំណត់ដោយ $y_r=logx_r+2000$ ចំពោះ $r=1,2,3,...,n$ ។ ចូរបង្ហាញថា $y_1,y_2,y_3,...,y_n$ ជាស្វ៊ីតនព្វន្តកើន ។

II. ១. គេឱ្យវ៉ិចទ័រទីតាំងនៃចំណុច $A$ និង $B$ រៀងគ្នា $\vec{a}=\vec{j}-4\vec{k}$ និង $\vec{b}=6\vec{i}-5\vec{j}-\vec{k}$ ។ ចូរបង្ហាញថា បន្ទាត់ $AB$ ស្របនឹងវ៉ិចទ័រ $2\vec{i}-2\vec{j}+\vec{k}$ បន្ទាប់មកសរសេរសមីការបន្ទាត់ $AB$ ។

២. បង្ហាញថា ត្រីកោណ $ABC$ ដូចរូប គេទាញបាន $\dfrac{a}{sinA}=\dfrac{b}{sinB}=\dfrac{c}{sinC}$ ។




III. ១. គេឱ្យ $B=\begin{bmatrix}1&1&0\\1&1&1\\1&2&0\end{bmatrix}$ ។ រក $det(B)$ និង $det\left(B^{-1}\right)$ រួចកំណត់ទំនាក់ទំនងរវាង $det(B)$ និង $det\left(B^{-1}\right)$ ។

២. គេឱ្យប្លង់ $P_1,P_2$ ប្រសព្វគ្នា និង $\vec{n_1},\vec{n_2}$ ជាវ៉ិចទ័រណរម៉ាល់រៀងគ្នានៃប្លង់ ។ បង្ហាញ

ថា មុំរវាងប្លង់ $P_1, P_2$ ស្មើនឹងមុំផ្គុំដោយ $\overrightarrow{n_1}, \overrightarrow{n_2}$ រួចទាញរូបមន្តទូទៅសម្រាប់គណនាមុំរវាងប្លង់ពីរប្រសព្វគ្នា។

IV. ១. ចំពោះគ្រប់ $x \in [3,7]$ ចូរបង្ហាញថា $2\sqrt{2} < \int_3^7 \frac{dx}{\sqrt{lnx}} < 4$។

២. ប្រើស៊េរី Maclaurine ស្រាយបញ្ជាក់ថា $e^{ix} = cosx + isinx$ ។

៣. សរសេរ $\frac{2x^2 - x + 4}{(1+x^2)(2-x)}$ ជារាង $\frac{Ax+B}{1+x^2} + \frac{C}{2-x}$ ដែល $A, B, C$ ជាចំនួនថេរ ហើយបន្ទាប់មកពន្លាត $\frac{2x^2 - 4x + 4}{(1+x^2)(2-x)}$ ជាដឺក្រេកើនរហូតដល់តួដែលមាន $x^3$ ។

V. ១. គេឱ្យអថេរចៃដន្យ $X$ មានបំណែងចែកប្រូបាប

| $X$ | $-2$ | $-1$ | $0$ | $1$ | $2$ |
|---|---|---|---|---|---|
| $P(X=x)$ | $0.2$ | $a$ | $0.1$ | $b$ | $0.4$ |

គេដឹងថា $E(X) = 0.1$ រកតម្លៃនៃ $a$ និង $b$ ។

២. គេឱ្យកន្សោម $2x^3 + ax^2 + bx + c$ ។ បើគេចែកពហុធានេះជាមួយ $x-2$ និង $x+1$ គេបានសំណល់ដែលមានតម្លៃស្មើគ្នា។ បង្ហាញថា $a + b = -6$ ។

៣. ដោះស្រាយសមីការឌីផេរ៉ង់ស្យែល $yy' + y^2 = x$ ។

## ដំណោះស្រាយ

I. ១. ស្រាយបញ្ជាក់ថា $(cos8x + cos2x)^2 + (sin8x + sin2x)^2 = 4cos^2 3x$

យើងបាន $(cos8x + cos2x)^2 + (sin8x + sin2x)^2 = cos^2 8x + 2cos8xcos2x$

$$+ cos^2 x + sin^2 8x + 2sin8xsin2x + sin^2 x$$

$$= 2 + 2(cos8xcos2x + sin8xsin2x)$$

$$= 2 + 2cos(8x - 2x)$$

$$= 2(1 + cos6x) = 4 \cdot \frac{1 + cos2 \cdot 3x}{2}$$

$= 4cos^2 3x$ ព្រោះ $cos^2 3x = \frac{1 + cos6x}{2}$

រកតម្លៃ $x$ ចំពោះ $(cos8x + cos2x)^2 + (sin8x + sin2x)^2 = 3$ ដែល $0^0 < x < 180^0$

យើងអាចសរសេរ $4cos^2 3x = 3$

នោះ $cosx = \pm\frac{\sqrt{3}}{2}$

•ចំពោះ $cos3x = \frac{\sqrt{3}}{2} = cos30^0$

$\Leftrightarrow 3x = \pm 30^0 + 360^0 k,\ (k \in \mathbb{Z})$

$\Rightarrow x = \pm 10^0 + 120^0 k,\ (k \in \mathbb{Z})$

- បើ $x = 10^0 + 120^0 k$

យើងទាញបាន $x \in \{30^0, 130^0\}$

- បើ $x = -10^0 + 120^0 k$

យើងទាញបាន $x \in \{110^0\}$

•ចំពោះ $cos3x = -\frac{\sqrt{3}}{2} = cos150^0$

$\Leftrightarrow 3x = \pm 150^0 + 360^0 m$

$\Rightarrow x = \pm 50^0 + 120^0 m,\ (m \in \mathbb{Z})$

- បើ $x = 50^0 + 120^0 m$

យើងទាញបាន $x \in \{50^0, 170^0\}$

- បើ $x = -50^0 + 120^0 m$

យើងទាញបាន $x \in \{70^0\}$

ដូចនេះ តម្លៃ $x$ ដែលត្រូវរករួមមាន $\{10^0, 50^0, 110^0, 130^0, 170^0\}$

២. ស្រាយតាមវិចារកំណើនថាផលបូក $S_n = ne^{nx}$ ចំពោះគ្រប់ចំនួនគត់វិជ្ជមាន $n$

យើងមាន $S_n = \sum_{r=1}^{n} e^{rx}(r - re^{-x} + e^{-x})$ ចំពោះចំនួនពិត $x \neq 0$

- ចំពោះ $n = 1$ នោះ $S_1 = e^x(1 - e^{-x} + e^{-x}) = e^x = 1 \cdot e^{1 \cdot x}$ ពិត

- ចំពោះ $n = 2$ នោះ $S_2 = e^x(1 - e^{-x} + e^{-x}) + e^{2x}(2 - 2e^{-x} + e^{-x}) = e^x + 2e^{2x} - 2e^x + e^x = 2 \cdot e^{2 \cdot x}$ ពិត

- ឧបមាថាពិតរហូតដល់ $n = k$ គឺ $S_k = \sum_{r=1}^{k} e^{rx}(r - re^{-x} + e^{-x}) = k \cdot e^{kx}$

- សិក្សាករណី $n = k + 1$

$S_{k+1} = S_k + e^{(k+1)‘x}((k+1)‘ - (k+1)e^{-x} + e^{-x})$

$= ke^{kx} + (k+1)e^{(k+1)x} - (k+1)e^{kx} + e^{kx}$

$= (k+1)e^{(k+1)x}$ ពិត

៣. បង្ហាញថា $y - 1, y_2, y_3, ..., y_n$ ជាស្វ៊ីតនព្វន្តកើន

$x_1, x_2, x_3, ..., x_n$ ជាស្វ៊ីតធរណីមាត្រវិជ្ជមានកើន នោះគេទាញបាន $x_1 < x_2 < x_3 < ... < x_n$

ផលធៀបរួម $q = \frac{x_{n+1}}{x_n} > 1$

ស្វ៊ីត $y_1, y_2, y_3, ..., y_r$ កំណត់ដោយ $y_r = log x_r + 2000$ ចំពោះ $r = 1,2,3,...,n$

យើងពិនិត្យមើល $y_{r+1} - y_r = log x_{r+1} - log x_r = log\frac{x_{r+1}}{x_r} = log q$

$\Rightarrow y_1, y_2, y_3, ..., y_r$ ជាស្វ៊ីតនព្វន្តដែលមានផលសងរួម $d = log q \quad (1)$

តែ $q > 1$ នោះ $log q > log 1 = 0 \quad (2)$

តាម $(1)\&(2) \Rightarrow y_1, y_2, y_3, ..., y_r$ ជាស្វ៊ីតនព្វន្តកើន

II. ១. បន្ទាត់ $AB$ ស្របនឹងវ៉ិចទ័រ $2\vec{i} - 2\vec{j} + \vec{k}$ បន្ទាប់មកសរសេរសមីការបន្ទាត់ $AB$

វ៉ិចទ័រទីតាំងនៃចំណុច $A$ និង $B$ គឺ $\vec{a} = \vec{j} - 4\vec{k}$ និង $\vec{b} = 6\vec{i} - 5\vec{j} - \vec{k}$

យើងបាន $\overrightarrow{AB} = \vec{b} - \vec{a} = \left(6\vec{i} - 5\vec{j} - \vec{k}\right) - \left(\vec{j} - 4\vec{k}\right) = 6\vec{i} - 6\vec{j} + 3\vec{k}$

ផលធៀប $\frac{2}{6} = \frac{-2}{-6} = \frac{1}{3}$ នោះវ៉ិចទ័រ $\overrightarrow{AB}$ និងវ៉ិចទ័រ $2\vec{i} - 2\vec{j} + \vec{k}$ កូលីនេអ៊ែរ ។

តាង $K$ ជាចំណុចចល័តនៅលើបន្ទាត់ $(AB)$ ហើយមានវ៉ិចទ័រទីតាំង $\vec{k} = x\vec{i} + y\vec{j} + z\vec{k}$

យើងបាន $\vec{k} - \vec{a} = \lambda\begin{pmatrix}2\\-2\\1\end{pmatrix}, (\lambda \in \mathbb{R})$

$\Leftrightarrow \vec{k} = \vec{a} + \lambda\begin{pmatrix}2\\-2\\1\end{pmatrix} = \begin{pmatrix}0\\1\\-4\end{pmatrix} + \lambda\begin{pmatrix}2\\-2\\1)\end{pmatrix}, (\lambda \in \mathbb{R}$

ដូចនេះ សមីការបន្ទាត់ $AB$ គឺ $\vec{k} = \begin{pmatrix}0\\1\\-4\end{pmatrix} + \lambda\begin{pmatrix}2\\-2\\1\end{pmatrix}, (\lambda \in \mathbb{R})$

ឬ $AB : \begin{cases} x = 2\lambda \\ y = 1 - 2\lambda \\ z = -4 + \lambda \end{cases}, (\lambda \in \mathbb{R})$

២. បង្ហាញថា ត្រីកោណ $ABC$ ដូចរូប គេទាញបាន $\frac{a}{sinA} = \frac{b}{sinB} = \frac{c}{sinC}$

យើងមាន $\vec{a} + \vec{b} + \vec{c} = \vec{0} \quad (1)$

គុណ (1) ដោយវ៉ិចទ័រ $\vec{a}$

$\Rightarrow \vec{a} \times \vec{a} + \vec{a} \times \vec{b} + \vec{a} \times \vec{c} = \vec{0}$

ឬ $\vec{a} \times \vec{b} = \vec{c} \times \vec{a}$

គុណ (1) ដោយវ៉ិចទ័រ $\vec{c}$

នោះ $\vec{c}\times\vec{a}+\vec{c}\times\vec{b}+\vec{c}\times\vec{c}=\vec{0}$

ឬ $\vec{c}\times\vec{a}=\vec{b}\times\vec{c}$

យើងទាញបានថា $\vec{a}\times\vec{b}=\vec{b}\times\vec{c}=\vec{c}\times\vec{a}$

$\Rightarrow absinC=bcsinA=casinB$

$\Leftrightarrow \dfrac{a}{sinA}=\dfrac{b}{sinB}=\dfrac{c}{sinC}$ ពិត

គ. គណនា $det(B)$ និង $det\left(B^{-1}\right)$ រួចរកទំនាក់ទំនងរវាង $det(B)$ និង $det\left(B^{-1}\right)$

យើងមាន $B=\begin{bmatrix}1&1&0\\1&1&1\\0&2&1\end{bmatrix}$

យើងបាន $det(B)=(1+0+0)-(0+2+1)=-2$

យើងរកម៉ាទ្រីសប្រាស $B^{-1}$

តាម $B^{-1}=\dfrac{1}{det(B)}\cdot adj(B)=\dfrac{1}{det(B)}\cdot\left[B_{cof}\right]^T$

$C_{11}=(-1)^{1+1}\begin{vmatrix}1&1\\2&1\end{vmatrix}=-1$ $\qquad c_{12}=(-1)^{1+2}\begin{vmatrix}1&1\\0&1\end{vmatrix}=-1$

$C_{13}=(-1)^{1+3}\begin{vmatrix}1&1\\0&2\end{vmatrix}=2$ $\qquad C_{21}=(-1)^{2+1}\begin{vmatrix}1&0\\2&1\end{vmatrix}=-1$

$C_{22}=(-1)^{2+2}\begin{vmatrix}1&0\\0&1\end{vmatrix}=1$ $\qquad C_{23}=(-1)^{2+3}\begin{vmatrix}1&1\\0&2\end{vmatrix}=-2$

$C_{31}=(-1)^{3+1}\begin{vmatrix}1&0\\1&1\end{vmatrix}=1$ $\qquad C_{32}=(-1)^{3+2}\begin{vmatrix}1&0\\1&1\end{vmatrix}=-1$

$C_{33}=(-1)^{3+3}\begin{vmatrix}1&1\\1&1\end{vmatrix}=0$

នោះ $B^{-1}=\dfrac{1}{2}\begin{bmatrix}-1&-1&1\\-1&1&-1\\2&-2&0\end{bmatrix}=\begin{bmatrix}\frac{1}{2}&\frac{1}{2}&-\frac{1}{2}\\\frac{1}{2}&-\frac{1}{2}&\frac{1}{2}\\-1&1&0\end{bmatrix}$

នោះ $det\left(B^{-1}\right)=\begin{vmatrix}\frac{1}{2} & \frac{1}{2} & -\frac{1}{2}\\ \frac{1}{2} & -\frac{1}{2} & \frac{1}{2}\\ -1 & 1 & 0\end{vmatrix}=\left(0-\frac{1}{4}-\frac{1}{4}\right)-\left(-\frac{1}{4}+0+\frac{1}{4}\right)=-\frac{1}{2}$

ដោយ $det(B)=-2,\ det\left(B^{-1}\right)=-\frac{1}{2}$

ទំនាក់ទំនងគឺ $det\left(B^{-1}\right)=\frac{1}{det(B)}$

ឃ. បង្ហាញថា មុំរវាងប្លង់ $P_1,P_2$ ស្មើនឹងមុំដែលផ្គុំឡើងដោយ $\overrightarrow{n_1}$ និង $\overrightarrow{n_2}$ រួចទាញរករូបមន្តទូទៅសម្រាប់គណនាមុំរវាងប្លង់ពីរប្រសព្វគ្នា




តាងΔ ជាបន្ទាត់ប្រសព្វរវាងប្លង់ $P_1$ និង $P_2$ ហើយ $\alpha$ ជាមុំរវាងប្លង់ទាំងពីរ

តាមចំណុច $C\in\Delta$ សង់បន្ទាត់ $CB\subseteq P_1$ និង $CD\subseteq P_2$

បន្ទាត់កែងនឹង $P_1$ ត្រង់ $B$ និងបន្ទាត់កែងនឹង $P_2$ ត្រង់ $D$ កាត់គ្នាត្រង់ $A$

$\Rightarrow AB\parallel\overrightarrow{n_1}$ និង $AD\parallel\overrightarrow{n_2}$

គេបាន $\angle BAD$ និង $\angle BCD$ ជាមុំមានជ្រុងត្រូវគ្នាកែងរៀងគ្នា

$\Rightarrow \angle BAD$ និង $\angle BCD$ ជាមុំបន្ថែមគ្នាព្រោះមុំមួយជាមុំស្រួច និងមុំមួយទៀតជាមុំកែង

$\Rightarrow \angle BAD+\angle BCD=180^0$

តែ $\angle BCD+\alpha=180^0$

$\Rightarrow \angle BAD=\alpha$ មានន័យថាមុំរវាងបន្ទាត់ $AB$ និង $AD$ ស្មើនឹងមុំរវាងប្លង់ទាំងពីរ

ដូចនេះ មុំរវាងប្លង់ $P_1,P_2$ ស្មើនឹងមុំដែលផ្គុំឡើងដោយ $\overrightarrow{n_1}$ និង $\overrightarrow{n_2}$

តាង $\overrightarrow{n_1}=(a_1,b_1,c_1)$' និង $\overrightarrow{n_2}=(a_2,b_2,c_2)$
យើងបាន $\overrightarrow{n_1}\cdot\overrightarrow{n_2}=\left|\overrightarrow{n_1}\right|\cdot\left|\overrightarrow{n_2}\right|cos\alpha$
$\Rightarrow cos\alpha=\dfrac{\overrightarrow{n_1}\cdot\overrightarrow{n_2}}{\left|\overrightarrow{n_1}\right|\cdot\left|\overrightarrow{n_2}\right|}=\dfrac{a_1a_2+b_1b_2+c_1c_2}{\sqrt{a_1^2+b_1^2+c_1^2}\cdot\sqrt{a_2^2+b_2^2+c_2^2}}$
ដូចនេះ មុំរវាងប្លង់ពីរប្រសព្វគ្នាគឺ $\alpha=arccos\dfrac{a_1a_2+b_1b_2+c_1c_2}{\sqrt{a_1^2+b_1^2+c_1^2}\cdot\sqrt{a_2^2+b_2^2+c_2^2}}$

III. ១. បង្ហាញថា $2\sqrt{2}<\displaystyle\int_3^7\frac{dx}{\sqrt{lnx}}<4$
ចំពោះគ្រប់ $x\in[3,7]:\ 3\le x\le 7$
នោះ $e<x<e^2$
$\Leftrightarrow lne<lnx<lne^2$ ឬ $1<lnx<2$
$\Rightarrow \dfrac{1}{\sqrt{2}}<\dfrac{1}{\sqrt{lnx}}<1$
$\dfrac{\sqrt{2}}{2}\displaystyle\int_3^7 dx<\int_3^7\frac{dx}{\sqrt{lnx}}<\int_3^7 dx$
$\Leftrightarrow \dfrac{\sqrt{2}}{2}[x]_3^7<\displaystyle\int_3^7\frac{dx}{\sqrt{lnx}}<[x]_3^7$
$\Leftrightarrow \dfrac{\sqrt{2}}{2}(7-3)<\displaystyle\int_3^7\frac{dx}{\sqrt{lnx}}<(7-3)$
$\Leftrightarrow 2\sqrt{2}<\displaystyle\int_3^7\frac{dx}{\sqrt{lnx}}<4$ ពិត
២. ប្រើស៊េរី Maclaurine ស្រាយបញ្ជាក់ថា $e^{ix}=cosx+isinx$
តាមស៊េរី Maclaurine យើងមាន

$$e^{ix}=\left(1-\frac{x^2}{2!}+\frac{x^4}{4!}-\frac{x^6}{6!}+\cdots\right)+i\left(x-\frac{x^3}{3!}+\frac{x^5}{5!}-\frac{x^7}{7!}+\cdots\right)$$

$cosx=1-\dfrac{x^2}{2!}+\dfrac{x^4}{4!}-\dfrac{x^6}{6!}+\cdots$
$sinx=x-\dfrac{x^3}{3!}+\dfrac{x^5}{5!}-\dfrac{x^7}{7!}+\cdots$
$\Rightarrow cosx+isinx=\left(1-\dfrac{x^2}{2!}+\dfrac{x^4}{4!}-\dfrac{x^6}{6!}+\cdots\right)+i\left(x-\dfrac{x^3}{3!}+\dfrac{x^5}{5!}-\dfrac{x^7}{7!}+\cdots\right)$
$\Rightarrow cosx+isinx=e^{ix}$ ពិត

៣. សរសេរ $\dfrac{2x^2-x+4}{(1+x^2)(2-x)}$ ជារាង $\dfrac{Ax+B}{1+x^2}+\dfrac{C}{2-x}$ ដែល $A,B,C$ ជាចំនួនថេរ ហើយបន្ទាប់មកពន្លាត $\dfrac{2x^2-x+4}{(1+x^2)(2-x)}$ ជាដឺក្រេកើនរហូតដល់តួដែលមាន $x^3$

យើងបាន $\dfrac{2x^2-x+4}{(1+x^2)(2-x)}=\dfrac{Ax+B}{1+x^2}+\dfrac{C}{2-x}$

$\Leftrightarrow 2x^2-x+4=(2-x)(Ax+B)+C\left(1+x^2\right)$

$\Leftrightarrow 2x^2-x+4=(C-A)x^2+(2A-B)x+(2B+C)$

យើងទាញបាន $\begin{cases} C-A=2 \\ 2A-B=-1 \\ 2B+C=4 \end{cases}$

ដូចនេះ $A=0,B=1,C=2$

ចំពោះ $A=0,B=1,C=2$ យើងបាន $\dfrac{2x^2-x+4}{(1+x^2)(2-x)}=\dfrac{1}{1+x^2}+\dfrac{2}{2-x}$

តាមទ្វេធាញូតុន $(1+x)^n=1+nx+\dfrac{n(n-1)}{2!}x^2+\dfrac{n(n-1)(n-2)}{3!}x^3+\cdots$

ចំពោះ $|x|<1$

យើងបាន

$$\begin{aligned}\frac{1}{1+x^2}&=\left(1+x^2\right)^{-1}=1+(-1)x^2+\frac{(-1)(-1-1)}{2!}x^4\\&+\frac{(-1)(-1-1)(-1-2)}{3!}x^6+\cdots\\&=1-x^2+x^4-x^6+\cdots\end{aligned}$$

$$\begin{aligned}\frac{2}{2-x}&=\frac{2}{2\left(1-\frac{x}{2}\right)}=\left(1-\frac{x}{2}\right)^{-1}\\&=1+(-1)\left(-\frac{x}{2}\right)+\frac{(-1)(-1)}{2!}\left(-\frac{x}{2}\right)^2\\&+\frac{(-1)(-1-1)(-1-2)}{3!}\left(-\frac{x}{2}\right)^3+\cdots\\&=1+\frac{x}{2}+\frac{x^2}{4}+\frac{x^3}{8}+\cdots\end{aligned}$$

យើងបាន $\dfrac{2x^2-x+4}{(1+x^2)(2-x)}=(1+1)+\dfrac{x}{2}+\left(\dfrac{x^2}{4}-x^2\right)+\dfrac{x^3}{8}+\cdots$

ដូចនេះ $\frac{2x^2-x+4}{(1+x^2)(2-x)}=2+\frac{1}{2}x-\frac{3}{4}x^2+\frac{x^3}{8}+\cdots$ ដែល $|x|<1$

របៀបទី២:

តាមរូបមន្តផលបូកស៊េរីធរណីមាត្រ $1+r+r^2+\cdots=\frac{1}{1-r}$ ចំពោះ $|r|<1$

នោះ $a+ar+ar^2+\cdots=\frac{a}{1-r}$

យើងបាន $\frac{1}{1+x^2}=\frac{1}{1-(-x^2)}=1+(-x^2)+(-x^2)^2+(-x^2)^3+\cdots=1-x^2+x^4-x^6+\cdots$

និង $\frac{2}{2-x}=\frac{1}{1-\frac{x}{2}}=1+\frac{x}{2}+\left(\frac{x}{2}\right)^2+\left(\frac{x}{2}\right)^3+\cdots=1+\frac{x}{2}+\frac{x^2}{4}+\frac{x^3}{8}+\cdots$

ដែល $|x^2|<1$ និង $\left|\frac{x}{2}\right|<1 \Leftrightarrow |x|<1$

ដូចនេះ $\frac{2x^2-x+4}{(1+x^2)(2-x)}=2+\frac{1}{2}x-\frac{3}{4}x^2+\frac{x^3}{8}+\cdots$ ដែល $|x|<1$

IV. ១. រកតម្លៃ $a$ និង $b$

យើងមាន $\sum P(X=x)=0.2+a+0.1+b+0.4=1 \Rightarrow a+b=0.3 \quad (1)$

$E(X)=(-2)(0.2)+(-1)(a)+(0)(0.1)+(1)(b)+(2)(0.4)=0.1$

$\Rightarrow a-b=0.3 \quad (2)$

តាម (1) និង (2) យើងបាន

$$\begin{cases} a+b=0.3 \\ a-b=0.3 \end{cases}$$

ដូចនេះ $a=0.3, b=0$

២. បង្ហាញថា $a+b=-6$

តាង $P(x)=2x^3+ax^2+bx+c$

$P(x)$ ចែកនឹង $x+1, x-2$ បានសំណល់ដូចគ្នា

តាមទ្រឹស្តីបទសំណល់ យើងបាន $P(-1)=P(2)$

ឬ $-2+a-b+c=16+4a+2b+c$

$\Rightarrow a+b=-6$ ពិត

៣. ដោះស្រាយសមីការឌីផេរ៉ង់ស្យែល $yy'+y^2=x$

សមីការអាចសរសេរទៅជា $(y^2)'+2y^2=2x$

តាង $m=y^2$ នោះ $m'+2m=2x$ ជាសមីការឌីផេរ៉ង់ស្យែលលំដាប់ទី១ មានមេគុណ

ថេរមិនអូម៉ូសែន
កត្តាអាំងតេក្រាល $IF = e^{\int 2dx} = e^{2x}$
យើងបាន $e^{2x}m' + 2me^{2x} = 2xe^{2x}$
$\Rightarrow \left(me^{2x}\right)' = 2xe^{2x}$
$\Leftrightarrow me^{2x} = \left(x - \dfrac{1}{2}\right)e^{2x} + t,\ t \in \mathbb{R}$
$\Leftrightarrow m = x - \dfrac{1}{2} + te^{-2x}$
$\Rightarrow y^2 = x - \dfrac{1}{2} + te^{-2x}$
ដូចនេះ សមីការឌីផេរ៉ង់ស្យែលមានចម្លើយ $y^2 = x - \dfrac{1}{2} + te^{-2x},\ t \in \mathbb{R}$

## ប្រលងជ្រើសរើសសិស្សពូកែវិទ្យាល័យព្រះស៊ីសុវត្ថិ
## សម្រាប់ឆ្នាំសិក្សា ២០១៩-២០២០
## វិញ្ញាសា : គណិតវិទ្យា រយ:ពេល ៣ ម៉ោង

I. គេឱ្យស្ទីត $(u_n)$ កំណត់ដោយ $u_n = e^n + e^{-n}$ ។ គណនា $\sum_{k=0}^{2020} u_k$ ។

II. គេឱ្យអនុគមន៍ $f(x) = x^x$ ។ គណនា $f'(x)$ ។

III. គេមានសមីការដឺក្រេទី២ $2x^2 + 2x + cos\alpha = 0\ (0 < \alpha < \pi)$ ។
ក ) កំណត់តម្លៃ $\alpha$ ដែលធ្វើឱ្យសមីការមានឫស ។
ខ ) គណនាតម្លៃ $\alpha$ ដែលផ្ទៀងផ្ទាត់កន្សោម $\dfrac{1}{x_1} + \dfrac{1}{x_2} = \dfrac{4}{\sqrt{3}}$ រួចទាញបង្ហាញថា $x_1^2 + x_2^2 < 1.9$ ។

IV. $a, b, c$ ជារង្វាស់ជ្រុងនៃត្រីកោណ $ABC$ ។ បង្ហាញថា $\dfrac{sin(B-C)}{sin(B+C)} = \dfrac{b^2 - c^2}{a^2}$ ។

V. គេមានស្ទីត $(u)$ កំណត់ដោយ $u_0 = a, \ldots, u_{n+1} = \dfrac{665}{666}u_n + 3$ ដែល $a \in \mathbb{R}$ និង $n \in \mathbb{N}$ ។
ក ) តើ $a$ មានតម្លៃស្មើប៉ុន្មានទើបស្ទីត $(u)$ ជាស្ទីតថេរ ?
ខ ) ករណី $(u)$ មិនមែនជាស្ទីតថេរ គេពិនិត្យស្ទីត $(v)$ កំណត់ដោយ $v_n = u_n - 1998$ ។

១. បង្ហាញថា $(v)$ ជាស្វ៊ីតធរណីមាត្រ រួចគណនាតួ $v_0$ និងរេសុងវា។
២. គណនាជាអនុគមន៍នៃ $n$ និង $a$ តួទូទៅ $u_n$ នៃស្វ៊ីត $(u)$ និងផលបូក $S_n = u_0+u_1+u_2+\cdots+u_n$ ។

VI. $ABCDA'B'C'D'$ ជាគូបដែលជ្រុងមានប្រវែងស្មើ 1។
ក) $\left(A,\overrightarrow{AB},\overrightarrow{AD},\overrightarrow{AA'}\right)$ ជាតម្រុយអរតូណរម៉ាល់មានទិសដៅវិជ្ជមាន។ ចូរកំណត់កូអរដោនេកំពូលទាំងអស់នៃគូប។
ខ) គណនារង្វាស់មុំផ្ចិតដោយបន្ទាត់ $AC'$ និង $A'B$។
គ) តាង $M,N,P$ ជាចំណុចកណ្ដាលរៀងគ្នានៃអង្កត់ $[A'B']$;$[BC]$;$[DD']$។ កំណត់សមីការប្លង់ $(MNP)$ រួចគណនាចម្ងាយពី $A$ ទៅប្លង់ $(MNP)$។
ឃ) កំណត់សមីការស្វ៊ែរចារឹកក្នុង និងក្រៅគូប $ABCDA'B'C'D'$។

VII. គណនា $S=\dfrac{3^2+1}{3^2-1}+\dfrac{5^2+1}{5^2-1}+\dfrac{7^2+1}{7^2-1}+\cdots+\dfrac{999^2+1}{999^2-1}$។

## ដំណោះស្រាយ

I. គណនា $\sum\limits_{k=0}^{2020} u_k$

$$\begin{aligned}\sum_{k=0}^{2020}\left(e^k+e^{-k}\right) &= \sum_{k=0}^{2020} e^k+\sum_{k=0}^{2020} e^{-k}\\ &=\left(1+e+e^2+\cdots+e^{2020}\right)+\left(1+e^{-1}+e^{-2}+\cdots+e^{-2020}\right)\\ &=\left(\frac{e^{2021}-1}{e-1}\right)+\left(\frac{e^{-2021}-1}{e-1}\right)\\ &=\frac{e^{2021}-1}{e-1}+\frac{e\left(e^{-2021}-1\right)}{e-1}\\ &=\frac{1}{e-1}\left(e^{2021}-e^{-2020}+e-1\right)\end{aligned}$$

II. គណនា $f'(x)$
យើងមាន $f(x)=x^x$
$lnf(x)=lnx^x$ ឬ $lnf(x)=xlnx$
យើងបាន $[lnf(x)]'=[xlnx]'$
$\Leftrightarrow \dfrac{f'(x)}{f(x)}=(x)'lnx+(lnx)'\cdot x$

$\Leftrightarrow \dfrac{f'(x)}{f(x)} = lnx + 1$

នោះ $f'(x) = f(x)(lnx + 1)$

ដូចនេះ $f'(x) = x^x(lnx + 1)$

III. ក ) កំណត់តម្លៃ $\alpha$ ដែលធ្វើឱ្យសមីការមានឫស

សមីការ $2x^2 + 2x + cos\alpha = 0$

$\Delta' = 1 - 2cos\alpha$

សមីការមានឫសកាលណា $\Delta' \geq 0$

$\Leftrightarrow 1 - 2cos\alpha \geq 0$

$\Leftrightarrow \alpha \in \left[\dfrac{\pi}{3}, \pi\right[$

ខ ) គណនាតម្លៃ $\alpha$

គេមានកន្សោម $\dfrac{1}{x_1} + \dfrac{1}{x_2} = \dfrac{4}{\sqrt{3}}$

$\Leftrightarrow \dfrac{x_1 + x_2}{x_1 x_2} = \dfrac{4}{\sqrt{3}}$

$\Leftrightarrow \dfrac{-1}{\dfrac{cos\alpha}{2}} = \dfrac{4}{\sqrt{3}}$

$\Rightarrow cos\alpha = -\dfrac{\sqrt{3}}{2} \ \Rightarrow \alpha = \dfrac{5\pi}{6}$

ដូចនេះ $\alpha = \dfrac{5\pi}{6}$

បង្ហាញថា $x_1^2 + x_2^2 < 1.9$

$x_1^2 + x_2^2 = (x_1 + x_2)^2 - 2x_1x_2$

$= (-1)^2 - 2 \cdot \dfrac{cos\alpha}{2}$

$= 1 - 2cos\alpha = 1 + \dfrac{\sqrt{3}}{2} < 1.9$

ដូចនេះ $x_1^2 + x_2^2 < 1.9$

IV. បង្ហាញថា $\dfrac{sin(B-C)}{sin(B+C)} = \dfrac{b^2 - c^2}{a^2}$

យើងបាន $\dfrac{sin(B-C)}{sin(B+C)} = \dfrac{sinBcosC - sinCcosB}{sinBcosC + sinCcosB}$

ដោយ $\dfrac{a}{sinA} = \dfrac{b}{sinB} = \dfrac{c}{sinC} = k$

$$\Rightarrow \begin{cases} sinB = \dfrac{b}{k} \\ sinC = \dfrac{c}{k} \end{cases}$$

$cosB = \dfrac{a^2+c^2-b^2}{2ac}$ និង $cosC = \dfrac{a^2+b^2-c^2}{2ab}$

$$\frac{sin(B-C)}{sin(B+C)} = \frac{\frac{b}{k}\left(\frac{a^2+b^2-c^2}{2ab}\right) - \frac{c}{k}\left(\frac{a^2+c^2-b^2}{2ac}\right)}{\frac{b}{k}\left(\frac{a^2+b^2-c^2}{2ab}\right) + \frac{c}{k}\left(\frac{a^2+c^2-b^2}{2ac}\right)}$$

$$= \frac{a^2+b^2-c^2-a^2-c^2+b^2}{a^2+b^2-c^2+a^2+c^2-b^2}$$

$= \dfrac{b^2-c^2}{a^2}$ ពិត

V. ក ) កមណត់តម្លៃ $a$ ដើម្បីឱ្យ $(u)$ ជាស្វីតថេរ

$(u)$ ជាស្វីតថេរ នោះ $u_0 = a = u_1 = u_2 = ... = u_n = u_{n+1} = ... = a$

$\Rightarrow a = \dfrac{665}{666}a + 3$

$\Rightarrow a - \dfrac{665}{666}a = 3$

$\Leftrightarrow \dfrac{1}{666}a = 3 \Rightarrow a = 1998$

ដូចនេះ $a = 1998$

ខ ) ១. បង្ហាញថា $(v)$ ជាស្វីតធរណីមាត្រ

យើងមាន $v_n = u_n - 1998$ នោះ $v_{n+1} = u_{n+1} - 1998$

$\Rightarrow v_{n+1} = \left(\dfrac{665}{666}u_n + 3\right) - 1998$

$\Rightarrow v_{n+1} = \dfrac{665}{666}u_n - 1995$

តែ $v_n = u_n - 1998$ នោះ $u_n = v_n + 1998$

យើងបាន $v_{n+1} = \dfrac{665}{666}(v_n + 1998) - 1995$

$\Rightarrow \dfrac{v_{n+1}}{v_n} = \dfrac{665}{666}$ ថេរ

នោះ $(v_n)$ ជាស្វីតធរណីមាត្រដែលមានរេសុង $q = \dfrac{665}{666}$ និង $v_0 = u_0 - 1998 = a - 1998$

២. គណនាជាអនុគមន៍នៃ $n$ និង $a$ តួទូទៅ $u_n$ នៃស្វ៊ីត $(u)$ និងផលបូក

$S_n = u_0 + u_1 + u_2 + \cdots + u_n$

យើងមាន $u_n = v_n + 1998$

តែ $v_n = v_0 \times q^n = (a-1998)\left(\frac{665}{666}\right)^n$

នោះ $u_n = (a-1998)\left(\frac{665}{666}\right)^n + 1998$

ដូចនេះ $u_n = (a-1998)\left(\frac{665}{666}\right)^n + 1998$

យើងបាន $S_n = u_0 + u_1 + u_2 + \cdots + u_n = \sum_{k=0}^{n} u_k$

$$S_n = \sum_{k=0}^{n}\left[(a-1998)\left(\frac{665}{666}\right)^n + 1998\right]$$

$$S_n = (a-1998)\left(\frac{665}{666}\right)^0 + 1998 + (a-1998)\left(\frac{665}{666}\right)^1$$

$$+1998 + (a-1998)\left(\frac{665}{666}\right)^2 + 1998 + (a-1998)\left(\frac{665}{666}\right)^n + 1998$$

$$= (a-1998)\left[\left(\frac{665}{666}\right)^0 + \left(\frac{665}{666}\right)^1 + \left(\frac{665}{666}\right)^2 + \cdots + \left(\frac{665}{666}\right)^n\right]$$

$$+(n+1)\cdot 1998$$

$$= (a-1998)\frac{1-\left(\frac{665}{666}\right)^{n+1}}{1-\frac{665}{666}} + (n+1)\cdot 1998$$

$$= 666(a-1998)\left[1-\left(\frac{665}{666}\right)^{n+1}\right] + (n+1)\cdot 1998$$

VI. ក ) កំណត់កូអរដោនេកំពូលទាំងអស់នៃគូប

$A(0,0,0); B(1,0,0); C(1,1,0); D(0,1,0)$

$A'(0,0,1); B'(1,0,1); C'(1,1,1); D'(0,1,1)$

ខ ) គណនាវង្វាស់មុំ

$\overrightarrow{AC'} = (1,1,1);\ \overrightarrow{A'B} = (1,0,-1)$

$\overrightarrow{AC'} \cdot \overrightarrow{A'B} = 0$ នោះ $\overrightarrow{AC'} \perp \overrightarrow{A'B}$

ដូចនេះ $\left(\widehat{\overrightarrow{AC'},\overrightarrow{A'B}}\right)=90^0$




គ ) កំណត់សមីការប្លង់ $(MNP)$

$M,N,P$ ជាចំណុចកណ្ដាលរៀងគ្នានៃអង្កត់ $[A'B'];[BC];[DD']$

នោះ $M\left(\frac{1}{2},0,1\right);N\left(1,\frac{1}{2},0\right);P\left(0,1,\frac{1}{2}\right)$

$\overrightarrow{MN}=\left(\frac{1}{2},\frac{1}{2},-1\right)$; $\overrightarrow{MP}=\left(-\frac{1}{2},1,-\frac{1}{2}\right)$

$$\overrightarrow{MN}\times\overrightarrow{MP}=\begin{vmatrix}\vec{i} & \vec{j} & \vec{k}\\ \frac{1}{2} & \frac{1}{2} & -1\\ -\frac{1}{2} & 1 & -\frac{1}{2}\end{vmatrix}=\begin{vmatrix}\frac{1}{2} & -1\\ 1 & -\frac{1}{2}\end{vmatrix}\vec{i}-\begin{vmatrix}\frac{1}{2} & -1\\ -\frac{1}{2} & -\frac{1}{2}\end{vmatrix}\vec{j}+\begin{vmatrix}\frac{1}{2} & \frac{1}{2}\\ -\frac{1}{2} & 1\end{vmatrix}\vec{k}$$

$$=\frac{3}{4}\vec{i}+\frac{3}{4}\vec{j}+\frac{3}{4}\vec{k}$$

យើងបាន $(MNP):\ \frac{3}{4}\left(x-\frac{1}{2}\right)+\frac{3}{4}(y-0)+\frac{3}{4}(z-1)=0$

ដូចនេះ សមីការប្លង់ $(MNP):\ 6x+6y+6z-9=0$

គណនាចម្ងាយពីចំណុច $A$ ទៅប្លង់ $(MNP)$

$d(A,(MNP))=\frac{|0+0+0-9|}{\sqrt{36+36+36}}=\frac{\sqrt{3}}{2}$ ឯកតាប្រវែង

ឃ ) សរសេរសមីការស្វ៊ែរ

ស្វ៊ែរចារឹកក្នុងគូប

$$\left(x-\frac{1}{2}\right)^2+\left(y-\frac{1}{2}\right)^2+\left(z-\frac{1}{2}\right)^2=\left(\frac{1}{2}\right)^2$$

ស្វ៊ែរចារឹកក្នុងគូប

$$\left(x-\frac{1}{2}\right)^2+\left(y-\frac{1}{2}\right)^2+\left(z-\frac{1}{2}\right)^2=\left(\frac{\sqrt{3}}{2}\right)^2$$

VII. គណនា $S=\frac{3^2+1}{3^2-1}+\frac{5^2+1}{5^2-1}+\frac{7^2+1}{7^2-1}+\cdots+\frac{999^2+1}{999^2-1}$

យើងបាន $S=\frac{3^2-1+2}{3^2-1}+\frac{5^2-1+2}{5^2-1}+\frac{7^2-1+2}{7^2-1}+\cdots+\frac{999^2-1+2}{999^2-1}$

$$S=\left(1+\frac{2}{3^2-1}\right)+\left(1+\frac{2}{5^2-1}\right)+\left(1+\frac{2}{7^2-1}\right)+\cdots+\left(1+\frac{2}{999^2-1}\right)$$

$$S\ =\ 499+\left(\frac{1}{3-1}-\frac{1}{3+1}\right)+\left(\frac{1}{5-1}-\frac{1}{5+1}\right)+\left(\frac{1}{7-1}-\frac{1}{7+1}\right)+\cdots+$$

$$\left(\frac{1}{999-1}-\frac{1}{999+1}\right)$$

$$S=499+\frac{1}{2}-\frac{1}{1000}$$

$$S=499+\frac{499}{1000}$$

ដូចនេះ $S=499\times\frac{1001}{1000}$

# ចំណេះដឹងបន្ថែម

■ **ទ្រឹស្តីបទតម្លៃមធ្យម** : បើ $F(x)$ ជាប់គ្រប់ $x\in[a,b]$ និង $F'(x)$ កើតមានចំពោះគ្រប់ $x\in(a,b)$ នោះមានយ៉ាងហោចណាស់ចំនួន $z$ មួយដែល $\dfrac{F(b)-F(a)}{b-a}=F'(z)$ ។

■ **ទ្រឹស្តីបទ** : The Chain Rule : បើ $f(u)$ និង $g(x)$ មានដេរីវេ នោះ $F(x)=f[g(x)]$ មានដេរីវេ និង $F'(x)=f'(u).g'(x)$ ដែល $u=g(x)$ ។

■ **ទ្រឹស្តីបទរ៉ូល** : ឧបមាថា $f$ មានដេរីវេលើចន្លោះបើក $(a,b)$ និងជាប់លើចន្លោះបិទ $[a,b]$ ។ បើ $f(a)$ និង $f(b)$ មានតម្លៃសូន្យទាំងពីរ នោះមានយ៉ាងហោចចំនួន $c$ មួយនៅចន្លោះ $(a,b)$ ដែល $f'(c)=0$ ។

## ■ អនុគមន៍កើន និង អនុគមន៍ចុះ

*និយមន័យ*

គេថាអនុគមន៍ $f$

i. កើននៅលើចន្លោះ $I$ ប្រសិនបើចំពោះពីរចំនួន $x_1$ និង $x_2$ នៅចន្លោះ $I$

$x_1<x_2$ នាំអោយ $f(x_1)<f(x_2)$

ii. ចុះនៅលើចន្លោះ $I$ ប្រសិនបើចំពោះពីរចំនួន $x_1$ និង $x_2$ នៅចន្លោះ $I$

$x_1<x_2$ នាំអោយ $f(x_1)>f(x_2)$

### ទ្រឹស្តីបទ

ឧបមាថា $f$ មានដេរីវេនៅលើចន្លោះបើ $I$

i បើ $f'(x)>0$ ចំពោះគ្រប់ $x$ នៅចន្លោះ $I$ នោះ $f$ ជាអនុគមន៍កើននៅចន្លោះ $I$

ii បើ $f'(x)<0$ ចំពោះគ្រប់ $x$ នៅចន្លោះ $I$ នោះ $f$ ជាអនុគមន៍ចុះនៅចន្លោះ $I$

iii បើ $f'(x)=0$ ចំពោះគ្រប់ $x$ នៅចន្លោះ $I$ នោះ $f$ ជាអនុគមន៍ថេរនៅចន្លោះ $I$

## ■ ទំនាក់ទំនងរវាងឫស និង មេគុណ

1. បើ $\alpha,\beta$ ជាឫសនៃសមីការដឺក្រេទីពីរ $ax^2+bx+c=0$ នោះ

- $\alpha+\beta=-\dfrac{b}{a}$
- $\alpha\beta=\dfrac{c}{a}$
- $|\alpha-\beta|=\dfrac{\sqrt{D}}{|a|}$ ដែល $D=\Delta=b^2-4ac$

2. បើ $\alpha,\beta,\gamma$ ជាឫសនៃសមីការដឺក្រេទី៣ $ax^3+bx^2+cx+d=0$ នោះ

- $\alpha+\beta+\gamma=-\dfrac{b}{a}$
- $\alpha\beta+\beta\gamma+\gamma\alpha=\dfrac{c}{a}$
- $\alpha\beta\gamma=-\dfrac{d}{a}$

3. បើ $\alpha,\beta,\gamma,\delta$ ជាឫសនៃសមីការដឺក្រេទីបួន $ax^4+bx^3+cx^2+dx+e=0$ នោះ

- $\alpha+\beta+\gamma+\delta=-\dfrac{b}{a}$
- $\alpha\beta+\beta\gamma+\gamma\delta+\delta\alpha=\dfrac{c}{a}$
- $\alpha\beta\gamma+\beta\gamma\delta+\gamma\delta\alpha+\delta\alpha\beta=-\dfrac{d}{a}$
- $\alpha\beta\gamma\delta=\dfrac{e}{a}$

4. ជាទូទៅ បើសមីការពហុធា $a_0x^n+a_1x^{n-1}+a_2x^{n-2}+a_3x^{n-3+}\cdots+a_n=0$ មាន $n$ ឫសតាងដោយ $\alpha_1,\alpha_2,\alpha_3,\ldots,\alpha_n$ នោះ

- $\sum\alpha_1=-\dfrac{a_1}{a_0}$
- $\sum\alpha_1\alpha_2=\dfrac{a_2}{a_0}$
- $\sum\alpha_1\alpha_2\alpha_3=-\dfrac{a_3}{a_0}$

$$\vdots \qquad \vdots$$

- $\alpha_1\alpha_2\alpha_3\ldots\alpha_n=(-1)^n\dfrac{a_n}{a_0}$

## ■ ច្បាប់សញ្ញារបស់ដេកាត Descarte's Rule of sign:

1. ចំនួនឫសវិជ្ជមានច្រើនបំផុតនៃសមីការពហុធា $f(x)=0$ គឺជាចំនួនដងនៃបម្រែបម្រួលសញ្ញានៃមេគុណពី $(+)$ ទៅ $(-)$ និង ពី $(-)$ ទៅ $(+)$ ។
ឧទាហរណ៍ ៖ $x^3+3x^2+7x-11=0$ មានសញ្ញានៃមេគុណគឺ$(+++-)$ ។ ដោយការប្រែ ប្រួលសញ្ញាមានតែម្តងគត់ នោះចំនួនឫសវិជ្ជមាន មានច្រើនបំផុតគឺមួយ ។

2. ចំនួនឫសអវិជ្ជមានច្រើនបំផុតនៃសមីការពហុធា $f(x)=0$ គឺជាចំនួនដងនៃបម្រែបម្រួល សញ្ញានៃមេគុណពី $(+)$ ទៅ $(-)$ និង ពី $(-)$ ទៅ $(+)$ នៅក្នុងសមីការ $f(-x)=0$ ។

## ■ ការអនុវត្ត Calculus ទៅក្នុងសមីការពហុធា

1. បើសមីការពហុធា $f(x)=0$ មានឫសពិតចំនួន $n$ នោះសមីការ $f'(x)=0$ មានឫសពិតចំនួន $(n-1)$, $f''(x)$ មានឫសពិតចំនួន $(n-2),\ldots$, តែចម្រាសមកវិញអាចពិត ឬ មិនពិត ។
2. បើមានចំនួនពិតពីរ $a$ និង $b$ ដែល $f(a)$ និង $f(b)$ មានសញ្ញាផ្ទុយគ្នា នោះសមីការ $f(x)=0$ ត្រូវតែមានឫសពិតយ៉ាងហោចណាស់មួយ ឬមានឫសពិត ចំនួនសេសឫសស្ថិតនៅចន្លោះ $a$ និង $b$ ។
3. បើ $f(a)$ និង $f(b)$ មានសញ្ញាដូចគ្នា នោះអាចគ្មាន ឬមានឫស ចំនួនគូឫសនៃសមីការ $f(x)=$ ស្ថិតនៅចន្លោះ $a$ និង$b$ ។
4. បើ $f(a)=f(b)$ នោះនិងមានឫសពិតយ៉ាងហោចមួយនៃសមីការ $f(x)=0$ ស្ថិតនៅចន្លោះ $a$ និង $b$ ។
5. បើ $\alpha$ ជាឫសឌុបនៃសមីការ $f(x)=0$ នោះ $\alpha$ ក៏ជាឫសនៃសមីការ $f'(x)=0$ ។
6. បើ $\alpha$ ជាឫសរួមនៃសមីការ $f(x)=0$ និង $g(x)=0$ នោះ $\alpha$ ក៏ជាឫសរួមនៃសមីការ $f'(x)=0$ និង $g'(x)=0$ ។

## ■ វិសមភាព

1. លក្ខណៈគ្រឹះនៃវិសមភាព
   - បើ $a>b,\ b>c$ នោះ $a>c$
   - បើ $a>b$ នោះ $a+m>b+m$
   - បើ $a>b$ នោះ $am>bm$ បើ $m>0$ ហើយ $am<bm$ បើ $m<0$
   - បើ $a>b>0$ នោះ $\dfrac{1}{a}<\dfrac{1}{b}$
   - បើ $a_1>b_1, a_2>b_2,\ldots,a_n>b_n$ នោះ $a_1+a_2+\cdots+a_n>b_1+b_2+\cdots+b_n$ ចំពោះគ្រប់ចំនួនវិជ្ជមាន $a$ និង$b$

- បើ $a_1 > b_1, a_2 > b_2, ..., a_n > b_n$ នោះ $a_1a_2...a_n > b_1b_2...b_n$ ចំពោះគ្រប់ចំនួនវិជ្ជមាន $a$ និង$b$ ។
- បើ $a > b > 0$ និង $n > 0$ នោះ $a^n > b^n$ និង $a^{1/n} > b^{1/n}$ ( ព្រោះ $n$ វិជ្ជមាន នោះ $\frac{1}{n}$ វិជ្ជមាន )
- បើ $a > b > 0$ និង $x > 0$ នោះ $a^x > b^x$
- បើ $x > y > 0$ និង $a > 1$ នោះ $a^x > a^y$
- បើ $x > y > 0$ និង $0 < a < 1$ នោះ $a^x < a^y$
- បើ $x > y > 0$ និង $a > 1$ នោះ $log_a x > log_a y$
- បើ $x > y > 0$ និង $0 < a < 1$ នោះ $log_a x < log_a y$

2. បើ $a, b, x$ ជាចំនួនវិជ្ជមាន នោះ $\begin{cases} \frac{a+x}{b+x} > \frac{a}{b} & \text{បើ } a > b \\ \frac{a+x}{b+x} < \frac{a}{b} & \text{បើ } a < b \end{cases}$

3. បើ $a, b > 0$ និង $a \neq b$ នោះមធ្យមនព្វន្តនៃ $a$ និង $b$ ធំជាងមធ្យមធរណីមាត្រនៃ $a$ និង $b$ , i.e.,
$\left(\frac{a+b}{2}\right) > \sqrt{ab}$ ។

4. បើ $a_i$, $i = 1, 2, 3, ..., n$ ដែលមិនដូចគ្នាទាំងអស់នោះមធ្យមនព្វន្តនៃបរិមាណ $n$ ធំជាងមធ្យមធរណីមាត្រនៃបរិមាណ $n$, i.e,
$\frac{a_1 + a_2 + \cdots + a_n}{n} > (a_1a_2...a_n)^{1/n}$ ។
សំគាល់ ក្នុងពេលដែល $a_1 = a_2 = ... = a_n$ i.e, ចំនួនទាំងអស់ស្មើគ្នា នោះមធ្យមនព្វន្តនៃបរិមាណ $n$=មធ្យមធរណីមាត្រនៃបរិមាណ $n$ ។

5. បើ $a > b > 0$ និង $a \neq b$ នោះ
   - $\frac{a^m + b^m}{2} > \left(\frac{a+b}{2}\right)^m$ បើ $m < 0$ ឬ $m > 1$
   - $\frac{a^m + b^m}{2} < \left(\frac{a+b}{2}\right)^m$ បើ $0 < m < 1$

   កត់សំគាល់ បើ $a$ និង $b$ ស្មើគ្នា នោះយើងអាចប្រើសញ្ញាស្មើ ។

6. បើ $a_i > 0$, $i = 1, 2, 3, .., n$ និង $m_1, m_2, ..., m_n$ ជាចំនួនសនិទានវិជ្ជមាន នោះ

- $\dfrac{a_1^m+a_2^m+\cdots+a_n^m}{n}>\left(\dfrac{a_1+a_2+\cdots+a_n}{n}\right)^m$ បើ $m<0$ ឬ $m>1$
- $\dfrac{a_1^m+a_2^m+\cdots+a_n^m}{n}<\left(\dfrac{a_1+a_2+\cdots+a_n}{n}\right)^m$ បើ $0<m<1$

7. Weighted-Mean

- $a_i>0,\ i=1,2,3,\ldots,n$ និង $m_1,m_2,\ldots,m_n$ ជាចំនួនសនិទានវិជ្ជមាន នោះ
$\left(\dfrac{m_1a_1+m_2a_2+\cdots+m_na_n}{m_1+m_2+\cdots+m_n}\right)\geq\left(a_1^{m_1}a_2^{m_2}\ldots a_n^{m_n}\right)^{1/(m_1+m_2+\cdots+m_n)}$
សមភាពកើតមានចំពោះ $a_1=a_2=\ldots=a_n$
- $a_1,a_2,\ldots,a_n$ និង $b_1,b_2,\ldots,b_n$ ជាពីរសំណុំនៃចំនួនសនិទាន ហើយចំនួនទាំងឡាយនៅក្នុងសំណុំទី១ មិនស្មើនឹងចំនួនណាមួយផ្សេងទៀតឡើយ នោះចំពោះគ្រប់ចំនួនសនិទាន $m$
$\dfrac{b_1a_1^m+b_2a_2^m+\cdots+b_na_n^m}{b_1+b_2+\cdots+b_n}\lesseqgtr\left(\dfrac{b_1a_1+b_2a_2+\cdots+b_na_n}{b_1+b_2+\cdots+b_n}\right)^m$
អាស្រ័យលើ $m$ ស្ថិតនៅ ឬ មិនស្ថិតនៅចន្លោះ 0 និង 1 ។

8. Cauchy-Schwarz Inequality
$a_1,a_2,\ldots,a_n$ និង $b_1,b_2,\ldots,b_n$ ជាចំនួនពិត នោះ
$(a_1b_1+a_2b_2+\cdots+a_nb_n)^2\leq\left(a_1^2+a_2^2+\cdots+a_n^2\right)\left(b_1^2+b_2^2+\cdots+b_n^2\right)$ ។
សមភាពកើតមានកាលណា $\dfrac{a_1}{b_1}=\dfrac{a_2}{b_2}=\ldots=\dfrac{a_n}{b_n}$ ។

9. Tchebychef's Inequality
$a_1,a_2,\ldots,a_n$ និង $b_1,b_2,..,b_n$ ជាចំនួនពិត ។

- បើ $a_1\leq a_2\leq\ldots\leq a_n$ និង $b_1\leq b_2\leq\ldots\leq b_n$ នោះ
$(a_1+a_2+\cdots+a_n)(b_1+b_2+\cdots+b_n)\leq n(a_1b_1+a_2b_2+\cdots+a_nb_n)$
- បើ $a_1\leq a_2\leq\ldots\leq a_n$ និង $b_1\geq b_2\geq\ldots\geq b_n$ នោះ
$(a_1+a_2+\cdots+a_n)(b_1+b_2+\cdots+b_n)\geq n(a_1b_1+a_2b_2+\cdots+a_nb_n)$

10. Weierstress's Inequality
បើ $a_1,a_2,\ldots,a_n$ ជាចំនួនវិជ្ជមានតូចជាងឯកតា និង $s_n=a_1+a_2+\cdots+a_n$ នោះ
$(1-s_n)<(1-a_1)(1-a_2)\ldots(1-a_n)<\dfrac{1}{1+s_n}$
និង $(1+s_n)<(1+a_1)(1+a_2)\ldots(1+a_n)<\dfrac{1}{1-s_n}$

11. Holder's Inequality

សំណើ ១១.១ បើ $a$ និង $b$ ជាចំនួនពិតវិជ្ជមាន និង $p,q$ ជាចំនួនពិតផ្ទៀងផ្ទាត់ $p,q>1$ ហើយ $\frac{1}{p}+\frac{1}{q}=1$ នោះ $ab\leq\frac{a^p}{p}+\frac{b^q}{q}$ ។

សម្រាយបញ្ជាក់

តាង $f:\mathbb{R}\to\mathbb{R}_{>}0$ ជាអនុគមន៍អ៊ិចស្ប៉ូណង់ស្យែល $f(x)=e^x$ ចំពោះ $x\in\mathbb{R}$

យើងបាន $f''(x)=e^x>0$ នោះ $f$ ជាអនុគមន៍ផត i.e., ចំពោះគ្រប់ $t\in[0,1]$

$$f(tx+(1-t)y)\leq tf(x)+(1-t)f(y),\text{ ចំពោះគ្រប់ } x,y\in\mathbb{R}$$

តាង $x=plna, y=qlnb$ និង $t=\frac{1}{p}$ នោះ $1-t=\frac{1}{q}$

នាំអោយ $ab=e^{ln(ab)}=e^{lna+lnb}$

$ab=e^{\frac{1}{p}\cdot plna+\frac{1}{q}\cdot qlnb}\leq\frac{1}{p}e^{plna}+\frac{1}{q}e^{qlnb}$

$ab\leq\frac{1}{p}e^{lna^p}+\frac{1}{q}e^{lnb^q}=\frac{a^p}{p}+\frac{b^q}{q}$

ទ្រឹស្តីបទ ១១.១ បើ $a_1,a_2,\ldots,a_n$ និង $b_1,b_2,\ldots,b_n$ ជាចំនួនពិត នោះ

$$\left|\sum_{k=1}^{n}a_kb_k\right|\leq\left(\sum_{k=1}^{n}|a_k|^p\right)^{\frac{1}{p}}\left(\sum_{k=1}^{n}|b_k|^q\right)^{\frac{1}{q}} \text{ ។}$$

សំណើ១១.២ ( Minkowski inequality ) បើ $a_1,a_2,\ldots,a_n$ និង $b_1,b_2,\ldots,b_n$ ជាចំនួនពិត និង $p\geq1$

$$\left(\sum_{k=1}^{n}|a_i+b_i|^p\right)^{1/p}\leq\left(\sum_{k=1}^{n}|a_i|^p\right)^{1/p}+\left(\sum_{k=1}^{n}|b_i|^p\right)^{1/p} \text{ ។}$$

ទ្បេម ២.១ គេអោយ $(a_n)$ និង $(b_n)$ ជាស្វ៊ីតចំនួនពិតដែល $a_n\leq b_n$ ចំពោះគ្រប់ $n\geq1$ ។ បើ $\lim_{n\to\infty}a_n=a$ និង $\lim_{n\to\infty}b_n=b$ នោះ $a\leq b$ ។

## ■ សញ្ញាស៊ិចម៉ា

1. គេអោយស្វ៊ីត $a_1,a_2,a_3,a_4,\ldots$ ។ គេអាចសរសេរផលបូក $n$ តួដំបូងដោយប្រើ សញ្ញាផលបូក ឬ សញ្ញាស៊ិចម៉ា គឺសញ្ញា $\sum$ ( ស៊ិចម៉ាធំ ) ដូចខាងក្រោម :

$$\sum_{k=1}^{n}a_k=a_1+a_2+a_3+a_4+\cdots+a_n \text{ ។}$$

2. លក្ខណៈនៃផលបូក

គេអោយ $a_1,a_2,a_3,a_4,\ldots$ និង $b_1,b_2,b_3,b_4,\ldots$ ជាស្វ៊ីត ។ ចំពោះគ្រប់ចំនួនគត់

វិជ្ជមាន $n$ និង ចំនួនពិត $c$ គេបាន

- $\sum_{k=1}^{n}(a_k+b_k)=\sum_{k=1}^{n}a_k+\sum_{k=1}^{n}b_k$
- $\sum_{k=1}^{n}(a_k-b_k)=\sum_{k=1}^{n}a_k-\sum_{k=1}^{n}b_k$
- $\sum_{k=1}^{n}ca_k=c\left(\sum_{k=1}^{n}a_k\right)$

យើងអាចប្រើលក្ខណៈមួយចំនួនដូចខាងក្រោមផងដែរ :

- $\sum_{k=1}^{n+m}a_k=\sum_{k=1}^{n}a_k+\sum_{k=n+1}^{n+m}a_k$
- $\sum_{k=1}^{n}a_k=\sum_{k=1+m}^{n+m}a_{k-m}$
- $\sum_{k=1}^{n}a_k=\sum_{k=1}^{n}a_{n-k+1}=\sum_{k=0}^{n-1}a_{n-k}$
- $\sum_{k=m}^{n}c=c\cdot(n-m+1)=c\cdot$ ( ចំនួនលេខដែលត្រូវបូកនៅក្នុងផលបូក ) ចំពោះចំនួនថេរ $c$

## ■ ទ្រឹស្តីបទទ្វេធា

$(a+x)^n=a^n+na^{n-1}x+\frac{n(n-1)}{2!}a^{n-2}x^2+\frac{n(n-1)(n-2)}{3!}a^{n-3}x^3+\cdots,$
$x^2<a^2$

## ■ ស៊េរីពន្លាត Taylor

អនុគមន៍ $f(x)$ អាចពន្លាតត្រង់ $x=a$ បើអនុគមន៍ជាប់ និងដេរីវេកើតមាន និង កំណត់ត្រង់ $x=a$ ។

$$f(x)=f(a)+f'(a)\frac{(x-a)}{1!}+f''(a)\frac{(x-a)^2}{2!}+f'''(a)\frac{(x-a)^3}{3!}+\cdots$$
$$+f^{n-1}(a)\frac{(x-a)^{n-1}}{(n-1)!}+R_n \text{ ។}$$

## ■ ស៊េរីពន្លាត Maclaurine

ស៊េរី Maclaurine ជាករណីពិសេសនៃស៊េរីពន្លាត Taylor ចំពោះ $a=0$ ។

$$f(x) = f(0) + f'(0)\frac{x}{1!} + f''(0)\frac{x^2}{2!} + f'''(0)\frac{x^3}{3!} + \cdots$$

$$f^{(n-1)}(0)\frac{x^{n-1}}{(n-1)!} + R_n$$ ។

# លំហាត់សម្រាប់ស្រាវជ្រាវបន្ថែម

លំហាត់ទី 1) គណនាចំនួនខាងក្រោម

១. $\sqrt{25^{\frac{1}{log_6 5}}+49^{\frac{1}{log_6 7}}}$

២. គណនា $log56$ ជាអនុគមន៍នៃ $a$ និង $b$ ដែល $a=log2$ $;b=log_2 7$ ។

លំហាត់ទី 2) ចូរដោះស្រាយសមីការ និង វិសមីការខាងក្រោម

១. $2.9^{log_2\left(\frac{x}{2}\right)}=x^{log_2 6}-x^2$

២. $5^x\cdot\sqrt[x]{8^{x-1}}=500$

៣. $x^2+(x+1)^2\le\frac{1}{x^2+x+1}$

៤. $log_n x+log_{\sqrt{n}}x+log_{\sqrt[3]{n}}x+\cdots+log_{\sqrt[n]{n}}x=\frac{n+1}{2}$

៥. $x^{log^2 x-3logx+1}>1000$

៦. $x=2^{log_5(x+3)}$

លំហាត់ទី 3) ប្រសិនបើស្វ៊ីត $\{a_n\}$ ត្រូវបានកំណត់ដោយទំនាក់ទំនងកំណើន $a_1=1$ ; $a_{n+1}=\frac{6a_n}{3a_n+4}$ $(n=1,2,3,\ldots)$ ។ ចូររកតួទី $n$ នៃស្វ៊ីត $\{a_n\}$ ។

លំហាត់ទី 4) ពិនិត្យស្វ៊ីត $\frac{1}{2},\frac{2}{3},\frac{1}{3},\frac{3}{4},\frac{2}{4},\frac{1}{4},\frac{4}{5},\frac{3}{5},\frac{2}{5},\frac{1}{5},\ldots$ ។

ក/ តើ $\frac{18}{25}$ ជាតួទីប៉ុន្មាននៃស្វ៊ីតនេះ ?

ខ/ រកផលបូកតួនៃស្វ៊ីតនេះរហូតដល់តួទី 666 ។

លំហាត់ទី 5) ចូររកដែនកំណត់ រួចសិក្សាភាពគូភាពសេសនៃអនុគមន៍ខាងក្រោម

១. $f(x)=\frac{|x^2-4|}{|x+4|+|x-4|}$

២. $f(x)=\sqrt{\frac{1-|x|}{2-|x|}}$

លំហាត់ទី 6) គេឱ្យប៉ារ៉ាបូល $y=x^2+2px+q$ មានកំពូលនៅលើអ័ក្សអាប់ស៊ីស ។ ចូររកតំលៃនៃ $p$ និង $q$ ។

លំហាត់ទី 7) គេឱ្យ $I_n = \int_0^{2\pi} |sint|\,cosntdt$ ។ គណនា $I_0 + I_2 + I_3$ $(n = 0, 1, 2, ...)$ ។

លំហាត់ទី 8) ស្រាយបញ្ជាក់វិសមភាព $\sum_{r=1}^{n} \frac{1}{r^3} \le 2 - \frac{1}{n^2}$ ដោយប្រើអនុមាណរួមគណិតវិទ្យា ។

លំហាត់ទី 9) ១. គណនាដេរីវេ $y = x^{\frac{1}{x}}$ ។
២.គណនាដេរីវេ $y = x^{x^2}$ ។

លំហាត់ទី 10) ១. រកសមីការបន្ទាត់ប៉ះខ្សែកោង $x^2 + 3xy - y^2 = 3$ ត្រង់ចំណុច $(1;2)$ ។
២. រកសមីការបន្ទាត់ប៉ះខ្សែកោង $\sqrt{x} + \sqrt{y} = 2$ ត្រង់ចំណុច $A(a; (2-\sqrt{a})^2)$ ដែល $0 < a < 4$ ។

លំហាត់ទី 11) ១. ដោះស្រាយប្រព័ន្ធសមីការ $\begin{cases} sin2x + cosy = 1 \\ siny + cos2x = 1 \end{cases}$ $(0^0 \le x < 360^0,\ 0^0 \le y < 360^0)$ ។
២. ចំពោះត្រីកោណ $ABC$ យក $BC = a, CA = b$ និង $AB = c$ ។ បង្ហាញថាបើ $a < \frac{a+b+c}{3}$ នោះ $\angle A < 60^0$ ។

លំហាត់ទី 12) បើ $x^{\frac{1}{4}} + x^{-\frac{1}{4}} = 3$ ចូរគណនា $x^{\frac{3}{4}} + x^{-\frac{3}{4}}$ ដែល $x > 0$ ។

លំហាត់ទី 13) គេឱ្យស្វ៊ីត $\{a_n\} = \{2, 3, 7, 18, 44, 101, ...\}$ ។
ក/ កំណត់តួទូទៅនៃស្វ៊ីត $\{a_n\}$ ។
ខ/ កំណត់ផលបូកតួទូទៅដំបូងនៃស្វ៊ីត $\{a_n\}$ ។

លំហាត់ទី 14) ស្វ៊ីត $\{a_n\}$ ត្រូវបានកំណត់ដោយទំនាក់ទំនងកំណើនដូចខាងក្រោម $a_1 = p,\ 2a_{n+1} + a_n - 3n - 2 = 0$ ( $p$ ជាចំនួនថេរវិជ្ជមាន ) ។ ចូររកតួទូទៅនៃស្វ៊ីត $\{a_n\}$ ។

លំហាត់ទី 15) គេឱ្យបីវ៉ិចទ័រ $\vec{a} = (1;2;-1)$, $\vec{b} = (-1;0;2)$ និង $\vec{c} = (3;1;0)$ ។ ចូររកមាឌតេត្រាអែតដែលផ្គុំឡើងដោយវ៉ិចទ័រទាំងបី ។

លំហាត់ទី 16) ក្រុមហ៊ុនមួយចង់លើកទឹកចិត្តបុគ្គលិកជាច្រើនអ្នកនៅជំណាច់ឆ្នាំដោយមានការចាប់ឆ្នោតដើម្បីទទួលប្រាក់រង្វាន់តាមលេខសន្លឹកឆ្នោត ។ អ្នកដែលចាប់បានសន្លឹកឆ្នោតលេខ 1 ទទួលបានទឹកប្រាក់ 300$ ហើយអ្នកដែលចាប់បានសន្លឹកឆ្នោតលេខ 2 ទទួលបានទឹកប្រាក់ 70% នៃទឹកប្រាក់សន្លឹកឆ្នោត
លេខ 1 បើគេធ្វើរបៀបនេះជា
បន្តបន្ទាប់ តើក្រុមហ៊ុនចំណាយសរុបអស់ប៉ុន្មាន ក្នុងករណីដូចខាងក្រោម :
ក/ បុគ្គលិកមាន 10 នាក់
ខ/ បុគ្គលិកមានច្រើនមិនកំណត់ ។

លំហាត់ទី 17) អនុគមន៍ផ្គត់ផ្គង់មួយកំណត់ដោយ $P=\sqrt{2-2sinx}$, $(0\le x\le 90^0)$ ។ ចូររកភាពលើសរបស់អ្នកផលិត $(P.S)$ ត្រង់ $x=\frac{\pi}{6}$ ។

លំហាត់ទី 18) ឧបមាថានៅក្នុងថ្នាក់មួយមាននិស្សិត 30 នាក់។ បើតាមគេធ្វើការអង្កេតបានឱ្យដឹងថា មាននិស្សិតចំនួន 20 នាក់ ចូលចិត្តលេងកីឡាហែលទឹក និង 16 នាក់ចូលចិត្តវាយសី ។
តាង $U=\{$និស្សិតនៅក្នុងថ្នាក់$\}$ , $A=\{$និស្សិតលេងកីឡាហែលទឹក$\}$
និង $B=\{$និស្សិតលេងកីឡាវាយសី$\}$។
ដោយតាង $n(A\cap B)=x$ ។
ក/ ពន្យល់ពីសំណុំ $A\cup B$ និងរក $n(A\cup B)$ ជាអនុគមន៍នៃ $x$ ។
ខ/ កំណត់តម្លៃធំបំផុត និងតូចបំផុតនៃ $x$ ។

លំហាត់ទី 19) តាង $A,B,C$ ជាត្រីកោណដែលមានជ្រុង $a,b,c$ រៀងគ្នា ដែល $a+b=4c$ ។ បង្ហាញថា $cot\frac{A}{2}cot\frac{B}{2}=\frac{5}{3}$ ។

លំហាត់ទី 20) កំលាំងកកិតមួយសមាមាត្រទៅនឹងល្បឿនដែលមានសមីការឌីផេរ៉ង់ស្យែល $ma=-kx-lv$ ដែល $l$ ជាមេគុណកកិត $(l>0)$ និង $v=x'(t)$ ។
ចូរដោះស្រាយសមីការឌីផេរ៉ង់ស្យែលនេះ ។

លំហាត់ទី 21) គេឱ្យ $f(a)=\int_0^{\pi}|1+acosx|sin^2xdx$ ។
ក/ បង្ហាញថា $f(-a)=f(a)$ ។
ខ/ កំណត់តម្លៃ $f(a)$ បើ $|a|\le 1$ ។
គ/ កំណត់តម្លៃ $f(\sqrt{2})$ ។

លំហាត់ទី 22) ១. រកអនុគមន៍ $f:\mathbb{R}\to\mathbb{R}$ ផ្ទៀងផ្ទាត់ $\forall x,y\in\mathbb{R}:\ f\left((x-y)^2\right)=x^2-$

$2y\cdot f(x)+(f(y))^2$ ។
២. រកអនុគមន៍ $f:\mathbb{N}\to\mathbb{N}$ ផ្ទៀងផ្ទាត់ $g(x+1)=g(x)+1$ ដែល $x\in\mathbb{N}$, $g(1)=5$។ គណនា $g(2013)$ ។

លំហាត់ទី 23) ដោះស្រាយសមីការ : $(x+4)(x+3)(x+2)(x+1)=0$ រួចកំនត់តំលៃ $k$ ដើម្បីអោយសមីការ $(x+4)(x+3)(x+2)(x+1)=k$ មានរឺស ។

លំហាត់ទី 24) ដោះស្រាយវិសមីការ : $log_2\dfrac{x+1}{x+3}<log_{\sqrt{2}}\dfrac{x-1}{x+3}$ ។

លំហាត់ទី 25) គណនា :
ក- $I=\int_1^2 2(2x+1)\left(x^2+x-3\right)dx$
ខ- $J=\int_0^{\frac{\pi}{3}} cosxdx+\int_{\frac{\pi}{3}}^{\frac{2\pi}{3}} cosxdx+\int_{\frac{3\pi}{2}}^{\pi} cosxdx$

លំហាត់ទី 26) គេអោយខ្សែកោង $(C_m)$ តាងអនុគមន៍ $f_m(x)=x^3-mx+2$ ។
១- បង្ហាញថាខ្សែកោង $(C_m)$ កាត់តាមចំនុចនឹង $I$ មួយដែលគេដឹង គណនាកូអរដោនេវា ។
២- កំនត់តំលៃ $m$ ដែលធ្វើអោយ $(C_m)$ មានអតិបរមាស្មើ $4$ ។ ក្នុងករណីនេះ សិក្សាអថេរភាព និង សង់ខ្សែកោង $(C)$ នៃអនុគមន៍ $y$ ។ បង្ហាញថា ចំនុចរបត់ $I$ ជាផ្ចិតឆ្លុះ ។
៣- បន្ទាត់ $(D)$ មួយប៉ះខ្សែកោង $(C)$ ត្រង់ចំនុចអតិបរមា ។
ក- សរសេរសមីការនៃបន្ទាត់ $(D)$
ខ- គណនាក្រឡាផ្ទៃដែលខ័ណ្ឌដោយខ្សែកោង $(C)$ បន្ទាត់ $(D)$ និង បន្ទាត់សមីការ $x=-1$ និង $x=2$ ។

លំហាត់ទី 27) គេអោយពីរ៉ាមីតចតុមុខនិយ័ត $SABCD$ បាត $ABCD$ ជាការេ ជ្រុងមានរង្វាស់ $a$ ។ មុខខាងផ្គុំជាមួយប្លង់បាតបានមុំ $60^0$ ។
ក- គណនារង្វាស់កំពស់ និង អាប៉ូតែមនៃពីរ៉ាមីតនោះ ។
ខ- គណនាក្រឡាផ្ទៃទាំងអស់នៃពីរ៉ាមីតនោះ ។
គ- ប្លង់មួយកាត់តាម $[AB]$ កាត់ $[SC]$ និង $[SD]$ រៀងគ្នាត្រង់ $M$ និង $N$ ។ ស្រាយបញ្ជាក់ថា មុខកាត់ $ABMN$ ជាចតុកោណព្នាយសមបាត ។

លំហាត់ទី 28) រកលេខពីរខ្ទង់ចុងក្រោយនៃចំនួន $3^{999}$ ។

លំហាត់ទី 29) ១/ គេអោយ $log_{10}2 = 0,3010$ និង $log_{10}3 = 0,4771$ ។ រកចំនួនខ្ទង់នៃចំនួន $3^{80}$ និង ចំនួនខ្ទង់នៃចំនួន $6^{50}$ រួចប្រៀបធៀប $3^{80}$ និង $6^{50}$ ។
២/ ស្រាយបញ្ជាក់ថា $log_2 9$ ជាចំនួនអសនិទាន ។

លំហាត់ទី 30) ស៊ីត $\{a_n\}$ បំពេញលក្ខខណ្ឌខាងក្រោមចំពោះ $n = 1;2;3;...$
ដោយ $\sum_{k=1}^{n} \frac{1}{k}\left(a_k + \frac{1}{k+1}\right) = 2^n + 1 - \frac{1}{n+1}$ ។
១/ គណនាតួទី $n$ នៃស៊ីត $\{a_n\}$ ជាអនុគមន៍នៃ $n$ ។
២/ គណនា $\sum_{k=1}^{n} a_k$ ។

លំហាត់ទី 31) បង្ហាញថា ចំនួន $\underbrace{11...11}_{2005 \text{ លេខ } 1} \cdot \underbrace{10...05}_{2004 \text{ លេខ } 0} + 1$ ជាការេប្រាកដ ។

លំហាត់ទី 32) សរសេរសមីការទូទៅនៃប៉ារ៉ាបូលដែលមានកំនុំ $F(3;-1)$ ហើយមានបន្ទាត់ប្រាប់ទិស $(D)$ សមីការ $x - 2y + 1 = 0$ ។ សង់ក្រាបប៉ារ៉ាបូលនេះ ។

លំហាត់ទី 33) ចំពោះគ្រប់ចំនួនគត់វិជ្ជមាន $n$ ស្រាយបញ្ជាក់ថា $n^5 - n$ ជាពហុគុណនៃ 30 ។

លំហាត់ទី 34) រកតម្លៃតូចបំផុត និង ធំបំផុតនៃអនុគមន៍ $f(x) = sin^4x - sinxcosx + cos^4x$ ។

លំហាត់ទី 35) រកគ្រប់អនុគមន៍ចំនួនពិត $f : \mathbb{R} \to \mathbb{R}$ ផ្ទៀងផ្ទាត់លក្ខខណ្ឌ :

$$f(xy) = \frac{f(x) + f(y)}{x + y} \text{ ដែល } x, y \in \mathbb{R}, x + y \neq 0 \text{ ។}$$

លំហាត់ទី 36) គេអោយ $n$ ជាចំនួនគត់វិជ្ជមាន។ ស្រាយបញ្ជាក់ថា $\sum_{k=0}^{n} \frac{\binom{2n-k}{k}}{\binom{2n-k}{n}} \cdot \frac{(2n-4k+1)}{(2n-2k+1)} \cdot 2^{n-2k} = \frac{\binom{n}{m}}{\binom{2n2-m}{n-m}} \cdot 2^{n-2m}$ ចំពោះចំនួនគត់មិនអវិជ្ជមាន $m \leq n$ ។

លំហាត់ទី 37) ( ទូទៅកម្ម ទ្រឹស្តីបទតម្លៃមធ្យម ) ឧបមាថា $f$ និង $g$ ទាំងពីរផ្ទៀងផ្ទាត់សម្មតិកម្មទ្រឹស្តីបទតម្លៃមធ្យម ។ ស្រាយបញ្ជាក់ថា បើ $g'$ មិនមានឫសនៅចន្លោះ $(a,b)$ នោះមានយ៉ាងហោចណាស់ចំនួន $c$ មួយនៅចន្លោះ $(a,b)$ ដែល

$$\frac{f(b) - f(a)}{g(b) - g(a)} = \frac{f'(c)}{g'(c)} \text{ ។}$$

លំហាត់ទី 38) ដោះស្រាយប្រព័ន្ធ

$$\begin{cases} 4^{|x^2-8x+12|-log_4 7} = 7^{2y-1} \\ |y-3|-3|y|-2(y+1)^2 \geq 1 \end{cases}$$ ។

លំហាត់ទី 39) ដោះស្រាយវិសមីការ

$$\frac{1}{x}-\frac{1}{1+x}+\frac{1}{2+x}-\frac{1}{3+x}+\frac{1}{4+x}-\frac{1}{5+x}+\frac{1}{6+x}-\frac{1}{7+x}>0$$ ។

លំហាត់ទី 40) ស្រាយបញ្ជាក់ថាឫសទាំងអស់នៃសមីការ $x^5+ax^4+bx^3+cx^2+dx+e=0$ មិនអាចជាចំនួនពិតទេ បើ $2a^2<5b$ ។

លំហាត់ទី 41) បើ $a>0$ ដោះស្រាយសមីការ

$$\left(a+\sqrt{a^2-1}\right)^{x^2-2x}+\left(a-\sqrt{a^2-1}\right)^{x^2-2x}=2a$$ ។

លំហាត់ទី 42) ស្រាយបញ្ជាក់ថា ចំពោះគ្រប់ចំនួនគត់ធម្មជាតិ $n$ ចំនួន $\underbrace{44\ldots4}_{n \text{ ដង}}\underbrace{888\ldots8}_{n \text{ ដង}}9$ ជាការេប្រាកដ ។

លំហាត់ទី 43) ស្រាយបញ្ជាក់ សមភាពខាងក្រោម

$$\sqrt{\underbrace{11\ldots1}_{2n \text{ ដង}}-\underbrace{22\ldots2}_{n \text{ ដង}}}=\underbrace{3\ldots\ldots3}_{n \text{ ដង}}$$ ។

លំហាត់ទី 44) ស្រាយបញ្ជាក់ថា គ្មានពហុធាដែលមានមេគុណជាចំនួនគត់ផ្ទៀងផ្ទាត់ $P(1)=21$ និង $P(13)=87$ ឡើយ ។

លំហាត់ទី 45) គណនាលីមីតខាងក្រោម:

ក ) $\lim\limits_{x\to 8}\frac{2-\sqrt[3]{x}}{x-8}$;

ខ ) $\lim\limits_{x\to\pm\infty}\frac{(3x-1)^{30}(2x+5)^{20}}{(2x+1)^{50}}$;

គ ) $\lim\limits_{x\to 1}(1-x)tan\frac{\pi x}{2}$ ។

( អាហារូបករណ៍គុយបា ២០២០ )

លំហាត់ទី 46) ១. រកកូអរដោនេផ្ចិត កំពូល កំណុំ និងសមីការអាស៊ីមតូតរបស់អ៊ីពែបូល ដែលមានសមីការ $(H)$: $4x^2-y^2=16$ ។
២. សង់អ៊ីពែបូល $(H)$ ។

លំហាត់ទី 47) ឡានដឹកអ្នកដំណើរមួយមានកៅអីអង្គុយចំនួន 6 តម្រៀបជា 3 ជួរ ដោយនៅជួរមុខ មានកៅអីចំនួន 2 ជួរកណ្តាលមានកៅអីចំនួន 2 និង ជួរចុងក្រោយមានកៅអីចំនួន 2។ អ្នកដំណើរ 6 នាក់ $A;B;C;D;E$ និង $F$ ( ក្នុងនោះអ្នកដំណើរ $A;E$ ជាអ្នកចេះបើកបរ ) ឡើងជិះលើរថយន្តដោយចៃដន្យ។

ក ) តើអ្នកដំណើរទាំងនោះអាចអង្គុយបានប៉ុន្មានរបៀប ?

ខ ) រកប្រូបាបដែល $A;E$ អង្គុយជាប់គ្នា។

( អាហារូបករណ៍គុយបា ២០២០ )

លំហាត់ទី 48) គេឱ្យអនុគមន៍ $f(x) = ln\left(\dfrac{x+1}{x-1}\right)$ មានក្រាប $(C)$។

ក ) រកដែនកំណត់នៃ $f$។ រកលីមីតចុងដែនកំណត់ និងទាញរកសមីការអាស៊ីមតូតនៃ $(C)$។

ខ ) សិក្សាអថេរភាពនៃ $f$។ គណនា $f(2); f(-2)$។

គ ) សង់ក្រាប $(C)$ និង អាស៊ីមតូត។ ( គេឱ្យ $ln3 = 1.1$ )

( អាហារូបករណ៍គុយបា ២០២០ )

លំហាត់ទី 49) គណនាលីមីតខាងក្រោម:

ក ) $\lim\limits_{x\to 0} \dfrac{1}{x^2\left[1+cot^2(2x)\right]}$;

ខ ) $\lim\limits_{x\to +\infty} \left(1 - cos^2\dfrac{4}{\sqrt{x}}\right)x$។

( ប្រលងធមាសលើកទី២ វិទ្យាស្ថានជាតិអប់រំ ២០២០ )

លំហាត់ទី 50) គណនាអាំងតេក្រាលខាងក្រោម:

ក ) $I = \displaystyle\int \left(sin^2x \cdot cos2x \cdot cosx\right)dx$;

ខ ) $J = \displaystyle\int \frac{1}{sinx}dx$។

( ប្រលងធមាសលើកទី២ វិទ្យាស្ថានជាតិអប់រំ ២០២០ )

លំហាត់ទី 51) គេឱ្យ $secx + \dfrac{1}{cotx} = 3$។ គណនា $secx - \dfrac{1}{cotx}$។

( ប្រលងធមាសលើកទី២ វិទ្យាស្ថានជាតិអប់រំ ២០២០ )

លំហាត់ទី 52) គេឱ្យស្វ៊ីតមួយកំណត់ដោយ $\{a_n\}$ : $a_1 = 10,\ a_{n+1} = 3a_n + 4n - 9$។ កំណត់តួទី $n$ នៃស្វ៊ីត $\{a_n\}$។

(ប្រលងឆមាសលើកទី២ វិទ្យាស្ថានជាតិអប់រំ ២០២០)

លំហាត់ទី 53) គេឱ្យស្វ៊ីត $\{u_n\}$ កំណត់ដោយ $u_1 = -1, u_2 = 1$ និង $u_{n+2} = 5u_{n+1} - 6u_n$ ដែល $n = 1, 2, 3, \ldots$។

១. គេតាង $a_n = u_{n+1} - 2u_n$ និង $b_n = u_{n+1} - 3u_n$។ បង្ហាញថា $\{a_n\}$ និង $\{b_n\}$ ជាស្វ៊ីតធរណីមាត្រ។

២. ទាញរកតួ $\{u_n\}$ ជាអនុគមន៍នៃ $n$។

(ប្រលងឆមាសលើកទី២ វិទ្យាស្ថានជាតិអប់រំ ២០២០)

លំហាត់ទី 54) ដោះស្រាយវិសមីការ $\sqrt{2(5^x + 24)} - \sqrt{5^x - 7} \geq \sqrt{5^x + 7}$។

(ប្រលងអាហារូបករណ៍ថៃ ២០១៧)

លំហាត់ទី 55) គេឱ្យអនុគមន៍ $f$ កំណត់ក្នុង $\mathbb{R}$ ដោយ $f(x) = \dfrac{x^2 + 2x + 2}{x + 1}$។ ចូរកំណត់តម្លៃតូចបំផុតនៃអនុគមន៍ $f$។

(ប្រលងអាហារូបករណ៍ថៃ ២០១៧)

លំហាត់ទី 56) នៅលើក្រដាសកាតុង 100 រាងការេប៉ុនគ្នា និងដូចគ្នាមានចុះលេខពី 1 ដល់ 100។

គណនាប្រូបាបដើម្បីចាប់បាន៖

ក) យកបានក្រដាសកាតុងដែលគ្មានលេខ 5។

ខ) យកបានក្រដាសកាតុងដែលមានលេខរៀងចែកដាច់នឹង 2 ឬ ចែកដាច់នឹង 5 ឬ ចែកដាច់នឹង 2ផង និងចែកដាច់នឹង 5 ផង។

(ប្រលងអាហារូបករណ៍ថៃ ២០១៧)

លំហាត់ទី 57) ចំពោះអ៊ីពែបូល $\dfrac{x^2}{a^2} - \dfrac{y^2}{b^2} = 1$ ចូរស្រាយបញ្ជាក់ថា ៖

១. បន្ទាត់ប៉ះនឹងក្រាបអ៊ីពែបូលដែលមានមេគុណប្រាប់ទិស $m$ គឺ $y = mx \pm \sqrt{a^2m^2 - b^2}$។

២. បន្ទាត់ប៉ះនឹងក្រាបអ៊ីពែបូលត្រង់ចំណុច $P(x_1, y_1)$ គឺ $\dfrac{x_1 x}{a^2} - \dfrac{y_1 y}{b} = 1$។

(ប្រលងអាហារូបករណ៍ថៃ ២០១៧)

**លំហាត់ទី 58)** គណនាលីមីតខាងក្រោម:

ក) $\lim_{x\to -1}\dfrac{x^{2017}+1}{x^{2015}+1}$;

ខ) $\lim_{x\to -3}\dfrac{2x^2+5x-3}{3x^2+5x-3}$;

គ) $\lim_{x\to 0}\dfrac{1+2x^2-cosx}{x^2}$;

ឃ) $\lim_{x\to 2}\dfrac{3x-6}{sin\pi x}$។

(ប្រលងអាហារូបករណ៍ថៃ ២០១៨)

**លំហាត់ទី 59)** គេចង់បង្កើតលេខសំងាត់របស់សោមួយដោយមានលេខចំនួន ៤ ខ្ទង់ ខុសពីសូន្យ (ពីលេខ ១ ដល់លេខ ៩)។

១. តើគេអាចជ្រើសរើសលេខសំងាត់នេះបានប៉ុន្មានរបៀប?

២. គេជ្រើសរើសលេខសម្ងាត់មួយដោយចៃដន្យ។ ចូររកប្រូបាបនៃព្រឹត្តិការណ៍៖

ក. លេខសម្ងាត់ជាលេខគូ។

ខ. លេខសម្ងាត់ទាំង ៤ ខ្ទង់ជាលេខគូ។

គ. លេខសម្ងាត់ទាំង ៤ខ្ទង់ មានលេខ១ តែម្តងគត់។

ឃ. លេខសម្ងាត់ទាំង៤ ខ្ទង់ខុសៗគ្នា។

(ប្រលងអាហារូបករណ៍ថៃ ២០១៨)

**លំហាត់ទី 60)** គេមានអនុគមន៍ $f(x)=\dfrac{x^2+2xcos\alpha+1}{x+2sin\alpha}$។ បង្ហាញថា ចំពោះគ្រប់ $\alpha\in\mathbb{R}$ អនុគមន៍ $f$ មានអតិបរមាមួយ និង អប្បបរមាមួយ។

(ប្រលងអាហារូបករណ៍ថៃ ២០១៨)

**លំហាត់ទី 61)** រកសមីការប៉ារ៉ាបូលដែលមានអ័ក្សឆ្លុះ ស្របនឹងអ័ក្សអាប់ស៊ីសហើយក្រាបនៃប៉ារ៉ាបូលកាត់តាមចំណុច $(4,-2)$, $(0,0)$ និង $(3,-3)$ រួចសង់ក្រាបនៃប៉ារ៉ាបូល។

(ប្រលងអាហារូបករណ៍ថៃ ២០១៨)

**លំហាត់ទី 62)** ត្រីកោណ $MNP$ នៅក្នុងប្លង់កុំផ្លិចដែលកំពូល $M,N$ និង $P$ តាងចំនួនកុំផ្លិច $W,W^2$ និង $W^3$ រៀងគ្នា។ បើ $MN=MP$:

១. ចូររកទីតាំងរបស់ចំណុច $M$។
២. បើ $\angle NMP = 90^0$ ចូររកចំនួនកុំផ្លិច $W$។
៣. សរសេរ $W$ ជាទម្រង់ត្រីកោណមាត្រ។

( ប្រលងអាហារូបករណ៍វៀតណាម ២០១៦ )

លំហាត់ទី 63) គេឱ្យសមីការ $2x^2 + y^2 = 8$ និង $y^2 = 6x$។
១. រកកូអរដោនេចំណុចប្រសព្វនៃខ្សែកោងទាំងពីរ។
២. រកមេគុណប្រាប់ទិសនៃបន្ទាត់ប៉ះទៅនឹងខ្សែកោងទាំងពីរត្រង់ចំណុចប្រសព្វនោះ។
៣. បង្ហាញថាបន្ទាត់ប៉ះទៅនឹងខ្សែកោងទាំងពីរត្រង់ចំណុចប្រសព្វនេះកែងគ្នា។

( ប្រលងអាហារូបករណ៍វៀតណាម ២០១៦ )

លំហាត់ទី 64) គេឱ្យអនុគមន៍ $f$ ដែលកំណត់ដោយ $f(x) = x + 1 + 2ln\dfrac{x}{x-1}$ មានក្រាប $(C)$។
១. រកលីមីតនៃ $f$ ត្រង់ចំណុចចុងសងខាងនៃដែនកំណត់ រួចទាញរកអាស៊ីមតូតនៃក្រាប $(C)$។
២. រកសមីការអាស៊ីតូតទ្រេត $(\Delta)$ នៃក្រាប $(C)$ រួចសិក្សាទីតាំងនៃ $(C)$ ធៀបនឹង $(\Delta)$។
៣. សិក្សាអថេរភាពនៃ $f$ រួចសង់ក្រាប $(C)$។
៤. គណនាផ្ទៃក្រឡាផ្នែកនៃប្លង់ដែលខ័ណ្ឌដោយខ្សែកោង $(C)$ បន្ទាត់ $(\Delta)$ បន្ទាត់ $x = 2, x = 3$។

( ប្រលងអាហារូបករណ៍វៀតណាម ២០១៦ )

លំហាត់ទី 65) គេបង្កើតចំនួនមានលេខ 3 ខ្ទង់ផ្សេងគ្នាដោយយកចេញពីលេខ $1,2,3,4$។ រកប្រូបាបនៃព្រឹត្តិការណ៍ខាងក្រោម:
១. ចំនួននោះជាពហុគុណនៃ 3។
២. ចំនួននោះជាពហុគុណនៃ 2។
៣. ចំនួននោះជាពហុគុណនៃ 2 ឬ ពហុគុណនៃ 3។

( ប្រលងអាហារូបករណ៍វៀតណាម ២០១៦ )

លំហាត់ទី 66) រកគ្រប់ចម្លើយនៃសមីការ $sik\theta = sin\theta,\ 0 \le \theta \le 2\pi$ ។

លំហាត់ទី 67) រកគ្រប់ចំនួនគត់ $n \geq 1$ ដែល $\binom{n}{k}$ ជាចំនួនសេសចំពោះគ្រប់ $k$, $0 \leq k \leq n$ ។

លំហាត់ទី 68) គណនាផលគុណមិនកំណត់ $\left(\frac{1}{2}\right)^{\frac{1}{3}}\left(\frac{1}{4}\right)^{\frac{1}{9}}\left(\frac{1}{8}\right)^{\frac{1}{27}}\left(\frac{1}{16}\right)^{\frac{1}{81}}\ldots$ ។

លំហាត់ទី 69) ចំពោះចំនួនពិត $x$, $\{x\}$ តាងអោយ $x-[x]$ ដែល $[x]$ ជាចំនួនគត់ធំបំផុតតូចជាង $x$។ បង្ហាញថា $\lim_{x\to+\infty}\{(2+\sqrt{3})^n\}=1$។

លំហាត់ទី 70) ចំនួនគត់វិជ្ជមាន $n$ នៅក្នុងរបាប់គោល $b$ គឺ $n = 1254_b$ ហើយចំនួន $2n$ នៅក្នុងរបាប់ដូចគ្នានេះគឺ $2n = 2541_b$ ។ កំណត់តម្លៃ $n$ និង $b$ នៅក្នុងរបាប់គោលដប់។

លំហាត់ទី 71) ឧបមាថា $a,b$ និង $c$ ជាចំនួនគត់ផ្ទៀងផ្ទាត់

$$\begin{cases} a+b+c=4 \\ a^2+b^2+c^2=1690 \\ a^3+b^3+c^3=10108 \end{cases}$$ ។

រកចំនួនគត់ធំបំផុតក្នុងចំណោមចំនួនទាំងបី ។

លំហាត់ទី 72) រកគ្រប់ចំនួនគត់វិជ្ជមាន $m,s$ និង $t$ ដែលផ្ទៀងផ្ទាត់ $m! = 4s! + 10t!$ ។
( សំគាល់ : $1! = 1, 2! = (1)(2) = 2, 3! = (1)(2)(3) = 6$, -ល- )

លំហាត់ទី 73) បង្ហាញថា $\dfrac{(3\sqrt{3}+5)^{1/3}+(3\sqrt{3}-5)^{1/3}}{2^{2/3}\sqrt{3}} = 1$ ។

លំហាត់ទី 74) រកតម្លៃនៃ $xyz$ បើគេដឹងថា

$$x+y+z=1$$
$$x^2+y^2+z^2=2$$
$$x^3+y^3+z^3=3$$ ។

លំហាត់ទី 75) រកគ្រប់ចំនួនមិនអវិជ្ជមាន $x,y$ និង $z$ ដែល $\begin{cases} z^x = y^{2x} \\ 2^z = 2\cdot 4^x \\ x+y+z=16 \end{cases}$ ។